ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សន្និបាត



## បូកសរុបលទ្ធផលការងារ

## អប់រំ យុវជន និងកីឡា

## ឆ្នាំសិក្សា២០១៥ - ២០១៦ និងទិសដៅ

## ឆ្នាំសិក្សា២០១៦ - ២០១៧

ថ្ងៃទី២១ - ២២ - ២៣ ខែមីនា ឆ្នាំ២០១៧

| មាតិកា | ទំព័រ |
|---|---|
| **ផ្នែកទី ១៖ លទ្ធផល និងទិសដៅ** | |



| | |
|---|---|
| **១. សេចក្តីផ្តើម** | ១ |
| **២. វឌ្ឍនភាព** | ២ |
| **២.១ លទ្ធផលរួមរបស់វិស័យអប់រំ យុវជន និងកីឡា** | ២ |
| ២.១.១ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយក្នុងឆ្នាំ ២០១៦ | ២ |
| ២.១.២ វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល | ៣ |
| ២.១.៣ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៦ | ៥ |
| ២.១.៤ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា២០១៥-២០១៦ | ៩ |
| ២.១.៥ វឌ្ឍនភាពនៃការគ្រប់គ្រង និងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ | ១១ |
| ២.១.៦ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ១៤ |
| ២.១.៧ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ | ១៨ |
| ២.១.៨ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ២០ |
| ២.១.៩ វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់ទាំង ១៥ ចំណុច | ២៧ |
| **២.២ លទ្ធផលតាមអនុវិស័យ** | ៣៥ |
| ២.២.១ អនុវិស័យ ការអប់រំកុមារតូច | ៣៥ |
| ២.២.២ អនុវិស័យ ការអប់រំបឋមសិក្សា | ៤៦ |
| ២.២.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ៥៩ |
| ២.២.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា | ៧៦ |
| ២.២.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ | ៨៨ |
| ២.២.៦ អនុវិស័យ ការអភិវឌ្ឍយុវជន | ៩៩ |
| ២.២.៧ អនុវិស័យ ការអប់រំកាយ និងកីឡា | ១០៧ |
| **៣. ទិសដៅឆ្នាំសិក្សា ២០១៦-២០១៧** | ១១៧ |
| **៣.១ ទិសដៅតាមអនុវិស័យ** | ១១៧ |
| ៣.១.១ អនុវិស័យ ការអប់រំកុមារតូច | ១១៧ |
| ៣.១.២ អនុវិស័យ ការអប់រំបឋមសិក្សា | ១១៧ |
| ៣.១.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ១១៨ |
| ៣.១.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា | ១១៩ |
| ៣.១.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ | ១១៩ |
| ៣.១.៦ អនុវិស័យ ការអភិវឌ្ឍយុវជន | ១២០ |
| ៣.១.៧ អនុវិស័យ ការអប់រំកាយ និងកីឡា | ១២០ |
| **៣.២ បញ្ហាប្រឈម និងទិសដៅកំណែទម្រង់ឆ្លងអនុវិស័យ** | ១២១ |
| ៣.២.១ ការពង្រឹងការងារគោលនយោបាយនិងផែនការ | ១២១ |
| ៣.២.២ ការងារវិមជ្ឈការ និងវិសហមជ្ឈការ | ១២២ |
| ៣.២.៣ ការងារគ្រប់គ្រងបុគ្គលិក | ១២២ |
| ៣.២.៤ ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ១២៣ |

| | |
|---|---|
| ៣.២.៥ ការងារបណ្ដុះបណ្ដាល និងវិក្រឹតការ | ១២៤ |
| ៣.២.៦ ការងារអភិវឌ្ឍកម្មវិធីសិក្សា | ១២៤ |
| ៣.២.៧ ការងាររដ្ឋបាល | ១២៥ |
| ៣.២.៨ ការងារព័ត៌មាន និងកិច្ចការអាស៊ាន | ១២៥ |
| ៣.២.៩ ការងារសំណង់សិក្សា | ១២៦ |
| ៣.២.១០ ការងារបោះពុម្ព និងចែកផ្សាយ | ១២៦ |
| ៣.២.១១ ការងារអធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | ១២៦ |
| ៣.២.១២ ការងារសវនកម្មផ្ទៃក្នុង | ១២៧ |
| ៣.២.១៣ ការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | ១២៧ |
| **៤. សេចក្ដីសន្និដ្ឋាន** | ១២៧ |
| **ផ្នែកទី២ ៖ ឧបសម្ព័ន្ធ** | |
| ឧបសម្ព័ន្ធទី១ ៖ ចំនួនសកម្មភាពនៃផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៦ | ១៣១ |
| ឧបសម្ព័ន្ធទី២ ៖ ចំនួនសកម្មភាពនៃទិសដៅសន្និបាតអប់រំឆ្នាំសិក្សា ២០១៥-២០១៦ | ១៣២ |
| ឧបសម្ព័ន្ធទី៣ ៖ វឌ្ឍនភាពការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា២០១៥-២០១៦ កំណែទម្រង់សំខាន់ៗ | ១៣៣ |
| ឧបសម្ព័ន្ធទី៤ ៖ វឌ្ឍនភាពការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា ២០១៥-២០១៦ អនុវិស័យ | ១៣៧ |
| ឧបសម្ព័ន្ធទី៥ ៖ វឌ្ឍនភាពការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា ២០១៥-២០១៦ ឆ្លងអនុវិស័យ | ១៤៦ |
| ឧបសម្ព័ន្ធទី៦ ៖ វឌ្ឍនភាពការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៦ | ១៤៩ |
| ឧបសម្ព័ន្ធទី៧ ៖ វឌ្ឍនភាពតារាងម៉ាទ្រិកសកម្មភាពគោលនយោបាយឆ្នាំ២០១៦ | ១៨៩ |
| **ផ្នែកទី៣ ៖ ប្រធានបទពិភាក្សា** | |
| ប្រធានបទពិភាក្សា | ២០១ |

# ផ្នែកទី១

# លទ្ធផល និងទិសដៅ

## ១.	សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡា បានឈានដល់ដំណាក់កាលពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨ ដែលមានលក្ខណៈកាន់តែស៊ីជម្រៅ និងមុតស្រួច ក្នុងបរិបទកំណែទម្រង់វិស័យអប់រំឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព ស្របតាមដំណើរការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា។ គោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងចង្កោមសកម្មភាពជាអាទិភាពរបស់ក្រសួងត្រូវបានសម្រេច ដើម្បីឆ្លើយតបទៅនឹងប្រព័ន្ធអប់រំមួយ ដែលធានាគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធពីសំណាក់ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធក្នុងការប្រើប្រាស់ឱ្យអស់សក្តានុពលធនធានសរុប។

ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃបានកំណត់ការទទួលខុសត្រូវរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការបំពេញភារកិច្ចពិនិត្យតាមដាន និងវាយតម្លៃគុណផលតាមអនុវិស័យប្រកបដោយជវភាព។ សន្និបាតអប់រំ បានផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធទាំងអស់ បានចូលរួមពិភាក្សា ពិនិត្យវឌ្ឍនភាពការងារ បញ្ហាប្រឈម និងកំណត់ទិសដៅសម្រាប់ឆ្នាំបន្ត។ សមិទ្ធផលការងារតាមអនុវិស័យ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៦ ត្រូវបានផ្ទៀងផ្ទាត់ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ពិនិត្យឡើងវិញ និងកំណត់នូវសកម្មភាព និងចំណុចដៅ។

វឌ្ឍនភាពនៃការអនុវត្តការងារតាមអនុវិស័យ និងការពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៦ បានឆ្លុះបញ្ចាំងនៅក្នុងខ្លឹមសារនៃរបាយការណ៍សន្និបាតអប់រំ ដើម្បីជាមូលដ្ឋានសម្រាប់ពិនិត្យឡើងវិញពីសកម្មភាព និងចំណុចដៅរបស់សូចនាករបំពេញការងារគន្លឹះៗ។ របាយ-ការណ៍សន្និបាតអប់រំឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព បញ្ហាប្រឈម និងអនុសាសន៍ជារួមរបស់ក្រសួង និងតាមអនុវិស័យទាំង៧ រួមមានការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស ការអប់រំឧត្តមសិក្សា ការអប់រំក្រៅប្រព័ន្ធ ការអភិវឌ្ឍយុវជន និងការអប់រំកាយនិងកីឡា។ លទ្ធផលសន្និបាតអប់រំនឹងក្លាយជាមូលដ្ឋានដ៏មានសារៈសំខាន់ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំ។

គុណភាពនៃការរៀបចំសន្និបាតអប់រំក៏ត្រូវបានលើកកម្ពស់ តាមរយៈរបាយការណ៍បូកសរុបការងារកាន់តែមានលក្ខណៈសាមញ្ញ វិភាគ និងផ្តោតសំខាន់លើលទ្ធផល។

ក្នុងឆ្នាំសិក្សា២០១៥-២០១៦ កន្លងមកនេះ ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចលទ្ធផលធំៗដូចតទៅ ៖

# ២. វឌ្ឍនភាព

## ២.១ លទ្ធផលរួមរបស់វិស័យអប់រំ យុវជន និងកីឡា

### ២.១.១ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយឆ្នាំ ២០១៦

ក្រសួងបានគ្រោងអនុវត្តសកម្មភាពគោលនយោបាយ ៥៥ សម្រាប់ឆ្នាំ ២០១៦ ក្នុងនោះ សកម្មភាពបានបញ្ចប់ ១៣ ស្មើនឹង ២៣,៦ ភាគរយ កំពុងអនុវត្ត ៣៤ ស្មើនឹង ៦១,៨ ភាគរយ និងមិនបានអនុវត្ត ៨ ស្មើនឹង ១៤,៥ ភាគរយ។ (រូបភាពទី១)

គោលនយោបាយទី១ មាន ២០ សកម្មភាព បានបញ្ចប់ ៤ ស្មើនឹង ២០ ភាគរយ កំពុងអនុវត្ត ១១ ស្មើនឹង ៥៥ ភាគរយ និងមិនទាន់បានអនុវត្ត ៥ ស្មើនឹង ២៥ ភាគរយ។ គោលនយោបាយទី២ មាន ៣៥ បានបញ្ចប់ ៩ ស្មើនឹង ២៥,៧ ភាគរយ កំពុងអនុវត្ត ២៣ ស្មើនឹង ៦៥,៧ ភាគរយ និងមិនបានអនុវត្ត ៣ ស្មើនឹង ៨,៦ ភាគរយ។

រូបភាពទី១៖ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយឆ្នាំ ២០១៦




អនុវិស័យអប់រំកុមារតូចមាន ៦ សកម្មភាព កំពុងអនុវត្ត ៥ ស្មើនឹង ៨៣,៣ ភាគរយ និងមិនទាន់អនុវត្ត ១៦,៧ ភាគរយ។ អនុវិស័យការអប់រំបឋមសិក្សាមាន ៨ សកម្មភាព បានបញ្ចប់ ២ ស្មើនឹង ២៥ ភាគរយ កំពុងអនុវត្ត ៤ ស្មើនឹង ៥០ ភាគរយ និងមិនបានអនុវត្ត ២៥ ភាគរយ។ អនុវិស័យការអប់រំមធ្យមសិក្សា និងការអប់រំបច្ចេកទេសមាន ១៣ សកម្មភាព បានបញ្ចប់ ៤ ស្មើនឹង ៣០,៨ ភាគរយ កំពុងអនុវត្ត ៦ ស្មើនឹង ៤៦,១ ភាគរយនិងមិនបានអនុវត្ត ៣ ស្មើនឹង ២៣,១ភាគរយ។ អនុវិស័យការអប់រំឧត្តមសិក្សាមាន ១៦ សកម្មភាព បានបញ្ចប់ ៥ ស្មើនឹង ៣១,២ ភាគរយ កំពុងអនុវត្ត ១១ ស្មើនឹង ៦៨,៨ ភាគរយ។ អនុវិស័យអប់រំក្រៅប្រព័ន្ធមាន ៤ សកម្មភាព បានបញ្ចប់ ១ ស្មើនឹង ២៥ ភាគរយ កំពុងអនុវត្ត ១ ស្មើនឹង ២៥ ភាគរយ និងមិនបានអនុវត្ត ៥០ ភាគរយ។ អនុវិស័យការអភិវឌ្ឍយុវជនមាន ៣ សកម្មភាព បានបញ្ចប់ ១ ស្មើនឹង ៣៣,៣ ភាគរយ កំពុងអនុវត្ត ២ ស្មើនឹង ៦៦,៧ ភាគរយ។ អនុវិស័យការអប់រំកាយនិងកីឡាមាន ៥ សកម្មភាព កំពុងអនុវត្ត ៥ ស្មើនឹង ១០០ ភាគរយ។

### រូបភាពទី២៖ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយឆ្នាំ ២០១៦ (តាមអនុវិស័យ)




សកម្មភាពគោលនយោបាយដែលបានអនុវត្តចប់សព្វគ្រប់រួមមាន៖ ការពិនិត្យឡើងវិញលើការគ្រប់គ្រង និងការបែងចែកសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាដល់គ្រប់សាលាបឋមសិក្សានៅទូទាំងប្រទេស ការកែសម្រួលនិងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសុខភាពសិក្សានៅបឋមសិក្សា ការរៀបចំលិខិតបទដ្ឋានគតិយុត្តិនិងយន្តការស្តីពីការពង្រីកវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ការរៀបចំលិខិតបទដ្ឋាននិងយន្តការការងាររបស់ទីប្រឹក្សាអាជីពនៅតាមសាលាមធ្យមសិក្សា ការកែសម្រួលនិងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសុខភាពសិក្សានៅមធ្យមសិក្សា ការរៀបចំប្រកាសស្តីពីការកែសម្រួលភារកិច្ចនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ការកែលម្អប្រព័ន្ធស្តីពីការទទួលស្គាល់និងការបង្កើតគ្រឹះស្ថានឧត្តមសិក្សា ការរៀបចំសេចក្តីណែនាំស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ការរៀបចំគោលការណ៍ណែនាំស្តីពីការវាយតម្លៃតាមថ្នាក់រៀនជាប្រចាំ ការរៀបចំសេចក្តីណែនាំស្តីពីការអភិវឌ្ឍកម្មវិធីចុះកម្មសិក្សា ការរៀបចំរចនាសម្ព័ន្ធនិងយន្តការអនុវត្តគោលនយោបាយស្តីពីការស្រាវជ្រាវនិងអភិវឌ្ឍ ការរៀបចំស្តង់ដាមជ្ឈមណ្ឌលសិក្សាសហគមន៍ ការរៀបចំផែនការស្តីពីការចូលរួមរបស់យុវជនក្នុងសកម្មភាពស្ម័គ្រចិត្ត។ សេចក្តីលម្អិតវឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយមាននៅក្នុងឧបសម្ព័ន្ធទី៨។

## ២.១.២ វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល

### តារាងទី១ ៖ វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល

| សូចនាករស្នូល | ស្ថានភាព ២០១៥-១៦ | ចំណុចដៅ ២០១៦-១៧ | ជាក់ស្តែង ២០១៦-១៧ | ចំណុដៅ ២០១៩-២០ |
|---|---|---|---|---|
| **គោលនយោបាយទី១ ៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា** | | | | |
| ១. ភាគរយកុមារអាយុ ៥ឆ្នាំក្នុងការអប់រំកុមារតូចគ្រប់រូបភាព | ៦៤,១% | ៦៦% | ៦៦,៣៥% | ៧២% |
| ២. ចំនួនស្រុកដែលមានអត្រាត្រួតថ្នាក់នៅបឋមសិក្សាតិចជាងឬស្មើ ១០ ភាគរយ | ១៧១ | ១៧៦ | ១៧៣ | ១៩៣ |

| | | | | |
|---|---|---|---|---|
| ៣. ចំនួនខេត្តដែលបានសម្រេចអត្រាបញ្ចប់មធ្យមសិក្សាបឋមភូមិយ៉ាងតិច ៨០ ភាគរយ | ៨ | ៩ | ១១ | ១៤ |
| ៤. អត្រាអក្ខរកម្មជនពេញវ័យ (អាយុ ១៥ឡើង) | ៧៨,១% (២០១៤) | ៧៩,៨% | ៧៨,១%* | ៨៥% |
| ៥. រង្វាយតម្លៃតេស្តស្តង់ដាថ្នាក់ជាតិសិស្សថ្នាក់ទី៣ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា | | | | |
| ការអាន | ៤២,៧ | | ៣៥,២ (២០១៤-១៥) | កើន ៥ពិន្ទុ |
| គណិតវិទ្យា | ៤៣,៤ | | ៤១,០ (២០១៤-១៥) | កើន ៥ពិន្ទុ |
| ៦. ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានធ្វើការវាយតម្លៃ | ១០ | ៣០ | ៣៨** | ៩០ |
| ៧. ភាគរយគ្រូបង្រៀនបឋមសិក្សាមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ+២ | ៥៧% | ៥៨% | ៦៩,៦២% | ៦១% |
| ៨. ភាគរយគ្រូឧទ្ទេសមានបរិញ្ញាបត្រជាន់ខ្ពស់ | ១០% | ១៥% | ២០,២%*** | ២៤% |
| **គោលនយោបាយទី២ ៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្រ្តីអប់រំគ្រប់លំដាប់ថ្នាក់** | | | | |
| ៩. ចំនួននាយកសាលាបឋមសិក្សា និងមធ្យមសិក្សាទទួលបានការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសាលារៀនផ្តែកលើលទ្ធផល | N/A | ៥០០ | ៩៩៨ | ៥០០ |
| ១០. ភាគរយនៃការទូទាត់ថវិកា | ៩៤,៣% (២០១៥) | ៩៥% | ៩៤%**** | ៩៥% |

*ប្រភព៖ * ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ ២០១៥*
*សម្គាល់៖ ** ការវាយតម្លៃសាកល្បង *** មិនរាប់បញ្ចូលវិទ្យាស្ថានជាតិអប់រំ **** តួលេខបណ្តោះអាសន្ន*

កុមារអាយុ ៥ឆ្នាំ បានទទួលសេវាអប់រំតាមគ្រប់រូបភាព ៦៦,៣៥ ភាគរយ នៃចំនួនប្រជាជនអាយុ ៥ឆ្នាំ កើន ២,២៥ ភាគរយ ធៀបទៅនឹងឆ្នាំសិក្សា ២០១៥-២០១៦ (ចំណុចដៅ ESP ៦៦ ភាគរយ)។

ស្រុកដែលមានអត្រាត្រួតថ្នាក់នៅបឋមសិក្សាតិចជាង ឬស្មើ ១០ ភាគរយ មាន ១៧៣ ក្រុង ស្រុក ខណ្ឌ (ចំណុចដៅ ១៧៦ ស្រុក) បើធៀបទៅនឹងឆ្នាំសិក្សា២០១៥-២០១៦ កើន ២ ស្រុក។

រាជធានី ខេត្តដែលបានសម្រេចអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិយ៉ាងតិច ៨០ ភាគរយ មាន ១១ លើ ២៥ រាជធានី ខេត្ត។

អត្រាអក្ខរកម្មជនពេញវ័យអាយុ ១៥ឆ្នាំឡើង បានប្រែប្រួលពី ៨០,៧០ ភាគរយ នៅឆ្នាំ២០១៣ មក ៧៨,១០ ភាគរយ នៅឆ្នាំ២០១៤។ វឌ្ឍនភាពសូចនាករទាំងពីរនេះទាមទារឱ្យមានការពង្រឹកថ្នាក់អក្ខរកម្មវិជ្ជាជីវៈបន្ថែមទៀត។

តេស្តរង្វាយតម្លៃថ្នាក់ជាតិថ្នាក់ទី៨ មុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យាបានអនុវត្តលើសាលាសំណាកគំរូ ២៣០ ក្នុងរាជធានី-ខេត្តទាំង២៥ សិស្សចូលរួម ៥ ៩០២ នាក់ ស្រី ៥៤,៥ ភាគរយ។ ភាគរយ

ឆ្លើយត្រូវដែលសិស្សសម្រេចបានលើមុខវិជ្ជាភាសាខ្មែរគឺ ៥៥,៦ ភាគរយ គណិតវិទ្យា គឺ ៤៩,០ ភាគរយ និងរូបវិទ្យា ៥២,៨ ភាគរយ ធ្វើតេស្តកាលពីឆ្នាំសិក្សា២០១៣-២០១៤។

តេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៣ មុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាបានអនុវត្តលើសាលាសំណាកគំរូ ២២៨ ក្នុងរាជធានី-ខេត្តទាំង២៥ សិស្សចូលរួម ៥ ៨៥១ នាក់ ស្រី ៥២,៨ ភាគរយ។ ភាគរយឆ្លើយត្រូវដែលសិស្សសម្រេចបានលើមុខវិជ្ជាភាសាខ្មែរ ៣៥,២ ភាគរយ និងគណិតវិទ្យា ៩១,០ ភាគរយ ធ្វើតេស្តកាលពីឆ្នាំសិក្សា២០១៤-២០១៥។

តេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៦ មុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាបានអនុវត្តលើសាលាសំណាកគំរូ ២៣០ ក្នុងរាជធានី-ខេត្តទាំង២៥ សិស្សចូលរួម ៥ ៩៣៩ នាក់ ស្រី ៥៤,៦ ភាគរយ។ ភាគរយឆ្លើយត្រូវដែលសិស្សសម្រេចបានលើមុខវិជ្ជាភាសាខ្មែរគឺ ៥២,១ ភាគរយ និងគណិតវិទ្យា គឺ ៤៨,៣ ភាគរយ ធ្វើតេស្តកាលពីឆ្នាំសិក្សា២០១៥-២០១៦។

គ្រឹះស្ថានឧត្តមសិក្សាដែលបានធ្វើការវាយតម្លៃសាកល្បងមាន ៣៨ ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ធៀបទៅនឹងឆ្នាំសិក្សា២០១៥-២០១៦ កើន ២៨។

គ្រូបង្រៀនបឋមសិក្សាមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ+២ មាន ៦៩,៦២ ភាគរយ ខ្ពស់ជាងចំណុចដៅ ១១,៦២ ភាគរយ (ចំណុចដៅ ៥៨ ភាគរយ)។

គ្រូឧទ្ទេសមានបរិញ្ញាបត្រជាន់ខ្ពស់ ២០,២ ភាគរយ ធៀបនឹងចំណុចដៅកើន ៥,២ ភាគរយ (ចំណុចដៅ ១៥ ភាគរយ)។

នាយកសាលាបឋមសិក្សា និងមធ្យមសិក្សាទទួលបានការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលមាន ៩៤៨ នាក់ ធៀបចំណុចដៅកើន ៤៤៨ នាក់ ក្នុងនោះនាយកសាលាបឋមសិក្សា ៦១៨ នាក់ និងនាយកសាលាមធ្យមសិក្សា ៣៣០ នាក់។

ឆ្នាំ ២០១៦ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តថវិកាកម្មវិធីពេញលេញ និងបោះផ្សាយអាណត្តិបើកប្រាក់សរុប ១ ៩០៨,០ ពាន់លានរៀល ស្មើនឹង ៩៤ ភាគរយ និងអនុវត្តលទ្ធកម្មបាន ១០៩ ៩៦៧ ១០៥ ៨០២ រៀល។ រដ្ឋបាលកណ្តាលអនុវត្តបាន ២៤៤,៩ ពាន់លានរៀល ស្មើនឹង ៨៤,២ ភាគរយ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត អនុវត្តបាន ១ ៦៦៣,១ ពាន់លានរៀល ស្មើនឹង ៩៥,៦ ភាគរយ *(តួលេខបណ្តោះអាសន្ន)*។

## ២.១.៣ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៦

ផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៦ បានបង្ហាញពីសកម្មភាព ៩១៦ ត្រូវអនុវត្ត ធៀបទៅនឹងឆ្នាំ ២០១៥ កើន ២៦៥ (ឆ្នាំ២០១៥ មាន ៦៥១)។ គិតត្រឹមខែធ្នូ ឆ្នាំ ២០១៦ សកម្មភាពបានអនុវត្តចប់មាន ៧៦៧ ស្មើនឹង ៨៣,៧ ភាគរយ បើធៀបទៅនឹងឆ្នាំ២០១៥ កើន ៨,៦ ភាគរយ (ឆ្នាំ២០១៥ អនុវត្តបាន ៧៥,១ ភាគរយ) សកម្មភាពកំពុងអនុវត្តមាន ៨៥ ស្មើនឹង ៩,៣ ភាគរយ និងមិនបានអនុវត្តមាន ៦៤ ស្មើនឹង ៧,០ ភាគរយ។ សេចក្តីលម្អិតនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៦ ឧបសម្ព័ន្ធទី១ និងទី៦។

## រូបភាពទី៣ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៦ (តាមកម្មវិធីអង្គភាពថ្នាក់ជាតិ)




## រូបភាពទី៤ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៦ (តាមអង្គភាព)



បើពិនិត្យតាមកម្មវិធីវិញបានបង្ហាញឱ្យឃើញថា៖

**កម្មវិធីទី១** ៖ ការអភិវឌ្ឍអប់រំចំណេះទូទៅនិងអប់រំក្រៅប្រព័ន្ធមាន ៨ អង្គភាព បានគ្រោងសកម្មភាព ២២៥ ក្នុងនោះសកម្មភាពបានអនុវត្តចប់ ១៩២ ស្មើនឹង ៨៥,៣ ភាគរយ កំពុងអនុវត្ត ១៦ ស្មើនឹង ៧,១ ភាគរយ និងមិនបានអនុវត្ត ១៧ ស្មើនឹង ៧,៦ ភាគរយ ក្នុងនោះ នាយកដ្ឋានអប់រំកុមារតូច និងនាយកដ្ឋានបណ្ដុះ-បណ្ដាលនិងវិក្រឹតការ បានអនុវត្តសកម្មភាពចប់ ១០០ ភាគរយ។ *(សូមមើលរូបភាពទី៥)*

## រូបភាពទី៥ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៦ របស់កម្មវិធីទី១



**កម្មវិធីទី២** ៖ ការអភិវឌ្ឍឧត្តមសិក្សានិងស្រាវជ្រាវវិទ្យាសាស្ត្រមាន ១២ អង្គភាព បានគ្រោងសកម្មភាព ២៨៩ ក្នុងនោះសកម្មភាពបានអនុវត្តចប់ ២៣១ ស្មើនឹង ៧៩,៩ ភាគរយ កំពុងអនុវត្ត ៣២ ស្មើ-នឹង ១១,១ ភាគរយ និងមិនបានអនុវត្ត ២៦ ស្មើនឹង ៩,០ ភាគរយ ក្នុងនោះសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងសាកលវិទ្យាល័យបាត់ដំបងបានអនុវត្តសកម្មភាពចប់ ១០០ ភាគរយ ដោយឡែកនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រអនុវត្តបានក្រោម ៥០ ភាគរយ។ *(សូមមើលរូបភាពទី៦)*

## រូបភាពទី៦ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៦ របស់កម្មវិធីទី២




**កម្មវិធីទី៣** ៖ ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡាមាន ៤ អង្គភាព បានគ្រោងសកម្មភាព ៥៤ ក្នុងនោះសកម្មភាពបានអនុវត្តចប់ ៤២ ស្មើនឹង ៧៧,៨ ភាគរយ កំពុងអនុវត្ត ១០ ស្មើនឹង ១៨,៥ ភាគរយ និងមិនទាន់អនុវត្ត ២ ស្មើនឹង ៣,៧ ភាគរយ ក្នុងនោះវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាអនុវត្តបានក្រោម ៥០ ភាគរយ។

**កម្មវិធីទី៤**៖ ការអភិវឌ្ឍយុវជនមាន ២ អង្គភាព បានគ្រោងសកម្មភាព ៤១ ក្នុងនោះសកម្មភាពបានអនុវត្តចប់ ៣៧ ស្មើនឹង ៩០,២ ភាគរយ កំពុងអនុវត្ត ១ ស្មើនឹង ២,៤ ភាគរយ និងមិនទាន់អនុវត្ត ៣ ស្មើនឹង ៧,៣ ភាគរយ។ (*សូមមើលរូបភាពទី៧*)

## រូបភាពទី៧ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៦ របស់កម្មវិធីទី៣ និងទី៤



**កម្មវិធីទី៥៖** ការគាំទ្រការគ្រប់គ្រងសេវាអប់រំនិងអភិបាលកិច្ចល្អមាន ១៥ អង្គភាព បានគ្រោងសកម្មភាព ២៨២ ក្នុងនោះសកម្មភាពបានអនុវត្តចប់ ២៤១ ស្មើនឹង ៨៥,៥ ភាគរយ កំពុងអនុវត្ត ២៥ ស្មើនឹង ៨,៩ ភាគរយ និងមិនទាន់អនុវត្ត ១៦ ស្មើនឹង ៥,៧ ភាគរយ ក្នុងនោះនាយកដ្ឋាន ផែនការ ហិរញ្ញវត្ថុ អធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ សម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ រដ្ឋបាល និងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ បានអនុវត្តសកម្មភាពចប់ ១០០ ភាគរយ។ (*សូមមើលរូបភាពទី៨*)

**រូបភាពទី៨ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៦ របស់កម្មវិធីទី៥**




**កម្មវិធីទី៦ ៖** កម្មវិធីផ្សេងៗមានសកម្មភាព ២៥ ក្នុងនោះសកម្មភាពបានអនុវត្តចប់ ២៤ ស្មើនឹង ៩៦,០ ភាគរយ សកម្មភាពកំពុងអនុវត្ត ១ ស្មើនឹង ៤,០ ភាគរយ។ ការងារកំណែទម្រង់វិស័យអប់រំ ការពិនិត្យតាមដានវាយតម្លៃ និងគ្រប់គ្រងមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ និងការបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំបានអនុវត្តសម្មភាពចប់ ១០០ ភាគរយ។ (*សូមមើលរូបភាពទី៩*)

**រូបភាពទី៩ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៦ របស់កម្មវិធីទី៦**



## ២.១.៤ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំសិក្សា ២០១៥- ២០១៦

សន្និបាតអប់រំឆ្នាំ ២០១៦ បានលើកទិសដៅ ១៩២ ក្នុងនោះទិសដៅកំណែទម្រង់សំខាន់ៗ ៣២ ទិសដៅអនុវិស័យ ១២៩ និងទិសដៅឆ្លងអនុវិស័យ ៣១។ ទិសដៅ ១១៦ ស្មើនឹង ៦០ ភាគរយ បានអនុវត្តចប់ ទិសដៅ ៦៨ ស្មើនឹង ៣៥ ភាគរយ កំពុងអនុវត្ត និងទិសដៅ ៨ ស្មើនឹង ៤ ភាគរយ មិនបានអនុវត្ត។

ទិសដៅកំណែទម្រង់សំខាន់ៗ ២២ ស្មើនឹង ៦៩ ភាគរយ ទិសដៅអនុវិស័យ ៧៤ ស្មើនឹង ៥៧ ភាគរយ និងទិសដៅឆ្លងអនុវិស័យ ២០ ស្មើនឹង ៦៥ ភាគរយ បានអនុវត្តចប់។ ទិសដៅកំណែទម្រង់សំខាន់ៗ ១០ ស្មើនឹង ៣១ ភាគរយ ទិសដៅអនុវិស័យ ៤៧ ស្មើនឹង ៣៦ ភាគរយ និងទិសដៅឆ្លងអនុវិស័យ ១១ ស្មើនឹង ៣៥ ភាគរយ កំពុងអនុវត្ត។ ទិសដៅអនុវិស័យ ៨ ស្មើនឹង ៦ ភាគរយ មិនបានអនុវត្ត។ (រូបភាពទី៥)

សេចក្ដីលម្អិតវឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំ២០១៦ ឧបសម្ព័ន្ធទី២ ទី៣ ទី៤ និងទី៥។

**រូបភាពទី១០ ៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំ ២០១៦ ថ្នាក់ជាតិ (កំណែទម្រង់សំខាន់ៗ អនុវិស័យ និងឆ្លងអនុវិស័យ)**




- **វឌ្ឍនភាពនៃការអនុវត្តទិសដៅកំណែទម្រង់សំខាន់ៗ**

ទិសដៅកំណែទម្រង់សំខាន់ៗសរុប ៣២ ក្នុងនោះការពង្រឹងប្រព័ន្ធផែនការ ១៣ ការងារវិមជ្ឈការនិងវិសហមជ្ឈការ ៦ ការគ្រប់គ្រងបុគ្គលិក ៦ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៧។ ទិសដៅ ២២ ស្មើ-នឹង ៦៩ ភាគរយ បានអនុវត្តចប់ (ការពង្រឹងប្រព័ន្ធផែនការ ៨ ការងារវិមជ្ឈការនិងវិសហមជ្ឈការ ៤ ការគ្រប់គ្រងបុគ្គលិក ៦ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៤)។ ទិសដៅ ១០ ស្មើនឹង ៣១ ភាគរយ កំពុងអនុវត្ត។ (រូបភាពទី១១)

សេចក្ដីលម្អិតវឌ្ឍនភាពនៃការអនុវត្តទិសដៅកំណែទម្រង់សំខាន់ៗឆ្នាំ២០១៦ ឧបសម្ព័ន្ធទី២ និងទី៣។

**រូបភាពទី១១ ៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅកំណែទម្រង់សំខាន់ៗ ឆ្នាំ២០១៦**




- ***វឌ្ឍនភាពនៃការអនុវត្តទិសដៅតាមអនុវិស័យ***

ទិសដៅសរុបរបស់អនុវិស័យទាំង ៧ មាន ១២៩ ក្នុងនោះអនុវិស័យការអប់រំកុមារតូច ១៦ ការអប់រំបឋមសិក្សា ២៤ ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស ២៦ ការអប់រំឧត្តមសិក្សា ១៨ ការអប់រំក្រៅប្រព័ន្ធ ៩ ការអភិវឌ្ឍយុវជន ១៤ និងការអប់រំកាយនិងកីឡា ២២។ ទិសដៅ ៧៤ ស្មើនឹង ៥៧ ភាគរយ បានអនុវត្តចប់ ទិសដៅ ៤៧ ស្មើនឹង ៣៦ ភាគរយ កំពុងអនុវត្ត និងទិសដៅ ៨ ស្មើនឹង ៦ ភាគរយ មិនទាន់អនុវត្ត។

ទិសដៅអនុវិស័យការអប់រំកុមារតូច ១១ ស្មើនឹង ៦៩ ភាគរយ ការអប់រំបឋមសិក្សា ១១ ស្មើនឹង ៤៦ ភាគរយ ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស ១២ ស្មើនឹង ៤៦ ភាគរយ ការអប់រំឧត្តមសិក្សា ១១ ស្មើ-នឹង ៦១ ភាគរយ ការអប់រំក្រៅប្រព័ន្ធ ៩ ស្មើនឹង ៨៩ ភាគរយ ការអភិវឌ្ឍយុវជន ៩ ស្មើនឹង ៦៤ ភាគរយ និង ការអប់រំកាយនិងកីឡា ១២ ស្មើនឹង ៥៥ ភាគរយ បានអនុវត្តចប់។

សេចក្តីលម្អិតវឌ្ឍនភាពនៃការអនុវត្តទិសដៅអនុវិស័យឆ្នាំ២០១៦ ឧបសម្ព័ន្ធទី២ និងទី៤។

**រូបភាពទី១២ ៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅអនុវិស័យ ឆ្នាំ២០១៦**



- ***វឌ្ឍនភាពនៃការអនុវត្តទិសដៅឆ្លងអនុវិស័យ***

ទិសដៅឆ្លងអនុវិស័យ ៣១ ក្នុងនោះការអភិវឌ្ឍកម្មវិធីសិក្សា ៥ ការងាររដ្ឋបាល ៤ ការងារទំនាក់ទំនងវប្បធម៌និងអាហារូបករណ៍ ៣ ការងារព័ត៌មាននិងកិច្ចការអាស៊ាន ៦ ការងារសំណង់សិក្សា ៣ ការងារបោះពុម្ពនិងចែកផ្សាយ ៤ និងការងារធានាគុណភាពអប់រំ ៦។ ទិសដៅ ២០ ស្មើនឹង ៦៥ ភាគរយ បានអនុវត្តចប់ និងទិសដៅ ១១ ស្មើនឹង ៣៥ ភាគរយ កំពុងអនុវត្ត ។ (រូបភាពទី១៣)

សេចក្តីលម្អិតវឌ្ឍនភាពនៃការអនុវត្តទិសដៅឆ្លងអនុវិស័យឆ្នាំ២០១៦ ឧបសម្ព័ន្ធទី២ និងទី៥។

***រូបភាពទី១៣ ៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅឆ្លងអនុវិស័យ ឆ្នាំ២០១៦***




## ២.១.៥ វឌ្ឍនភាពនៃការគ្រប់គ្រង និងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ

- ***ការងារផែនការ និងរបាយការណ៍***

ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០១៧-២០១៩ ផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧ របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ ២០១៦ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ កំពុងធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍ដោយចីរភាព (គោលដៅទី៤ ស្តីពីការអប់រំ) ឆ្នាំ ២០៣០ និងបានផ្តល់ធាតុចូលរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ ២០១៦ នៃការអនុវត្តផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ព្រមទាំងបានរៀបចំរបាយការណ៍ស្តីពីសមិទ្ធផលអប់រំ យុវជន និងកីឡាសម្រាប់ផ្ញើជូនក្រសួង ស្ថាប័នពាក់ព័ន្ធ។

- ***កម្មវិធីវិនិយោគសាធារណៈឆ្នាំ ២០១៧-២០១៩***

ក្រសួងបានរៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៧-២០១៩ មាន ២៧ គម្រោង ក្នុងនោះ គម្រោងកំពុងដំណើរការមាន ២១ គម្រោង និងគម្រោងកំពុងចរចា (ស្នើសុំថ្មី) មាន ៦ គម្រោង ដែលមានថវិកាសរុប ២០៨,៥ លាន ដុល្លារអាមេរិក។

### តារាងទី២៖ កម្មវិធីវិនិយោគសាធារណៈ (PIP) ឆ្នាំ២០១៣-២០១៥ ដល់ឆ្នាំ ២០១៧-២០១៩

(គិតជាពាន់ដុល្លារអាមេរិក)

| ឆ្នាំ | សរុបគម្រោងជំនួយ | | គម្រោងកំពុងដំណើរការ | | | | គម្រោងកំពុងចរចា | |
|---|---|---|---|---|---|---|---|---|
| | | | គម្រោងវិនិយោគ | | គម្រោងជំនួយបច្ចេកទេស | | | |
| | គម្រោង | ថវិកា | គម្រោង | ថវិកា | គម្រោង | ថវិកា | ចំនួនគម្រោង | ថវិកាគ្រោង |
| ២០១៣-២០១៥ | ៤១ | ២៣១ ៨៣៣ | ១ | ១ ១៩០ | ២២ | ១៤១ ៩៧២ | ១៨ | ៨៨ ६៧១ |
| ២០១៤-២០១៦ | ២៩ | ២៦៦ ៥៧១ | ២ | ២១ ៥០០ | ១៤ | ១១៦ ៧៩២ | ១៣ | ១២៨ ២៧៨ |
| ២០១៥-២០១៧ | ២៧ | ១៩៨ ២៩២ | ៥ | ៤៩ ៥៧០ | ១៣ | ៩៨ ១០៩ | ៩ | ៥០ ៦១៩ |
| ២០១៦-២០១៨ | ២៧ | ១៨៦ ២៩១ | ៧ | ៥៧ ៩៥៣ | ១៣ | ៣៧ ៩៦៩ | ៧ | ៩០ ៣៦៩ |
| ២០១៧-២០១៩ | ២៧ | ២០៨ ៩៨១ | ១៤ | ១៥៧ ០៥៥ | ៧ | ៥ ៥៤០ | ៦ | ៤៥ ៨៨៥ |

យើងសង្កេតឃើញថា ចំនួនគម្រោងនៃកម្មវិធីវិនិយោគសាធារណៈឆ្នាំ២០១៧-២០១៩ មិនមានការថយចុះទេ បើធៀបទៅនឹងបីឆ្នាំចុងក្រោយ ក្នុងនោះគម្រោងវិនិយោគបានកើនឡើងទ្វេដង រីឯគម្រោងជំនួយបច្ចេកទេសបានថយចុះ។

- **វឌ្ឍនភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ**

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់វិស័យអប់រំឆ្នាំ ២០១៦ មានថវិកាសរុបជាង ៩០ លានដុល្លារអាមេរិក បានកើនឡើងបើធៀបនឹងឆ្នាំ ២០១៥។ ក្នុងចំណោមដៃគូអភិវឌ្ឍទាំង១០ សហភាពអឺរ៉ុបបានផ្តល់ថវិកាច្រើនជាងគេ បន្ទាប់មកមានអង្គការស្បៀងអាហារពិភពលោក និងអង្គការយូនីសេហ្វ។

ភ្នាក់ងារផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដល់វិស័យអប់រំ ១០ ដែលស្ថិតនៅក្នុងលំដាប់ខ្ពស់ជាងគេ មានបង្ហាញនៅក្នុងតារាងខាងក្រោម៖

### តារាងទី៣ ៖ ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍សំខាន់ៗក្នុងវិស័យអប់រំ

(ឯកតាៈ ពាន់ដុល្លារអាមេរិក)

| ល.រ | ដៃគូអភិវឌ្ឍ | ចំណាយជាក់ស្តែង ឆ្នាំ ២០១៤ | ចំណាយជាក់ស្តែង ឆ្នាំ ២០១៥ | ចំណាយជាក់ស្តែង ២០១៦ | ផែនការឆ្នាំ ២០១៧ | ផែនការឆ្នាំ ២០១៨ | ផែនការឆ្នាំ ២០១៩ |
|---|---|---|---|---|---|---|---|
| ១ | សហភាពអឺរ៉ុប | ១ ០២១ | ៨ ៤៩៨ | ២៤ ១៤៩ | ២៨ ៦១៥ | ៣៦១ | N/A |
| ២ | អង្គការស្បៀងអាហារពិភពលោក | ៩ ៩៥៨ | ៨ ៩១០ | ១៤ ៩១០ | N/A | N/A | N/A |
| ៣ | អង្គការយូនីសេហ្វ | ៧ ២២៧ | ៦ ៩៩៧ | ៩ ០៦៥ | ៦ ៥៦០ | ៣ ៣៧៥ | N/A |
| ៤ | ធនាគារអភិវឌ្ឍអាស៊ី | ៥០៩ | ៥ ៥០០ | ៤ ៦០០ | ៥ ២០០ | ៣ ២០០ | N/A |
| ៥ | ប្រទេសស៊ុយអែត | ១១ ៩៤៨ | ៧ ៩១៤ | ៣ ៩៧៥ | ១៣៩ | N/A | N/A |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦ | ធនាគារពិភពលោក | ៧ ៤៨៩ | ១ ៧៣៦ | ៣ ៨៨៨ | ៩ ១៧១ | ១០ ៨០១ | N/A |
| ៧ | ប្រទេសជប៉ុន | ៦ ៥០៣ | ៨ ៩៨៧ | ៣ ៧១៤ | ២ ៨៣៤ | ២ ៧១៩ | N/A |
| ៨ | សាធារណរដ្ឋកូរ៉េ | ១ ៩៣២ | ៣ ៧២៣ | ២ ៦៤៩ | ២ ៨០០ | N/A | N/A |
| ៩ | ប្រទេសនូវែលសេឡង់ | ៣ ០៨២ | ១ ១២៨ | ២ ៦៣៥ | ៩៥០ | ៨៥២ | N/A |
| ១០ | ប្រទេសអាមេរិក | ៦ ៣៣៤ | ៧ ២០៦ | ២ ២៣៣ | N/A | N/A | |
| សរុបភាគីផ្តល់ជំនួយចំនួន១០ | | **៥៥ ៥០៣** | **៦០ ៥៩៩** | **៧១ ៨២០** | **៥៥ ៨៧១** | **២១ ៣១០** | N/A |
| សរុបភាគីផ្តល់ជំនួយទាំងអស់ | | **៥៥ ៨៣៧** | **៦១ ៣៥៨** | **៩០ ៨៨៤** | **៥៨ ២៥៨** | **២១ ៦២៤** | N/A |

ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក) ទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧

- **គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការដែលបានអនុម័ត**

- ជប៉ុនបានអនុម័តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ សម្រាប់អនុវត្តនៅក្នុងឆ្នាំ ២០១៧ គឺគម្រោង "ការកសាងមូលដ្ឋានគ្រឹះសម្រាប់វិទ្យាស្ថានគរុកោសល្យ" ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការបច្ចេកទេស
- ភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិបានអនុម័តគម្រោង "លើកកម្ពស់អំណានថ្នាក់ដំបូងនៅបឋមសិក្សា" មានថវិកា ៦,៩ លានដុល្លារអាមេរិក សម្រាប់ឆ្នាំ ២០១៦-២០១៨
- ធនាគារអភិវឌ្ឍន៍អាស៊ីបានអនុម័តគម្រោង "អភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ" មានថវិកា ៤៨ លានដុល្លារអាមេរិក សម្រាប់ឆ្នាំ ២០១៧-២០២១។

- **គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការដែលបានស្នើសុំ**

- ហិរញ្ញប្បទានឥតសំណងពីសាធារណរដ្ឋកូរ៉េ សម្រាប់ឆ្នាំ២០១៨ ចំនួន ២ គម្រោង ៖
    - គម្រោងអំណានថ្នាក់ដំបូងនៅកម្ពុជា
    - គម្រោងលើកកម្ពស់សុខភាព និងអប់រំសុខភាពសម្រាប់សិស្សស្រីដែលសិក្សានៅតាមគ្រឹះស្ថានសិក្សាសាធារណៈ
- ហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនចំនួន ២ គម្រោង ៖
    - គម្រោងកែលម្អបរិស្ថានសាលារៀន និងសម្ភារបរិក្ខារអប់រំ មានថវិកា ៤០ លានដុល្លារអាមេរិក
    - គម្រោងសាលារៀនជំនាន់ថ្មីនៅវិទ្យាល័យព្រះស៊ីសុវត្ថិ មានថវិកា ៦ លានដុល្លារអាមេរិក
- មូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំជំហានទី៣ មានថវិកា ២០,៦ លានដុល្លារអាមេរិក
- ថវិកាគាំទ្រពីសហភាពអឺរ៉ុប មានថវិកា ១០០ លានដុល្លារអាមេរិក សម្រាប់ឆ្នាំ២០១៨-២០២១
- ហិរញ្ញប្បទានឥណទានធនាគារពិភពលោក "កែលម្អការអប់រំមធ្យមសិក្សា" មានថវិកា ៤០ លានដុល្លារអាមេរិក សម្រាប់ឆ្នាំ២០១៧-២០២១។

- **ទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិបំពេញការងារនៅតាមអង្គភាពក្រោមឱវាទក្រសួង និងថ្នាក់ក្រោមជាតិ**

ក្រសួងបានប្រមូលនិងរៀបចំចងក្រងព័ត៌មានស្តីពីទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិដែលបានបំពេញការងារនៅក្រោមឱវាទក្រសួង និងនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បី

ពិនិត្យតាមដានអំពីវឌ្ឍនភាពនៃការបំពេញការងាររបស់ទីប្រឹក្សាបច្ចេកទេស។ ឆ្នាំ២០១៦ ទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិបម្រើការងារនៅអង្គភាពក្រោមឱវាទក្រសួងមាន ១៥ នាក់ ស្មើនឹង ១២១ នាក់-ខែ និងនៅតាមមន្ទីរអបរំ យុវជន និងកីឡារាជធានី ខេត្ត មានទីប្រឹក្សាបច្ចេកទេស ២៩ នាក់ ដែលភាគច្រើនជាអ្នកស្ម័គ្រចិត្ត។

ជារួម ចំនួនទីប្រឹក្សាបច្ចេកទេសបម្រើការងារនៅក្នុងក្រសួង មានការថយចុះជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ស្របទៅនឹងគោលការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ។

- *លទ្ធផលការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ*

ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិបានប្រជុំ ៣ ដង និងធ្វើវិបស្សនា ១ ដង តាមផែនការកំណត់នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំដើម្បីអនុវត្តកំណែទម្រង់វិស័យអប់រំឱ្យមានប្រសិទ្ធភាព។

ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត បានដំណើរការប្រជុំទៀងទាត់តាមត្រីមាស និងមានរបៀបវារៈសំខាន់ៗដើម្បីដោះស្រាយបញ្ហាអប់រំនៅមូលដ្ឋានរៀងៗខ្លួន។

## ២.១.៦ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ទមជ្ឈការ និងវិសហមជ្ឈការ

### *ការលើកកម្ពស់អភិបាលកិច្ចនៅគ្រប់កម្រិត*

ក្រសួងបាន៖

- ផ្សព្វផ្សាយក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានអ្នកចូលរួម ៣២៩ នាក់ ស្រី ១៥,៥០ ភាគរយ
- ផ្សព្វផ្សាយគោលការណ៍អភិបាលកិច្ចល្អសម្រាប់ពង្រឹងការផ្តល់សេវាអប់រំ មានអ្នកចូលរួម ១៩០ នាក់ ស្រី ១៣,៦៨ ភាគរយ
- ពង្រឹងសមត្ថភាពបុគ្គលិកអប់រំ ស្តីពីច្បាប់អប់រំ និងលិខិតបទដ្ឋានគតិយុត្ត មានអ្នកចូលរួម ៧៦១ នាក់ ស្រី ៣៥,៣៩ ភាគរយ
- ផ្សព្វផ្សាយនីតិវិធីនៃការតាក់តែងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអប់រំ មានអ្នកចូលរួម ៦៧ នាក់ ស្រី ១០,៤៤ ភាគរយ
- ផ្សព្វផ្សាយនីតិវិធីនៃការស្នើ ការតវ៉ា ការប្តឹង និងដំណោះស្រាយ មានអ្នកចូលរួម ៧៥ នាក់ ស្រី ១៤,៦៦ ភាគរយ
- ពង្រឹងសមត្ថភាពគ្រប់គ្រងវិវាទបុគ្គលិកអប់រំ មានអ្នកចូលរួម ១៣០ នាក់ ស្រី ១៧,៦៩ ភាគរយ
- ពិនិត្យតាមដានការអនុវត្តការផ្តល់សេវាអប់រំផ្អែកតាមគោលការណ៍អភិបាលកិច្ចល្អបាន ១១ ខេត្ត
- ពិនិត្យតាមដានការអនុវត្តច្បាប់ ស្តីពីការអប់រំ និងលិខិតបទដ្ឋានគតិយុត្តវិស័យអប់រំបាន ៧ ខេត្ត
- សិក្សាស្រាវជ្រាវលើវិវាទបុគ្គលិកអប់រំក្នុង និងក្រៅប្រព័ន្ធតុលាការ នៅខេត្តស្វាយរៀង កំពង់ចាម ព្រះវិហារ បាត់ដំបង កោះកុង និងខេត្តកំពង់ឆ្នាំង ដោយបានស្រាវជ្រាវលើវិវាទ ១២ករណី ក្នុងនោះ

មាន ៨ករណីក្នុងប្រព័ន្ធតុលាការ (៣ ករណីលើកលែងទោស ៥ ករណីកំពុងបន្តនីតិវិធី) និងក្រៅប្រព័ន្ធតុលាការ ៤ ករណី (៣ ករណីដោះស្រាយរួច ១ ករណីបន្តនីតិវិធី)

- ផ្តល់ការគាំពារផ្នែកច្បាប់លើករណីវិវាទដីធ្លី ២ ករណី (ការិយាល័យអប់រំ យុវជន និងកីឡាស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ១ ករណី និងអនុវិទ្យាល័យចតុមុខ រាជធានីភ្នំពេញ ១ ករណី)
- ផ្តល់ប្រឹក្សាច្បាប់លើវិវាទ ៦ ករណី រួមមាន ៖ ១. វិវាទបុគ្គលិកអប់រំនៅសាលាមត្តេយ្យ ៨មីនា ២. វិវាទមតិក ៣. វិវាទដីធ្លីនៅវិទ្យាល័យព្រះយុគន្ធរ ៤. វិវាទដីធ្លីនៅវិទ្យាស្ថានស្លឹករឹត នៅក្នុងវិទ្យា-ល័យបឹងត្របែក ៥. វិវាទចំណតរថយន្តក្រោមដីពហុកីឡដ្ឋានជាតិអូឡាំពិក និង ៦.កាប្តូរឈ្មោះ និងថ្ងៃខែឆ្នាំកំណើតលើសញ្ញាបត្រ
- សិក្សាភាពងាយរងគ្រោះដោយសារអំពើជួញដូរមនុស្ស ៧ ខេត្ត
- ពិនិត្យតាមដានការអនុវត្តច្បាប់ស្តីពីការអប់រំ និងផលប៉ះពាល់ការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយវិស័យអប់រំ ៥ ខេត្ត។

### *ការងារកំណែទម្រង់ការគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ*

ក្រសួងបាន ៖

- ផ្សព្វផ្សាយអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការផ្ទេរមុខងារ និងធនធានសម្រាប់ការងារអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ នៅខេត្តបាត់ដំបង
- ផ្សព្វផ្សាយគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ មានអ្នកចូលរួម ២៩៩ ណាក់ ស្រី ១១,០៣ ភាគរយ
- ផ្សព្វផ្សាយដល់បុគ្គលិកអប់រំ និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីការផ្ទេរមុខងារ និងធនធានវិស័យអប់រំ មានអ្នកចូលរួម ១៥០ នាក់ ស្រី ១០,៦៦ ភាគរយ នៅខេត្តក្រចេះ ត្បូងឃ្មុំ ពោធិ៍សាត់ និងកំពត
- បំប៉នសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីការផ្ទេរមុខងារ មានអ្នកចូលរួម ១៥៧ នាក់ ស្រី ២៥,៤៧ ភាគរយ
- ផលិតឯកសារស្តីពីការផ្តល់សេវាអប់រំផ្អែកតាមគោលការណ៍អភិបាលកិច្ចល្អ ៣២៥ ក្បាល
- ព្រាងផែនការសកម្មភាពគោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យអប់រំ
- សិក្សាផលប៉ះពាល់ និងបញ្ហាប្រឈមនៃការផ្ទេរមុខងារ និងធនធានវិស័យអប់រំឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកនៃខេត្តបាត់ដំបង

### *ការងាររៀបចំលិខិតបទដ្ឋាន និងការពង្រឹងការអនុវត្ត*

ក្រសួងបានរៀបចំ ៖

- លិខិតបទដ្ឋានគតិយុត្ត ២៨ ក្នុងនោះអនុក្រឹត្យ ៥ ប្រកាស ១៩ សេចក្តីសម្រេច ៧ សេចក្តីណែនាំ ២ និងសេចក្តីជូនដំណឹង ១

- វាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានវិស័យអប់រំ ៧ និងផ្តល់អាជ្ញាបណ្ណ ៨២
- អនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- អនុក្រឹត្យស្តីពីការផ្តល់ប្រាក់រង្វាន់ដល់ជ័យលាភីសិស្សពូកែផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និង វិទ្យាសាស្ត្រ
- អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការបង្កើតសាកលវិទ្យាល័យ **ហេង សំរិន** ត្បូងឃ្មុំ
- អនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការផ្តល់រង្វាន់ដល់ជ័យលាភីសិស្សពូកែ ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ
- ប្រកាសលេខ ៨៦ អយក.ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋាន នៃនាយកដ្ឋាននីតិកម្ម
- ប្រកាសលេខ ៨២ អយក.ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ
- ប្រកាសលេខ ១៧៥ អយក.ប្រក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកាត់សាលាបឋមសិក្សាព្រៃតាឡួយ និងសាលាបឋមសិក្សាបុះតាផង់ចេញពីការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត និងសាលាឧបសម្ព័ន្ធស្រែជើងរាស្ត្រ ចេញពីការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ ទៅឱ្យនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ
- ប្រកាសលេខ ២៨២ អយក.ប្រក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ ស្តីពីការទទួលស្គាល់នាយកសាលារៀនល្អ និងគ្រូបង្រៀនល្អ ជ័យលាភីពានរង្វាន់ **សម្តេចតេជោ សែន** ឆ្នាំសិក្សា ២០១៤-២០១៥
- ប្រកាសលេខ ៣៤៧ អយក.ប្រក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល
- ប្រកាសលេខ ៤០៧ អយក.ប្រក ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ស្តីពីការប្រើប្រាស់ត្រាមូលទឹក និងនិមិត្តសញ្ញារបស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល
- ប្រកាសលេខ ៤៦៥ អយក.ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិយុវជនកម្ពុជា
- ប្រកាសលេខ ៧០០ អយក.ប្រក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការកម្រិតវិន័យចំពោះបុគ្គលិកអប់រំក្នុងការប្រឡងសញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិ
- ប្រកាសលេខ ៧២៦ អយក.ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- ប្រកាសលេខ ៧២៧ អយក.ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការកម្រិតវិន័យចំពោះបុគ្គលិកអប់រំក្នុងការ ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

- ប្រកាសលេខ ៧៧២ អយក.ប្រក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ
- ប្រកាសលេខ ៧៧៣ អយក.ប្រក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា
- ប្រកាសលេខ ៩៦៥ អយក.ប្រក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ហិរញ្ញវត្ថុនៃនាយកដ្ឋានហិរញ្ញវត្ថុ
- ប្រកាសលេខ ៩៨៦ អយក.ប្រក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ស្ដីពីតម្លៃសមមូលនៃសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- ប្រកាសលេខ ១០០២ អយក.ប្រក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្ដីពីការប្រើប្រាស់ត្រាមូលរបស់នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- ប្រកាសលេខ ១០០៣ អយក.ប្រក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្ដីពីកម្រិតសមមូលសញ្ញាបត្របណ្ដុះបណ្ដាលគ្រូបង្រៀន
- ប្រកាសស្ដីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានទទួលស្គាល់គុណភាពអប់រំថ្នាក់ក្រោយបរិញ្ញាបត្រ
- ប្រកាសអន្តរក្រសួងស្ដីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍
- ប្រកាសស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- សេចក្ដីសម្រេចលេខ ៩៥ សសរ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦ ស្ដីពីការកំណត់និមិត្តសញ្ញានិងត្រារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- សេចក្ដីសម្រេចលេខ ២០ សសរ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការបង្កើតគណៈកម្មការការសិទ្ធិមនុស្សរបស់ក្រសួងអប់រំ យុវជន និងកីឡា
- សេចក្ដីសម្រេចលេខ ៣៦ អយក.សសរ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្ដីពីការៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមការងារដឹកនាំ និងគ្រប់គ្រងសកម្មភាពគោលនយោបាយស្ដីពីគ្រូបង្រៀន
- សេចក្ដីសម្រេចលេខ ០១ កជយ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្ដីពីបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- សេចក្ដីសម្រេចលេខ ០៣ កជយ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្ដីពីការបង្កើក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួងស្ថាប័ន
- សេចក្ដីសម្រេចលេខ ០៤ កជយ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្ដីពីការបង្កើក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានីខេត្ត
- សេចក្ដីសម្រេចលេខ ៣៥ អយក.សសរ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្ដីពីការរៀបចំការងារបច្ចេកទេស និងអនុវត្តផែនការ សកម្មភាព គោលនយោបាយ ស្ដីពីគ្រូបង្រៀន

- សេចក្តីណែនាំលេខ ១៥ អយក.សណន ចុះថ្ងៃទី០២ ខែមិនា ឆ្នាំ២០១៦ ស្តីពីការប្រារព្ធទិវាជាតិអំណាន ១១ មីនា
- សេចក្តីណែនាំលេខ ៩៥ អយក.សណន ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស ១២ធ្នូ នៅតាមគ្រឹះស្ថានសិក្សាទូទាំងប្រទេស
- សេចក្តីជូនដំណឹងលេខ ៥៧៨ សជណ.អវ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីគោលការណ៍រៀបចំផ្តល់ប្រាក់រង្វាន់ជូន ជ័យលាភី ក្នុងការប្រឡងប្រណាំងអាន សូត្រកំណាព្យ តែងនិពន្ធ និងការប្រសិទ្ធនាមពានរង្វាន់ក្នុង ទិវាជាតិអំណាន
- សេចក្តីព្រាងសេចក្តីណែនាំបច្ចេកទេសអនុវត្តមុខងារវិស័យអប់រំ ដែលបានប្រគល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ
- សេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុក ស្ថិតក្រោម រចនាសម្ព័ន្ធ រដ្ឋបាលក្រុង ស្រុក។

## ២.១.៧ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ

*ស្ថានភាពបុគ្គលិកអប់រំ*

បុគ្គលិកអប់រំគ្រប់កម្រិតសរុប ១១៦ ៤៥៧ នាក់ ស្រី ៤៤,៥៤ ភាគរយ ក្នុងនោះនៅថ្នាក់ជាតិ ៣ ០៨២ នាក់ ស្រី ២៧,២៥ ភាគរយ និងថ្នាក់ក្រោមជាតិ ១១៣ ៣៧៥ នាក់ ស្រី ៤៥,២៦ ភាគរយ។ ក្របខណ្ឌគ្រូមត្តេយ្យសិក្សា ៣ ៨៨៧ នាក់ ស្រី ៩៨,២៥ ភាគរយ គ្រូបឋមសិក្សា ៥៦ ៨៨០ នាក់ ស្រី ៥៨,៩១ ភាគរយ គ្រូកម្រិតមូលដ្ឋាន ៤១ ២៩៦ នាក់ ស្រី ៣៩,៨៩ ភាគរយ គ្រូកម្រិតឧត្តម ១៤ ៥៥១ នាក់ ស្រី ២៨,២៣ ភាគរយ ក្របខណ្ឌគ្រូបច្ចេកទេស ១១៦ នាក់ ស្រី ១៥,៥១ ភាគរយ ក្របខណ្ឌអធិការបឋម ៦២ នាក់ ស្រី ២០,៩៦ ភាគរយ និងអធិការមធ្យម ៦៥ នាក់ ស្រី ២១,៥៣ ភាគរយ។

ក្រសួងប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា ៤៦៩ នាក់ ស្រី ៣៧,៣១ ភាគរយ ក្នុងនោះក្រោមឱវាទទីស្តីការក្រសួង ២៧០ នាក់ ស្រី ៣៥,៩២ ភាគរយ។ គ្រូបង្រៀនជាប់កិច្ចសន្យាចំណោះទូទៅ ៥ ៨៤២ នាក់ ស្រី ៥១,៦៤ ភាគរយ និងគ្រូអក្ខរកម្មជាប់កិច្ចសន្យា ២ ៩៧២ នាក់ ស្រី ៣៤,៨៣ ភាគរយ។ គ្រូបង្រៀនពីរថ្នាក់ពីរពេល ១៣ ៤៧៣ នាក់ ស្រី ៤៤,០៦ ភាគរយ គ្រូបង្រៀនថ្នាក់គួបពីរកម្រិតថ្នាក់ ២ ៩០៥ នាក់ ស្រី ៣៣,៣២ ភាគរយ គ្រូបង្រៀនថ្នាក់គួបបីកម្រិតថ្នាក់ ១៩០ នាក់ ស្រី ១៦,៨២ ភាគរយ។

ក្រសួងបានរៀបចំ៖

- ក្រុមការងារកំណែទម្រង់រដ្ឋបាលសាធារណៈ
- កែសម្រួលអនុក្រឹត្យស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ
- ឧបករណ៍វាយតម្លៃការបំពេញការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បើកគណនីប្រាក់បៀវត្សសម្រាប់គ្រូបង្រៀនចេញថ្មីគ្រប់កម្រិត ដើម្បីបើកប្រាក់តាមប្រព័ន្ធធនាគារ

- រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងអង្គភាពក្រោមឱវាទទីស្តីការក្រសួង និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ឱ្យស្របតាមបរិបទកំណែទម្រង់។

*ការជ្រើសរើសបុគ្គលិកអប់រំ*

ក្រសួងបាន ៖

- ជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តមបង្រៀននៅគ្រឹះស្ថានឧត្តមសិក្សា ២៧ នាក់ ស្រី ១៤,៨១ ភាគរយ
- ពង្រាយគ្រូបង្រៀនពីសាលាលើសទៅសាលាខ្វះគ្រូ ៩៤ នាក់ ស្រី ៣៩,៣៦ ភាគរយ ពង្រាយគ្រូចេញថ្មីគ្រប់កម្រិត ៥ ៣៨៤ នាក់ ស្រី ៦០,៣២ ភាគរយ
- តែងតាំងគ្រូបង្រៀនកម្មសិក្សាគ្រប់កម្រិត ៤ ២៣៥ នាក់ ស្រី ៧៣,២៩ ភាគរយ
- បញ្ចូលក្របខណ្ឌពិសេស ១៦ នាក់ ស្រី ៤៣,៧៥ ភាគរយ
- បញ្ចូលក្របខណ្ឌគ្រូបង្រៀនខ្មែរឥស្លាម ១ ៣៩១ នាក់ ស្រី ២៤,០៨ ភាគរយ ទៅក្នុងក្របខណ្ឌគ្រូបង្រៀន
- បែងចែកក្របខណ្ឌថ្មី ៣ ៨៨៨ កន្លែងសម្រាប់ការប្រឡងជ្រើសរើសក្របខណ្ឌឆ្នាំ២០១៦។

*ការលើកទឹកចិត្តបុគ្គលិកអប់រំ*

ក្រសួងបាន៖

- ផ្តល់ពានរង្វាន់ **សម្តេចតេជោសែន** ដល់នាយកល្អ ៣ រូប និងគ្រូបង្រៀនល្អ ៥ រូប
- រៀបចំសំណុំលិខិតបើកប្រាក់បៀវត្សជូនគ្រូចេញថ្មី ៤ ៩៦៤ នាក់ ស្រី ៦២,៦៣ ភាគរយ
- កែសម្រួលទិន្នន័យមន្ត្រីរាជការក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស ៥០ អង្គភាព
- តែងតាំងមន្ត្រីគ្រប់គ្រងនៅថ្នាក់ជាតិ ១៦៦ នាក់ ស្រី ១៩,២៧ ភាគរយ និងដំឡើងថ្នាក់ ឋានន្តរសក្តិជូនបុគ្គលិកអប់រំ ៨៦ ៩១៣ នាក់ ស្រី ៤៣,៤៣ ភាគរយ
- តាំងស៊ប់ក្នុងក្របខណ្ឌជូនគ្រូបង្រៀនចេញថ្មីដែលបានបញ្ចប់កម្មសិក្សាឆ្នាំ២០១៥ និងអតីតបុគ្គលិក ៦ ៣៥០ នាក់ ស្រី ៥៧,៤០ ភាគរយ
- តាំងស៊ប់ក្នុងក្របខណ្ឌជូនគ្រូបង្រៀនចេញថ្មីអតីតបុគ្គលិកឆ្នាំ២០១៦ ជាគ្រូកម្រិតឧត្តម ៤៩៩ នាក់ ស្រី ២៧,៦៥ ភាគរយ និងគ្រូបង្រៀនកម្រិតមូលដ្ឋានអតីតបុគ្គលិក ១ ៥២៥ នាក់ ស្រី ៥៣,០៤ ភាគរយ
- ដំឡើងថ្នាក់ និងឋានន្តរសក្តិជូនបុគ្គលិកអប់រំ ៩៤ ៣១៨ នាក់ ស្រី ៤១,៩០ ភាគរយ
- ពិនិត្យនិងចេញនីត្យានុកូលភាពលើការងារតែងតាំងមន្ត្រីគ្រប់គ្រងនៅថ្នាក់ក្រោមជាតិ ៥ ៧១៨ នាក់ ស្រី ១១,០៨ ភាគរយ
- ដាក់មន្ត្រីរាជការឱ្យនៅទំនេរគ្មានបៀវត្ស ៦៦៣ នាក់ ស្រី ៣៤,២៣ ភាគរយ និងចូលបម្រើការងារវិញ ៦០៤ នាក់ ស្រី ៣០,៦២ ភាគរយ

- អនុញ្ញាតច្បាប់ឱ្យមន្ត្រីរាជការព្យាបាលជំងឺ ១០៥ នាក់ ស្រី ៤៨,៥៧ ភាគរយ ឈប់សម្រាកដោយមានភារកិច្ចផ្ទាល់ខ្លួន ២៩ នាក់ ស្រី ៧៥,៨៦ ភាគរយ និងលំហែមាតុភាព ២៣ នាក់
- ផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់មន្ត្រីរាជការ ៧៩៦ នាក់ ស្រី ៣៦,៩៣ ភាគរយ និងផ្ទេរក្របខណ្ឌមន្ត្រីរាជការទៅក្រសួង ស្ថាប័ននានា ១៨៦ នាក់ ស្រី ១៣,៩៧ ភាគរយ
- ដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ ១ ៧៧៩ នាក់ ស្រី ៣២,១៥ ភាគរយ និងលុបឈ្មោះមន្ត្រីរាជការ ៤៧៧ នាក់ ស្រី ២៨,៧២ ភាគរយ
- បំពាក់គ្រឿងឥស្សរិយយសការងារជូនបុគ្គលិកអប់រំ ២ ៤៤៨ នាក់ ស្រី ២៩,៨៦ ភាគរយ ក្នុងនោះថ្នាក់ជាតិ ៨១៥ នាក់ ស្រី ២៦,០១ ភាគរយ ថ្នាក់ក្រោមជាតិ ១ ៦១១ នាក់ ស្រី ៣១,៦៥ ភាគរយ និងដៃគូអភិវឌ្ឍ ២២នាក់ ស្រី ៤០,៩០ ភាគរយ
- លើកសរសើរអង្គភាពមានស្នាដៃការងារឆ្នាំសិក្សា២០១៤-២០១៥ ចំនួន ៣២៨ អង្គភាព ក្នុងនោះទង់លេខ១ ចំនួន ៩៤ លេខ ២ ចំនួន ៩៤ និងបណ្ណសរសើរចំនួន ១៤០
- ផ្តល់លិខិតសរសើរជូនគ្រូបង្រៀន ៥៦៤ នាក់ ស្រី ២៤,២៩ ភាគរយ ដែលបានស្ម័គ្រចិត្តបង្រៀនបំប៉នសិស្សថ្នាក់ទី១២ នៅខេត្តកណ្តាល និងរាជធានីភ្នំពេញ
- ផ្តល់លិខិតថ្លែងអំណរគុណដល់គណៈមេប្រយោគប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ៧៥០ នាក់ ស្រី ៩,៨៦ ភាគរយ
- ផ្តល់បណ្ណសរសើរដល់បុគ្គលិកអប់រំ ដែលមានស្នាដៃបំពេញការងារល្អបម្រើវិស័យអប់រំ យុវជន និងកីឡារហូតដល់ចូលនិវត្តន៍ ១ ៧៣៣ នាក់ ស្រី ៤០ ភាគរយ
- សុំគ្រឿងឥស្សរិយយសការងារឆ្នាំសិក្សា២០១៥-២០១៦ ជូនបុគ្គលិកអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៨ ៨១៤ នាក់ ស្រី ២៤,៥៣ ភាគរយ និងបណ្ណសរសើរ ៣៥២ អង្គភាព។

## ២.១.៨ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### *ការងារហិរញ្ញកិច្ច*

ឆ្នាំ ២០១៦ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តថវិកាកម្មវិធីពេញលេញ និងបោះផ្សាយអាណត្តិបើកប្រាក់សរុប ១ ៩០៨,០ ពាន់លានរៀល ស្មើនឹង ៩៤ ភាគរយ និងអនុវត្តលទ្ធកម្មបាន ១០៩ ៩៦៧ ១០៥ ៨០២ រៀល។ រដ្ឋបាលកណ្តាលអនុវត្តបាន ២៤៤,៩ ពាន់លានរៀល ស្មើនឹង ៨៤,២ ភាគរយ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត អនុវត្តបាន ១ ៦៦៣,១ ពាន់លានរៀល ស្មើនឹង ៩៥,៦ ភាគរយ (តួលេខបណ្តោះអាសន្ន) ។

ក្រសួងបាន ៖

- អនុវត្តប្រព័ន្ធ FMIS តាមអង្គភាពថវិកានៅរដ្ឋបាលកណ្តាល ៣៦ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ២៥

- បង្កើតប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ នៅរដ្ឋបាលកណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- រៀបចំសៀវភៅនីតិវិធីគ្រប់គ្រងមូលនិធិកែលម្អសាលារៀន
- រៀបចំកែសម្រួលអនុក្រឹត្យស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ
- រៀបចំគោលការណ៍ពិសេសសម្រាប់ការបង្រៀនពេញពេលសាកល្បងនៅសាលាបឋមសិក្សា ៣ នៅខេត្តសៀមរាប
- រៀបចំលិខិតលេខ ២៤៦៦ សហវ.ហាក ស្តីពីការអនុញ្ញាតជាគោលការណ៍ផ្តល់ប្រាក់អាហារូបករណ៍សម្រាប់ទ្រទ្រង់ជីវភាពនិស្សិតពិការ ដែលកំពុងស្នាក់នៅក្នុងមជ្ឈមណ្ឌលអន្តេវាសិកដ្ឋាន និងកំពុងសិក្សាកម្រិតឧត្តម នៅរាជធានីភ្នំពេញ
- រៀបចំលិខិតលេខ ៤៩០៥ សហវ.អថ ស្តីពីការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើនប្រាក់ឧបត្ថម្ភដល់គ្រប់គណៈកម្មការនានាសម្រាប់ការប្រឡងគ្រូគ្រប់កម្រិត
- ទទួលគោលការណ៍ផ្តល់ប្រាក់ឧបត្ថម្ភម៉ោងបន្ថែម ៣៥ ០០០ រៀល ក្នុង ១ម៉ោង ជូនគ្រូឧទ្ទេសដែលបង្រៀនបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ និងគ្រូបង្រៀនកម្រិតមូលដ្ឋានតាមប្រព័ន្ធពន្លឿនឆ្ពោះទៅគ្រូបង្រៀនកម្រិតឧត្តមសិក្សាតាមលិខិតលេខ ៨១៤៩ សហវ.ហាក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០១៦
- អនុវត្តកិច្ចលទ្ធកម្មចុះកិច្ចសន្យា ៦០ គម្រោង មានទឹកប្រាក់ ១០៤ ០៥៦ ៥២០ ០០០ រៀល រួមមាន ១) លទ្ធកម្មទំនិញ ៣៩ គម្រោង មានទឹកប្រាក់ ៥៣ ៧០៩ ១០០ ០០០ រៀល។ ២) លទ្ធកម្មសំណង់ ២១ គម្រោង មានទឹកប្រាក់ ៥០ ៣៤៧ ៤២០ ០០០រៀល
- បង្កើតក្រុមលទ្ធកម្ម ៣៤ រួមមាន មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ២៥ សាកលវិទ្យាល័យ និងវិទ្យាស្ថាន ៩
- ធ្វើកិច្ចលទ្ធកម្មសំណង់អាទិភាពចាំបាច់ និងបន្ទាន់សំខាន់ៗក្នុងកញ្ចប់លទ្ធកម្មសំណង់ ២១ រួមមាន ១) សាងសង់អគាររដ្ឋបាលថ្មីនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង ២) អគាមណ្ឌលប្រឡង និងបំពាក់គ្រឿងសង្ហារិម ៤ អគារ នៅរាជធានីភ្នំពេញ កំពត កំពង់ស្ពឺ និងខេត្តកណ្តាល ៣) ជួសជុលមណ្ឌលប្រឡង ៤៧ ទីតាំង និង ៤) ជួសជុលអគារសិក្សាដែលរងគ្រោះដោយខ្យល់ កន្ត្រាក់ ៨ សាលា ...
- បណ្តុះបណ្តាលក្រុមលទ្ធកម្មស្តីពី នីតិវិធីនៃការអនុវត្តកិច្ចលទ្ធកម្ម នីតិវិធីសាកសួរតម្លៃដល់សាលារៀន ២១៦ សាលា និងនីតិវិធីលំនាំស្នង់តម្លៃចំពោះកិច្ចលទ្ធកម្មទឹកប្រាក់ក្រោម ២០ លានរៀល ជូនអង្គភាពថវិកាថ្នាក់កណ្តាល ២៥ អង្គភាព។

## *ការងារសាងសង់*

គម្រោងថវិកាជាតិ

ក្រសួងបាន៖

- ពង្រីកសាលាបឋមសិក្សាមួយចំនួនទៅជាអនុវិទ្យាល័យ និងបំពាក់សម្ភារៈ
- ជួសជុលអគារសិក្សាវិទ្យាល័យព្រះស៊ីសុវត្ថិ ៣ អគារ
- ជួសជុលអគាររដ្ឋបាលតាមអង្គភាពក្រោមឱវាទក្រសួង
- សាងសង់អគារសិក្សាមួយខ្នង ៦ ជាន់ មាន ៦០ បន្ទប់ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- បំពាក់សម្ភារពិសោធន៍ដល់គ្រឹះស្ថានឧត្តមសិក្សា ៤
- ជួសជុលកែលម្អអគារសិក្សាមួយចំនួនក្នុងខេត្តឧត្តរមានជ័យ ព្រះវិហារ និងកំពង់ចាម
- សាងសង់អគារសិក្សា ៤៦ ខ្នង ស្មើនឹង ៣០៤ បន្ទប់ និងបង្គន់អនាម័យ ៣៧ ខ្នង ស្មើនឹង ១៤៨បន្ទប់
- ចាក់ដីបំពេញស្រះ និងរៀបចំប្រព័ន្ធលូ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកណ្តាល
- សាងសង់អគារសិក្សាបាន ១៤ ខ្នង ស្មើនឹង ៩៥ បន្ទប់ និងបង្គន់អនាម័យ ១៤ ខ្នង ស្មើនឹង ៥៦ បន្ទប់ (ខេត្តកណ្តាល ១២ ខ្នង វិទ្យាល័យបារិត ១ ខ្នង និងបឋមសិក្សាស្វាយសុខោ ១ ខ្នង)
- សាងសង់ពង្រីកបន្ថែមអគារការិយាល័យប្រឡង ១ខ្នង ៣ជាន់ នៅនាយកដ្ឋានមធ្យមសិក្សា
- សាងសង់ប្រព័ន្ធលូរំដោះទឹក នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ
- សាងសង់អគារវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ១ខ្នង ៨ជាន់ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- សាងសង់អគាររដ្ឋបាលមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង ១ខ្នង ៣ជាន់
- ធ្វើផ្លូវបេតុង ក្នុងអន្តេវាសិកដ្ឋាននិស្សិតបរទេស និងនិស្សិតនារី នៅរាជធានីភ្នំពេញ
- ធ្វើផ្លូវបេតុង ចាក់ដីបំពេញស្រះ និងរៀបចំប្រព័ន្ធប្រឡាយបង្ហូរទឹកក្នុងទីលានកីឡានៅខេត្តព្រៃវែង
- ធ្វើផ្លូវបេតុង កែលម្អរបងប្រវែង ២០៣,៦ ម៉ែត្រ និងជួសជុលអគារសិក្សា ៥ខ្នង ២៨បន្ទប់ នៅវិទ្យាល័យទួលអំពិល ក្នុងរាជធានីភ្នំពេញ
- ជួសជុលមណ្ឌលប្រឡងទាំង ៤៧ កន្លែងនៅតាមរាជធានី ខេត្ត និងដាក់ឱ្យប្រើប្រាស់
- ជួសជុលអគារសិក្សាដែលរងផលប៉ះពាល់ដោយគ្រោះធម្មជាតិ ១០ខ្នង នៅខេត្តបន្ទាយមានជ័យ ២ ខ្នង ប៉ៃលិន ២ខ្នង ព្រះសីហនុ ១ខ្នង កណ្តាល ១ខ្នង ស្វាយរៀង ១ខ្នង ត្បូងឃ្មុំ ១ខ្នង បាត់ដំបង ១ ខ្នង និងព្រះវិហារ ១ខ្នង
- លើកគម្រោងសាងសង់អគារសិក្សាថ្មីក្នុងឆ្នាំ២០១៦-២០១៧ ចំនួន ៣៨ ខ្នង
- លើកគម្រោងជាអាទិភាព សម្រាប់ជួសជុលអគារសិក្សាក្នុងឆ្នាំ២០១៦-២០១៧ ចំនួន ៥១ខ្នង

- លើកគម្រោងជាអាទិភាពសម្រាប់សាងសង់អគារសិក្សាថ្មីក្នុងឆ្នាំ២០១៦ ចំនួន ២២ខ្នង នៅខេត្តព្រៃវែង ២ខ្នង កំពង់ធំ ៣ខ្នង កំពង់ចាម ៣ខ្នង ឧត្តរមានជ័យ ៦ខ្នង សៀមរាប ២ខ្នង កណ្តាល ១ខ្នង ព្រះវិហារ ១ខ្នង ក្រចេះ ១ខ្នង បាត់ដំបង ១ខ្នង ស្វាយរៀង ១ខ្នង និងតាកែវ ១ខ្នង។

### គម្រោងអភិវឌ្ឍន៍វិស័យអប់រំទី៣ (ESDP-III/ADB)

ក្រសួងបានបញ្ចប់ ការងារសាងសង់អគារនៅអនុវិទ្យាល័យក្នុងឃុំដែលគ្មានអនុវិទ្យាល័យ ១៤ កន្លែង អនុវិទ្យាល័យដែលមានសិស្សច្រើន ១៣ កន្លែង ពង្រីកបឋមសិក្សាទៅជាអនុវិទ្យាល័យ ៦ កន្លែង ផ្ទះសំណាក់គ្រូ ១១ កន្លែង និងបង្គន់អនាម័យ ២៤ កន្លែង សរុប ៦៨ កន្លែង ។

### គម្រោងកម្មវិធីសកម្មភាពពង្រីកការគាំទ្រវិស័យអប់រំទី២ (GPE/FTI-II)

ក្រសួងបាន៖

- សាងសង់និងជួសជុលអគារមត្តេយ្យសិក្សាធនធាន ៧៣ កន្លែង មត្តេយ្យសិក្សាសហគមន៍ ៥០០ កន្លែង សាងសង់សាលាបឋមសិក្សា ៣៧ កន្លែង និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក ២០ កន្លែង សរុប ៦៣០ កន្លែង
- បំប៉នសហគមន៍ស្តីពីបច្ចេកទេសគ្រប់គ្រងដំណើរការសាងសង់ មានអ្នកចូលរួម ១ ២១៦ នាក់ ស្រី ២២២ នាក់
- បំប៉នសហគមន៍ស្តីពីការអនុវត្តគោលការណ៍សាងសង់អគារមត្តេយ្យសិក្សាធនធាន បឋមសិក្សា និងការិយាល័យអប់រំ យុវជន និងកីឡា ដោយអនុវត្តនីតិវិធីការចូលរួមរបស់សហគមន៍ មានអ្នកចូលរួម ៤៥៦ នាក់ ស្រី ១១៧ នាក់។

ក្នុងឱកាសចុះសួរសុខទុក្ខប្រជាពលរដ្ឋនៅតាមបណ្តាខេត្តនានាឆ្នាំ២០១៦ នេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** បានផ្តល់អគារសិក្សាថ្មី ៣០៦ ខ្នង ស្មើនឹង ៣ ៣៦៤ បន្ទប់ ជួសជុលអគារសិក្សា ២៧ ខ្នង ស្មើនឹង ១០១ បន្ទប់ និងសាលប្រជុំ ៣ ខ្នង។ គិតមកត្រឹមខែកុម្ភៈ ឆ្នាំ២០១៧ សំណង់អគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** មាន ៣ ៩៣២ ខ្នង ស្មើនឹង ២២ ២៥០ បន្ទប់។

### *ការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ*

ក្រសួងបាន៖

- ធ្វើបច្ចុប្បន្នភាពទិន្នន័យអចលនទ្រព្យដី ៩ ១២០ ទីតាំង ក្នុងនោះដីរបស់ក្រសួងអប់រំ យុវជន និងកីឡា ៧ ៨៩៩ ទីតាំង (មានកម្មសិទ្ធិ ១ ៧២១ ទីតាំង និងបានវាស់វែងរួច ៦៣១ ទីតាំង) និងដីវត្ត ១ ២២១ ទីតាំង និងទិន្នន័យយានយន្តរួមមានរថយន្ត ៣៥៣ គ្រឿង និងម៉ូតូ ១ ៥៣៩ គ្រឿង

- បំប៉នសមត្ថភាពមន្ត្រីជំនាញថ្នាក់រដ្ឋបាលមន្ទីរ ក្រុង ខណ្ឌ ស្រុក និងនាយក នាយិកាសាលារៀន ១ ១៣១ ស្រី ២,៣៨ ភាគរយ ស្តីពីការគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ
- ប្រមូលចំណូលបានមកពីជួលអចលនទ្រព្យ និងជម្រះបរិក្ខារសង្ហារិមចាស់ៗ ៥៣ ៥២៨,៥០ ដុល្លារ និង ១ ៧៩៤ ០០០ រៀល
- ជម្រះអគារសិក្សាចេញពីបញ្ជីសារពើភ័ណ្ឌ ៦ខ្នង ស្មើនឹង ៤២បន្ទប់ និងបរិក្ខារសង្ហារិម ២ ៨៩២ ឯកតា និងទទួលបានគោលការណ៍ជម្រះរថយន្ត និងគ្រឿងចក្រ ២៨ គ្រឿង
- ដោះស្រាយវិវាទដីធ្លីសាលារៀន ៧កន្លែង
- ពិនិត្យនិងវាយតម្លៃការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ២៤ ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ៣២ និងសាលារៀន ២៥៦
- សម្របសម្រួលការនាំចូលដោយពន្ធ និងអាករជាបន្ទុករបស់រដ្ឋ ២២លើក។

## *ការពង្រឹងសវនកម្មផ្ទៃក្នុង*

ក្រសួងបាន ៖

- រៀបចំទម្រង់ដំបូងស្តីពីរបាយការណ៍សម្រង់ព័ត៌មានលើការបំពេញការងាររបស់មន្ត្រីសវនកម្មផ្ទៃក្នុងនៅតាមសវនដ្ឋាន
- ធ្វើសវនកម្មផ្ទៃក្នុងតាមស្តង់ដារបាយការណ៍ដែលបានផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ៤០៦ សវនដ្ឋាន (មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ១៦ ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ៨៩ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការ ១០ និងសាលារៀនចំណោះទូទៅ ២៩១)
- ធ្វើសវនកម្មលើការអនុវត្តគម្រោង SIG ៧២ សវនដ្ឋាន (មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ៨ ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក ២០ និងសាលារៀនចំណោះទូទៅ ៤៤
- ប្រតិបត្តិសវនកម្មនៅវិទ្យាល័យចំនួន ៣ ក្នុងរាជធានីភ្នំពេញ ដើម្បីវាស់ស្ទង់សមត្ថភាពមន្ត្រីនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងតាមស្តង់ដារបាយការណ៍ដែលបានផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានរៀបចំផែនការពង្រឹងសមត្ថភាពនិងបណ្តុះបណ្តាល
- សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សាកល្បងធ្វើសវនកម្មលើសមិទ្ធកម្មនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត និងសាលារៀន ១
- ពិនិត្យតាមដានការបំពេញការងាររបស់មន្ត្រីសវនកម្មផ្ទៃក្នុងនៅតាមសវនដ្ឋានថ្នាក់ក្រោមជាតិ និងសាលារៀន ១៧៥ អង្គភាព (មន្ទីរអប់រំ យុវជន និងកីឡាខេត្ត៥ ការិអប់រំ យុវជន និងកីឡាស្រុក ៥៧ សាលាគរុកោសល្យ និងវិក្រឹតការ ៣ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ៣ និងសាលារៀនចំណោះទូទៅ ១២៧)។

## *ការងារអធិការកិច្ច និងអធិការអប់រំ*

ក្រសួងបាន ៖

- ធ្វើអធិការកិច្ច និងផ្តល់របាយការណ៍អធិការកិច្ច ៤៣០ អង្គភាព សម្រេចបាន ៩១,៨៨ ភាគរយ
- ត្រួតពិនិត្យវឌ្ឍនភាពការកែលម្អតាមអនុសាសន៍ ៥០ អង្គភាព សម្រេចបាន ៦៤,១០ ភាគរយ
- ស្រាវជ្រាវ និងដោះស្រាយបណ្តឹងតវ៉ាចំនួន ២៧ ករណី សម្រេចបាន ៩០ ភាគរយ
- សម្រង់ព័ត៌មានការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ជាតិ ៨ អង្គភាព និងគ្រឹះស្ថានឧត្តមសិក្សា ៨ អង្គភាព សម្រេចបាន ១០០ ភាគរយ
- ផ្សព្វផ្សាយរបាយការណ៍អធិការកិច្ចនៅខេត្តព្រះសីហនុ មានអ្នកចូលរួម ១៧៥ នាក់ ស្រី ២៥ ភាគរយ
- ធ្វើអធិការកិច្ចតាមប្រធានបទ "ការបង្រៀនគណិតវិទ្យាថ្នាក់ទី៩" ចំនួន ៤០ សាលា និង "ការបង្រៀនគីមីវិទ្យាថ្នាក់ទី១២ " ចំនួន ៣៥ សាលា
- សាកល្បងឧបករណ៍អធិការកិច្ចតាមប្រធានបទ "ការបង្រៀនគីមីវិទ្យាថ្នាក់ទី១២" សាលា ៣ ក្នុងខេត្តកែប កោះកុង និងរតនគិរី
- សាកល្បងតេស្តវាយតម្លៃថ្នាក់តំបន់កម្រិតបឋមសិក្សា ៣៥ សាលា នៅខេត្តកំពត កំពង់ស្ពឺ កំពង់ធំ កោះកុង ព្រះសីហនុ ព្រៃវែង ត្បូងឃ្មុំ រតនគិរី ក្រចេះ បាត់ដំបង បន្ទាយមានជ័យ និងរាជធានីភ្នំពេញ
- ធ្វើតេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៦ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យានៅតាមសាលារៀនបឋមសិក្សារដ្ឋ ២១២ និងសាលាឯកជន ១៨
- ផ្សព្វផ្សាយស្តីពី " បញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា" ដល់គណៈគ្រប់គ្រងមន្ទីរអប់រំ យុវជន និងកីឡា និងមន្ត្រីអធិការរាជធានី ខេត្តទាំង២៥ នៅខេត្តកំពត មានអ្នកចូលរួម ១២៨ នាក់ ស្រី ២០,៣១ ភាគរយ
- ពិគ្រោះយោបល់ជាមួយប្រតិភូអធិការដ្ឋានអប់រំនៃព្រះរាជាណាចក្រស៊ុយអែត និងបណ្តុះបណ្តាលស្តីពី " ឧបករណ៍អធិការកិច្ច និងវិភាគ " មានអធិការចូលរួម ៥៣ នាក់ ស្រី ២២,៦៤ ភាគរយ
- ពិគ្រោះយោបល់ ស្តីពីលទ្ធផលតេស្តវាយតម្លៃលទ្ធផលសិក្សាថ្នាក់ជាតិថ្នាក់ទី៨ លើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា នៅខេត្តព្រះសីហនុ មានអ្នកចូលរួម ៥៤ នាក់ ស្រី ២៥,៩២ ភាគរយ
- បំប៉នសមត្ថភាពមន្ត្រីថ្នាក់ជាតិ និងអធិការកិច្ចថ្នាក់ខេត្ត ស្តីពីកម្មវិធីវាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ" មានអ្នកចូលរួម ៨៧ នាក់ ស្រី ១៤,៩៤ ភាគរយ ក្នុងនោះមន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ៦៦ នាក់ ស្រី ៩,០៩ ភាគរយ ដៃគូអភិវឌ្ឍ ៩ នាក់ ស្រី ៤៤,៤៤ ភាគរយ ប្រតិភូ NEQMAP (ប្រទេសប៊ូតាន ឡាវ ម៉ុងហ្គោលី មីយ៉ាន់ម៉ា នេប៉ាល់ ប៉ាគីស្ថាន និងស្រីលង្កា) ៧ នាក់ ស្រី ២៨,៥៧ ភាគរយ និងគ្រូឧទ្ទេសវិទ្យាស្ថានកូរ៉េ សម្រាប់កម្មវិធីសិក្សានិងវាយតម្លៃ (KICE) សាធារណរដ្ឋកូរ៉េ ៥ នាក់ ស្រី ៤០ ភាគរយ

- រៀបចំកម្រងសំណួរតេស្តថ្នាក់ទី៦ មានអ្នកចូលរួម ៤៨ នាក់ ស្រី ១៩,៥៨ ភាគរយ ដោយសហការជាមួយគ្រូឧទ្ទេសមកពីសាធារណរដ្ឋកូរ៉េ
- ពិគ្រោះយោបល់លើ លទ្ធផលតេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៣ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា មានអ្នកចូលរួម ៤៤ នាក់ ស្រី ២០,៤៥ ភាគរយ
- ផ្សព្វផ្សាយលទ្ធផលតេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៣ និងទី៨ មានអ្នកចូលរួម ១៣៨ នាក់ ស្រី ២៣,១៨ ភាគរយ
- អនុវត្តកម្មវិធីវាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ មានអ្នកចូលរួម ៨៧ នាក់ ស្រី ២០,៦៨ ភាគរយ
- បំប៉នសមត្ថភាពមន្ត្រីការិយាល័យអធិការកិច្ច ១៩២ នាក់ ស្រី ១៩,៧១ ភាគរយ នៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ស្តីពីបញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា
- បំប៉នសមត្ថភាពមន្ត្រីអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ១២៤ នាក់ ស្រី ២៩,០៣ ភាគរយ ស្តីពី "កម្មវិធីវាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ
- បំប៉នសមត្ថភាពមន្ត្រីអប់រំថ្នាក់រាជធានី ខេត្ត ៣៦ នាក់ ស្រី ៥,៥៥ ភាគរយ ស្តីពីតេស្តវាយតម្លៃលើមុខវិជ្ជាគណិតវិទ្យា
- បំប៉នក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុក និងនាយកសាលាលើការសាកល្បងការងារអធិការកិច្ច ៦០ សាលា នៅខេត្តតាកែវ ស្ទឹងត្រែង និងសៀមរាប ដោយសហការជាមួយប្រតិភូអធិការដ្ឋានអប់រំប្រទេសស៊ុយអែត
- សាកល្បងអនុវត្តតេស្តវាយតម្លៃថ្នាក់តំបន់កម្រិតបឋមសិក្សា (SEA-PLM) មានអ្នកចូលរួម ១៤៨ នាក់ ស្រី ២៩,៧២ ភាគរយ
- អនុវត្តសាកល្បងលើការផ្តល់ដំបូន្មាន និងការណែនាំនៃការធ្វើអធិការកិច្ច តាមកាលកំណត់ ដល់នាយកសាលា អធិការ និងក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក ២៨១ នាក់ ស្រី ១៤,៩៤ ភាគរយ នៅខេត្តសៀមរាប ស្ទឹងត្រែង និងតាកែវ
- បញ្ជូនមន្ត្រីអប់រំបុរស ៦ នាក់ ទៅបំប៉នសមត្ថភាពលើការវិភាគទិន្នន័យកម្រិតខ្ពស់ នៅសាធារណរដ្ឋកូរ៉េបញ្ជូនមន្ត្រីអប់រំបុរស ៣ នាក់ ទៅចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាអន្តរជាតិលើកទីបី និងកិច្ចប្រជុំគណៈគ្រប់គ្រងគម្រោងថ្នាក់ជាតិ នៃកម្មវិធីវាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ នៅប្រទេសប៉ារ៉ាហ្គាយ
- បញ្ជូនមន្ត្រីអប់រំបុរស ៣ នាក់ ទៅចូលរួមកិច្ចប្រជុំគណៈគ្រប់គ្រងគម្រោងថ្នាក់ជាតិនៃកម្មវិធីវាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ នៅប្រទេសហ្សាំប៊ៀ
- បញ្ជូនមន្ត្រីអប់រំ ៨ នាក់ ស្រី ១២,៥ ភាគរយ ទៅចូលរួមសិក្ខាសាលាស្តីពី Regional Code ដើម្បីត្រៀមអនុវត្តតេស្ត SEA-PLM នៅប្រទេសថៃ

- បញ្ជូនប្រតិភូអប់រំ ២០ នាក់ ស្រី ១០ ភាគរយ ទៅចូលរួមសិក្ខាសាលាស្តីពី ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សនៅថ្នាក់ជាតិ និងថ្នាក់តំបន់របស់កម្ពុជានៅសាធារណរដ្ឋកូរ៉េ
- បញ្ជូនមន្ត្រីអប់រំ ៣ នាក់ ស្រី ៣៣,៣៣ ភាគរយ ទៅចូលរួមសិក្ខាសាលាស្តីពី ការសរសេរ និងការផ្សព្វផ្សាយរង្វាយតម្លៃលទ្ធផលសិក្សាកម្រិតទូលាយ នៅប្រទេសថៃ។

## ២.១.៩ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ទាំង ១៥ ចំណុច

ផ្អែកលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់វិស័យអប់រំកន្លងមក ក្រសួងអប់រំ យុវជន និងកីឡា បានបន្តប្តេជ្ញាអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាទាំង ១៥ ចំណុច ដោយឈរលើមូលដ្ឋានសសរស្តម្ភ ៥ និងមានវឌ្ឍនភាពដូចខាងក្រោម ៖

*សសរស្តម្ភទី ១ ៖ ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន*

- កំពុងបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ៧០០ នាក់ តាមប្រព័ន្ធពន្លឿន ដើម្បីឱ្យក្លាយទៅជាគ្រូកម្រិតឧត្តម
- កំពុងអភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងភូមិភាគបាត់ដំបង ឱ្យក្លាយទៅជាវិទ្យាស្ថានគរុកោសល្យ
- អនុម័តស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ កំពុងរៀបចំស្តង់ដាគ្រូបង្រៀន និងបានពិភាក្សាលើឯកសារទស្សនាទានស្តីពីគន្លងអាជីពគ្រូបង្រៀន

*សសរស្តម្ភទី ២ ៖ ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អបរិស្ថានសិក្សា*

- អនុម័តនិងផ្សព្វផ្សាយក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស
- អនុម័តនិងផ្សព្វផ្សាយសេចក្តីណែនាំការបង្រៀនប្រវត្តិវិទ្យា និងអក្សរសិល្ប៍នៅមធ្យមសិក្សា
- អនុម័តកម្មវិធីអប់រំមាតាបិតា
- អនុម័តឯកសារទស្សនាទានស្តីពីការបង្រៀនពេញ១ថ្ងៃ
- អនុម័តនិងផ្សព្វផ្សាយឱ្យប្រើប្រាស់គោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមា ស្តីពីទឹកស្អាត និងអនាម័យនៅតាមសាលារៀន
- អនុម័តនិងអនុវត្តសេចក្តីណែនាំស្តីពីចលនាប្រឡងប្រណាំងសាលារៀនស្អាត
- ផ្សព្វផ្សាយការអនុវត្តច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក
- បំពាក់ឧបករណ៍អ៊ិនធឺណិតនៅតាមគ្រឹះស្ថានសិក្សា ២២៤
- ជួសជុល និងកែលម្អមណ្ឌលប្រឡងមធ្យមសិក្សាទុតិយភូមិ ៥៧
- ដាក់ឱ្យដំណើរការសាលារៀនជំនាន់ថ្មីនៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ

- សាងសង់អគារសិក្សាមត្តេយ្យសិក្សាសហគមន៍ សាលាមត្តេយ្យសិក្សាធនធាន សាលាបឋមសិក្សា ផ្ទះគ្រូស្នាក់នៅ និងអគារការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក នៅតាមបណ្តាខេត្ត
- ផ្គត់ផ្គង់សម្ភារបរិក្ខារស្តង់ដាអប្បបរមាការងាររដ្ឋបាលសាលារៀនដល់វិទ្យាល័យមួយចំនួន ក្នុងខេត្ត ១១។

*សសរស្តម្ភទី ៣ ៖ ការដាក់ឱ្យអនុវត្តអធិការកិច្ច*

- អនុម័តនិងដាក់ឱ្យអនុវត្តបញ្ញត្តិធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ
- បានព្រាងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃតំបន់អធិការកិច្ចអប់រំ
- បានរៀបចំឧបករណ៍សម្រាប់ធ្វើអធិការកិច្ច សៀវភៅជំនួយស្មារតីអធិការកិច្ច និងទម្រង់របាយ-ការណ៍អធិការកិច្ច
- បំប៉នសមត្ថភាពអធិការអប់រំដែលមានស្រាប់ ៥១ នាក់ ស្រី ៥ នាក់
- បញ្ចប់ការបណ្តុះបណ្តាលអធិការអប់រំ ៣១ នាក់ ស្រី ៣ នាក់
- កំពុងបណ្តុះបណ្តាលអធិការអប់រំ ៧៣ នាក់ ស្រី ៩ នាក់
- បំប៉នមន្ត្រីដែលមិនមែនជាអធិការអប់រំដែលកំពុងបម្រើការនៅតាមការិយាល័យអធិការកិច្ច នៅតាមរាជធានី ខេត្ត និងនាយកដ្ឋានធានាគុណភាពអប់រំ ៣៧៩ នាក់ ស្រី ៥៦ នាក់
- បំប៉ននាយកវិទ្យាល័យអំពីនីតិវិធី និងដំណើរការអធិការកិច្ចអប់រំ នៅតាមរាជធានី ខេត្ត ៩ មានអ្នកចូលរួម ១៦៤ នាក់ ស្រី ៤ នាក់
- រៀបចំរចនាសម្ព័ន្ធអធិការកិច្ចនៅតាមតំបន់។

*សសរស្តម្ភទី៤៖ ការពង្រឹងវង្វាយតម្លៃសិក្សាដូចជាការប្រឡង វង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ*

- បំប៉នមន្ត្រីជំនាញអំពីការងារតេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ មានអ្នកចូលរួម ៣៩៥ នាក់ ស្រី ៧៧ នាក់
- ផ្សព្វផ្សាយរបាយការណ៍លទ្ធផលតេស្តថ្នាក់ជាតិថ្នាក់ទី៣ និងទី៨ លើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា
- ធ្វើតេស្តល្បឿនអំណានថ្នាក់ទី១ ទី២ និងទី៣ នៃសាលាបឋមសិក្សា
- ធ្វើតេស្តវង្វាយតម្លៃថ្នាក់តំបន់កម្រិតបឋមសិក្សា និងរៀបចំតេស្តវាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ។

*សសរស្តម្ភទី ៥ ៖ ការកែទម្រង់ឧត្តមសិក្សា*

- កែលម្អនីតិវិធី និងដំណើរការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា
- វាយតម្លៃសាកល្បងលើគ្រឹះស្ថានឧត្តមសិក្សា ៣៨
- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យាឧត្តមសិក្សា
- ព្រាងសេចក្តីណែនាំស្តីពីការធានាគុណភាពអប់រំផ្ទៃក្នុងកម្រិតកម្មវិធីសម្រាប់គ្រឹះស្ថានឧត្តមសិក្សា

- ព្រាងប្រកាសស្តីពីការបង្កើតគណៈកម្មាធិការវិទ្យាសាស្ត្រកម្ពុជាសម្រាប់ការស្រាវជ្រាវ និងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងការបង្កើតសាលាថ្នាក់បណ្ឌិត
- ព្រាងស្តង់ដាទទួលស្គាល់គុណភាពអប់រំកម្រិតបណ្ឌិត
- ដំណើរការសាកលវិទ្យាល័យ **ហេង សំរិន** ត្បូងឃ្មុំ វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល និង វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ
- ពង្រឹងនិងពង្រីកការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

ខាងក្រោមនេះ ជាសមិទ្ធផលតាមកំណែទម្រង់នីមួយៗ ៖

*កំណែទម្រង់ទី ១ ៖ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

- ដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យាអង្គភាពថវិកាថ្នាក់កណ្តាល ៣៦ និង២៥ រាជធានី ខេត្ត
- បណ្តុះបណ្តាលមន្ត្រីលទ្ធកម្មនៅសាលារៀន ២១៦ ក្នុងការសាងសង់បង្គន់អនាម័យ
- បណ្តុះបណ្តាលមន្ត្រីហិរញ្ញវត្ថុលើគ្រប់ជំនាញហិរញ្ញវត្ថុ និងមន្ត្រីសវនកម្មផ្ទៃក្នុង អំពីការសរសេរស្តង់ដារបាយការណ៍សវនកម្មតាមគំរូក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើប្រតិបត្តិការសវនកម្មផ្ទៃក្នុងសាកល្បងបាន ២៣១/៣៦០ សវនដ្ឋាន។

*កំណែទម្រង់ទី ២ ៖ ការពង្រាយគ្រូបង្រៀន*

- ពិនិត្យឡើងវិញសេចក្តីពណ៌នាមុខដំណែងបុគ្គលិកអប់រំបម្រើការងារផ្នែករដ្ឋបាល
- ពិនិត្យ និងកែសម្រួលឡើងវិញលក្ខខណ្ឌ និងនីតិវិធីស្តីពីការផ្ទេរនិងផ្លាស់ប្តូរកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំ
- វាយតម្លៃ និងធ្វើស្វ័យប្រកាសស្តីពីស្ថានភាព លើស ខ្វះ គ្រូបង្រៀនកម្រិតមូលដ្ឋាន និងកម្រិតឧត្តម នៅតាមអនុវិទ្យាល័យ និងវិទ្យាល័យនៅទូទាំងប្រទេស
- ត្រួតពិនិត្យការប្រើប្រាស់ក្របខណ្ឌមន្ត្រីរាជការ គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរវេន និង គ្រូបង្រៀនថ្នាក់គួប ២៥ រាជធានី ខេត្ត ៨០ ក្រុង ស្រុក ខណ្ឌ និង ១០០ សាលារៀន
- សហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា ត្រួតពិនិត្យការបែងចែកគ្រូបង្រៀនចេញថ្មី និងការផ្លាស់ប្តូរគ្រូបង្រៀនតាមរាជធានី ខេត្ត
- ជំរុញការអនុវត្តគោលការណ៍ស្តីពីការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ
- ពង្រាយគ្រូបង្រៀនពីសាលាលើសទៅសាលាខ្វះគ្រូ ៩៤ នាក់ ស្រី ៣៩,៣៦ ភាគរយ ពង្រាយគ្រូចេញថ្មីគ្រប់កម្រិត ៥ ៣៥៤ នាក់ ស្រី ៦០,៣២ ភាគរយ
- បញ្ចូលគ្រូខ្មែរឥស្លាម ១ ៥០០ នាក់ និងគ្រូជនជាតិដើមភាគតិច ២០ នាក់ ក្នុងក្របខណ្ឌ
- បញ្ចូលសាលាសហគមន៍ពហុភាសា ៥០ ឱ្យចូលជាសាលារដ្ឋ។

*កំណែទម្រង់ទី ៣ ៖ កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន*

- អភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងភូមិភាគបាត់ដំបង ឱ្យក្លាយទៅជាវិទ្យាស្ថានគរុកោសល្យ
- អនុម័តស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ រៀបចំស្តង់ដាគ្រូបង្រៀន និងរៀបចំឯកសារទស្សនាទានស្តីពីគន្លងអាជីពគ្រូបង្រៀន

*កំណែទម្រង់ទី ៤ ៖ ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន*

- អភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសសាលាគរុកោសល្យផ្នែកគណិតវិទ្យា វិទ្យាសាស្ត្រ និងកម្មសិក្សាគរុកោសល្យ
- អនុវត្តប្រព័ន្ធក្រេឌីតសម្រាប់វាយតម្លៃសមត្ថភាពបុគ្គលិកអប់រំ
- បង្កើតការិយាល័យគាំទ្រគ្រូបង្រៀន និងរៀបចំគោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន
- អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ទៅជាគ្រូបង្រៀនកម្រិតឧត្តមតាមប្រព័ន្ធពន្លឿនឆ្ពោះ ទៅកម្រិតបរិញ្ញាបត្រ ៦ មុខវិជ្ជា រួមមាន គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា អក្សរសាស្ត្រខ្មែរ និងប្រវត្តិវិទ្យា
- បណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ៧០០ នាក់ ដែលកំពុងបង្រៀននៅវិទ្យាល័យ តាមប្រព័ន្ធពន្លឿន ដើម្បីឱ្យក្លាយទៅជាគ្រូបង្រៀនកម្រិតឧត្តម
- បណ្តុះបណ្តាលគ្រូឧទ្ទេសមជ្ឈមណ្ឌលគរុកោសល្យ ៥៦ នាក់ ឱ្យមានបរិញ្ញាបត្រជាន់ខ្ពស់។

*កំណែទម្រង់ទី ៥ ៖ ការងារអធិការកិច្ច*

- រៀបចំបញ្ញត្តិធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ
- រៀបចំសៀវភៅណែនាំស្តីពីការធ្វើអធិការកិច្ចតាមកាលកំណត់ និងឧបករណ៍អធិការកិច្ច
- អភិវឌ្ឍសមត្ថភាពអធិការអប់រំដែលមានស្រាប់ ៥១ នាក់ ស្រី ៥ នាក់ នៃរាជធានី ខេត្តទាំង ២៥
- បំប៉នសមត្ថភាពមន្ត្រីការិយាល័យអធិការកិច្ច (មិនមែនអធិការ) ទាំង ២៥ រាជធានី ខេត្ត ស្តីពីបញ្ញត្តិនៃការធានាគុណភាពអប់រំ ៨៥ នាក់ ស្រី១៦ នាក់
- បំប៉នសមត្ថភាពដល់ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ ស្តីពីរបៀបផ្តល់ដំបូន្មានដល់នាយកសាលា និងគ្រូបង្រៀន ២៨១ នាក់ ស្រី ៤៦ នាក់
- បណ្តុះបណ្តាលអធិការអប់រំ និងរៀបចំរចនាសម្ព័ន្ធអធិការកិច្ចនៅថ្នាក់ក្រោមជាតិជាតំបន់អធិការកិច្ច ៨ តំបន់ រួមមានតំបន់រាជធានីភ្នំពេញ តាកែវ ព្រះសីហនុ បាត់ដំបង សៀមរាប ព្រៃវែង កំពង់ចាម និងស្ទឹងត្រែង
- ធ្វើអធិការកិច្ចតាមកាលកំណត់សាកល្បង ៧០ សាលាដើម្បីពិនិត្យឡើងវិញ និងកែលម្អឧបករណ៍អធិការកិច្ច

- កែលម្អកម្មវិធីសិក្សា ការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន និងការងារគ្រប់គ្រងដទៃទៀត ផ្អែកលើលទ្ធផលនៃការធ្វើអធិការកិច្ចអប់រំ។

### *កំណែទម្រង់ទី ៦ ៖ វាយតម្លៃលទ្ធផលសិក្សា*

- ផ្សព្វផ្សាយលទ្ធផលតេស្តថ្នាក់ជាតិថ្នាក់ទី៣ និងថ្នាក់ទី៨ លើមុខវិជ្ជាភាសាខ្មែររូបវិទ្យា និងគណិតវិទ្យា
- តាក់តែងវិញ្ញាសាតេស្ត បោះពុម្ពសៀវភៅតេស្ត និងធ្វើតេស្តថ្នាក់ទី៦ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាបាន ២២៨ ក្នុងនោះសាលារដ្ឋ ២១០ និងសាលាឯកជន ១៨
- ធ្វើតេស្តវង្វាយតម្លៃថ្នាក់តំបន់កម្រិតបឋមសិក្សា សាកល្បងបាន ៣៥ សាលា
- ធ្វើតេស្តវង្វាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ សាកល្បងបាន ៥៦ សាលា
- ធ្វើតេស្តល្បឿនអំណានថ្នាក់ទី១ ទី២ និងទី៣ នៃសាលាបឋមសិក្សា។ លទ្ធផលសិស្សចេះអានពីថ្នាក់ទី១ ទី២ និងទី៣ សរុប ៣៥ ភាគរយ ក្នុងនោះ ថ្នាក់ទី១ ស្មើនឹង ១០ ភាគរយ នៃសិស្សបានធ្វើតេស្ត ១ ៣៥៨ នាក់ ថ្នាក់ទី២ ស្មើនឹង ៣៤ ភាគរយ នៃសិស្សបានធ្វើតេស្ត ១ ៣៨៤ នាក់ ថ្នាក់ទី៣ ស្មើនឹង ៦០ ភាគរយ នៃសិស្សបានធ្វើតេស្ត ១ ៣៨៧ នាក់។

### *កំណែទម្រង់ទី ៧ ៖ កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ*

- កែលម្អសេចក្តីណែនាំស្តីពីការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិថ្នាក់ជាតិ
- បន្តវិមជ្ឈការការទទួលខុសត្រូវដល់រាជធានី ខេត្ត និងរៀបចំស្តង់ដាវិញ្ញាសាសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ
- កែលម្អយន្តការកំណែនិងប្រព័ន្ធពិនិត្យតាមដានសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- កែលម្អមេរៀនសង្ខេបមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា សម្រាប់ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- ពង្រឹងការជ្រើសរើសសមាសភាពគណៈមេប្រយោគនៅជំណាក់កាលកំណែ និងអ្នកត្រួតពិនិត្យកំណែ
- កែលម្អយន្តការបូកស្រង់ពិន្ទុតាមកុំព្យូទ័រ
- អនុម័តមេរៀនសង្ខេបស្តីពី ប្រវត្តិសាស្ត្រខ្មែរសម្រាប់សិស្សថ្នាក់ទី១២។

### *កំណែទម្រង់ទី ៨ ៖ កំណែទម្រង់កម្មវិធីសិក្សានិងសៀវភៅសិក្សាគោល*

- ដាក់ឱ្យប្រើប្រាស់សៀវភៅសិក្សាអង់គ្លេសថ្មីថ្នាក់ទី៥ ទី៦ ទី៧ ទី៨ និងទី៩
- ផ្សព្វផ្សាយក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសដល់អនុគណៈកម្មការគ្រប់មុខវិជ្ជា
- ផ្សព្វផ្សាយសេចក្តីណែនាំការបង្រៀនប្រវត្តិវិទ្យា និងអក្សរសិល្ប៍នៅមធ្យមសិក្សា
- រៀបចំគំរូតែងសេចក្តីសម្រាប់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ
- រៀបចំកម្មវិធីសិក្សាលម្អិត និងស្តង់ដាមុខវិជ្ជាឯកទេស។

***កំណែទម្រង់ទី ៩ ៖ ការសាងសង់អគារសិក្សានិងការជួសជុល***

- ជួសជុល និងកែលម្អមណ្ឌលប្រឡងមធ្យមសិក្សាទុតិយភូមិ ៩៧
- ដាក់ឱ្យដំណើរការសាលារៀនជំនាន់ថ្មីនៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ
- សាងសង់បង្គន់អនាម័យ ប្រព័ន្ធទឹកស្អាត និងកន្លែងលាងសម្អាតដៃ ២១៦ សាលា ក្នុង ២៥ រាជធានីខេត្ត
- សាងសង់អគារសិក្សាមត្តេយ្យសិក្សាសហគមន៍ សាលាមត្តេយ្យធនធាន សាលាបឋមសិក្សា ផ្ទះគ្រូស្នាក់នៅ និងអគារការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនៅតាមបណ្តាខេត្ត
- ប្រមូលព័ត៌មានសាលារៀនពេងដោល សាលាត្រៀមបង្កើត សាលាឧបសម្ព័ន្ធ និងសាលាសម្ព័ន្ធ។

***កំណែទម្រង់ទី ១០ ៖ ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា***

- កែលម្អនីតិវិធី និងដំណើរការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា
- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យាឧត្តមសិក្សា
- ព្រាងឯកសារស្តីពី ការធានាគុណភាពអប់រំផ្ទៃក្នុងកម្រិតកម្មវិធីសម្រាប់គ្រឹះស្ថានឧត្តមសិក្សា។

***កំណែទម្រង់ទី ១១ ៖ ការលើកកម្ពស់វិស័យកីឡា***

- អនុវត្តគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា
- ផ្សព្វផ្សាយការអនុវត្តសៀវភៅអប់រំកាយកម្រិតបឋមសិក្សា
- ការបណ្តុះបណ្តាលធនធានមនុស្ស ៖
    - បណ្តុះបណ្តាលថ្នាលកីឡាករ កីឡាការិនី ចំនួន ៩ប្រភេទកីឡា សរុប ១៧២ នាក់ មានកីឡាបាល់ទាត់ តេក្វាន់ដូ WTF ប៉េតង់ ហែលទឹក បាល់បោះ ចំបាប់ អត្តពលកម្ម បាល់ទះ និងប្រដាល់
    - បណ្តុះបណ្តាលក្រុមជម្រើសជាតិ ចំនួន ២៦ ប្រភេទកីឡា សរុប ៩១៧ នាក់
    - បើកវគ្គបណ្តុះបណ្តាលគ្រូបង្វឹកកីឡាបាល់បោះ កីឡាវាយសី កីឡាកាយសម្ព័ន្ធ កីឡាសីប៉ាក់តាក្រ
    - បើកវគ្គបណ្តុះបណ្តាលអាជ្ញាកណ្តាល ចៅក្រម កីឡាបាល់ទះ កីឡាប្រដាល់ កីឡាតេក្វាន់ដូ
    - បណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋានឯកទេសអប់រំកាយ និងកីឡា។
- ការជួសជុល កែលម្អ និងកសាងហេដ្ឋារចនាសម្ព័ន្ធកីឡា
    - ការកែលម្អ និងកសាងហេដ្ឋារចនាសម្ព័ន្ធកីឡា៖
        - ពហុកីឡដ្ឋានជាតិអូឡាំពិក៖ សាងសង់ទីលានបាល់បោះ ៣ ទីលានតេនីស ២ ទីលានបាល់ទះ ២
        - សាលាវិទ្យាល័យព្រះស៊ីសុវត្ថិ៖ សាងសង់ទីលានបាល់បោះ ៣ ទីលានបាល់ទះ ៣
        - វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា៖ សាលដំបូលទូក ១
        - សាងសង់ថ្នាលនិស្សិយកីឡានៅតំបន់បឹងស្នោរ រាជធានីភ្នំពេញ

- កែលម្អរចនាសម្ព័ន្ធការប្រកួតៈ បានរៀបចំការប្រការប្រកួតកីឡាជាតិឆ្នាំ២០១៦ និងរៀបចំរាល់ ២ ឆ្នាំម្តង
- អនុម័តកម្មវិធីសិក្សាអប់រំកាយនៅមធ្យមសិក្សាបឋមភូមិ។

*កំណែទម្រង់ទី ១២ ៖ ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន*

- បង្កើតក្រុមប្រឹក្សាអភិវឌ្ឍយុវជនតាមក្រសួង សម្រេចបាន ២០ លើ ៣៣ និងរៀបចំបង្កើតគណៈ-កម្មការជំនាញអន្តរក្រសួង ៤
- ជំរុញចលនាប្រឡងប្រណាំង ៣ ល្អនៅតាមក្រុមប្រឹក្សាយុវជន ក្រុមប្រឹក្សាកុមារ ដោយជ្រើសរើសយុវជនឆ្នើម ១០ នាក់ក្នុង ១ រាជធានី ខេត្ត
- បណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់ក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារ តាមរយៈការបោះជំរំថ្នាក់ជាតិ
- ធ្វើបច្ចុប្បន្នភាពចំនួនក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារ ២៣ រាជធានី ខេត្ត
- បានជំរុញឱ្យមានក្លឹបសិក្សានៅតាមវិទ្យាល័យ និងត្រៀមរួចរាល់នូវស្លាកសញ្ញាសម្រាប់សម្គាល់សិស្សតាមមុខវិជ្ជា
- អនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញខ្លី ក្នុងខេត្តសៀមរាប កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ តាកែវ និងកណ្តាល មានទីតាំងមជ្ឈមណ្ឌលនិងហេដ្ឋារចនាសម្ព័ន្ធ។ ការបណ្តុះបណ្តាលនេះផ្តោតសំខាន់លើជំនាញកុំព្យូទ័រនិងអគ្គិសនី មានសិស្សចូលរួម ៨០០ នាក់។
- ដំណើរការមជ្ឈមណ្ឌលព័ត៌មានទីផ្សារ នៅខេត្តកណ្តាល កំពង់ចាម និងកំពង់ធំ ដោយមានការគាំទ្រពីភ្នាក់ងារការងារជាតិស៊ុយអែត។ កម្មវិធីនេះផ្តល់កុំព្យូទ័រ និងបំពាក់អ៊ីនធឺណិត សម្រាប់ដំណើរការមជ្ឈមណ្ឌល ផលិតបណ្ណផ្ទត់ស្តីពី ការទីផ្សារការងារសម្រាប់ចែកដល់សិស្សានុសិស្សនៅវិទ្យាល័យ ព្រមទាំងការធ្វើកម្មសិក្សាចំពោះសិស្សថ្នាក់ទី ១០ និង ១១ នៅតាមបណ្តាក្រុមហ៊ុននានា
- សហការជាមួយអង្គការពលកម្មអន្តរជាតិ ដើម្បីអនុវត្តកម្មវិធីអភិវឌ្ឍសហគ្រាសសហគមន៍ និងកម្មវិធីសហគ្រិនភាព នៅតាមវិទ្យាល័យ ៥ នៅខេត្តកណ្តាល តាកែវ កំពង់ឆ្នាំង និងរាជធានីភ្នំពេញ តាមកម្មវិធីសិក្សា ១១០ ម៉ោង លើមុខវិជ្ជាយល់ដឹងអំពីធុរកិច្ច
- ជ្រើសរើសយុវជនដែលជាប្រធានក្រុមប្រឹក្សាយុវជន ១០ នាក់ ក្នុងមួយខេត្តមកចូលរួមកម្មវិធីបោះជំរំ និងទស្សនកិច្ចសិក្សា។

*កំណែទម្រង់ទី ១៣ ៖ ការអប់រំបច្ចេកទេស*

- អនុម័តក្របខណ្ឌកម្មវិធីអប់រំបំណិនជីវិតថ្នាក់ទី៤ ដល់ទី៩ និងកម្មវិធីសិក្សាផ្នែកអប់រំបំណិនជីវិត (ខ្លឹមសារ ម៉ោងបង្រៀន វិធីសាស្ត្រ)
- បណ្តុះបណ្តាលគ្រូអប់រំបំណិនជីវិត ២០ នាក់ ជំនាញកសិបសុកម្ម និងអេឡិចត្រូនិច-ICT (វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល)
- ពិនិត្យតាមដានការអនុវត្តកម្មវិធីបំណិនជីវិតដោយប្រើឧបករណ៍រង្វាយតម្លៃ
- រៀបចំស្តង់ដាពេងជាងអប់រំបំណិនជីវិត និងសម្ភារបរិក្ខារនៅសាលាមធ្យមសិក្សា
- ពង្រីកការអនុវត្តកម្មវិធីប្រឹក្សាអាជីពសម្រាប់សិស្សមធ្យមសិក្សា

- អនុម័តឯកសារស្តីពីការផ្តល់ប្រឹក្សាអាជីពនិងព័ត៌មានស្តីពី ការសិក្សាជំនាញដោយផ្អែកលើឧត្តមានុវត្តន៍ នៅសាលាមធ្យមសិក្សា ៤ ក្នុងខេត្តបាត់ដំបង
- ផលិតឯកសារសម្រាប់គ្រូ និងបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ ១៣ នាក់ សម្រាប់ពង្រីកវិសាលភាពនៅខេត្តគោលដៅផ្សេងទៀត
- ផ្សព្វផ្សាយការអប់រំតម្រង់ទិសវិជ្ជាជីវៈសម្រាប់សិស្សនៅមធ្យមសិក្សា
- បណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ៧ ខេត្តមានអ្នកចូលរួម ២៥ នាក់
- ធ្វើវេទិកាតម្រង់ទិសវិជ្ជាជីវៈសិស្សមធ្យមសិក្សាក្នុងខេត្តស្វាយរៀង និងសៀមរាប មានសិស្សចូលរួម ៤ ៩៨៣ នាក់ ស្រី ២ ២៩៦ នាក់
- ធ្វើវេទិកាស្តីពីការជ្រើសរើសអាជីព និងការសិក្សានៅឧត្តមសិក្សា នៅខេត្តព្រៃវែង តាកែវ កំពត កែប និងបន្ទាយមានជ័យ
- ផ្សព្វផ្សាយសេចក្តីព្រាងស្តីពីស្តង់ដាវិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេស
- កែលម្អកម្មវិធីសិក្សាឱ្យស្របតាមតម្រូវការទីផ្សារការងារលើជំនាញមេកានិច អគ្គីសនី អេឡិចត្រូនិក កេ្សត្រសាស្ត្រ និងបសុវប្បកម្ម
- ពង្រឹងការអនុវត្តកម្មវិធីអប់រំបច្ចេកទេសនៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- បំប៉នសមត្ថភាពគ្រូជំនាញកសិកម្ម ៨ នាក់ ជំនាញអគ្គិសនី និងអេឡិចត្រូនិក ២២ នាក់
- ពង្រីកវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសថ្មី ៣
- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលកសិកម្មនៅវិទ្យាល័យរស្មីសោភ័ណ ស្រុកស្ទោង ខេត្តកំពង់ធំ និងបណ្តុះបណ្តាលជំនាញកសិកម្មដល់សិស្សនិងសហគមន៍ជុំវិញសាលា ដោយសហការជាមួយសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

***កំណែទម្រង់ទី ១៤ ៖ ការបង្កើតសាលារៀនជំនាន់ថ្មី***

- អនុម័តគោលនយោបាយស្តីពី សាលារៀនជំនាន់ថ្មី
- ដំណើរការសាលារៀនជំនាន់ថ្មីនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ដោយរៀបចំឱ្យមានបន្ទប់ពិសោធន៍តាមមុខវិជ្ជា បន្ទប់កុំព្យូទ័រនិងបំពាក់កុំព្យូទ័រ បន្ទប់មុខវិជ្ជា បន្ទប់សាស្ត្រាចារ្យ និងបណ្ណាល័យ។ សាលារៀនជំនាន់ថ្មីបានអនុវត្តកម្មវិធីសិក្សាតាមបែបសិស្សចល័តតាមកាលវិភាគ ទៅតាមបន្ទប់មុខវិជ្ជា ដោយបង្កើនម៉ោងសិក្សាពី ៣២ ម៉ោង ទៅ ៤២ ម៉ោង ក្នុងមួយសប្តាហ៍។ សាលារៀនបានជ្រើសរើសសិស្សថ្នាក់ទី៧ និងទី៨ ចំនួន ៨ ថ្នាក់ សិស្ស ៣១៤ នាក់ ស្រី ១៣៩ នាក់ ថ្នាក់ទី១០ និងថ្នាក់ទី ១១ ចំនួន ៨ ថ្នាក់ សិស្ស ២៦៥ នាក់ ស្រី ១១៤ នាក់។ សិស្សទាំងពីរកម្រិតសរុប ៥៧៩ នាក់ ស្រី ២៥៣ នាក់។

***កំណែទម្រង់ទី ១៥ ៖ ការរៀបចំគន្លងអាជីព និងការបណ្តុះបណ្តាលនាយកសាលា***

- អភិវឌ្ឍឯកសាទស្សនាទានស្តីពីគន្លងអាជីពគ្រូបង្រៀន
- រៀបចំសៀវភៅមគ្គុទេសក៍នាយកសាលា
- បំប៉ននាយកសាលាគ្រប់កម្រិតលើការងារអភិបាលកិច្ច គ្រប់គ្រង ដឹកនាំ និងប្រព័ន្ធអធិការកិច្ចអប់រំ
- រៀបចំប្រព័ន្ធសន្សំក្រេឌីតសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈនាយកសាលា។

# ២.២ លទ្ធផលតាមអនុវិស័យ

## ២.២.១ អនុវិស័យ ការអប់រំកុមារតូច

### ក. លទ្ធផលសម្រេចបាន

### ក.១ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ឆ្នាំសិក្សា២០១៦-២០១៧ សាលាមត្តេយ្យសិក្សាគ្រប់រូបភាពមាន ៧ ២៤១ សាលា/កន្លែង កើន ៣២៨ ក្នុងនោះសាលាមត្តេយ្យសិក្សារដ្ឋមាន ៤ ០១៤ កើន ៣០៩ (សាលាមត្តេយ្យសិក្សាដាច់ដោយឡែក ១៥៨ កើន ៧) មត្តេយ្យសិក្សាឯកជន ៣៩៣ កើន ៧២ និងមត្តេយ្យសិក្សាសហគមន៍ ២ ៨៣៤ កន្លែង ថយ ៥១ កន្លែង ដែលមានទីតាំង ១ ០២១ ឃុំ សង្កាត់ ក្នុងចំណោម ១ ៦៤៦ ឃុំ សង្កាត់។

*កំណើនសាលាមត្តេយ្យសិក្សាខាងលើ បានជួយកសាងមូលដ្ឋានគ្រឹះ សម្រាប់ឱ្យកុមារត្រៀមខ្លួនជាស្រេចចូលរៀនត្រឹមត្រូវតាមអាយុនៅបឋមសិក្សាបានច្រើន។*

ថ្នាក់មត្តេយ្យសិក្សាគ្រប់រូបភាពមាន ១០ ៦៦៣ កើន ៣៩៦ ក្នុងនោះថ្នាក់មត្តេយ្យសិក្សារដ្ឋ ៦ ៤០៣ កើន ៤៣០ មត្តេយ្យសិក្សាសហគមន៍ ២ ៩៦៦ ថយ ៣៣ និងមត្តេយ្យសិក្សាឯកជន ១ ២៩៤ ថយ ១។

កុមារអាយុពី ០ ទៅ ៥ ឆ្នាំ បានទទួលសេវាអប់រំគ្រប់រូបភាពមាន ៤២៦ ០២៥ នាក់ ស្មើនឹង ២១,៧៩ ភាគរយ នៃចំនួនប្រជាជនអាយុពី ០ ទៅ ៥ ឆ្នាំ ស្រី ២១៤ ២៤៩ នាក់ ស្មើនឹង ៥០,២៩ ភាគរយ។

កុមារអាយុ ៣ ឆ្នាំ បានទទួលសេវាអប់រំគ្រប់រូបភាពមាន ៦៣ ៥០៩ នាក់ ស្មើនឹង ២០,៣៣ ភាគរយ នៃចំនួនប្រជាជនអាយុ ៣ ឆ្នាំ ស្រី ៣២ ៨០០ នាក់ ស្មើនឹង ៥១,៦៤ ភាគរយ កើន ២ ៥៦០ នាក់ ស្រីកើន ១ ០៣០ នាក់។

កុមារអាយុ ៤ ឆ្នាំ បានទទួលសេវាអប់រំគ្រប់រូបភាពមាន ១១៣ ០១០ នាក់ ស្មើនឹង ៣៧,៣៧ ភាគរយ នៃចំនួនប្រជាជនអាយុ ៤ ឆ្នាំ ស្រី ៥៧ ៧០៩ នាក់ ស្មើនឹង ៥១,០៦ ភាគរយ កើន ២៨ ៦៦៧ នាក់ ស្រីកើន ១៤ ៧៨១ នាក់។

កុមារអាយុ ៥ឆ្នាំ បានទទួលសេវាអប់រំតាមគ្រប់រូបភាព ១៩៦ ៦៦៩ នាក់ ស្មើនឹង ៦៦,៣៥ ភាគរយ នៃចំនួនប្រជាជនអាយុ ៥ឆ្នាំ (ចំណុចដៅ ESP ៦៦ ភាគរយ) ស្រី ៩៧ ១២៧ នាក់ ស្មើនឹង ៤៩,៣៨ ភាគរយ កើន ៩ ២៥៧ នាក់ ស្រីកើន ១ ៨០៥ នាក់។

### រូបភាពទី១៤ ៖ ភាគរយកុមារតូចទទួលបានការអប់រំធៀបនឹងចំណុចដៅ ESP




### រូបភាពទី១៥ ៖ ភាគរយក្រុមអាយុកុមារតូចឆ្នាំសិក្សា២០១៦ -២០១៧ធៀបនឹងឆ្នាំសិក្សា២០១៥-២០១៦




ប្រភពទិន្នន័យ EMISD និង ECED

### រូបភាពទី១៦ ៖ ភាគរយកុមារអាយុ ៥ឆ្នាំ ទទួលបានការអប់រំតាមរាជធានី ខេត្ត




ប្រភពទិន្នន័យ ECED

*រូបភាពខាងលើបានបង្ហាញថា ការប្រមូលកុមារតូច អាយុ ៤ និង ៥ ឆ្នាំ តាមគ្រប់រូបភាពទទួលបានលទ្ធផលល្អប្រសើរ និងខ្ពស់ជាងចំណុចដៅ។ លទ្ធផលនេះ បញ្ជាក់ពីការខិតខំរបស់រាជរដ្ឋាភិបាល សហគមន៍ មាតាបិតា និងអ្នកពាក់ព័ន្ធ តាមរយៈការសង់អគារសិក្សា និងការផ្តល់សម្ភារបរិក្ខារ។ ក្នុងនោះរាជធានី ខេត្ត ១៤ បានប្រមូលកុមារអាយុ ៥ឆ្នាំ ឱ្យទទួលសេវាអប់រំខ្ពស់ជាងចំណុចដៅ។*

បុគ្គលិកអប់រំផ្នែកកុមារតូចមាន ១១ ១៥១ នាក់ ស្រី ៩១,១៧ ភាគរយ កើន ៣៩ នាក់ ស្រីកើន ២,៥ ភាគរយ ក្នុងនោះបុគ្គលិកអប់រំមត្តេយ្យសិក្សារដ្ឋ ៥ ០៨៤ នាក់ ស្រី ៩៥,៦៥ ភាគរយ កើន ៣៦០ នាក់ ស្រីកើន ៨,៥ ភាគរយ បុគ្គលិកមត្តេយ្យសិក្សាសហគមន៍ ៣ ០១៤ នាក់ ស្រី ៩៥,៧១ ភាគរយ ថយ ១២៤ នាក់ ស្រីថយ ១,៥ ភាគរយ និងបុគ្គលិកមត្តេយ្យសិក្សាឯកជន ៣ ០៥៣ នាក់ ស្រី ៧៩,២៣ ភាគរយ ថយ ១៩៧ នាក់ ស្រីថយ ៣,៧ ភាគរយ។

*កង្វះបុគ្គលិកអប់រំផ្នែកអប់រំកុមារតូច ជាកង្វល់សម្រាប់ថ្នាក់ក្រោមជាតិ ក្នុងការពង្រីកសេវាអប់រំកុមារតូច។ ប្រការនេះ ទាមទារឱ្យមានការសិក្សាមួយច្បាស់លាស់ពីតម្រូវការ និងការពង្រាយបុគ្គលិកផ្នែកអប់រំកុមារតូចឱ្យបានជាក់លាក់ស្របតាមផែនការរយៈពេលវែងរបស់ថ្នាក់ក្រោមជាតិ។*

### *មត្តេយ្យសិក្សារដ្ឋ*

កុមារអាយុ ៣ ឆ្នាំ បានទទួលសេវាអប់រំ ១៣ ៩៧០ នាក់ ស្មើនឹង ៩,៣ ភាគរយ ស្រី ៧ ៥៨៦ នាក់។ កុមារអាយុ ៤ ឆ្នាំ បានទទួលសេវាអប់រំ ៥២ ៦៩៣ នាក់ ស្មើនឹង ១៧,៤ ភាគរយ ស្រី ២៧ ០៤៤ នាក់។ កុមារអាយុ ៥ ឆ្នាំ បានទទួលសេវាអប់រំ ១២៣ ៩៩៥ នាក់ ស្មើនឹង ៩១,៨ ភាគរយ ស្រី ៦០ ៩០៦ នាក់។

### *មត្តេយ្យសិក្សាឯកជន*

កុមារអាយុ ៣ ឆ្នាំ បានទទួលសេវាអប់រំ ៦ ៨១៥ នាក់ ស្មើនឹង ២,២ ភាគរយ ស្រី ៣ ៣៥៨ នាក់។ កុមារអាយុ ៤ ឆ្នាំ បានទទួលសេវាអប់រំ ១៥ ២៩៩ នាក់ ស្មើនឹង ៥,១ ភាគរយ ស្រី ៧ ៧១០ នាក់។ កុមារអាយុ ៥ ឆ្នាំ បានទទួលសេវាអប់រំ ១៦ ៣៨០ នាក់ ស្មើនឹង ៥,៥ ភាគរយ ស្រី ៧ ៨០៣ នាក់។

### *មត្តេយ្យសិក្សាសហគមន៍*

កុមារអាយុ ៣ ឆ្នាំ បានទទួលសេវាអប់រំ ១៩ ០៥៩ នាក់ ស្មើនឹង ៦,១ ភាគរយ ស្រី ៩ ៨៨៥ នាក់។ កុមារអាយុ ៤ ឆ្នាំ បានទទួលសេវាអប់រំ ២៣ ៥៤៩ នាក់ ស្មើនឹង ៧,៨ ភាគរយ ស្រី ១២ ១២៧ នាក់។ កុមារអាយុ ៥ ឆ្នាំ បានទទួលសេវាអប់រំ ២២ ១៣០ នាក់ ស្មើនឹង ៧,៥ ភាគរយ ស្រី ១១ ០៥៩ នាក់។

### *ការអប់រំកុមារតូចតាមផ្ទះ*

កុមារអាយុពី ០ ដល់ក្រោម ៣ ឆ្នាំ បានទទួលសេវាអប់រំ ៥២ ៨៣៧ នាក់ ស្មើនឹង ៥,១ ភាគរយ ស្រី ២៦ ៦១៣ នាក់។ កុមារអាយុ ៣ ឆ្នាំ បានទទួលសេវាអប់រំ ២៤ ១៦៥ នាក់ ស្មើនឹង ៧,៧ ភាគរយ ស្រី ១២ ០៧១ នាក់។ កុមារអាយុ ៤ ឆ្នាំ បានទទួលសេវាអប់រំ ២១ ៩៧៤ នាក់ ស្មើនឹង ៧,១ ភាគរយ ស្រី ១០ ៨២៨ នាក់។ កុមារអាយុ ៥ ឆ្នាំ បានទទួលសេវាអប់រំ ៣៤ ១៦៤ នាក់ ស្មើនឹង ១១,៥ ភាគរយ ស្រី ១៧ ៣៥៩ នាក់។

ការអប់រំកុមារតូចតាមផ្ទះ និងក្រុមខ្ទង់ផ្ទះ មានមាតាបិតាកុមារចូលរួម ៩៥ ១៩៨ នាក់ ប្រធានក្រុមមាតាបិតា ១៥ ៩០៤ នាក់ មាតាបិតាបង្គោល ៣ ៩៦២ នាក់ ស្រី ៣ ៩០២ នាក់ និងកុមារ ១៣២ ៦៩០ នាក់ ស្រី ៦៦ ៨៧១ នាក់ ។

ភូមិដែលបានអនុវត្តកម្មវិធីអប់រំកុមារតូចតាមផ្ទះមាន ៣ ១១៤ ក្នុងចំណោម ១៤ ១១៩ ភូមិ ស្ថិតក្នុងឃុំ សង្កាត់ ៨៩៦ ក្នុងចំណោម ១ ៦៣៣ និងស្រុក ខណ្ឌ ១៧០ ក្នុងចំណោម ១៩៧។

## ការអនុវត្តកម្មវិធីនានា

### *ការផ្តល់ថវិកាដំណើរការ និងថវិកាកែលម្អសាលារៀន*

គ្រប់សាលារៀន និងថ្នាក់មត្តេយ្យសិក្សាទាំងអស់បានទទួលថវិកាដំណើរការ និងថវិកាកែលម្អសាលារៀន ដោយអនុវត្តតាមនីតិវិធី គោលការណ៍ណែនាំបានត្រឹមត្រូវ។ សាលារៀននីមួយៗមានការរៀបចំផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីគណៈកម្មការទ្រទ្រង់សាលា ការអនុវត្តថវិកាកាន់តែមានគណនេយ្យភាពចំពោះចំណូលចំណាយដោយមានបិទផ្សាយតារាងតម្លាភាព។

*ថវិកាដំណើរការ និងថវិកាកែលម្អសាលារៀននៅមានកម្រិត ដែលទាមទារឱ្យគិតគូរពិចារណាបន្ថែមទៀត ក្នុងការវិនិយោគរយៈពេលវែង។*

### *កម្មវិធីអប់រំពហុភាសា*

កម្មវិធីអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិច បានអនុវត្តក្នុងក្រុង ស្រុក ១៩ កើន ១ នៃខេត្តគោលដៅ ៥ មានខេត្តរតនគិរី ស្ទឹងត្រែង មណ្ឌលគិរី ព្រះវិហារ និងខេត្តក្រចេះ។ កម្មវិធីនេះបានអនុវត្តនៅតាមសាលាសិក្សាមត្តេយ្យសិក្សារដ្ឋ ៣ កន្លែង ថយ ១ មានសិស្ស ៩៤ នាក់ ស្រី ៥១ នាក់ និងមត្តេយ្យសិក្សាសហគមន៍ ៨០ កន្លែង មានសិស្ស ១ ៩៧៤ នាក់ ស្រី ៧៨៤ នាក់ កើន ១៣ នាក់ ស្រី ២ នាក់។ ភាសាដែលបានប្រើប្រាស់រួមមានភាសាទំពួន គ្រឹង ពួង កួយ ក្រោល កាវ៉ែត កាចក់ ព្រៅ ...។

កម្មវិធីមត្តេយ្យសិក្សាចល័ត បានគ្របដណ្តប់លើកុមារមានអាយុពី ៣ ទៅ ៥ ឆ្នាំ រស់នៅតំបន់ជនជាតិដើមភាគតិច ដែលមានគ្រួសារបម្លាស់ទីលំនៅ និងមានចម្ងាយឆ្ងាយពីសាលាមត្តេយ្យសិក្សារដ្ឋ ឬមត្តេយ្យសិក្សាសហគមន៍។ កម្មវិធីនេះអនុវត្តតាមរយៈ ការចល័តដោយប្រើយានជំនិះផ្សេងៗមាន ២ ភូមិ ក្នុងឃុំកោះពាក្យ ស្រុកវើនសៃ និងឃុំតាវែងក្រោម ស្រុកតាវែង និងចល័តតាមរដូវកាលមាន ៣ ភូមិ ក្នុងឃុំតាឡាវ ស្រុកអណ្តូងមាស និងឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនគិរី។

*លទ្ធផលដែលទទួលបានក្នុងឆ្នាំសិក្សានេះ មានភាពប្រហាក់ប្រហែលនឹងឆ្នាំសិក្សាកន្លងទៅ ដោយសេវានេះពុំមានការពង្រីកវិសាលភាពគ្របដណ្តប់តំបន់ជនជាតិដើមភាគតិចនៅឡើយ។*

*ការអប់រំកុមារតូចនៅតំបន់ជនជាតិដើមភាគតិច ដែលមានទម្រង់ជាថ្នាក់មត្តេយ្យសិក្សាចល័ត ដោយសហការជាមួយដៃគូអភិវឌ្ឍបានផ្តល់ឧត្តមានុវត្តន៍ សម្រាប់អនុវិស័យអប់រំកុមារតូច។*

### *កម្មវិធីអប់រំបរិយាបន្ន*

ការអប់រំបរិយាបន្នសម្រាប់កុមារពិការនៅមត្តេយ្យសិក្សា បានអនុវត្តនៅខេត្តសៀមរាប បាត់ដំបង កំពង់ធំ ព្រៃវែង រតនគិរី ក្រចេះ និងរាជធានីភ្នំពេញ។ កម្មវិធីនេះ បានអនុវត្តដោយផ្សារភ្ជាប់ជាមួយមត្តេយ្យសិក្សារដ្ឋ ១៧៦ សាលា កើន ១១៣ មានកុមារ ១៦៥ នាក់ ស្រី ៤៩ នាក់ កើន ៤០ នាក់ ស្រី ៦ នាក់។

គ្រូមត្តេយ្យសិក្សារដ្ឋបានទទួលការបណ្តុះបណ្តាលជំនាញអប់រំបរិយាបន្ន ២៣៥ នាក់ ស្រី ២២៣ នាក់ កើន ១២៤ នាក់ ស្រី ១១៣ នាក់។ មត្តេយ្យសិក្សាសហគមន៍បានអនុវត្តកម្មវិធីអប់រំបរិយាបន្ន ៩១ កន្លែង កើន ២៤ មានសិស្ស ៣៥ នាក់ ស្រី ២១ នាក់ កើន ១៥ នាក់ ស្រី ១២ នាក់។ គ្រូមត្តេយ្យសិក្សាសហគមន៍បានទទួលការបណ្តុះបណ្តាលជំនាញអប់រំបរិយាបន្ន ៩១ នាក់ ស្រី ៣៧ នាក់ កើន ២៤ នាក់ ស្រី ២០ នាក់។

*ការអប់រំបរិយាបន្ននៅមត្តេយ្យសិក្សាទទួលបានលទ្ធផលល្អ បង្កឱកាសឱ្យកុមារពិការបានចូលរៀនប្រកបដោយសមធម៌។*

### *លទ្ធផលនៃការសិក្សា*

កុមារអាយុ ៥ឆ្នាំបានបញ្ចប់ការសិក្សាថ្នាក់មត្តេយ្យសិក្សាកម្រិតខ្ពស់ ១៧២ ០៦៧ នាក់ ស្រី ៨៥ ៥៧៥ នាក់ កើន ៥ ៨៨០ នាក់ ស្រីកើន ២ ០៤២ នាក់។ កុមារចូលរៀនថ្នាក់ទី១ នៃសាលាបឋមសិក្សាបានឆ្លងកាត់សេវាអប់រំកុមារតូចគ្រប់រូបភាព ៦៤,០១ ភាគរយ កើន ២,១៦ ភាគរយ។

### *ការកែលម្អបរិស្ថានសាលា ថ្នាក់រៀន និងសម្ភារៈសិក្សា*

ក្រសួងបានវាយតម្លៃបរិស្ថានសាលា ថ្នាក់រៀន និងសម្ភារៈសិក្សារបស់មត្តេយ្យសិក្សារដ្ឋ ៥០ និងថ្នាក់មត្តេយ្យសិក្សាសហគមន៍ ១០០ តំណាងទូទាំងប្រទេស។ លក្ខខណ្ឌវាយតម្លៃនេះផ្តោតលើ ១). បរិវេណនិងសង្ហារិម ២). ភាសានិងការពិចារណា ៣). អន្តរកម្មគ្រូនិងកុមារ ៤). រចនាសម្ព័ន្ធនៃកម្មវិធី និង ៥). មាតាបិតានិងគ្រូបង្រៀន។

**រូបភាពទី១៧ ៖ លទ្ធផលការវាយតម្លៃសាលាមត្តេយ្យសិក្សារដ្ឋ**




**រូបភាពទី១៨ ៖ លទ្ធផលការវាយតម្លៃថ្នាក់មត្តេយ្យសិក្សាសហគមន៍**



*រូបភាពខាងលើ ទាមទារឱ្យមានការគាំទ្រផ្នែកបច្ចេកទេស និងការផ្តល់ធាតុចូលបន្តទៀតសម្រាប់មត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពបរិស្ថានសាលា ថ្នាក់រៀន និងសម្ភារៈសិក្សា។*

### *ការអភិវឌ្ឍកម្មវិធីសិក្សា និងចងក្រងឯកសារ*

ក្រសួងបាន ៖

- ព្រាងសេចក្តីណែនាំស្តីពីការអនុវត្តសកម្មភាពល្បែងសេរីនៅមត្តេយ្យសិក្សា
- អនុម័តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស (ចាប់ពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សា)
- ផលិតនិងចាក់ផ្សាយកម្មវិធី "ស្រឡាញ់កូន" ចំនួន ៣៩ វគ្គ ដោយសហការជាមួយក្រសួងព័ត៌មាន និងកំពុងដំណើរការចាក់ផ្សាយតាមស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជារៀងរាល់ថ្ងៃច័ន្ទ និងសុក្រ វេលាម៉ោង ៥:០០នាទីល្ងាច
- រៀបចំកែលម្អគោលការណ៍ណែនាំកម្មវិធីអប់រំមាតាបិតា
- បោះពុម្ពឯកសារអប់រំមាតាបិតាចំនួន ១៣ ជំពូក
- ព្រាងសេចក្តីណែនាំស្តីពីការរៀបចំថ្នាក់សម្រាប់មត្តេយ្យសិក្សាឡើងវិញ។

### *ការអនុវត្តម៉ោង និងកម្មវិធីសិក្សា*

ការអនុវត្តកម្មវិធីសិក្សា និងកាលវិភាគនៅសាលារៀននិងថ្នាក់រៀនមត្តេយ្យសិក្សារដ្ឋ សម្រេចបាន ៧២,២០ ភាគរយ នៅមត្តេយ្យសិក្សាកម្រិតទាប ៧៦,៩៥ ភាគរយ នៅមត្តេយ្យសិក្សាកម្រិតមធ្យម និង ៨៧,២៤ ភាគរយ នៅមត្តេយ្យសិក្សាកម្រិតខ្ពស់ នៃកម្មវិធីសិក្សាប្រចាំឆ្នាំ។

ការអនុវត្តកម្មវិធីសិក្សា និងកាលវិភាគនៅមណ្ឌល ឬថ្នាក់មត្តេយ្យសិក្សាសហគមន៍សម្រេចបាន ៧៧ ភាគរយ នៃកម្មវិធីសិក្សាប្រចាំឆ្នាំ បើធៀបទៅនឹងឆ្នាំសិក្សាកន្លងមកកើន ៨,៤ ភាគរយ។

សកម្មភាពល្បែងសេរីបានអនុវត្តនៅតាមថ្នាក់រៀនមត្តេយ្យសិក្សារដ្ឋ ១៩ ថ្នាក់ ក្នុងនោះ ១០ ថ្នាក់នៅរាជធានីភ្នំពេញ។

### *ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន*

ក្រសួងបាន៖

- ប្រឡងបញ្ចប់ការបណ្តុះបណ្តាលគរុសិស្សមត្តេយ្យសិក្សាជំនាន់ទី២៨ ចំនួន ២៤៩ នាក់ ស្រី ៩៦,៣៦ ភាគរយ
- កំពុងបណ្តុះបណ្តាលគរុសិស្សមត្តេយ្យសិក្សាជំនាន់ទី២៩ ឆ្នាំទី២ ចំនួន ១៩៩ នាក់ ស្រី ៩៤,៩៧ ភាគរយ
- ប្រឡងជ្រើសរើសគរុសិស្សមត្តេយ្យសិក្សាជំនាន់ទី៣០ ចំនួន ២០០ នាក់ ស្រី ៩៥ ភាគរយ

- បំប៉នសមត្ថភាពនាយក នាយិកាសាលាមត្តេយ្យសិក្សា និងសាលាបឋមសិក្សាមានថ្នាក់មត្តេយ្យសិក្សា ៤ ៣៩២ នាក់ ស្រី ២២,៥៧ ភាគរយ ស្តីពីការងារគ្រប់គ្រងសាលារៀនមត្តេយ្យសិក្សាតាមស្តង់ដាគុណភាព
- បំប៉នគ្រូមត្តេយ្យសិក្សារដ្ឋ ១២៥ នាក់ ស្រី ៨១,៦ ភាគរយ ស្តីពីការអប់រំបរិយាបន្ន
- បំប៉នគ្រូមត្តេយ្យសិក្សារដ្ឋ និងគ្រូមត្តេយ្យសិក្សាសហគមន៍ ៥២ នាក់ ស្រី ៨២,៦៩ ភាគរយ ស្តីពីកម្មវិធីពហុភាសា
- បំប៉នតាមស្តង់ដាកំណត់ដល់គ្រូមត្តេយ្យសិក្សាសហគមន៍ ២៧៧ នាក់ ស្រី ៩៥,៣០ ភាគរយ និងមាតាបិតាបង្គោល ២៤៥ នាក់ ស្រី ២១៨ នាក់
- បំប៉នគ្រូមត្តេយ្យសិក្សាសហគមន៍ ១ ៤៨២ នាក់ ស្រី ៩៧,៩៧ ភាគរយ ស្តីពីការប្រជុំប្រចាំខែសម្រាប់កម្មវិធីមត្តេយ្យសិក្សា។

### *ការងារពិនិត្យតាមដាន និងសិក្សាស្រាវជ្រាវ*

ក្រសួងបាន ពិនិត្យតាមដានការអនុវត្តគម្រោងកម្មវិធីកែលម្អសាលារៀន ៦៣ សាលាមត្តេយ្យសិក្សា និងថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា នៅខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពត កំពង់ស្ពឺ ឧត្តរមានជ័យ កោះកុង ប៉ៃលិន ព្រះសីហនុ ស្ទឹងត្រែង និងខេត្តតាកែវ ទទួលបានលទ្ធផលដូចខាងក្រោម៖

- គណៈកម្មការទ្រទ្រង់សាលារៀនមូលដ្ឋាន ៧៨ ភាគរយ បានចូលរួមប្រជុំមួយខែម្តង ឬច្រើនដង
- គណៈកម្មការទ្រទ្រង់សាលារៀនមូលដ្ឋាន ៧៧ ភាគរយ បានចុះពិនិត្យមើលដោយគណៈកម្មការសម្របសម្រួលជំនួយថ្នាក់ស្រុក
- គណៈកម្មការទ្រទ្រង់សាលារៀនមូលដ្ឋាន ៦០ ភាគរយ ត្រូវបានពិនិត្យដោយគណៈកម្មការ សម្របសម្រួលជំនួយថ្នាក់ខេត្ត
- គណៈកម្មការទ្រទ្រង់សាលារៀនមូលដ្ឋាន ៨០ ភាគរយ អនុវត្តតាមឯកសារគោលការណ៍ណែនាំស្តីពីបច្ចេកទេសនិងហិរញ្ញវត្ថុសម្រាប់ការអនុវត្តគម្រោងកម្មវិធីកែលម្អសាលារៀន
- សាលាមត្តេយ្យសិក្សា និងសាលាបឋមសិក្សាដែលមានថ្នាក់មត្តេយ្យសិក្សា ៧០ ភាគរយ មានកិច្ចតែងការបង្រៀនតាមគោលការណ៍ណែនាំ។

ក្រសួងបាន ពិនិត្យដំណើរការនៃការអនុវត្តការងាររបស់សាលាមត្តេយ្យសិក្សាឯកជន ៣៥ សាលា នៅខេត្តព្រៃវែង កំពង់ចាម កំពត សៀមរាប ព្រះសីហនុ និងកំពង់ឆ្នាំង ដើម្បីជំរុញឱ្យសាលាមត្តេយ្យសិក្សាឯកជនទាំងនោះរៀបចំដំណើរការការងារស្របតាមកម្មវិធីរបស់ក្រសួង ក្នុងនោះ សាលាឯកជន ៣២ មានច្បាប់អនុញ្ញាតត្រឹមត្រូវ ២៥ សាលាបានរៀបចំផែនការអភិវឌ្ឍន៍ ៣០ សាលាបានរៀបចំស្ថិតិសិស្សបានត្រឹមត្រូវ និងប្រជុំបច្ចេកទេសបានទៀងទាត់។ អ្នកគ្រូមត្តេយ្យសិក្សា ២៣ នាក់ បានទទួលការបណ្តុះបណ្តាលគរុកោសល្យផ្នែកមត្តេយ្យសិក្សា និង ២១ នាក់ បានរៀបចំកិច្ចតែងការបង្រៀន។

ក្រសួងបាន ពិនិត្យតាមដាន និងវាយតម្លៃដំណើរការអនុវត្តកម្មវិធីមត្តេយ្យសិក្សាសហគមន៍ផ្សារភ្ជាប់នឹងកម្មវិធីអប់រំមាតាបិតា នៅខេត្តកំពង់ស្ពឺ ស្ទឹងត្រែង កោះកុង តាកែវ កំពង់ឆ្នាំង ក្រចេះ មណ្ឌលគិរី ស្វាយរៀង រតនគិរី ព្រៃវែង ព្រះសីហនុ កណ្ដាល និងកំពត ស្មើនឹង ៣៤ ស្រុក ៦៩ ឃុំ សង្កាត់ ៧៥ ភូមិ ក្នុងគោលបំណងពិនិត្យតាមដានលើដំណើរការអនុវត្តកម្មវិធីអប់រំកុមារតូច ការបង្រៀនរបស់គ្រូ និងការរៀនរបស់កុមារសម្រាប់ថ្នាក់មត្តេយ្យសិក្សាសហគមន៍ផ្សារភ្ជាប់នឹងកម្មវិធីអប់រំមាតាបិតា និងបានសម្ភាសគ្រូមត្តេយ្យសិក្សាសហគមន៍ ៧៥ នាក់ ស្រី ៦០ នាក់ ក្រុមប្រឹក្សាឃុំ សង្កាត់បុរស ៦ នាក់ មាតាបិតាបង្គោល ៥៨ នាក់ ស្រី ៥៤ នាក់ ប្រធានភូមិ ៧៥ នាក់ ស្រី ១០ នាក់ ដើម្បីស្វែងយល់ពីគុណភាពសេវានិងការគាំទ្ររបស់សហគមន៍។

## ក.២ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

### *ការអភិវឌ្ឍសមត្ថភាព*

ក្រសួងបានបំប៉នសមត្ថភាព ៖

- ជនបង្គោលថ្នាក់ក្រោមជាតិ ២៥ នាក់ ស្រី ៨០ ភាគរយ ស្ដីពីកម្មវិធីអប់រំពហុភាសា នៅខេត្តក្រចេះ
- មន្ត្រីអប់រំកុមារតូច ១០ នាក់ ស្រី ៨០ ភាគរយ ស្ដីពីការប្រមូលទិន្នន័យព័ត៌មាន សម្រាប់វាយតម្លៃការអភិវឌ្ឍកុមារតូច និងបរិស្ថានសិក្សាសេវាអប់រំកុមារតូច
- ស្ដីពីស្ថានភាពថែទាំបរិស្ថាន និងការផ្ដល់អាហារូបត្ថម្ភកុមារនៅតាមភូមិគោលដៅ ២៤៥ នាក់ ស្រី ៥៩,១៨ ភាគរយ
- គ្រូឧទ្ទេសថ្នាក់ក្រោមជាតិ ៣៤ នាក់ ស្រី ៧៣,៥២ ភាគរយ ស្ដីពីការអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យអប់រំកុមារតូច
- មន្ត្រីអប់រំ ២៤៥ នាក់ ស្រី ៥៩,១៨ ភាគរយ ស្ដីពីស្ថានភាពថែទាំបរិស្ថាន និងការផ្ដល់អាហារូបត្ថម្ភកុមារតាមភូមិគោលដៅ
- គ្រូបង្គោលថ្នាក់ក្រោមជាតិ ៦៥ នាក់ ស្រី ៧០,៧៦ ភាគរយ ស្ដីពីការអនុវត្តកម្មវិធីអប់រំបញ្ចូលគ្នាផ្អែកមត្តេយ្យសិក្សា
- គ្រូឧទ្ទេសថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ម្ដាយបង្គោល ប្រធានក្រុមម្ដាយ ២៤៩ នាក់ ស្រី ៥១,៨០ ភាគរយ ក្នុងនោះឪពុកម្ដាយបង្គោល ១៩៩ នាក់ ស្រី ៨៩,៤៤ ភាគរយ ស្ដីពីកម្មវិធីអប់រំកុមារតូចតាមផ្ទះ និងអប់រំឪពុកម្ដាយ
- មន្ត្រីអប់រំ ៤២៤ នាក់ ស្រី ៦៦,៧៤ ភាគរយ ស្ដីពីដំណើរការអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃសម្រាប់អនុវិស័យអប់រំកុមារតូច
- មន្ត្រីអប់រំថ្នាក់ក្រោមជាតិ ១០២ នាក់ ស្រី ៨៥,២៩ ភាគរយ ស្ដីពីគោលការណ៍ណែនាំសម្រាប់សាលាមត្តេយ្យសិក្សាធនធាន
- មន្ត្រីអប់រំ ៨៧៥ នាក់ ស្រី ៩៣,៦ ភាគរយ ស្ដីពីការប្រជុំប្រចាំខែសម្រាប់កម្មវិធីអប់រំមាតាបិតា

- មន្ត្រីអប់រំ ១៤ នាក់ ស្រី ៨៥,៧១ ភាគរយ ស្តីពីការរៀបចំរបាយការណ៍ ការវិភាគទិន្នន័យ លើការវាយតម្លៃផ្នែកបរិស្ថានសេវាអប់រំកុមារតូច
- មន្ត្រីអប់រំ ៣០២ នាក់ ស្រី ៦៩,២០ ភាគរយ ស្តីពីកម្មវិធីអប់រំមាតាបិតាដែលមានកូនអាយុក្រោម ២ ឆ្នាំ និងស្ត្រីមានផ្ទៃពោះ
- គ្រូបង្គោលថ្នាក់ក្រោមជាតិ ៦៥ នាក់ ស្រី ៧០,៧៦ ភាគរយ ស្តីពីការអនុវត្តកម្មវិធីអប់រំបញ្ចូលគ្នាផ្នែកមត្តេយ្យសិក្សា
- មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ គណៈអភិបាលខេត្ត ក្រុង ស្រុក ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ៧៦ នាក់ ស្រី ៣១,៦៥ ភាគរយ ស្តីពីការគ្រប់គ្រងសេវាអប់រំកុមារតូច។

ក្រសួងបានបញ្ជូនមន្ត្រីអប់រំ ៖

- ៤ នាក់ ស្រី ២៣,៧៤ ភាគរយ ឱ្យចូលរួមសិក្ខាសាលាស្តីពីការរៀបចំគោលការណ៍ណែនាំសម្រាប់ស្តង់ដា និងសមត្ថភាពផ្នែកអនុវិស័យអប់រំកុមារតូច នៅប្រទេសថៃ
- បុរស ១ នាក់ ឱ្យចូលរួមសន្និសីទអន្តរជាតិស្តីពីគោលនយោបាយ និងការអប់រំពហុភាសា នៅប្រទេសភូមា
- ស្ត្រី ២ នាក់ ឱ្យចូលរួមប្រជុំពិគ្រោះយោបល់ស្តីពីការបង្កើតមជ្ឈមណ្ឌល SEAMEO សម្រាប់ការថែទាំ និងអប់រំកុមារតូច និងការគាំពារ នៅប្រទេសឥណ្ឌូនេស៊ី
- បុរស ១ នាក់ ឱ្យចូលរួមវេទិកាអប់រំអន្តរជាតិស្តីពីមត្តេយ្យសិក្សា នៅសាធារណរដ្ឋកូរ៉េ
- បុរស ២ នាក់ ឱ្យចូលរួមសន្និសីទថ្នាក់តំបន់ស្តីពីការអភិវឌ្ឍកុមារតូច នៅប្រទេសម៉ាឡេស៊ី
- បុរស ១ នាក់ ឱ្យចូលរួមសន្និសីទថ្នាក់តំបន់ស្តីពីការអភិវឌ្ឍកុមារតូច នៅប្រទេសឥណ្ឌូនេស៊ី
- ៧ នាក់ ស្រី ៧១,៤២ ភាគរយ ឱ្យចូលរួមទស្សនកិច្ចសិក្សាស្តីពីការអប់រំកុមារតូចនៅប្រទេសជប៉ុន
- ២ នាក់ ស្រី ៥០ ភាគរយ ឱ្យទៅចូលរួមវេទិកាស្តីពី បញ្ហាប្រឈម និងយុទ្ធសាស្ត្រលើកុមារ និងយុវជននៅតំបន់អាស៊ាន នៅប្រទេសម៉ាឡេស៊ី។

### *ការកសាងលិខិតបទដ្ឋាន*

ក្រសួងបានព្រាងសេចក្តីណែនាំ៖

- ការអនុវត្តស្តង់ដាសម្រាប់សេវាអប់រំកុមារតូច
- ការអនុវត្តប្រជុំបច្ចេកទេសប្រចាំសប្តាហ៍
- ការអនុវត្តតេស្តទៀងទាត់កម្រិតមត្តេយ្យសិក្សា
- ការប្រមូលកុមារចូលរៀននៅថ្នាក់មត្តេយ្យសិក្សាសហគមន៍
- ការអនុវត្តការងារក្រុមកុមារក្នុងដំណើរការបង្រៀននិងរៀន

- ស្តីពីទំនាក់ទំនងរវាងគ្រូមត្តេយ្យសិក្សានិងមាតាបិតាកុមារ និងរៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍។

*ការងារគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច*

គណៈកម្មាធិការជាតិនេះបាន៖

- ប្រជុំគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច មានអ្នកចូលរួម ៦៣ នាក់ ស្រី ២៨,៥៧ ភាគរយ
- ធ្វើសិក្ខាសាលាពិនិត្យឡើងវិញក្របខណ្ឌលទ្ធផលផែនការសកម្មភាពជាតិគាំពារ និងអភិវឌ្ឍកុមារតូច ឆ្នាំ២០១៤-២០១៨ នៅខេត្តសៀមរាប មានអ្នកចូលរួម ៣៥ នាក់ ស្រី ៤២,៨៥ ភាគរយ
- ប្រជុំពិគ្រោះយោបល់រវាងដៃគូអភិវឌ្ឍ និងបណ្តាញការងារគាំពារនិងអភិវឌ្ឍកុមារតូចតំបន់អាស៊ីប៉ា-ស៊ីហ្វិច ដើម្បីរៀបចំសន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍកុមារតូច នៅខេត្តសៀមរាប
- បោះពុម្ពរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៥ របស់គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច។

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

*ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| | ការអប់រំកុមារតូច | ជាក់ស្តែង ២០១៥-១៦ | ចំណុចដៅ ២០១៦-១៧ | ជាក់ស្តែង ២០១៦-១៧ | ស្ថានភាព |
|---|---|---|---|---|---|
| គោលនយោបាយទី១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | |
| ១ | ភាគរយកុមារអាយុ ៥ឆ្នាំបានចូលរៀន | ៦៤,១% | ៦៦% | ៦៦,៣៥% | ↑ |
| ២ | ភាគរយកុមារអាយុ ៤ឆ្នាំបានចូលរៀន | ២៨,៧% | ៣៥% | ៣៧,៣៧% | ↑ |
| ៣ | ភាគរយកុមារអាយុ ៣ឆ្នាំបានចូលរៀន | ១៩,៧៩% | ២៧% | ២០,៣៣% | ↓ |
| ៤ | ចំនួនគ្រូបង្រៀនមត្តេយ្យសិក្សាទទួលការបណ្តុះបណ្តាល (បណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន) រូបមន្ត ១២+៤ ក្នុងឆ្នាំនីមួយៗ | N/A | N/A | អនុវត្តនៅឆ្នាំ២០១៨ | |
| ៥ | ភាគរយគ្រូបង្រៀនមត្តេយ្យសិក្សាយ៉ាងហោចណាស់មានបរិញ្ញាបត្រ ក្នុងឆ្នាំនីមួយៗ | ៣% | ៣.១% | ២,០% | ↓ |
| ៦ | ចំនួនគ្រូបង្រៀនមត្តេយ្យសិក្សាបានទទួលការអភិវឌ្ឍជំនាញវិជ្ជាជីវៈបន្ត ក្នុងឆ្នាំនីមួយៗ | n/a | ២០០ | ១៥២ | ↓ |
| ៧ | ភាគរយសេវាអប់រំកុមារតូចគោរពតាមស្តង់ដាគុណភាព | ១១% | ១៦,៩% | ១៥,១៧% | ↑ |
| ៨ | ភាគរយសេវាអប់រំកុមារតូចដែលបានអនុវត្តតេស្តទៀងទាត់ដើម្បីវាស់សមត្ថភាពកុមារអាយុ ៥ ឆ្នាំ ជាទៀងទាត់ | ២០% | ២៥,៣% | ២៥,៦៥% | ↑ |
| ៩ | ភាគរយកុមារក្នុងសេវាគាំពារនិងអភិវឌ្ឍកុមារតូច ដែលមានស្ថានភាពអាហារូបត្ថម្ភ | N/A | ៤០% | ២៧% | ↓ |

| | | | | | |
|---|---|---|---|---|---|
| ១០ | ភាគរយកុមារនៅតាមសាលាមត្តេយ្យសិក្សាសាធារណៈ ទទួលបានថ្នាំទម្លាក់ព្រូន | ៩៥% | ៩០% | ៨៩% | → |
| គោលនយោបាយទី២ ៖ ធានាស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | |
| | N/A | | | | |

សម្គាល់: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- សមត្ថភាព និងធនធានក្នុងការអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃនៅមិនទាន់ឆ្លើយតប
- ចំនួនគ្រូមត្តេយ្យសិក្សាបណ្តុះបណ្តាលថ្មីមិនឆ្លើយតបទៅនឹងតម្រូវការពង្រីកសេវា
- អគារ ថ្នាក់រៀន ទាំងថ្នាក់កំពុងដំណើរការ និងថ្នាក់បង្កើតថ្មី មិនទាន់សមស្រប និងគ្រប់គ្រាន់
- សម្ភារបរិក្ខារ សម្ភារៈបង្រៀន និងរៀនសម្រាប់ដំណើរការថ្នាក់មត្តេយ្យសិក្សាមិនទាន់សមស្របតាមតម្រូវការអភិវឌ្ឍរបស់កុមារតូច។

## ២.២.២ អនុវិស័យ ការអប់រំបឋមសិក្សា

### ក. លទ្ធផលសម្រេចបាន

### ក.១ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ឆ្នាំសិក្សា ២០១៦-២០១៧ សាលាបឋមសិក្សារដ្ឋមាន ៧ ១៩៤ កើន ៥៩ ធៀបនឹងឆ្នាំសិក្សា ២០១៥-២០១៦។ សាលារៀនមិនគ្រប់កម្រិតមាន ៥៩៨ ថយ ៨១។ សាលាកុមារមេត្រីកម្រិតមធ្យមនិងកម្រិតអភិវឌ្ឍមាន ៥ ១៩៦ កើន ១៩។ សាលាបឋមសិក្សាឯកជន ៩១៧ មានទីតាំងនៅគ្រប់រាជធានី ខេត្ត។

ថ្នាក់រៀនសាលារដ្ឋមាន ៦១ ២៥៥ កើន ១ ០៣១ ថ្នាក់ និងបន្ទប់រៀនសាលារដ្ឋមាន ៤២ ៧១២ កើន ៥៦៥ បន្ទប់។

សិស្សបឋមសិក្សារដ្ឋមាន ២ ០២២ ០៦១ នាក់ ស្រី ៩៧៤ ២៣១ នាក់ ស្មើនឹង ៤៨,១៨ ភាគរយ កើន ១១ ៣៨៨ នាក់ ស្រីកើន ២ ៨១៩ នាក់។ សិស្សបឋមសិក្សាឯកជន ៨៩ ៥៧០ នាក់ ស្រី ៤៤ ០៩៥ នាក់ ស្មើនឹង ៤៩,៣ ភាគរយ។ អត្រាពិតចូលរៀនថ្មីសរុប ៩៥,១ ភាគរយ ស្រី ៩៤,០ ភាគរយ ថយសរុប ០,១ ភាគរយ ស្រីថយ ១,៤ ភាគរយ ក្នុងនោះ ឯកជនថយ ០,៥ ភាគរយ ស្រី ០,៦ ភាគរយ និងរដ្ឋថយ ០,៣ ភាគរយ ស្រីថយ ០,៨ ភាគរយ។ អត្រាពិតចូលរៀនថ្មីរដ្ឋ ៩១,០ ភាគរយ ស្រី ៩០,១ ភាគរយ និងអត្រាពិតចូលរៀនថ្មីឯកជន ៤,១ ភាគរយ ស្រី ៣,៩ ភាគរយ។

*ប្រការនេះ ទាមទារឱ្យមាតាបិតា ឬអ្នកអាណាព្យាបាល និងអ្នកពាក់ព័ន្ធយកចិត្តទុកដាក់បន្ថែមទៀតលើការនាំកូនទៅចុះឈ្មោះចូលរៀនថ្នាក់ទី១ ត្រូវតាមអាយុកំណត់ ដោយអត្រាកុមារចូលរៀនថ្នាក់ទី១ លើសអាយុនៅមានកម្រិតខ្ពស់នៅឡើយ។*

បុគ្គលិកបឋមសិក្សារដ្ឋ ៥៧ ៨៤៤ នាក់ ស្រី ២៩ ០០៧ នាក់ ស្មើនឹង ៥០,២ ភាគរយ កើន ១ ៨០១ នាក់ ស្រី ១ ៨២៧ នាក់ ក្នុងនោះបុគ្គលិកបង្រៀន ៨៦ ១៩៩ នាក់ ស្រី ២៥ ៧១៣ នាក់ ស្មើនឹង ៥៦ ភាគរយ កើន ១ ២៨៣ នាក់ ស្រី ១ ៨០២ នាក់ គ្រូបង្រៀនពីរវេន ១១ ៨១៣ នាក់ ស្រី ៥ ០៨៧ នាក់ និងគ្រូបង្រៀនថ្នាក់គួប ២ ៦៥៩ នាក់ ស្រី ៩០១ នាក់។

#### ការអនុវត្តកម្មវិធី និងសកម្មភាពនានា

#### *ការផ្តល់ថវិកាដំណើរការ និងថវិកាកែលម្អសាលារៀន*

ថវិកាកែលម្អសាលារៀន និងថវិកាដំណើរការសាលារៀន ត្រូវបានផ្តល់គ្រប់សាលារៀនតាមប្រព័ន្ធធនាគារ។ សាលារៀននីមួយៗមានការរៀបចំផែនការអភិវឌ្ឍប្រចាំឆ្នាំ ដោយមានការចូលរួមពីគណៈកម្មការទ្រទ្រង់សាលារៀន។ រាល់ចំណូលដែលបានពីប្រភពនានា និងការចំណាយមានតារាងតម្លាភាពបិទផ្សាយទូលំទូលាយ។ សាលារៀនមួយចំនួនក្នុងឃុំចំនួន ៣០០ នៃស្រុក ៥១ បានអនុវត្តកម្មវិធីគណនេយ្យភាពសង្គម។

*ប្រការនេះ បានជួយឱ្យសាលារៀនមានលទ្ធភាពប្រើប្រាស់ធនធានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងកាន់តែប្រសើរជាងមុន។*

### *កម្មវិធីអប់រំពហុភាសា*

ក្រសួងបាន ៖

- អនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិចមានសាលា ៨០ កើន ១៣ គ្រូ ២១៦ នាក់ ស្រី ៣៦,១ ភាគរយ សិស្ស ៤ ៨១៨ នាក់ ស្រី ៤៧,៤ ភាគរយ ក្នុងស្រុកគោលដៅ ១៥ នៃខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងក្រចេះ។ កម្មវិធីនេះ គឺជាស្ពានឆ្លងពីភាសាកំណើតទៅភាសាជាតិ និងបានអនុវត្តសម្រាប់ ៤ ភាសាគឺ គ្រឹង ទំពួន ព្នង និងកាវ៉ែត ពីថ្នាក់ទី១ ដល់ថ្នាក់ទី៣
- ដាក់ឱ្យអនុវត្តផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា២០១៥-២០១៨ ដោយប្រកាសដាក់បញ្ចូលសាលាសហគមន៍ ៥០ ជាសាលាសាធារណៈ
- បណ្តុះបណ្តាល និងបំប៉នបច្ចេកទេសដល់គ្រូបង្រៀនថ្នាក់អប់រំពហុភាសាជារៀងរាល់ឆ្នាំ គាំទ្រពីអង្គការយូនីសេហ្វ និងគម្រោងដៃគូរួមគ្នាផ្តល់ឱកាសអប់រំដល់កុមារបាត់បង់ឱកាសនៅកម្ពុជា និងសហការបច្ចេកទេសជាមួយអង្គការឃែរ។

*ប្រការនេះ បានជួយដល់កុមារជនជាតិដើមភាគតិចមានឱកាសចូលរៀននៅសាលាបឋមសិក្សាសាធារណៈប្រកបដោយសមធម៌។*

### *កម្មវិធីពន្លឿនការសិក្សា*

ក្រសួងបានអនុវត្ត ៖

- កម្មវិធីពន្លឿនការសិក្សាក្នុងក្រុង ស្រុក ៧ នៅខេត្តកំពត ក្រចេះ និងព្រះវិហារ មានសាលារៀន ១៦ សិស្ស ៥០០ នាក់ ស្រី ៤៨,២ ភាគរយ ដោយសហការជាមួយអង្គការយូនីសេហ្វ
- កម្មវិធីពន្លឿនការសិក្សានៅសាលា ១៩១ មានគ្រូបង្រៀន ២៤៧ នាក់ ស្រី ២៨,៥ ភាគរយ និងសិស្សមាន ៦ ៧៣៣ នាក់ ស្រី ៩៦,៥៦ ភាគរយ និងមន្ត្រីបង្គោលថ្នាក់ជាតិ ៥ នាក់ និងថ្នាក់ក្រោមជាតិ ៤០ នាក់ ស្រី ២៥,៥ ភាគរយ ក្នុងស្រុក ខណ្ឌ ៣០ នៃរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ព្រៃវែង ព្រះសីហនុ និងសៀមរាប។ បោះពុម្ពសៀវភៅកម្មវិធីថ្នាក់ពន្លឿនសិក្សាសម្រាប់គ្រូ ៧២០ ក្បាល និងសម្រាប់សិស្ស ១៤ ៤០០ ក្បាល។ បង្កើតថ្នាក់បំប៉នសម្រាប់បង្រៀនសិស្សដែលរៀនយឺត និងកម្មវិធីរៀនសារឡើងវិញសម្រាប់សិស្សបោះបង់ការសិក្សា និងសិស្សធ្លាក់ចំណាត់ថ្នាក់ ១ ៦៩១ ថ្នាក់ អនុវត្តនៅតាមសាលាបឋមសិក្សា ១ ០០០ ក្នុងខេត្តសៀមរាប ក្រចេះ ត្បូងឃ្មុំ រតនគិរី កោះកុង និងកំពង់ធំ មានសិស្ស ១០ ៩៦២ នាក់ ស្រី ៥០ ភាគរយ ដោយសហការជាមួយអង្គការភាពញញឹមនៃកុមារ
- កម្មវិធីស្ពានចម្លងសិស្សថ្នាក់ទី៦ ទៅទី៧ ផ្តោតលើមេរៀនភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា ដើម្បីត្រៀមចូលរៀនថ្នាក់ទី៧ មានសិស្ស ៨០៦ នាក់ ស្រី ៩០ ភាគរយ សាលារៀន ២៧ ស្រុក

៨ នៅខេត្តសៀមរាប និងត្បូងឃ្មុំ និងកម្មវិធីស្ពានចម្លងសិស្សមត្តេយ្យសិក្សាត្រៀមចូលទី១ មានសិស្ស ៧៧២ នាក់ ស្រី ៥៥,៥ ភាគរយ នៅសាលាបឋមសិក្សា ២៩ ខេត្តត្បូងឃ្មុំ។ សិស្សទាំងនោះបានចូលរៀនថ្នាក់ទី១ ចំនួន ៧០៤ នាក់ ស្រី ៥០,៤ ភាគរយ ដោយសហការជាមួយអង្គការ ភ្លែនអន្តរជាតិកម្ពុជា

- កម្មវិធីអំណានដល់កុមារដែលរៀនយឺតមានសិស្ស ៤ ៨៣១ នាក់ ស្រី ៤០ ភាគរយ នៅសាលាបឋមសិក្សា ៦៥០ ក្នុង ៩ ខេត្ត និងរៀបចំទិវាអំណានជាតិមានសិស្សចូលរួម ៣៥ ៣៩២ នាក់ ស្រី ៥៥ ភាគរយ ក្នុងស្រុក ៤៣ ព្រមទាំងបានផ្តល់បរិក្ខារទឹកស្អាត និងអនាម័យដល់សាលា ២០ ដោយសហការជាមួយអង្គការទស្សនពិភពលោកកម្ពុជា។

*ប្រការនេះ បានជួយសិស្សដែលលើសអាយុ និងសិស្សបោះបង់ឱ្យមានឱកាសរៀនស្របតាមកម្រិតថ្នាក់ និងអាយុ។*

## *កម្មវិធីអប់រំបរិយាបន្ន*

ក្រសួងបាន៖

- បណ្តុះបណ្តាលគ្រូ ១ ៩៩៩ នាក់ ស្រី ៣៩,៨ ភាគរយ ស្តីពីកម្មវិធីអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ
- អនុវត្តគម្រោងវាស់គំហើញ ព្យាបាល និងបញ្ជូនរកសេវា នៅក្នុងស្រុក ១២ នៃរាជធានី ខេត្ត ៣ មានសិស្សថ្នាក់ទី៦ ចំនួន ២ ៥០០ នាក់ ស្រី ៥៤ ភាគរយ ក្នុងនោះសិស្សដែលត្រូវពាក់វ៉ែនតា ៣៨៣ នាក់ ស្រី ៦៨ ភាគរយ និងសិស្សមានជំងឺភ្នែក ២៥ នាក់ ស្រី ៦០ ភាគរយ ដោយសហការជាមួយអង្គការមជ្ឈមណ្ឌលអន្តរជាតិជប៉ុនដើម្បីសិទ្ធិកុមារ អង្គការកាតូលិកសង្គ្រោះនិងអភិវឌ្ឍន៍កុមារ គម្រោងវាស់គំហើញ ព្យាបាល និងបញ្ជូនរកសេវា គម្រោងកែលម្អសុខភាពសិក្សា
- ពិនិត្យសុខភាពភ្នែកសិស្ស ១ ២៤៤ នាក់ ស្រី ៣៩ ភាគរយ សិស្សបានទទួលវ៉ែនតា ៧២ នាក់ ស្រី ៥៥,៨ ភាគរយ និងសិស្ស ១៨ នាក់ ស្រី ៦១ ភាគរយ ត្រូវបញ្ជូនទៅមន្ទីរពេទ្យ ដោយសហការជាមួយគម្រោងកែលម្អសុខភាពសិក្សា
- អនុវត្តកម្មវិធីអប់រំបរិយាបន្ននៅសាលា ៩៨ ក្នុងស្រុក ១២ នៃខេត្ត៦ មានសិស្ស ១០៥ នាក់ ស្រី ៣៥ ភាគរយ និងផ្តល់សេវាអប់រំដល់កុមារពិការភ្នែក និង គ ថ្លង់ក្នុងសាលាពិសេស ៥ នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង សៀមរាប និងកំពង់ចាម មានគ្រូបង្រៀន ១១៦ នាក់ ស្រី ៤៤,៨ ភាគរយ និងសិស្សពិការ ៦៨៨ នាក់ ស្រី ២៦,៣ ភាគរយ ដោយសហការជាមួយអង្គការគ្រួសារថ្មី
- ផ្តល់សេវាអប់រំដល់កុមារខ្សោយបញ្ញានៅរាជធានីភ្នំពេញ កណ្តាល កំពង់ស្ពឺ កំពត ក្រចេះ ប៉ៃលិន សៀមរាប និងពោធិ៍សាត់ មានសាលារៀន ១៦៥ គ្រូបង្រៀន ៧៥០ នាក់ ស្រី ៨៨,៧ ភាគរយ សិស្ស ១ ៧៣៧ នាក់ ស្រី ៣៩,៦ ភាគរយ ដោយសហការជាមួយកម្មវិធីដៃគូរួមគ្នាផ្តល់ឱកាសអប់រំដល់កុមារបាត់បង់ឱកាសនៅកម្ពុជា។

*ប្រការនេះ បានជួយសិស្សពិការដែលបាត់បង់ឱកាស ឱ្យមានឱកាសចូលរៀន និងរៀនបានដូចកុមារធម្មតា។*

### *កម្មវិធីអាហារូបករណ៍និងស្បៀងអាហារនៅតាមសាលារៀន*

ក្រសួងបានផ្តល់៖

- អាហារូបករណ៍ដល់សិស្សក្រីក្រក្នុងសាលា ៣ ២៥៣ ត្រូវជា ៤៥,៩ ភាគរយ នៃសាលាបឋមសិក្សាទូទាំងប្រទេស សិស្សសរុប ៧៧ ៦៥៤ នាក់ ស្រី ៥៥ ភាគរយ ប្រើប្រាស់ថវិកាកម្មវិធី
- អាហារូបករណ៍ជាសាច់ប្រាក់ក្នុងសាលា ១ ២៥១ ត្រូវជា ១៧,៧ ភាគរយ នៃសាលាបឋមសិក្សាទូទាំងប្រទេសសិស្សសរុប ២៤ ៦០០ នាក់ ស្រី ៥៤,៩ ភាគរយ និងអាហារូបករណ៍ជាស្បៀងដល់សាលា ៧៦២ ត្រូវជា ១០,៨ ភាគរយ នៃសាលាបឋមសិក្សាទូទាំងប្រទេសសិស្សសរុប ១៥ ៨៤៤ នាក់ ស្រី ៥៦,៦ ភាគរយ ដោយសហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក
- អាហារូបករណ៍ដល់សិស្សក្រីក្រងាយរងគ្រោះ ២ ៣២៥ នាក់ ស្រី ៥០ ភាគរយ ដោយសហការជាមួយអង្គការឆាលហ្សានកម្ពុជា អង្គការខេប គម្រោងងាយស្រួលរៀននិងសាលារៀនជំនាន់ថ្មី
- អាហារូបករណ៍ដល់សិស្ស ២៨៧ ១៣០ នាក់ ស្រី ៤៩,៣ ភាគរយ នៃសាលារៀន ១ ១៣៨ បានបរិភោគអាហារពេលព្រឹក និងសិស្ស ១២ ៦៣២ នាក់ ស្រី ៥០ ភាគរយ នៃសាលា ៥៩ បានបរិភោគអាហារពេលព្រឹកប្រើប្រាស់កសិផលក្នុងសហគមន៍ ដោយសហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក
- អាហារូបករណ៍ជាថវិកា និងសម្ភារៈសិក្សាដល់កុមារលើសអាយុ កុមារមកពីគ្រួសារក្រីក្រ កុមារពិការ កុមារជនជាតិដើមភាគតិច កុមាររស់នៅតាមចិញ្ចើមថ្នល់ក្នុងរាជធានីភ្នំពេញ និង ២១ខេត្តមានកុមារ ២២ ៨៧៨ នាក់ ស្រី ៤៨ ភាគរយ ដោយសហការជាមួយគម្រោងដៃគូរួមគ្នាផ្តល់ឱកាសអប់រំដល់កុមារបាត់បង់ឱកាសនៅកម្ពុជា ក្រោមការសម្របសម្រួលរបស់អង្គការអេដអេអាក់ស្យុងក្នុងក្របខណ្ឌ ៥០ ០០០ នាក់ ស្រី ៣៥ ភាគរយ
- អាហារសម្រន់រាល់ថ្ងៃចំនួន ៧៣ សាលា ក្នុងខេត្តកំពង់ឆ្នាំង មានសិស្ស និងគ្រូ ២០ ០០០ នាក់ ស្រី ៤៦ ភាគរយ និងផ្តល់អាហារូបករណ៍ជាស្បៀងដល់សិស្ស ២ ៤៧៤ នាក់ ស្រី ៥៥ ភាគរយ ក្រៅពីនោះ ក៏បានផ្តល់របបស្បៀងលើកទឹកចិត្តដល់គ្រូទាំងអស់ដែលស្នាក់នៅផ្ទះគ្រូ (អ្នកផ្ទះឆ្ងាយ) និងគ្រូដែលមានវត្តមានបង្រៀនបានទៀងទាត់ ដោយសហការជាមួយកម្មវិធីអាហារសម្រាប់ការអប់រំរបស់អង្គការអភិវឌ្ឍន៍និងសង្គ្រោះអន្តរជាតិ ក្រោមជំនួយឧបត្ថម្ភក្រសួងកសិកម្មសហរដ្ឋអាមេរិកតាមរយៈការអនុវត្តកម្មវិធីស្បៀងអាហារតាមសាលារៀន។

*ប្រការនេះ បានជួយកុមារមកពីគ្រួសារក្រីក្របានចូលរៀន និងរៀនទៀងទាត់ចប់ភូមិសិក្សា និងឆ្លងភូមិសិក្សាទទួលបានលទ្ធផលល្អ។*

## *ការអប់រំសុខភាព*

ក្រសួងបាន ៖

- ប្រារព្ធទិវាលាងសម្អាតដៃនៅសាលាបឋមសិក្សាកំពតក្រុង ខេត្តកំពត ដោយមានការចូលរួមពីបុគ្គលិកអប់រំថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ ស្ថាប័នពាក់ព័ន្ធ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ៧០០ នាក់ ស្រី ៥២ ភាគរយ
- បំប៉នពីការអប់រំបង្ការជំងឺគ្រុនចាញ់ដល់គ្រូបឋមសិក្សា ៣៦៩ ស្រី ៥១ ភាគរយ នៅខេត្តបាត់ដំបង និងសៀមរាប
- ផ្តល់សម្ភារៈអនាម័យរួមមាន សាប៊ូ ច្រាស និងថ្នាំដុសធ្មេញ សម្រាប់អនុវត្តការលាងសម្អាតដៃ និងដុសសម្អាតមាត់ធ្មេញដល់សិស្សថ្នាក់ទី៣ និងទី៤ នៅតាមសាលាបឋមសិក្សា ១៦៤ ក្នុងខណ្ឌទាំង ១២ នៃរាជធានីភ្នំពេញ ដោយមានការចូលរួមពីលោកគ្រូ អ្នកគ្រូ និងសិស្ស ៦៤ ៥១៩ នាក់ ស្រី ៤៦ ភាគរយ
- បើកវគ្គប្រឡងប្រណាំង ស្តីពីការចម្អិនអាហារដែលមានសុវត្ថិភាព និងអនាម័យនៅតាមសាលាបឋមសិក្សាមួយចំនួនដែលអនុវត្តកម្មវិធីអាហារពេលព្រឹកក្នុងស្រុកទាំង ១១ នៃខេត្តសៀមរាបដោយមានអ្នកចូលរួម ៧៦២ នាក់ ស្រី ៥២ ភាគរយ
- ព្រាងខ្លឹមសារលម្អិតមុខវិជ្ជា "អប់រំសុខភាព" ចាប់ពីថ្នាក់ទី១ ដល់ទី៦ សម្រាប់កម្មវិធីសិក្សាថ្នាក់ជាតិ
- ផ្តល់ប្រអប់សង្គ្រោះបឋម និងសម្ភារៈ រួមទាំងសៀវភៅណែនាំ ស្តីពីវិធីសាស្ត្រសង្គ្រោះបឋមចំនួន ២២៤ ប្រអប់ ដោយថវិកាកម្មវិធី និង ១០០០ ប្រអប់ ដោយគម្រោងគាំទ្រវិស័យអប់រំទី២។ បច្ចុប្បន្នប្រអប់ និងសម្ភារៈ រួមទាំងសៀវភៅណែនាំស្តីពីវិធីសាស្ត្រសង្គ្រោះបឋម ៤ ៨៣៣ ប្រអប់ ស្មើនឹង ៦៨២ ភាគរយ នៃចំនួនសាលាបឋមសិក្សាសរុប ក្នុងនោះថវិកាកម្មវិធីមាន ១ ២២៣ ប្រអប់ ផ្តល់ដោយសប្បុរសជន និងថវិកាសាលាផ្ទាល់ ៦១០ ប្រអប់ និងគម្រោងគាំទ្រវិស័យអប់រំទី២ ចំនួន ៣ ០០០ ប្រអប់។ សាលាដែលទទួលបានប្រអប់សង្គ្រោះបឋម បានប្រើប្រាស់ថវិកាដំណើរការសាលារៀនក្នុងការបំពេញបន្ថែមនូវសម្ភារៈផងដែរ។ សាលាបឋមសិក្សាតាមរាជធានី ខេត្តដែលមានប្រអប់សង្គ្រោះបឋម ១០០ ភាគរយ រួមមាន រាជធានីភ្នំពេញ ខេត្តប៉ៃលិន កំពង់ឆ្នាំង កំពត ព្រះសីហនុ កែប និងព្រះវិហារ
- តម្រង់ទិសស្តីពីការអនុវត្តកម្មវិធីលាងសម្អាតដៃ និងដុសសម្អាតមាត់ធ្មេញ នៅតាមសាលាបឋមសិក្សា ដែលមាននាយកសាលា លោកគ្រូ អ្នកគ្រូ និងសហគមន៍ ១ ៦៦៨ នាក់ ស្រី ៤៧ ភាគរយ នៅតាមសាលាបឋមសិក្សា ១៤៦ កន្លែង ក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង កំពង់ធំ តាកែវ និងក្រចេះ មានសិស្ស ៩៥ ៦១៨ នាក់ ស្រី ៥៥ ភាគរយ
- សង់បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ និងប្រព័ន្ធទឹកស្អាតដល់សាលាបឋមសិក្សា ២១៦កន្លែងនៅគ្រប់រាជធានី ខេត្ត

- ពិគ្រោះយោបល់ពីលក្ខខណ្ឌអប្បបរមា ស្តីពីទឹកស្អាតនិងអនាម័យតាមសាលារៀន ដល់នាយកសាលា លោកគ្រូ អ្នកគ្រូ និងសហគមន៍ ១ ៥៥៣ នាក់ ស្រី ២៧ ភាគរយ នៅតាមសាលាបឋមសិក្សា ២១០ ក្នុងរាជធានីភ្នំពេញ ខេត្តតាកែវ ក្រចេះ កំពង់ឆ្នាំង កំពង់ធំ និងកំពត
- ទទួលសៀវភៅ "ការវិវត្តទៅជាក្មេងប្រុសពេញវ័យ" ៥១ ៣៥១ ក្បាល ពីអង្គការយូនីសេហ្វ និងបានបែងចែកដល់សិស្សប្រុសថ្នាក់ទី៥ និងទី៦ នៃសាលាបឋមសិក្សាក្នុងខេត្តប៉ៃលិន កំពង់ឆ្នាំង ព្រះសីហនុ ពោធិ៍សាត់ និងបន្ទាយមានជ័យ
- ពិនិត្យសុខភាព និងកាយសម្បទាដល់គរុសិស្សនៅតាមសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ១ ៣៣៦ នាក់ ស្រី ៥៥ ភាគរយ
- បំប៉នស្តីពីសុខភាពបន្តពូជ សុខភាពផ្លូវភេទ ព្រមទាំងការបង្ការជំងឺអេដស៍ និងគ្រឿងញៀនដល់លោកគ្រូ អ្នកគ្រូថ្នាក់ទី៥ និងទី៦ ចំនួន ៧៩៤ នាក់ ស្រី ២៨ ភាគរយ ដោយសហការជាមួយអង្គការវ៉ាក់
- ពិនិត្យសុខភាព និងកាយសម្បទាសិស្សានុសិស្សថ្នាក់ទី១ នៅខេត្តកំពង់ឆ្នាំង កំពត កែប ប៉ៃលិន និងខេត្តតាកែវ ១ ០៣០ សាលា មានសិស្ស ៤៧ ១៥៩ នាក់ ស្រី ៨៥,៥ ភាគរយ នៃសិស្សសរុប ដោយសហការជាមួយមន្ត្រីសុខាភិបាល
- ផ្តល់ថ្នាំទម្លាក់ព្រូនដល់សិស្សនៅតាមសាលាបឋមសិក្សាទូទាំងប្រទេសចំនួន ២ លើកក្នុងមួយឆ្នាំ ដោយសហការជាមួយក្រសួងសុខាភិបាល ។

*ប្រការនេះ បានជួយលើកកម្ពស់សុខភាពសិស្សសំដៅធានាការសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាព។*

## *ការវិភាគអត្រាលំហូរសិស្ស*

អត្រាឡើងថ្នាក់នៅបឋមសិក្សាបានកើនដល់ ៨៨,៧ ភាគរយ ស្រី ៩១,១ ភាគរយ និងប្រុស ៨៦,៥ ភាគរយ។ អត្រាត្រួតថ្នាក់បានថយមកត្រឹម ៦,៦ ភាគរយ ស្រី ៥,១ ភាគរយ និងប្រុស ៨,១ ភាគរយ។ អត្រាបោះបង់ការសិក្សាបានថយមកត្រឹម ៤,៦ ភាគរយ ស្រី ៣,៨ ភាគរយ និងប្រុស ៥,៥ ភាគរយ។

**តារាងទី៤ ៖ អត្រាលំហូរសិស្សនៅបឋមសិក្សា រវាងឆ្នាំសិក្សា ភូមិសាស្ត្រ និងយេនឌ័រ**

| | | អត្រាលំហូរ (សរុប) | | | អត្រាលំហូរ (ស្រី) | | | អត្រាលំហូរ (ប្រុស) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ |
| ២០១៥-១៦ | ថ្នាក់ជាតិ | ៨៨,៧ | ៦,៦ | ៤,៦ | ៩១,១ | ៥,១ | ៣,៨ | ៨៦,៥ | ៨,១ | ៥,៥ |
| | ប្រជុំជន | ៩១,៣ | ៤,៦ | ៤,០ | ៩៣,៧ | ៣,៤ | ២,៩ | ៨៩,១ | ៥,៨ | ៥,១ |
| | ជនបទ | ៨៨,២ | ៧,០ | ៤,៨ | ៩០,៦ | ៥,៥ | ៣,៩ | ៨៥,៩ | ៨,៥ | ៥,៥ |
| ២០១៤-១៥ | ថ្នាក់ជាតិ | ៨៧,០ | ៦,៧ | ៦,២ | ៨៩,៤ | ៥,៣ | ៥,២ | ៨៤,៧ | ៨,១ | ៧,២ |
| | ប្រជុំជន | ៩០,៩ | ៤,៦ | ៤,៥ | ៩៣,២ | ៣,៤ | ៣,៥ | ៨៨,៨ | ៥,៨ | ៥,៥ |
| | ជនបទ | ៨៦,៣ | ៧,២ | ៦,៦ | ៨៨,៧ | ៥,៧ | ៥,៦ | ៨៤,០ | ៨,៥ | ៧,៥ |

### *ការវិភាគអត្រាបញ្ចប់ការសិក្សា*

អត្រាបញ្ចប់ការសិក្សាបឋមសិក្សាបានថយមកត្រឹម ៧៩,៨៧ ភាគរយ ស្រី ៨៣,២២ ភាគរយ និង ប្រុស ៧៦,៧១ ភាគរយ។ លំនាំនៃការថយចុះអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាមានសភាពដូចគ្នានៅថ្នាក់ជាតិ តំបន់ប្រជុំជន និងតំបន់ជនបទ។

**តារាងទី៥ ៖ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សារវាងឆ្នាំសិក្សា ភូមិសាស្ត្រ និងយេនឌ័រ**

| | អត្រាបញ្ចប់ការសិក្សា ២០១៥-២០១៦ | | | អត្រាបញ្ចប់ការសិក្សា ២០១៦-២០១៧ | | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស |
| ថ្នាក់ជាតិ | ៨០,៦២ | ៨៣,៩៧ | ៧៧,៤៥ | ៧៩,៨៧ | ៨៣,២២ | ៧៦,៧១ |
| ប្រជុំជន | ៧២,៦១ | ៧៥,២១ | ៧០,២១ | ៧១,០៣ | ៧៤,០១ | ៦៨,២៨ |
| ជនបទ | ៨២,៥០ | ៨៦,០០ | ៧៩,១៨ | ៨១,៩៨ | ៨៥,៣៨ | ៧៨,៧៤ |

### *ការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន*

ក្រសួងបាន ៖

- បញ្ចប់ការបណ្តុះបណ្តាលគ្រូបឋមសិក្សា១២+២ និង៩+២ ចំនួន ៣ ២៤៤ នាក់ ស្រី ៦៥,៦ ភាគរយ និងកំពុងបណ្តុះបណ្តាល ១ ៧៨៣ នាក់ ស្រី ៦១,៣ ភាគរយ
- ប្រឡងជ្រើសរើសគ្រូបឋមសិក្សា ១២+២ ចំនួន ១ ៥១៣ នាក់ ស្រី ៦២ ភាគរយ
- បណ្តុះបណ្តាលបំណិនវិជ្ជាជីវៈ ការគ្រប់គ្រងរដ្ឋបាលជូនគណៈគ្រប់គ្រង ៦១៨ នាក់ ស្រី ១៧,៨ ភាគរយ
- បំប៉នគ្រូឧទ្ទេស ៣៨៤ នាក់ ស្រី ៩១,១ ភាគរយ និងបានបោះពុម្ពឯកសារសម្រាប់បំប៉នគ្រូកម្រិតមូលដ្ឋាន ៧ ៨៤៧ ក្បាល
- បំប៉នគ្រូបង្រៀនថ្នាក់ទី៤ ចំនួន ១ ២៩៧ នាក់ ស្រី ៤៤,៩ ភាគរយ ស្តីពីវិធីសាស្ត្របង្រៀនភាសាអង់គ្លេស
- បំប៉ននាយក គ្រូបង្រៀនថ្នាក់ទី១ ទី២ និងទី៣ និងអ្នកពាក់ព័ន្ធ ១ ៧៥៨ នាក់ ស្រី ៥៨,៤ ភាគរយ នៅតាមក្រុង ស្រុក ខណ្ឌមួយចំនួនក្នុងរាជធានីភ្នំពេញ ខេត្តកំពត កណ្តាល ព្រះវិហារ និងកំពង់ចាម ស្តីពីវិធីសាស្ត្របង្រៀនភាសាខ្មែរថ្នាក់ដំបូង
- ណែនាំស្តីពីវិធីសាស្ត្រប្រមូលកុមារក្រៅសាលារួមទាំងកុមារពិការដល់នាយកសាលាបឋមសិក្សា ៩៧១ នាក់ ស្រី ១២,៣ ភាគរយ នៅខេត្តបន្ទាយមានជ័យ ក្រចេះ និងកំពត
- បំប៉នស្តីពីស្តង់ដាអំណានថ្នាក់ទី១-៣ ដល់គ្រូបង្រៀនបឋមសិក្សា ១២៣ នាក់ ស្រី ៤៩,៦ ភាគរយ
- បំប៉នស្តីពីការផលិតសម្ភារឧបទេសជូនគ្រូឧទ្ទេស ២៩ នាក់ ស្រី ៣៤,៥ ភាគរយ
- បំប៉នស្តីពីការអភិវឌ្ឍវិជ្ជាជីវៈគ្រូឧទ្ទេសលើការប្រើប្រាស់ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ជូនគ្រូឧទ្ទេស និងគ្រូបង្រៀនសាលាបឋមសិក្សា ៣០២ នាក់ ស្រី ៧៥,៥ ភាគរយ

- បំប៉នស្តីពីវិធីសាស្ត្រផ្តល់ព័ត៌មានត្រឡប់ ផ្សព្វផ្សាយបទបញ្ញត្តិកម្មសិក្សាគរុកោសល្យជូនគ្រូបឋមសិក្សា ៣១៨ នាក់ ស្រី ៦៥,៧ ភាគរយ
- ពិគ្រោះយោបល់ថ្នាក់ជាតិ និងថ្នាក់តំបន់ ស្តីពីស្តង់ដាសាលាបឋមសិក្សាដល់បុគ្គលិកអប់រំ និងនាយកសាលា ២៧៣ នាក់ ស្រី ១៥ ភាគរយ
- បំប៉នឯកសារជំនួយការបង្រៀនគណិតវិទ្យាថ្នាក់ដំបូងដល់គ្រូថ្នាក់ទី១ ទី២ ទី៣ ចំនួន ១ ១៥៤នាក់ ស្រី ៦០,៥ ភាគរយ
- បំប៉នវិន័យបែបវិជ្ជមានដល់នាយកសាលា គ្រូបង្រៀន ១ ៨៤៨ នាក់ ស្រី ៤៤,៩ ភាគរយ
- បំប៉នបញ្ជីពិនិត្យតាមដានដល់ក្រុមពិនិត្យតាមដាន និងក្រុមបំប៉នថ្នាក់ស្រុក ១១៩ នាក់ ស្រី ១០,៨ ភាគរយ
- បណ្តុះបណ្តាលជាតំណាក់កាលៗដល់គ្រូ ៣ ៩៦១ នាក់ ស្រី ៣៥ ភាគរយ នៅតាមសាលារៀនគោលដៅ ១ ០៩៤ សាលា សហការជាមួយគម្រោងដៃគូរួមគ្នាផ្តល់ឱកាសអប់រំដល់កុមារបាត់បង់ឱកាសនៅកម្ពុជា
- បណ្តុះបណ្តាលវិធីសាស្ត្រប្រើប្រាស់សម្ភារៈជំនួយក្នុងការអាន និងសៀវភៅសិក្សាគោលក្នុងការបង្រៀនភាសាខ្មែរថ្នាក់ទី១ និងទី២ ដល់បុគ្គលិកអប់រំស្រុក នាយកសាលា គ្រូថ្នាក់ទី១ ទី២ ចំនួន ៥២០ នាក់ ស្រី ២៨,២ ភាគរយ មកពី ១៦៩ សាលា នៅក្នុងខេត្តសៀមរាប បន្ទាយមានជ័យ កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ និងព្រៃវែង និងបណ្តុះបណ្តាលគ្រូពីថ្នាក់ទី១-៦ អំពីរបៀបដឹកនាំសិស្សធ្វើសកម្មភាពអំណាននានា ១ ៣៩៥ នាក់ ស្រី ៤៤,៤ ភាគរយ ដោយសហការជាមួយអង្គការរូមធូរីដ
- បំប៉នគ្រូបង្រៀន ២៤៨ នាក់ ស្រី ៣៩,៦ ភាគរយ និងគ្រូសហគមន៍ ៣៧ នាក់ ស្រី ៧៣ ភាគរយ ស្តីពីស្តង់ដាអំណាន វិធីសាស្ត្របង្រៀនតាមបែបសាលាកុមារមេត្រី គោលវិធីសិស្សមជ្ឈមណ្ឌល ការរៀនតាមបែបសហការ និងវិធីបង្រៀនឆ្លើយតបទៅតាមតម្រូវការសិស្ស ដោយសហការជាមួយអង្គការឆាលហ្វានកម្ពុជា និងអង្គការខេប។

*ប្រការនេះ បានជួយអភិវឌ្ឍសមត្ថភាពនាយកសាលា គ្រូបង្រៀនឱ្យកាន់តែមានគុណភាព ដើម្បីឆ្លើយតបនឹងកំណែទម្រង់វិស័យអប់រំ។*

## *ការងារអភិវឌ្ឍកម្មវិធីសិក្សា*

ក្រសួងបាន៖

- អនុម័តក្របខណ្ឌកម្មវិធីសិក្សាថ្មី និង អភិវឌ្ឍកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាថ្នាក់ទី១ ដល់ទី៦ និងឯកសារវិធីសរសេរតែងសេចក្តីថ្នាក់ទី៣ ដល់ទី៦
- ផ្តត់ផ្គង់សៀវភៅសិក្សាគោល ៥ ២៦៨ ០០០ ច្បាប់ ដល់សាលារៀនទូទាំងប្រទេសស្របតាមផលធៀបសៀវភៅ-សិស្ស១:១ នៅថ្នាក់ទី១-៣ សិស្សម្នាក់ទទួលបាន ៣ក្បាល (ចំណុចដៅ៣)

ថ្នាក់ទី៤-៥ សិស្សម្នាក់ទទួលបាន ៥ក្បាល និងនៅថ្នាក់ទី៦ សិស្សម្នាក់ទទួលបាន ៤ ក្បាល (ចំណុចដៅ ៨)

- អនុម័តសៀវភៅភាសាអង់គ្លេសថ្នាក់ទី៥ និងទី៦
- អនុម័តឯកសារទស្សនាទានស្តីពីការបង្រៀន និងរៀនពេញមួយថ្ងៃ ។

*ប្រការនេះ បានជួយដល់ការរៀន និងបង្រៀនឱ្យសិស្សមានសៀវភៅអានគ្រប់ៗគ្នា ដើម្បីធានាដល់គុណភាពសិក្សារបស់សិស្ស។*

## *ការងារបណ្ណាល័យ*

សាលារៀនមានបណ្ណាល័យ ៣ ៥៥២ ក្នុងនោះ ជាអគារ ៦៧៣ ជាបន្ទប់ ២ ៣២៦ ជាទីចាត់ការ ៧៦៤ ជាជ្រុងថ្នាក់ ១៧៥ និងចល័ត ៨០។

ក្រសួងបាន៖

- បោះពុម្ពសៀវភៅស្តង់ដាបណ្ណាល័យបឋមសិក្សា ២៧ ០០០ ក្បាល និងចែកចាយដល់មន្ទីរ ការិយាល័យស្រុក ខណ្ឌ ក្រុង សាលាបឋមសិក្សា និងសាលាគរុកោសល្យ និងវិក្រឹតការទូទាំងប្រទេស
- អភិវឌ្ឍសេចក្តីព្រាងគោលការណ៍ណែនាំ និងឯកសារជំនួយស្តីពី ការជំរុញការអានតាមសាលារៀន
- បំប៉នបណ្ណារក្ស ២ ២៣៥ នាក់ ស្រី ៥៥,៣ ភាគរយ នៃបណ្ណារក្សសរុប ៣ ៨៨៧ នាក់ ស្រី ៥៨,៨ ភាគរយ បំប៉នគ្រូឧទ្ទេស នាយកសាលា និងបណ្ណារក្ស ២២០ នាក់ ស្រី ៤៨,២ ភាគរយ ស្តីពីការងារគ្រប់គ្រង និងស្តង់ដាបណ្ណាល័យបឋមសិក្សា
- បំប៉នមន្រ្តីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៣៣០ នាក់ ស្រី ២៨,៤ ភាគរយ ស្តីពីវិធីគូរគំនូរនៅបឋមសិក្សា
- ផ្តល់សៀវភៅអាន ៤ ១៦៥ ក្បាល ដល់បណ្ណាល័យនិងសកម្មភាពអំណាននៅ ១៧ សាលានៅខេត្តស្វាយរៀង និងក្រចេះ ដោយសហការជាមួយអង្គការអេឌូកូ
- បណ្តុះបណ្តាលអ្នកនិពន្ធ ៣៨ នាក់ រៀបចំពិព័រណ៍សៀវភៅថ្នាក់ជាតិលើក ទី៥ សាងសង់ និងជួសជុលអគារសិក្សា ២១ ខ្នង ស្មើនឹង ១០៨ បន្ទប់ និងបង្កើតបណ្ណាល័យថ្មី ៩៦ សាលា និងបន្តគាំទ្របណ្ណាល័យឆ្នាំចាស់ ១៥៧ សាលា ដោយសហការជាមួយអង្គការរូមធូរីដ
- សាងសង់អគារ ជួសជុលបន្ទប់បណ្ណាល័យ ២០ ក្នុងខេត្តស្វាយរៀង ក្រចេះ និងបំប៉នបណ្ណារក្ស ១១០ នាក់ ស្រី ២៩,១ ភាគរយ ដោយសហកាជាមួយអង្គការឆាលហ្វានកម្ពុជា និងអង្គការខេប
- សាងសង់អគារសិក្សា ៥ខ្នង បណ្ណាល័យស្តង់ដា ៤ បន្ទប់ ជួសជុលបន្ទប់រៀន និងបណ្ណាល័យ ២៣៩ បន្ទប់ ដោយសហការជាមួយកម្មវិធីដៃគូរួមគ្នាផ្តល់ឱកាសអប់រំដល់កុមារបាត់បង់ឱកាសនៅកម្ពុជា

- បង្កើតបណ្ណាល័យអេឡិត្រូនិចក្នុង ១០ សាលា ដើម្បីការរៀន និងបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិក ដោយសហការជាមួយអង្គការអេដអេអាក់ស្យុង
- អនុវត្តសកម្មភាពអំណានគ្រួសារ ដែលគាំទ្រដល់ទិវាអំណានជាតិនៅតាមសាលារៀន ២៥៣ ដោយសហការជាមួយអង្គការរូមធូរីដ។

*ប្រការនេះ បានធ្វើឱ្យសកម្មភាពអំណាននៅតាមបណ្ណាល័យត្រូវបានពង្រឹង ព្រមទាំងពង្រីកកម្មវិធីបំណិនអាន និងសរសេរ ដើម្បីបណ្តុះទម្លាប់អានដល់កុមារនៅសាលាបឋមសិក្សា។*

## *ការពិនិត្យតាមដាននិងវាយតម្លៃ*

ក្រសួងបាន៖

- ស្រាវជ្រាវការបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ ដល់ទី៦ និងវិធីសាស្ត្របង្រៀនបឋមសិក្សាដើម្បីជំរុញកម្មវិធីអំណានដំបូង
- ធ្វើអង្កេតថ្នាក់ ណែនាំគរុកោសល្យ ធ្វើថ្នាក់និទស្សន៍ ប្រជុំបច្ចេកទេស សម្ភាសន៍ជាមួយគ្រូបង្រៀនលើការប្រើប្រាស់សៀវភៅភាសាខ្មែរថ្នាក់ទី១ ទី២ និងទី៣
- ធ្វើតេស្តសិស្សលើការអាននិងសរសេរនៅតាមសាលារៀនគោលដៅ ៣៥៣ និងធ្វើតេស្តល្បឿនអំណាននៅដើមឆ្នាំ និងចុងឆ្នាំសិក្សាសម្រាប់សិស្សថ្នាក់ទី១ ទី២ ទី៣ និងទី៦ នៅតាមសាលាគោលដៅ ៣៦
- ជួយគ្រូបង្រៀនថ្នាក់ទី១ ទី២ និងទី៣ អំពីការបង្រៀន និងការផលិតសម្ភារឧបទេសនៃកម្មវិធីគណិតវិទ្យាថ្នាក់ដំបូងនៅតាមសាលារៀនគោលដៅ ១៤០
- ពិនិត្យតាមដានការអនុវត្តស្តង់ដាបណ្ណាល័យបឋមសិក្សា ១៨ សាលា ក្នុងខេត្ត១០ និងការប្រើប្រាស់សៀវភៅសិក្សាគោល ៨ខេត្ត និងពិនិត្យការវាយតម្លៃលើការដឹកនាំ និងគ្រប់គ្រងសាលារៀនផ្អែកលើគោលការណ៍អភិបាលកិច្ចល្អនៅក្នុងខេត្ត ១០
- ពិនិត្យតាមដាន និងជួយនាយកសាលាក្នុងការប្រើឧបករណ៍ និងវាយតម្លៃផ្អែកលើលទ្ធផលអនុវិស័យបឋមសិក្សាទូទាំងប្រទេស
- ផ្សព្វផ្សាយរបាយការណ៍លទ្ធផលតេស្តថ្នាក់ជាតិថ្នាក់ទី៣ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា
- សរសេរវិញ្ញាសាតេស្ត បោះពុម្ពសៀវភៅតេស្ត និងធ្វើតេស្តថ្នាក់ទី៦ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាបាន ២២៨ សាលា ក្នុងនោះសាលារដ្ឋ ២១០ សាលា និងសាលាឯកជន ១៨ សាលា
- ពង្រឹងការដឹកនាំ និងគ្រប់គ្រងសាលាបឋមសិក្សា ១៣ ក្នុងខេត្តក្រចេះ ដោយសហការជាមួយអង្គការអេឌូកូ
- ផ្តល់ឱកាសអប់រំដល់កុមារបាត់បង់ឱកាសនៅកម្ពុជាជួយពង្រឹងការដឹកនាំ និងគ្រប់គ្រងសាលាបឋមសិក្សា១៩៤ ក្នុង ២២ រាជធានីខេត្ត ដោយសហការជាមួយគម្រោងដៃគូរួមគ្នា។

*ប្រការនេះ បានជួយជំរុញឱ្យការរៀន និងបង្រៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព ។*

## ក.២ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

ក្រសួងបាន៖

- បំប៉នគណៈគ្រប់គ្រងសាលារៀន ១៩០ នាក់ ស្រី ១១ ភាគរយ ស្តីពីអភិបាលកិច្ចសម្រាប់ពង្រឹងការផ្តល់សេវាអប់រំ
- បំប៉នគណៈគ្រប់គ្រងសាលារៀន ៣៥ នាក់ ស្រី ១៤,៣ ភាគរយ ស្តីពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល
- អភិវឌ្ឍសមត្ថភាពស្តីពីការដឹកនាំគ្រប់គ្រងសាលារៀន អភិបាលកិច្ចសាលា ការកសាងផែនការនិងថវិកា ស្តង់ដាទាំង៩ នៃការវាយតម្លៃគុណភាពអប់រំគ្រូបង្រៀន ដល់គណៈគ្រប់គ្រងសាលា ៥ ០០០ នាក់ ក្នុងសាលារៀន ១ ២០០ ដើម្បីយកចិត្តទុកដាក់ផ្តោតលើគុណភាពនៃការអប់រំ និងគាំទ្រដល់កុមារបាត់បង់ឱកាសអប់រំ ដោយសហការជាមួយអង្គការ២៣ នៃកម្មវិធីដៃគូរួមគ្នាផ្តល់ ឱកាសអប់រំដល់កុមារបាត់បង់ឱកាសនៅកម្ពុជា អង្គការឆាលហ្វានកម្ពុជា និងអង្គការអេឌូកូ ។

*ប្រការនេះ បានជួយដល់កុមារបាត់បង់ឱកាសបានចូលរៀនប្រកដោយសមធម៌។*

### *ការចូលរួមរបស់សហគមន៍*

ក្រសួងបាន៖

- ដឹកនាំគណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា ២០៨ នាក់ ស្រី ១៨,៣ ភាគរយ មកពីខេត្ត ១១ ធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធ នៅសាលាបឋមសិក្សាវត្តបូព៌ មុខនាគ ទៀបាញ់គំរូ និងចំបក់ហែរ ក្នុងខេត្តសៀមរាប
- ប្រជុំបូកសរុបសាលាកុមារមេត្រី និងសហគមន៍ចូលរួមអភិវឌ្ឍវិស័យអប់រំប្រចាំឆ្នាំ មានអ្នកចូលរួម ១៣៨ នាក់ ស្រី ២០,៣ ភាគរយ
- បំប៉នសមត្ថភាពគណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា ស្តីពីការអនុវត្តតួនាទីភារកិច្ចរបស់គណៈកម្មការ ១ ៣៥១នាក់ ស្រី ៦៤,៤ ភាគរយ
- បំប៉នអំពីការអនុវត្តតួនាទី និងភារកិច្ចរបស់គណៈកម្មការទ្រទ្រង់សាលា ៣ ១១៤ នាក់ ស្រី ៣២ភាគរយ ដើម្បីជំរុញការចូលរួមរបស់មាតាបិតាលើការសិក្សារបស់សិស្សឱ្យប្រសើរឡើង នៅតាមសាលាគោលដៅ ២ ០០០ ក្នុង ២៥ រាជធានី ខេត្ត ដោយសហការជាមួយអង្គការ ២៣ នៃកម្មវិធីដៃគូរួមគ្នាផ្តល់ឱកាសអប់រំដល់កុមារបាត់បង់ឱកាសនៅកម្ពុជា អង្គការឆាលហ្វានកម្ពុជា អង្គការទស្សនៈពិភពលោក និងអេឌូកូ។

*ប្រការនេះ ជួយលើកកម្ពស់គណនេយ្យភាពសង្គមតាមសាលារៀន។*

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

ចំនួនក្រុង ស្រុក ខណ្ឌ ដែលមានអត្រាត្រួតថ្នាក់នៅបឋមសិក្សាតិចជាង ឬស្មើ ១០ ភាគរយ មាន ១៧៣ លើ ១៧៦។

*ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| | ការអប់រំបឋមសិក្សា | ជាក់ស្តែង ២០១៥-១៦ | ចំណុចដៅ ២០១៦-១៧ | ជាក់ស្តែង ២០១៦-១៧ | ស្ថានភាព |
|---|---|---|---|---|---|
| គោលនយោបាយទី ១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា | | | | | |
| ១ | អត្រាពិតចូលរៀនថ្មី | ៩៥,៩%* | ៩៧,៤% | ៩៥,១%* | → |
| | អត្រាពិតចូលរៀនថ្មី (ស្រី) | ៩៥,៤%* | ៩៧,៤% | ៩៤,០%* | → |
| ២ | អត្រាពិតនៃការសិក្សា | ៩៨,៤%* | ៩៩,០% | ៩៧,៧%* | → |
| | អត្រាពិតនៃការសិក្សា (ស្រី) | ៩៩,៣ * | ៩៩,០% | ៩៨,២% * | → |
| ៣ | អត្រាបោះបង់ការសិក្សា | ៦,២%** | ៥,៨% | ៤,៦%*** | ↑ |
| | អត្រាបោះបង់ការសិក្សា (ស្រី) | ៧,២%** | ៦,៥% | ៣,៨%*** | ↑ |
| ៤ | អត្រាបញ្ចប់ការសិក្សា | ៨០,៦% | ៨២,០% | ៧៩,៩% | → |
| | អត្រាបញ្ចប់ការសិក្សា (ស្រី) | ៨៣,៩% | ៨៤,០% | ៨៣,២% | → |
| ៥ | អត្រាត្រួតថ្នាក់ | ៦,៧%** | ៤,៤% | ៦,៦%*** | → |
| | អត្រាត្រួតថ្នាក់ (ស្រី) | ៨,១%** | ៤,៤% | ៥,១%*** | → |
| ៦ | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ | ៨២,១% | ៨៦,២% | ៨៥,៥% | ↑ |
| | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅម.បឋមភូមិ (ស្រី) | ៨៥,០% | ៨៦,២% | ៨៨,៣% | ↑ |
| ៧ | ចំនួនស្រុកដែលសម្រេចបានអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាយ៉ាងតិច ៨០% | ៩៥ | ១០៥ | ៩០ | ↓ |
| ៨ | ភាគរយសិស្សថ្មីថ្នាក់ទី ១ ដែលបានឆ្លងកាត់មត្តេយ្យសិក្សា | ៦១,៨៥% | ៦៤,១% | ៦៤,០១% | ↑ |
| ៩ | ភាគរយសាលាកុមារមេត្រីកម្រិតមធ្យម និងកម្រិតអភិវឌ្ឍ | ៧៣,៥% | ៧៦,១% | ៧៩,៣៧%**** | ↑ |
| ១០ | ភាគរយសាលាបឋមសិក្សាមាន | | | | |
| | បង្គន់អនាម័យ | ៨៥,៩% | ៨៧,០% | ៨១,៥% | → |
| | ទឹកស្អាត | ៥៨,១% | ៨៧,០% | ៥៩,១% | ↓ |
| | កន្លែងសម្អាតដៃ | ៤៧,២% | ៥០,៧% | ៦០,០% | ↑ |
| | ប្រអប់សង្គ្រោះបឋម | ៥៤,៣% | ៥៨,៩% | ៧០,០% | ↑ |
| ១១ | ចំនួនសិស្សទទួលអាហារូបករណ៍នៅបឋមសិក្សា | | ៧៥ ០០០ | ៧៧ ៦៥៤*** | ↑ |
| ១២ | ចំនួនគ្រូបង្រៀនបឋមសិក្សាទទួលការបណ្តុះបណ្តាលរូបមន្ត ១២+៤ ក្នុងឆ្នាំនីមួយៗ | n/a | n/a | អនុវត្តនៅឆ្នាំ២០១៨ | |
| ១៣ | ភាគរយគ្រូបង្រៀនបឋមសិក្សាយ៉ាងហោចណាស់មានបរិញ្ញាបត្រក្នុងឆ្នាំនីមួយៗ | ៦,៩% | ៧% | ៦,២% | → |

| | | | | | |
|---|---|---|---|---|---|
| ១៤ | ចំនួនគ្រូបង្រៀនបឋមសិក្សាបានទទួលការអភិវឌ្ឍ ជំនាញវិជ្ជាជីវៈបន្តក្នុងឆ្នាំនីមួយៗ | ១ ៥០០ | ៥០០ | ១ ៤៩២ | ↑ |
| គោលនយោបាយទី ២ ៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | |
| | N/A | | | | |

**សម្គាល់៖** ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓សម្រេចមិនបានតាមចំណុចដៅ

* រួមបញ្ចូលទាំងសាលាឯកជន ** ឆ្នាំសិក្សា២០១៤-២០១៥ ***ឆ្នាំសិក្សា២០១៥-២០១៦

**** មិនគិតសាលាបឋមសិក្សាមិនគ្រប់កម្រិត

## ៤. បញ្ហាប្រឈម

- ខ្វះគ្រូក្របខណ្ឌនៅតាមសាលារៀនជនបទ និងតំបន់ជួបការលំបាក
- សមត្ថភាពគ្រូបង្រៀនលើការអនុវត្តវិធីសាស្ត្របង្រៀននៅមានកម្រិត
- គណៈគ្រប់គ្រងសាលារៀនមិនទាន់មានសមត្ថភាពពេញលេញលើការដឹកនាំគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល
- ការសម្របសម្រួលអភិវឌ្ឍផែនការសកម្មភាព និងរបាយការណ៍រវាងក្រសួង និងដៃគូអភិវឌ្ឍមិនទាន់បានដាក់បញ្ចូលរួមគ្នាពេញលេញទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ការអនុវត្តកម្មវិធីថ្នាក់ពន្លឿននៅមិនទាន់គ្របដណ្តប់បានគ្រប់ខេត្ត
- ការបណ្តុះបណ្តាលស្តីពីការអប់រំបរិយាបន្ន វិធីសាស្ត្របង្រៀនកុមារមានពិការភាពនៅមិនទាន់បានទូលំទូលាយ
- ការអនុវត្តកម្មវិធីសិក្សា និងម៉ោងសិក្សាមិនទាន់គោរពបានពេញលេញ
- ខ្វះអគារសិក្សានៅតំបន់ជួបការលំបាក
- ហេដ្ឋារចនាសម្ព័ន្ធរូបវន្តរួមមាន ប្រព័ន្ធទឹកស្អាត បង្គន់អនាម័យ... របស់គ្រឹះស្ថានបឋមសិក្សារដ្ឋ ពុំទាន់ឆ្លើយតបទៅនឹងបរិបទបច្ចុប្បន្ន។

## ២.២.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

### ក. លទ្ធផលសម្រេចបាន

### ក.១ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ឆ្នាំសិក្សា ២០១៦-២០១៧ គ្រឹះស្ថានមធ្យមសិក្សារដ្ឋមាន ១ ៧៣១ ក្នុងនោះអនុវិទ្យាល័យ ១ ២៤៥ និងវិទ្យាល័យ ៤៨៦ (វិទ្យាល័យធនធាន ៣៦)។ វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ទី១២ មាន ៤៥៤ និងកម្រិតថ្នាក់ចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២ មាន ៣២។ អនុវិទ្យាល័យថយ ៦ និងវិទ្យាល័យកើន ២៣ ។

ឃុំ សង្កាត់ ១៣៨ លើ ១ ៦៤៦ ស្មើនឹង ៨,៤៥ ភាគរយ មិនទាន់មានអនុវិទ្យាល័យ និងស្រុក ៥ លើ ១៩៧ ស្មើនឹង ២,៥៣ ភាគរយ មិនទាន់មានវិទ្យាល័យនៅឡើយដោយសារស្ថានភាពភូមិសាស្ត្រ និងស្ថានភាពប្រជាសាស្ត្រមិនអំណោយផល ជាពិសេសនៅតាមតំបន់កោះ និងតំបន់ព្រៃភ្នំ ដែលប្រជាពលរដ្ឋរស់នៅរាយប៉ាយ។ តំបន់ទាំងនោះរួមមានស្រុកថ្មបាំង ខេត្តកោះកុង ស្រុកតាវែង អូរជុំ អូរយ៉ាដាវ និងលំផាត់ ខេត្តរតនគិរី។ ក្រសួងបានសាងសង់អគារសិក្សាថ្មីនៅតាមអនុវិទ្យាល័យដែលមានសិស្សលើសនិយាម ៩ ខ្នង និងសាងសង់អគារបន្ថែម និងបំពាក់គ្រឿងសង្ហារិមនៅក្នុងសាលាបឋមសិក្សា ដើម្បីពង្រីកទៅជាអនុវិទ្យាល័យ ៧ ខ្នង ហើយបច្ចុប្បន្ននេះ បាននិងកំពុងបន្តសាងសង់អគារសិក្សាជាបន្តបន្ទាប់ ដើម្បីឆ្លើយតបទៅនឹងបញ្ហាខ្វះអគារសិក្សានៅតាមឃុំ សង្កាត់ដែលពុំទាន់មានអនុវិទ្យាល័យ និងនៅតាមស្រុកដែលពុំទាន់មានវិទ្យាល័យ។

*៣៩ សង្កាត់ ក្នុងរាជធានីភ្នំពេញ មិនតម្រូវឱ្យបង្កើតអនុវិទ្យាល័យ ដោយសារស្ថានភាពភូមិសាស្ត្រ ចំណែកឯ ៣៦ ឃុំក្នុងខេត្តរតនគិរី មិនទាន់ទាមទារឱ្យបង្កើតអនុវិទ្យាល័យ ដោយសារកត្តាភូមិសាស្ត្រ និងប្រជាសាស្ត្រ។*

អនុវិទ្យាល័យ ១៦,៦ ភាគរយ និងវិទ្យាល័យ ៨,៨ ភាគរយ មិនទាន់មានបង្គន់អនាម័យ។ អនុវិទ្យាល័យ ៥៦,៦ ភាគរយ និងវិទ្យាល័យ ៤៦,១ ភាគរយ មិនទាន់មានទឹកស្អាត។

បុគ្គលិកអប់រំនៅមធ្យមសិក្សាមាន ៤៨ ២២០ នាក់ ស្រី ៣៨,៦៦ ភាគរយ ក្នុងនោះបុគ្គលិកអប់រំមធ្យមសិក្សាបឋមភូមិមាន ៣៣ ៧៦៣ នាក់ ស្រី ៤២,១២ ភាគរយ កើន ៥៩៩ នាក់ ស្រីកើន ៤០៩ នាក់ និងមធ្យមសិក្សាទុតិយភូមិមាន ១៤ ៤៥៧ នាក់ ស្រី ៣០,៥៩ ភាគរយ កើន ២៣ នាក់ ស្រីកើន ៨៩ នាក់។

បុគ្គលិកបង្រៀនមធ្យមសិក្សាមាន ៤១ ៤០៧ នាក់ ស្រី ៤០,៩៨ ភាគរយ កើន ៤៨៣ នាក់ ស្រីកើន ៤៦៤ នាក់ ក្នុងនោះបុគ្គលិកបង្រៀនមធ្យមសិក្សាបឋមភូមិមាន ២៨ ៧៨២ នាក់ ស្រី ៤៥,២៥ ភាគរយ កើន ៤២៨ នាក់ ស្រីកើន ៣៧០ នាក់ និងបុគ្គលិកបង្រៀនមធ្យមសិក្សាទុតិយភូមិមាន ១២ ៦២៥ នាក់ ស្រី ៣១,២៥ ភាគរយ កើន ៥៥ នាក់ ស្រីកើន ៩៤ នាក់។

គ្រូបង្រៀនចេញថ្មី ១ ៨៥៥ នាក់ ស្រី ៤៦,៤៦ ភាគរយ បានទៅសាលារៀនដែលខ្វះគ្រូ ក្នុងនោះនៅអនុវិទ្យាល័យ ៩៨៤ នាក់ ស្រី ៥៣,០៤ ភាគរយ និងនៅវិទ្យាល័យ ៨៧១ នាក់ ស្រី ៣៩,០៣ ភាគរយ។

*បុគ្គលិកអប់រំ និងបុគ្គលិកបង្រៀនកើន ស្របតាមកំណើនសិស្ស ទាំងនៅមធ្យមសិក្សាបឋមភូមិ ទាំងនៅមធ្យមសិក្សាទុតិយភូមិ ជាពិសេសកំណើនភេទស្រី ដែលបញ្ជាក់ពីការយកចិត្តទុកដាក់លើយេនឌ័រ។*

សិស្សមធ្យមសិក្សាបឋមភូមិរដ្ឋមាន ៥៨៥ ៩៧១ នាក់ ស្រី ៥១,៨១ ភាគរយ កើន ២៧ ៣៥០ នាក់ ស្រីកើន ១៨ ១៦៧ នាក់។ សិស្សមធ្យមសិក្សាបឋមភូមិឯកជនមាន ២២ ៩៨៤ នាក់ ស្រី ៤៩,៤៧ ភាគរយ។

អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៥៧,៦ ភាគរយ កើន ១,១ ភាគរយ ស្រី ៦១,៥ ភាគរយ កើន ២,១ ភាគរយ ក្នុងនោះអត្រារួមនៃការសិក្សាមធ្យមសិក្សាបឋមភូមិរដ្ឋ ៥៥,៧ ភាគរយ ស្រី ៥៩,៦ ភាគរយ និងអត្រារួមនៃការសិក្សាមធ្យមសិក្សាបឋមភូមិឯកជន ១,៩ ភាគរយ ស្រី ១,៩ ភាគរយ។

អត្រាឆ្លងភូមិសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ ៨៥,៥ ភាគរយ កើន ៣,៤ ភាគរយ ស្រី ៨៨,៤ ភាគរយ កើន ៣,៤ ភាគរយ។ អត្រាឆ្លងភូមិសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ ៧៤,៥ ភាគរយ កើន ២,១ ភាគរយ ស្រី ៧៧,៧ ភាគរយ កើន ៣,១ ភាគរយ។

សិស្សមធ្យមសិក្សាទុតិយភូមិរដ្ឋមាន ២៧៩ ៤៨០ នាក់ ស្រី ៥១,៣៣ ភាគរយ កើន ១៣ ០៣១ នាក់ ស្រី ៥ ០៦៤ នាក់។ សិស្សមធ្យមសិក្សាទុតិយភូមិឯកជន ១៧ ២៤៤ នាក់ ស្រី ៤៨,២៦ ភាគរយ។

អត្រារួមនៃការសិក្សាមធ្យមសិក្សាទុតិយភូមិ ២៦,៥ ភាគរយ ស្រី ២៨,១ ភាគរយ ក្នុងនោះអត្រារួមនៃការសិក្សាមធ្យមសិក្សាទុតិយភូមិរដ្ឋ ២៥,១ ភាគរយ ស្រី ២៦,៧ ភាគរយ និងអត្រារួមនៃការសិក្សាមធ្យមសិក្សាទុតិយភូមិឯកជន ១,៤ ភាគរយ ស្រី ១,៤ ភាគរយ។

*ប្រការនេះបញ្ជាក់ឱ្យឃើញថា ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត កម្មវិធីអាហារូបករណ៍ ... គួបផ្សំនឹងការចូលរួមរបស់សហគមន៍ធ្វើឱ្យអត្រាឆ្លងភូមិសិក្សាកើន ទាំងមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។*

**តារាងទី៦ ៖ ស្ថិតិមធ្យមសិក្សា ប្រៀបធៀបរវាងឆ្នាំសិក្សា ២០១៥-២០១៦ និង២០១៦-២០១៧**

| បរិយាយ | ២០១៥-២០១៦ | ២០១៦-២០១៧ | កើន/ថយ (+/-) |
|---|---|---|---|
| **អនុវិទ្យាល័យ** | | | |
| សាលារៀន | ១ ២៥១ | ១ ២៤៥ | -៦ |
| បន្ទប់រៀន | ៦ ៦៤០ | ៦ ៧០៤ | +៦៦ |
| បុគ្គលិកអប់រំនៅអនុវិទ្យាល័យសរុប | ១៨ ៣៤៧ | ១៨ ២៥២ | -៩៥ |
| បុគ្គលិកអប់រំនៅអនុវិទ្យាល័យស្រី | ៧ ៣០៨ | ៧ ៣៧២ | +៦៤ |
| ថ្នាក់រៀនមធ្យមសិក្សាបឋមភូមិ | ១២ ៥៩០ | ១២ ៨៣៨ | +២៤៨ |
| បុគ្គលិកអប់រំមធ្យមសិក្សាបឋមភូមិសរុប | ៣៣១៦៤ | ៣៣៧៦៣ | +៥៩៩ |
| បុគ្គលិកអប់រំមធ្យមសិក្សាបឋមភូមិស្រី | ១៣៨១១ | ១៤២២០ | +៤០៩ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាបឋមភូមិសរុប | ២៨៣៥៤ | ២៨៧៨២ | +៤២៨ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាបឋមភូមិស្រី | ១២៦៥៦ | ១៣០២៦ | +៣៧០ |
| សិស្សមធ្យមសិក្សាបឋមភូមិរដ្ឋសរុប | ៥៥៨ ៦២១ | ៥៨៥ ៩៧១ | +២៧ ៣៥០ |
| សិស្សមធ្យមសិក្សាបឋមភូមិរដ្ឋស្រី | ២៨៥ ៤៧៨ | ៣០៣ ៦៤៥ | +១៨ ១៦៧ |
| សិស្សមធ្យមសិក្សាបឋមភូមិឯកជនសរុប | ២៨ ២៣៥ | ២២ ៩៨៤ | -៥ ២៥១ |

| | | | |
|---|---|---|---|
| សិស្សមធ្យមសិក្សាបឋមភូមិឯកជនស្រី | ១៣ ៧៩៧ | ១១ ៣៧១ | -២ ៤២៦ |
| **វិទ្យាល័យ** | | | |
| សាលារៀន | ៤៦៣ | ៤៨៦ | +២៣ |
| បន្ទប់រៀន | ១០ ៣០១ | ១០ ៧៥៩ | +៤៥៨ |
| បុគ្គលិកអប់រំនៅវិទ្យាល័យសរុប | ២៩ ២៥១ | ២៩ ៩៥៤ | +៧០៣ |
| បុគ្គលិកអប់រំនៅវិទ្យាល័យស្រី | ១០ ៨៣៧ | ១១ ២៦៧ | +៤៣០ |
| ថ្នាក់រៀនមធ្យមសិក្សាទុតិយភូមិ | ៦ ០២០ | ៦ ២១៧ | +១៧ |
| បុគ្គលិកអប់រំមធ្យមសិក្សាទុតិយភូមិសរុប | ១៤ ៤៣៤ | ១៤ ៤៥៧ | +២៣ |
| បុគ្គលិកអប់រំមធ្យមសិក្សាទុតិយភូមិស្រី | ៤ ៣៣៤ | ៤ ៤២៣ | +៨៩ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាទុតិយភូមិសរុប | ១២ ៥៧០ | ១២ ៦២៥ | +៥៥ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាទុតិយភូមិស្រី | ៣ ៨៥២ | ៣ ៩៤៦ | +៩៤ |
| សិស្សមធ្យមសិក្សាទុតិយភូមិសាធារណៈសរុប | ២៦៦ ៤៤៩ | ២៧៩ ៤៧៩ | +១៣ ០៣០ |
| សិស្សមធ្យមសិក្សាទុតិយភូមិសាធារណៈស្រី | ១៣៣ ៦៥៧ | ១៤៣ ៤៦០ | +៩ ៨០៣ |
| សិស្សមធ្យមសិក្សាទុតិយភូមិឯកជនសរុប | ៨ ៦៩១ | ១៧ ២៤៤ | +៨ ៥៥៣ |
| សិស្សមធ្យមសិក្សាទុតិយភូមិឯកជនស្រី | ៤ ១៩៨ | ៨ ៣២២ | +៤ ១២៤ |

វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមាន ៧ ក្នុងនោះ គ្រឹះស្ថានសិក្សា ៥ កំពុងដំណើរការបង្រៀននិងរៀន។ សិស្សផ្នែកអប់រំបច្ចេកទេសមាន ១ ១៤៨ នាក់ ស្រី ៤០,៤១ ភាគរយ ក្នុងនោះវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ខេត្តកំពង់ធំមានសិស្ស ៦៨១ នាក់ ស្រី ៤៩,៣៣ ភាគរយ វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន-រ៉ូតា** ខ្សាច់កណ្តាល ខេត្តកណ្តាលមានសិស្ស ១៥៥ នាក់ ស្រី ៦,៤៥ ភាគរយ វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ខេត្តកំពង់ឆ្នាំងមានសិស្ស ២២២ នាក់ ស្រី ៤៣,៦៩ ភាគរយ វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសឯកជនសន្តប្រាំងស្វ័រ ខេត្តតាកែវមានសិស្ស ៥៣ នាក់ ស្រី ៣៩,៦២ ភាគរយ និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសពួក ខេត្តសៀមរាបមានសិស្សប្រុស ៣៧ នាក់។ វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **ហ៊ុន សែន** ជម្ពូវ័ន្ត រាជធានីភ្នំពេញ បានដាក់ឱ្យដំណើរការមុខវិជ្ជាជីវៈជម្រើសដល់សិស្សប្រុស ៦០ នាក់ ជំនាញអគ្គិសនី។ វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស បាវិត ខេត្តស្វាយរៀង កំពុងរៀបចំហេដ្ឋារចនាសម្ព័ន្ធ បណ្តាញអគ្គិសនី និងពុំទាន់មានគ្រូផ្នែកបច្ចេកទេស។

*ប្រការនេះបញ្ជាក់ថា សហគមន៍កាន់តែមានការចាប់អារម្មណ៍ និងយល់ដឹងពីសារប្រយោជន៍នៃការអប់រំបច្ចេកទេស ដែលនឹងផ្តល់ការងារសមរម្យដល់យុវជនឆ្លើយតបនឹងតម្រូវការទីផ្សារពលកម្ម។*

## តារាងទី៧ ៖ ស្ថិតិសិស្សនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស

| បរិយាយ | ២០១៥-១៦ | | ២០១៦-១៧ | | កើន/ថយ (+/-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | ៦៨០ | ៣២៩ | ៦៨១ | ៣៣៦ | ១ | ៧ |
| វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែនរ៉ូតា-** ខ្សាច់កណ្តាល | ១៦៦ | ១០ | ១៥៥ | ១០ | -១១ | ០ |
| វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស**ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** | ១៨៤ | ៨៨ | ២២២ | ៩៧ | ៣៨ | ៩ |
| វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជនសន្តប្រហ្វង់ស្វ័រ | ៣៦ | ១៧ | ៥៣ | ២១ | ១៧ | ៤ |
| វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសពួក | ០ | ០ | ៣៧ | ០ | ៣៧ | ០ |

## រូបភាពទី១៩ ៖ ស្ថិតិសិស្សផ្នែកអប់រំបច្ចេកទេសឆ្នាំសិក្សា ២០១៦-២០១៧




## រូបភាពទី២០ ៖ ការប្រែប្រួលចំនួនសិស្សអប់រំបច្ចេកទេស

វិទ្យាស្ថានបច្ចេកទេសកំពង់ឈើទាលខេត្តកំពង់ធំ

វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន-រ៉ូតា** ខ្សាច់កណ្តាល

វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី**



### តារាងទី៨ ៖ ចំនួនសិស្សផ្នែកអប់រំបច្ចេកទេសតាមជំនាញឆ្នាំសិក្សា២០១៦-២០១៧

| ល.រ | មុខជំនាញ | ឆ្នាំសិក្សា ២០១៥-២០១៦ | | ឆ្នាំសិក្សា ២០១៦-២០១៧ | | កើន-ថយ (+/-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | អគ្គិសនី | ៣៧៧ | ៥៣ | ៣៩៩ | ៥៧ | +២២ | +៤ |
| ២ | អេឡិចត្រូនិច | ១៦៧ | ៣៤ | ២២០ | ៥២ | +៥៣ | +១៨ |
| ៣ | កេរ្យត្រសាស្រ្ត | ៩៣ | ៦៧ | ២៦៧ | ១៧៥ | +១៧៤ | +១០៨ |
| ៤ | បសុវប្បកម្ម | ២៣៤ | ១៧២ | ២៦២ | ១៨០ | +២៨ | +៨ |
| **សរុប** | | **៨៧១** | **៣២៦** | **១១៤៨** | **៤៦៤** | **+២៧៧** | **+១៣៨** |

## ការអនុវត្តកម្មវិធីនានា

### *កម្មវិធីផ្តល់អាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សា*

កម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅកម្រិតមធ្យមសិក្សាបឋមភូមិ បានគ្របដណ្តប់លើសាលារៀន ៨០៩ ដែលមានសិស្សអាហារូបករណ៍ ៦៩ ៥១៤ នាក់ ស្រី ៦០ ភាគរយ។ កម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅកម្រិតមធ្យមសិក្សាទុតិយភូមិ បានគ្របដណ្តប់លើសាលារៀន ១២០ មានសិស្សអាហារូបករណ៍ ៣ ៦០០ នាក់ ស្រី ៦០ ភាគរយ គាំទ្រដោយថវិកាជាតិ។ ក្រៅពីនេះ អាហារូបករណ៍ផ្តល់ដោយដៃគូអភិវឌ្ឍនានាក្រោមរូបផ្សេងៗដូចជា ៖

- អង្គការយូនីសេហ្វឧបត្ថម្ភអាហារូបករណ៍ដល់សិស្សជនជាតិដើមភាគតិចថ្នាក់ទី១១ ចំនួន ៥២១ នាក់ ស្រី ៤៦,៤៥ ភាគរយ នៅខេត្តព្រះវិហារ ស្ទឹងត្រែង មណ្ឌលគិរី រតនគិរី និងក្រចេះ
- អង្គការកុមារមេត្តា ឧបត្ថម្ភកម្មវិធីអាហារូបករណ៍សិស្សមធ្យមសិក្សា ២០៨ នាក់ ស្រី ៥៤,៣២ ភាគរយ និងអង្គការព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍ បានផ្តល់អាហារូបករណ៍សិស្សមធ្យមសិក្សា ៣២ នាក់ ស្រី ៦៥,៦២ ភាគរយ នៅខេត្តឧត្តរមានជ័យ
- អង្គការរូមធូរីដបានផ្តល់សម្ភារៈសិក្សាដល់កុមារីដែលជួបការលំបាក ២ ៥៩១ នាក់ នៅខេត្តកំពង់ធំ និងសៀមរាប
- អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានផ្តល់សម្ភារៈសិក្សាដល់សិស្សស្រី ២៥ នាក់ ខេត្តសៀមរាប
- អង្គការថែរក្សាដើម្បីកម្ពុជា បានផ្តល់សម្ភារៈសិក្សាដល់សិស្សមធ្យមសិក្សា ៦៦ នាក់ ស្រី ៥៣,០៣ ភាគរយ។

*កម្មវិធីនេះ បានជួយបង្កើនអត្រាចូលរៀន និងកាត់បន្ថយអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សា ជាពិសេសសិស្សស្រី។*

## *ការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅកម្រិតមធ្យមសិក្សាបឋមភូមិ*

ក្រសួងបាន៖

- ផ្សព្វផ្សាយ និងប្រើប្រាស់ឯកសារគាំទ្រការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅកម្រិតមធ្យមសិក្សាបឋមភូមិ រួមមាន ឯកសារណែនាំក្រុមពិនិត្យតាមដាន និងវាយតម្លៃថ្នាក់ក្រុង ស្រុក ខណ្ឌ និង ឯកសារណែនាំប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ខេត្តតាកែវ កំពត ព្រះសីហនុ សៀមរាប ស្ទឹងត្រែង និងរតនគិរី
- ផ្សព្វផ្សាយ និងប្រើប្រាស់ឯកសារណែនាំគ្រូបង្រៀនអប់រំបំណិនជីវិតតាមមូលដ្ឋាន ក្នុងខេត្តតាកែវ សៀមរាប និងស្ទឹងត្រែង
- អនុវត្តកម្មវិធីសាលាកុមារមេត្រីនៅតាមសាលារៀន ៣៩៧ ស្មើនឹង ២៣,៣៨ ភាគរយ នៃសាលារៀន ដែលមានកម្រិតមធ្យមសិក្សាបឋមភូមិ ១ ៦៩៩ សាលា ក្នុងនោះកម្រិតមូលដ្ឋាន ១៧៨ ស្មើនឹង ១០,៤៨ ភាគរយ កម្រិតមធ្យម ១៨០ ស្មើនឹង ១០,៦០ ភាគរយ និងកម្រិតអភិវឌ្ឍ ៣៩ ស្មើនឹង ២,២៩ ភាគរយ ដែលគាំទ្រដោយអង្គការយូនីសេហ្វ នៅខេត្តតាកែវ កំពត ព្រះសីហនុ សៀមរាប ស្ទឹងត្រែង និងរតនគិរី
- បំប៉នបុគ្គលិកអប់រំនៅថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់សាលារៀនស្តីពីការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅមធ្យមសិក្សា ២១១ នាក់ ស្រី ២១,៣២ ភាគរយ ក្នុងនោះខេត្តតាកែវ ៦៩ នាក់ ស្រី ១៥,៩៤ ភាគរយ សៀមរាប ៧៧ នាក់ ស្រី ២៥,៩៧ ភាគរយ ស្ទឹងត្រែង ៦៥ នាក់ ស្រី ២១,៥៣ ភាគរយ គាំទ្រដោយអង្គការយូនីសេហ្វ
- បំប៉នគ្រូបង្រៀននៅតាមអនុវិទ្យាល័យស្តីពីការអប់រំបំណិនជីវិតមូលដ្ឋាន ៤៥ នាក់ ស្រី ១១,៣៦ ភាគរយ ក្នុងនោះខេត្តតាកែវ ១២ នាក់ ស្រី ៨,៣៣ ភាគរយ សៀមរាប បុរស ១៤ នាក់ និងស្ទឹងត្រែង ៦ នាក់ ស្រី ១៦,៦៦ ភាគរយ ត្បូងឃ្មុំ បុរស ២ នាក់ ថ្នាក់កណ្តាល ១០ នាក់ ស្រី ៣០ ភាគរយ គាំទ្រដោយអង្គការយូនីសេហ្វ។

  *កម្មវិធីនេះ បានលើកកម្ពស់គុណភាពអប់រំ និងពង្រឹងប្រសិទ្ធភាពនៃការងារគ្រប់គ្រង ដឹកនាំ។*

## *សាលារៀនជំនាន់ថ្មី*

ក្រសួងបាន៖

- អនុម័តគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី ដោយបានរៀបចំផែនការសកម្មភាព និងកំណត់អាទិភាពលើការលើកកម្ពស់អភិបាលកិច្ច សាលារៀនល្អ គណនេយ្យភាព លើកកម្ពស់ស្តង់ដាវិជ្ជាជីវៈបង្រៀន និងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា តាមរយៈការប្រើវិធីសាស្ត្របង្រៀនសំបូរបែបដូចជា ការសិក្សាបែបរិះរក កិច្ចការជាគម្រោង ការសិក្សាស្រាវជ្រាវមេរៀន
- ដំណើរការសាលារៀនជំនាន់ថ្មីចំនួន ៣ រួមមាន វិទ្យាល័យ **ហ៊ុន សែន** កំពង់ចាម ខេត្តកំពង់ចាម វិទ្យាល័យព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ និងអនុវិទ្យាល័យគោកព្រីង ខេត្តស្វាយរៀង ដោយរៀបចំ

ឱ្យមានបន្ទប់ពិសោធន៍តាមមុខវិជ្ជា បន្ទប់កុំព្យូទ័រនិងបំពាក់កុំព្យូទ័រ បន្ទប់មុខវិជ្ជា បន្ទប់សាស្ត្រាចារ្យ និងបណ្ណាល័យអេឡិចត្រូនិច។ សាលារៀនជំនាន់ថ្មីបានអនុវត្តកម្មវិធីសិក្សាតាមបែបសិស្សចល័តទៅតាមបន្ទប់មុខវិជ្ជា។ ដោយឡែកសាលាជំនាន់ថ្មីវិទ្យាល័យព្រះស៊ីសុវត្ថិ បានជ្រើសរើសសិស្សថ្នាក់ទី៧ ចំនួន ៦ថ្នាក់ សិស្ស ២១៥ នាក់ ស្រី ៩៣,៧២ ភាគរយ ថ្នាក់ទី១០ ចំនួន ៦ ថ្នាក់ សិស្ស ២២០ នាក់ ស្រី ៣៦,៨១ ភាគរយ។ សិស្សសរុបទាំងពីរកម្រិតមាន ៨៣៥ នាក់ ស្រី ៩០,២២ ភាគរយ

- ពង្រីកការបង្រៀន និងរៀនការអប់រំបំណិនជីវិត ប្រឹក្សាអាជីព ក្រុមប្រឹក្សាយុវជន និងក្លឹបសិក្សា រួមមាន ក្លឹបគណិតវិទ្យា ក្លឹបអក្សរសាស្ត្រខ្មែរ ក្លឹបរូបវិទ្យា ក្លឹបគីមីវិទ្យា ក្លឹបជីវវិទ្យា ក្លឹបប្រវត្តិវិទ្យា។

## *ការអនុវត្តកម្មវិធីទប់ស្កាត់សិស្សបោះបង់ការសិក្សា*

ក្រសួងបាន៖

- បន្តអនុវត្តកម្មវិធីកែលម្អសាលារៀននៅគ្រប់សាលាមធ្យមសិក្សាសាធារណៈ ដើម្បីប្រើប្រាស់ថវិកាឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់សាលារៀនដោយភាពទន់ភ្លន់
- បន្តអនុវត្តគម្រោងអភិវឌ្ឍវិស័យអប់រំទី៣ នៅសាលារៀន ១០០ ក្នុងខេត្តបាត់ដំបង សៀមរាប កំពង់ធំ ព្រះវិហារ ស្ទឹងត្រែង ត្បូងឃ្មុំ រតនគិរី មណ្ឌលគិរី ពោធិ៍សាត់ កំពង់ស្ពឺ ប៉ៃលិន បន្ទាយមានជ័យ និងឧត្តរមានជ័យ ដើម្បីឱ្យសាលាលើកគម្រោងផែនការសកម្មភាព ពិសេសសំដៅទប់ស្កាត់សិស្សបោះបង់ការសិក្សា
- អនុវត្តសាកល្បងឯកសារកម្រងសាលារៀន និងគណៈកម្មការទ្រទ្រង់សាលារៀនមធ្យមសិក្សា
- ពិនិត្យតាមដានការអនុវត្តប្រព័ន្ធរំលឹកជាមុន ដើម្បីទប់ស្កាត់សិស្សបោះបង់ការសិក្សា។

## *ការអប់រំបំណិនជីវិត*

ក្រសួងបាន៖

- អនុម័តក្របខណ្ឌកម្មវិធីអប់រំបំណិនជីវិតសម្រាប់មធ្យមសិក្សា
- ពង្រីកការអនុវត្តកម្មវិធីអប់រំបំណិនជីវិតមូលដ្ឋានសម្រាប់មធ្យមសិក្សា
- រៀបចំកសាងឯកសារស្តីពីការពង្រឹងគុណភាព និងប្រសិទ្ធភាពការអប់រំបំណិនជីវិតនៅមធ្យមសិក្សាបឋមភូមិ
- រៀបចំអនុវត្តកម្មវិធី ស្តីពីការបំណិនការងារ គាំទ្រដោយគម្រោងគាំទ្រវិស័យអប់រំទី៣ របស់ធនាគារអភិវឌ្ឍន៍អាស៊ី
- ពិនិត្យតាមដានការបង្រៀន និងរៀនផ្នែកអប់រំបំណិនជីវិតនៅខេត្តគោលដៅ ១៤ គឺខេត្តកែប តាកែវ បាត់ដំបង ព្រៃវែង កំពង់ចាម កំពង់ឆ្នាំង ពោធិសាត់ ត្បូងឃ្មុំ កំពង់ធំ ប៉ៃលិន ឧត្តរមានជ័យ ស្វាយរៀង បន្ទាយមានជ័យ និងស្ទឹងត្រែង លើមុខវិជ្ជាគេហវិទ្យា កសិកម្ម រោងជាង សិល្បៈ និងកុំព្យូទ័រ។

*ប្រការនេះបានរួមចំណែកជួយលើកកម្ពស់គុណភាពជីវិតប្រចាំថ្ងៃ។*

### *ការងារតម្រង់ទិសវិជ្ជាជីវៈ*

ក្រសួងបាន៖

- ផ្សព្វផ្សាយការអប់រំតម្រង់ទិសវិជ្ជាជីវៈដល់សិស្សថ្នាក់ទី៩ ចំនួន ៤ ២១៣ នាក់ ស្រី ៥៤,៦៤ ភាគរយ នៅខេត្តសៀមរាប និងស្វាយរៀង
- រៀបចំវេទិកាស្ដីពីការជ្រើសរើសអាជីព និងការសិក្សានៅឧត្តមសិក្សា នៅខេត្តព្រៃវែង តាកែវ កំពត កែប និងបន្ទាយមានជ័យ
- បំប៉នសមត្ថភាពគ្រូបង្គោលបុរស ២៥ នាក់ ស្ដីពីការប្រើប្រាស់ឯកសារអប់រំតម្រង់ទិសវិជ្ជាជីវៈសម្រាប់មធ្យមសិក្សាបឋមភូមិ។

*កម្មវិធីនេះ បានជួយតម្រង់ទិសសិស្សឱ្យស្គាល់មុខរបរ ចេះជ្រើសរើសមុខរបរ និងគន្លងសិក្សាទៅថ្ងៃអនាគតបានត្រឹមត្រូវជាងមុន។*

### *ការងារប្រឹក្សាអាជីព និងកម្មវិធីស្ពានចម្លង*

ក្រសួងបាន៖

- អនុម័តឯកសារប្រឹក្សាអាជីព និងព័ត៌មានស្ដីពីការសិក្សាជំនាញសម្រាប់កម្រិតមធ្យមសិក្សា
- រៀបចំបន្ទប់ផ្ដល់ប្រឹក្សាអាជីពនៅសាលាមធ្យមសិក្សាទាំង៤ ក្នុងខេត្តបាត់ដំបង ដោយសហការជាមួយអង្គការជំនួយព្រះវិហារហ្សាំងឡង់។

*កម្មវិធីនេះ បានរួមចំណែកផ្ដល់ឧត្តមានុវត្តន៍ក្នុងការផ្ដល់ប្រឹក្សាដល់សិស្ស។*

### *ការវិភាគអត្រាលំហូរសិស្ស*

អត្រាឡើងថ្នាក់នៅមធ្យមសិក្សាបឋមភូមិកើន ២,០ ភាគរយ ស្រីកើន ២,៤ ភាគរយ និងមធ្យមសិក្សាទុតិយភូមិកើន ៤,៩ ភាគរយ ស្រីកើន ៤,៧ ភាគរយ។ អត្រាត្រួតថ្នាក់នៅមធ្យមសិក្សាបឋមភូមិកើន ០,៣ ភាគរយ ស្រីកើន ០,២ ភាគរយ និងមធ្យមសិក្សាទុតិយភូមិថយ ០,៤ ភាគរយ ស្រីថយ ០,៤ ភាគរយ។ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិថយ ២,២ ភាគរយ ស្រីថយ ២,៧ ភាគរយ និងមធ្យមសិក្សាទុតិយភូមិថយ ៤,៤ ភាគរយ ស្រីថយ ៤,៣ ភាគរយ។

*ប្រការនេះបញ្ជាក់ឱ្យឃើញថា កំណែទម្រង់វិស័យអប់រំ ជាពិសេសការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន វិធីសាស្ត្របង្រៀន ការបង្កើតក្លឹបសិក្សា បានជំរុញឱ្យការរៀន និងបង្រៀនកាន់តែមានប្រសិទ្ធភាពជាងមុន។*

### តារាងទី៩ ៖ អត្រាលំហូរសិក្សានៅមធ្យមសិក្សា រវាងឆ្នាំសិក្សា ២០១៤-២០១៥ និង ២០១៥-២០១៦

| បរិយាយ | មធ្យមសិក្សាបឋមភូមិ | | | មធ្យមសិក្សាទុតិយភូមិ | | |
|---|---|---|---|---|---|---|
| | ២០១៤-១៥ | ២០១៥-១៦ | កើន-ថយ | ២០១៤-១៥ | ២០១៥-១៦ | កើន-ថយ |
| អត្រាឡើងថ្នាក់ | ៧៨,៦ | ៨០,៦ | +២,០ | ៧៣,០ | ៧៧,៩ | +៤,៩ |
| អត្រាត្រួតថ្នាក់ | ២,២ | ២,៥ | +០,៣ | ៣,២ | ២,៨ | -០,៤ |
| អត្រាបោះបង់ការសិក្សា | ១៩,២ | ១៧,០ | -២,២ | ២៣,៨ | ១៩,៤ | -៤,៤ |
| អត្រាឆ្លងភូមិសិក្សា | ៨២,១ | ៨៥,៥ | +៣,៤ | ៧២,៤ | ៧៤,៦ | +២,២ |

ផលធៀបសិស្ស-គ្រូកើនពី ១៩,៧ ដល់ ២១,៣ នៅមធ្យមសិក្សាបឋមភូមិ និងថយពី ២១,២ ដល់ ២០,៧ នៅមធ្យមសិក្សាទុតិយភូមិ។ ផលធៀបសិស្ស-ថ្នាក់នៅមធ្យមសិក្សាបឋមភូមិបានកើនពី ៤៤,៤ ដល់ ៤៤,៥ និងកើនពី ៤៤,៣ ដល់ ៤៦,០ នៅមធ្យមសិក្សាទុតិយភូមិ។ ផលធៀបសិស្ស-បន្ទប់បានថយពី ៤៨,៧ មក ៤៨,៣ នៅមធ្យមសិក្សាបឋមភូមិ និងកើនពី ៤៩,៧ ដល់ ៥០,៣ នៅមធ្យមសិក្សាទុតិយភូមិ។

### តារាងទី១០ ៖ ផលធៀបសំខាន់ៗនៅមធ្យមសិក្សា រវាងឆ្នាំសិក្សា ២០១៥-២០១៦ និង ២០១៦-២០១៧

| បរិយាយ | មធ្យមសិក្សាបឋមភូមិ | | | មធ្យមសិក្សាទុតិយភូមិ | | |
|---|---|---|---|---|---|---|
| | ២០១៥-១៦ | ២០១៦-១៧ | កើន-ថយ | ២០១៥-១៦ | ២០១៦-១៧ | កើន-ថយ |
| ផលធៀបសិស្ស-គ្រូ | ១៩,៧ | ២១,៣ | +១,៦ | ២១,២ | ២០,៧ | -០,៥ |
| ផលធៀបសិស្ស-ថ្នាក់រៀន | ៤៤,៤ | ៤៤,៥ | +០,១ | ៤៤,៣ | ៤៦,០ | +១,៧ |
| ផលធៀបសិស្ស-បន្ទប់រៀន | ៤៨,៧ | ៤៨,៣ | -០,៤ | ៤៩,៧ | ៥០,៣ | ០,៦ |

- បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ៩៣,៧២ ភាគរយ កើន ០,១២ ភាគរយ ស្រី ៩៦,៣៧ ភាគរយ កើន ០,៦០ ភាគរយ
- បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ៦២,១៨ ភាគរយ កើន ៦,៣០ ភាគរយ ស្រី ៦៥,៤៦ ភាគរយ កើន ៦,០៣ ភាគរយ។ សិស្សជាប់និទ្ទេស A មាន ៤០៥ នាក់ ស្រី ២០៤ នាក់ បានទទួលរង្វាន់លើកទឹកចិត្តសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

### រូបភាពទី២១ ៖ លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាឆ្នាំសិក្សា ២០១៥-២០១៦



បេក្ខជនប្រឡងជាប់សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈកម្រិត៣ ផ្នែកអគ្គិសនី ៨៤ នាក់ ស្រី ១៥,៤៧ ភាគរយ អេឡិចត្រូនិច ៣៤ នាក់ ស្រី ៣៥,២៩ ភាគរយ ក្សេត្រសាស្ត្រ ២៣ នាក់ ស្រី ៨២,៦០ ភាគរយ និងបសុវប្បកម្ម ៥៤ នាក់ ស្រី ៨១,៤៨ ភាគរយ។ (រូបភាពទី២៣ និងទី២៤)

តារាងទី២២ បង្ហាញថា លទ្ធផលសិក្សាសិស្សនារីមានការកើនឡើងគួរឱ្យកត់សម្គាល់។

**រូបភាពទី២២ ៖ ស្ថិតិសិស្សដាក់ពាក្យ និងសិស្សមកប្រឡងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត ៣**




**រូបភាពទី២៣ ៖ លទ្ធផលប្រឡងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ឆ្នាំសិក្សា២០១៥-២០១៦**




### *លទ្ធផលប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស និងប្រឡងអូឡាំព្យាដ*

ក្រសួងបាន៖

- ជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យាថ្នាក់ទី៩ និងទី១២ ដោយជ្រើសរើសយកជ័យលាភី ៦០ នាក់ ស្រី ៤០ ភាគរយ លើចំនួនបេក្ខជនសិស្សពូកែថ្នាក់រាជធានី ខេត្ត ៤៨០ នាក់ ស្រី ៤៩,១៦ ភាគរយ ដែលក្នុងមួយមុខវិជ្ជា និងមួយកម្រិតថ្នាក់ជ្រើសបាន ១០ នាក់
- បំប៉ន និងបញ្ជូនសិស្សប្រុស ២ នាក់ ផ្នែកគណិតវិទ្យា និងសិស្សប្រុស ២ នាក់ ផ្នែករូបវិទ្យា ទៅចូលរួមប្រកួតប្រជែងអ្នកស្រាវជ្រាវវិទ្យាសាស្ត្រវ័យក្មេងរបស់ស៊ីមេអូលើកទី១០ នៅម៉ាឡេស៊ី។ ជាលទ្ធផលក្រុមគណិតវិទ្យាទទួលបានពានរង្វាន់ល្អប្រសើរបំផុតម្នាក់មួយគ្រឿង

- បំប៉ន និងបញ្ជូនសិស្សប្រុស ៦ នាក់ ទៅចូលរួមប្រឡងគណិតវិទ្យាអូឡាំព្យាដអន្តរជាតិ នៅទីក្រុងហុងកុង នៅប្រទេសចិន។ ជាលទ្ធផល សិស្ស ១ នាក់ ទទួលបានពានរង្វាន់កិត្តិយស
- បំប៉ន និងបញ្ជូនសិស្ស ៥ នាក់ ស្រី ២០ ភាគរយ ទៅចូលរួមប្រឡងរូបវិទ្យាអូឡាំព្យាដទ្វីបអាស៊ីនៅទីក្រុងហុងកុង ប្រទេសចិន
- បំប៉ន និងបញ្ជូនសិស្ស ៦ នាក់ ស្រី ១៦,៦៦ ភាគរយ ទៅចូលរួមប្រឡងរូបវិទ្យាអូឡាំព្យាដអន្តរជាតិទៅប្រទេសស្វីស
- បំប៉ន និងបញ្ជូនសិស្ស ៦ នាក់ ស្រី ៥០ ភាគរយ ចូលរួមប្រឡងជ្រើសរើសអ្នកវិទ្យាសាស្ត្រអូឡាំព្យាដអន្តរជាតិ វ័យក្មេងក្រោមអាយុ ១៦ឆ្នាំ លើកទី១៣ នៅប្រទេសឥណ្ឌូនេស៊ី។ ជាលទ្ធផលសិស្ស ២ នាក់ ទទួលបានមេដាយសំរឹទ្ធិ ម្នាក់ ១ គ្រឿង។

*ប្រការនេះបង្ហាញឱ្យឃើញថា សក្តានុពលធនធានមនុស្សរបស់កម្ពុជាកាន់តែមានឧត្តមភាពប្រៀបធៀបនៅលើឆាកអន្តរជាតិ។*

## *ការអភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សា*

ក្រសួងបានៈ

- អនុម័តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស
- អនុម័តវិធីសាស្ត្រសរសេរតែងសេចក្តីថ្នាក់ទី៧ ដល់ថ្នាក់ទី១២
- អនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- អនុម័តសៀវភៅសិក្សាគោល ភាសាអង់គ្លេស ថ្នាក់ទី៩
- អភិវឌ្ឍកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា ពីថ្នាក់ទី៧ ដល់ទី១២ សម្រេចបាន ៩០ ភាគរយ
- រៀបចំខ្លឹមសារសៀវភៅសិក្សាគោលជំនាញមេកានិច និងអេឡិចត្រូនិក
- រៀបចំបំណែងចែកកម្មវិធីសិក្សាផ្នែកអប់រំបច្ចេកទេស សម្រាប់អនុវត្តនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- បញ្ជ្រាបឯកសារការប្រែប្រួលអាកាសធាតុសម្រាប់គ្រូពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២។

## *ការផ្តត់ផ្គង់សៀវភៅសិក្សាគោល*

ក្រសួងបានផ្គត់ផ្គង់សៀវភៅសិក្សាគោលតាមផលធៀបសៀវភៅ-សិស្ស ១:១ នៅមធ្យមសិក្សាបឋមភូមិ (សិស្ស ១ នាក់ ទទួលបានសៀវភៅសិក្សាគោល ១ ច្បាប់ គ្រប់មុខវិជ្ជា)។ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ផ្គត់ផ្គង់តាមផលធៀប ២:១ (សិស្ស ២ នាក់ ទទួលបានសៀវភៅសិក្សាគោល ១ ច្បាប់ គ្រប់មុខវិជ្ជា)។ សម្រាប់ឆ្នាំសិក្សា ២០១៦-២០១៧ សិស្សនៅមធ្យមសិក្សាសម្រេចបានសៀវភៅសិក្សាគោលគ្រប់គ្រាន់ តាមចំនួនផលធៀបខាងលើ។

*ប្រការនេះ ឆ្លុះបញ្ចាំងពីប្រសិទ្ធផលរបស់សិស្សតាមរយៈការប្រឡងគ្រប់ភូមិសិក្សា។*

### *ការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន*

ក្រសួងបាន៖

- បំប៉នគ្រូបង្រៀន ២៨ នាក់ ស្រី ១៤,២៨ ភាគរយ ស្តីពីការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលលើមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍-អង់គ្លេស
- អនុម័តស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន
- បំប៉នគ្រូឧទ្ទេស ១០៤ នាក់ ស្រី ២៦,៩២ ភាគរយ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រិតការខេត្ត ស្តីពីបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍
- បំប៉នគ្រូបង្រៀន ៣៨ នាក់ ស្រី ៦០,៥២ ភាគរយ ស្តីពីវិធីសាស្ត្ររៀបចំសៀវភៅបណ្ណាល័យ ដោយសហការជាមួយអង្គការ IBO
- បំប៉នគ្រូបង្រៀន ៤៧ នាក់ ស្រី ៤២,៥៥ ភាគរយ ស្តីពីការប្រើកម្មវិធីបណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋានមុខវិជ្ជាភាសាអង់គ្លេស ដោយសហការជាមួយអង្គការគីហ្សូណា
- បោះពុម្ពឯកសារបំប៉នគ្រូកម្រិតមូលដ្ឋានជំនាន់ទី១០ វេនទី១ ចំនួន ១៣មុខវិជ្ជាបាន ៧ ៨៤៧ ក្បាល
- បូកសរុបការងារបណ្តុះបណ្តាលគ្រូបង្រៀនឆ្នាំសិក្សា ២០១៥-២០១៦ មានអ្នកចូលរួម ១៩៥ នាក់ ស្រី ៣២,៤១ ភាគរយ
- អនុម័តកម្មវិធីពន្លឿនគ្រូកម្រិតមូលដ្ឋានទៅជាគ្រូបង្រៀនកម្រិតឧត្តម
- បំប៉នគ្រូកម្រិតមូលដ្ឋាន ៧០០ នាក់ ស្រី ២៨,៧១ ភាគរយ តាមប្រព័ន្ធពន្លឿនឆ្ពោះទៅកម្រិតបរិញ្ញាបត្រ
- បណ្តុះបណ្តាលគ្រូឧទ្ទេសដែលមានបរិញ្ញាបត្រ ៥៦ នាក់ ស្រី ៣៥,៧១ ភាគរយ ឱ្យទទួលបានបរិញ្ញាបត្រជាន់ខ្ពស់គណិតវិទ្យា និងវិទ្យាសាស្ត្រ
- បញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ១២+២ ជំនាន់ទី២៦ ចំនួន ៨៩០ នាក់ ស្រី ៥៨,៥៧ ភាគរយ និងគ្រូបង្រៀនកម្រិតឧត្តមបរិញ្ញា+១ ជំនាន់ទី២១ ចំនួន ៨៧១ នាក់ ស្រី ៣៩,០៣ ភាគរយ
- បន្តបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ១២+២ ជំនាន់ទី២៧ ចំនួន ៧៦៨ នាក់ ស្រី ៥៥,០៧ ភាគរយ និងគ្រូបង្រៀនកម្រិតឧត្តមបរិញ្ញា+១ ជំនាន់ទី២២ ចំនួន ៨៨០ នាក់ ស្រី ៤០,៥៦ ភាគរយ
- បំប៉នគ្រូបឋមសិក្សា និងមត្តេយ្យសិក្សា ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យទៅជាគ្រូកម្រិតមូលដ្ឋាន ២ ៩៩២ នាក់ ស្រី ៥០,៥៣ ភាគរយ ជំនាន់ទី៩ វេនទី២ និងជំនាន់ទី១០ វេនទី១
- ផ្សព្វផ្សាយគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡាដល់គរុនិស្សិតនៃវិទ្យាស្ថានជាតិអប់រំ ៨០០ នាក់ ស្រី ៤៣,៧៥ ភាគរយ។

*ប្រការនេះ បានជួយលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងគុណភាពអប់រំ។*

*ការងារបណ្ណាល័យ*

ក្រសួងបាន ៖

- រៀបចំទិវាជាតិអំណានក្រោមប្រធានបទ "បណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន"
- សង់បណ្ណាល័យសាលារៀន ១២ ក្នុងនោះខេត្តកំពង់ចាម ១ កំពង់ស្ពឺ ២ ព្រះវិហារ ១ តាកែវ ២ និង កំពង់ធំ ៦
- ផ្តល់សម្ភារបរិក្ខារ សង្ហារិម រួមមាន កុំព្យូទ័រលើតុ ៤ គ្រឿង ម៉ាស៊ីនបោះពុម្ព ១ គ្រឿង តុបណ្ណារក្ស ៣៨ តុអាន ១១០ តុកុំព្យូទ័រ ១៨ កៅអី ៣០០ និងទូធ្នើ ២៤០ សម្រាប់បណ្ណាល័យនៅរាជធានីភ្នំពេញ ខេត្តកណ្តាល បាត់ដំបង តាកែវ និងកំពង់ឆ្នាំង
- បូកសរុបការងារបណ្ណាល័យបង្អែកនៅខេត្តកណ្តាល តាកែវ ព្រៃវែង កំពង់ចាម កំពង់ធំ ស្វាយរៀង បាត់ដំបង ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង មានអ្នកចូលរួម ៦៥ នាក់ ស្រី ៤១,៥៣ ភាគរយ។

*ប្រការនេះ បានជួយដល់ការបង្រៀននិងរៀនរបស់គ្រូ និងសិស្ស ជាពិសេសការស្រាវជ្រាវបំពេញបន្ថែម។*

## ក.២ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

### *ការពង្រឹងប្រព័ន្ធគ្រប់គ្រង និងពិនិត្យតាមដានផ្អែកលើលទ្ធផល*

ក្រសួងបាន៖

- ពិនិត្យតាមដានការផ្តល់សេវាតម្រង់ទិសវិជ្ជាជីវៈ នៅខេត្តកំពត បាត់ដំបង ស្វាយរៀង កំពង់ចាម ព្រៃវែង មណ្ឌលគិរី និងសៀមរាប
- ពិនិត្យតាមដានការបង្រៀន និងរៀនផ្នែកអប់រំបំណិនជីវិតនៅខេត្តកែប តាកែវ បាត់ដំបង ព្រៃវែង កំពង់ចាម កំពង់ឆ្នាំង ពោធិ៍សាត់ ត្បូងឃ្មុំ កំពង់ធំ ប៉ៃលិន ស្វាយរៀង ឧត្តរមានជ័យ បន្ទាយមានជ័យ និង ស្ទឹងត្រែង លើមុខវិជ្ជាគេហវិទ្យា កសិកម្ម រោងជាង សិល្បៈ និងកុំព្យូទ័រ
- ពិនិត្យតាមដានការអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ នៅខេត្តក្រចេះ ត្បូងឃ្មុំ ស្ទឹងត្រែង កោះកុង ពោធិ៍សាត់ បន្ទាយមានជ័យ កំពត កំពង់ចាម ព្រៃវែង ស្វាយរៀង កំពង់ធំ សៀមរាប តាកែវ កំពង់ស្ពឺ និងរាជធានីភ្នំពេញ
- ពិនិត្យតាមដានការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ សម័យប្រឡង៖ ០៨ សីហា ២០១៦ នៅតាម ១២ រាជធានី ខេត្ត រួមមាន រាជធានីភ្នំពេញ ខេត្តកំពង់ចាម បន្ទាយមានជ័យ តាកែវ កណ្តាល ព្រះសីហនុ មណ្ឌលគិរី កំពង់ធំ កំពត ស្ទឹងត្រែង ព្រៃវែង និងកំពង់ស្ពឺ
- ពិនិត្យតាមដានលើការចំណាយថវិកាកែលម្អសាលារៀននៅតាមសាលារៀន ៤០ ក្នុងខេត្តតាកែវ កំពត កំពង់ចាម បន្ទាយមានជ័យ កណ្តាល ព្រះសីហនុ មណ្ឌលគិរី កំពង់ធំ ស្ទឹងត្រែង ព្រៃវែង និងកំពង់ស្ពឺ ដោយសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី តាមរយៈគម្រោងអភិវឌ្ឍន៍វិស័យអប់រំទី៣

- ពិនិត្យតាមដាន និងវាយតម្លៃលើការដឹកនាំ ការគ្រប់គ្រងសាលារៀនផ្អែកលើគោលការណ៍ អភិបាលកិច្ចល្អ នៅខេត្តបន្ទាយមានជ័យ ក្រចេះ កំពង់ធំ ស្វាយរៀង កែប បាត់ដំបង ព្រះសីហនុ ស្ទឹងត្រែង ត្បូងឃ្មុំ និងកោះកុង
- ធ្វើអធិការកិច្ចតាមប្រធានបទលើមុខវិជ្ជាគណិតវិទ្យាថ្នាក់ទី៩ បាន ៥០ សាលា នៅរាជធានីភ្នំពេញ ខេត្តកំពត បាត់ដំបង កំពង់ចាម កំពង់ស្ពឺ តាកែវ សៀមរាប ពោធិ៍សាត់ កំពង់ធំ ត្បូងឃ្មុំ កំពង់ឆ្នាំង ក្រចេះ ព្រៃវែង ស្វាយរៀង បន្ទាយមានជ័យ និងកណ្ដាល
- ធ្វើអធិការកិច្ចតាមប្រធានបទលើមុខវិជ្ជាគីមីវិទ្យាថ្នាក់ទី១២ បាន ៣៥ សាលា នៅខេត្តកំពត បាត់ដំបង កំពង់ចាម តាកែវ សៀមរាប កំពង់ធំ ត្បូងឃ្មុំ កំពង់ឆ្នាំង ស្វាយរៀង កោះកុង ព្រះវិហារ និងកណ្ដាល
- ធ្វើអធិការកិច្ចតាមកាលកំណត់ ២៩ សាលា នៅខេត្តតាកែវ សៀមរាប និងស្ទឹងត្រែង
- ធ្វើតេស្តវាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍលើសិស្សអាយុ ១៥ ឆ្នាំ ចំនួន ២ ០១៥ នាក់ ស្រី ៥៩,៩ ភាគរយ នៅតាមសាលាសំណាកគំរូ ៥៦ ក្នុងនោះអនុវិទ្យាល័យ ៣៩ និងវិទ្យាល័យ ១៧ នៅទូទាំងប្រទេស និងបានបញ្ចប់ដំណាក់កាលបញ្ចូលទិន្នន័យ។

*ប្រការនេះ បានជួយជំរុញឱ្យគណៈគ្រប់គ្រងសាលាបំពេញការងារប្រកបដោយប្រសិទ្ធភាព។*

## *ការអភិវឌ្ឍសមត្ថភាព*

ក្រសួងបាន៖

- បណ្ដុះបណ្ដាលគ្រូឧទ្ទេសផ្នែកប្រឹក្សាអាជីពថ្នាក់ជាតិ ១៣ នាក់ ស្រី ៤៦,១៥ ភាគរយ
- ពិគ្រោះយោបល់លើឯកសារកម្រងសាលារៀនមធ្យមសិក្សា និងគណៈកម្មការទ្រទ្រង់សាលារៀន ៣ ខេត្ត មានអ្នកចូលរួម ១២៧ នាក់ ស្រី ១១,០២ ភាគរយ ដោយសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី តាមរយៈគម្រោងអភិវឌ្ឍន៍វិស័យអប់រំទី៣
- បំប៉នគ្រូឧទ្ទេសថ្នាក់ជាតិលើឯកសារកម្រងសាលារៀនមធ្យមសិក្សា និងគណៈកម្មការទ្រទ្រង់សាលារៀន ៤៧ នាក់ ស្រី ១៩,១៤ ភាគរយ ដោយសហការជាមួយធនាគារអភិវឌ្ឍន៍ អាស៊ីតាម រយៈគម្រោងអភិវឌ្ឍន៍វិស័យអប់រំទី៣
- បំប៉ននាយកសាលាគោលដៅ (១០០ សាលារៀន) លើឯកសារកម្រងសាលារៀនមធ្យមសិក្សា និងគណៈកម្មការទ្រទ្រង់សាលារៀន ៤៧៨ នាក់ ស្រី ១៣,១៧ ភាគរយ ដោយសហការជាមួយធនាគារអភិវឌ្ឍន៍ អាស៊ីតាមរយៈគម្រោងអភិវឌ្ឍន៍វិស័យអប់រំទី៣
- បំប៉ននាយក នាយករងគ្រឹះស្ថានមធ្យមសិក្សា ២១២ នាក់ ស្រី ១២,៧៣ ភាគរយ ស្ដីពីការងារគ្រប់គ្រង និងដឹកនាំ ដោយសហការជាមួយមូលនិធិភាពជាដៃគូសម្រាប់ការអភិវឌ្ឍសមត្ថភាព
- បំប៉នបន្ថែមលើការប្រើប្រាស់ឧបករណ៍ពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ នៅខេត្តកំពត ៤៧ នាក់ ស្រី ៦,៣៨ ភាគរយ ដោយសហការជាមួយអង្គការយូនីសេហ្វ

- បំប៉នមន្ត្រីអប់រំថ្នាក់ខេត្ត និងនាយកសាលា ៩៩ នាក់ ស្រី ១១,៣៦ ភាគរយ ស្តីពីការអប់រំបំណិនជីវិត ដោយសហការជាមួយអង្គការយូនីសេហ្វ
- បំប៉នមន្ត្រីអប់រំថ្នាក់ស្រុក និងនាយកសាលា ២១១ នាក់ ស្រី ២១,៣២ ភាគរយ ស្តីពីការពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយសហការជាមួយអង្គការយូនីសេហ្វ
- បំប៉នរបៀបសរសេររបាយការណ៍ និងការគ្រប់គ្រងសិស្សអាហារូបករណ៍ក្រីក្រ នៅខេត្តកំពង់ឆ្នាំង និងខេត្តព្រៃវែង មានអ្នកចូលរួម ១០៩ នាក់ ស្រី ២០,១៩ ភាគរយ
- បំប៉នបច្ចេកទេសកុំព្យូទ័រសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា ២០១៥-១៦ មានអ្នកចូលរួម ៩១៨ នាក់ ស្រី ២,៦៣ ភាគរយ
- បំប៉នសមត្ថភាពស្តីពីការរៀបចំអក្សរសម្ងាត់ សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដល់បុគ្គលិកអប់រំរបស់អង្គភាពក្រោមឱវាទក្រសួង ២៩០ នាក់ ស្រី ២០ ភាគរយ
- ផ្សព្វផ្សាយលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៦ ដល់ប្រធានការិយាល័យប្រឡង និងមធ្យមសិក្សានៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងនាយក នាយិកាវិទ្យាល័យ ១៩២ នាក់ ស្រី ១២,៦៧ ភាគរយ ដោយសហការជាមួយគម្រោងថវិកាមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព
- កសាងឯកសារណែនាំ និងផ្សព្វផ្សាយអំពីរបៀបប្រើប្រាស់វីដេអូបង្រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រថ្នាក់ទី៩ និងថ្នាក់ទី១២ ចំនួន ៨៧ នាក់ ស្រី ១៣,៧៩ ភាគរយ ដោយសហការជាមួយគម្រោងថវិកាមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព
- បំប៉នសមត្ថភាពគ្រប់គ្រងបុគ្គលិកដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានអ្នកចូលរួម ១ ១២០ នាក់ ស្រី ៣៣,៩២ ភាគរយ
- បំប៉នគណៈគ្រប់គ្រងសាលារៀន ១៩០ នាក់ ស្រី ១១,០៥ ភាគរយ ស្តីពីអភិបាលកិច្ចល្អ សម្រាប់ពង្រឹងការផ្តល់សេវាអប់រំ
- ភ្ជាប់អ៊ិនធឺណិតជូនដល់អង្គភាព និងគ្រឹះស្ថានមធ្យមសិក្សារដ្ឋបាន ១០០
- ផ្សព្វផ្សាយវីដេអូអប់រំ សៀវភៅអំណាន កិច្ចតែងការបង្រៀន និងឯកសារស្រាវជ្រាវផ្សេងៗក្នុងមជ្ឈមណ្ឌលធនធានអប់រំអេឡិចត្រូនិក (គេហទំព័រគ្រូ) និងបណ្តាញទំនាក់ទំនងសង្គមគ្រូ ៩០៩ អត្ថបទ
- ផ្សព្វផ្សាយវីដេអូបង្រៀនគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យាថ្នាក់ទី៩ និងថ្នាក់ទី១២ ក្នុងមជ្ឈមណ្ឌលធនធានអប់រំអេឡិចត្រូនិក (គេហទំព័រគ្រូ) និងបណ្តាញទំនាក់ទំនងសង្គមគ្រូ ៨ ក្លីប
- បំប៉នសមត្ថភាពមន្ត្រីការិយាល័យអធិការកិច្ច ៨៥ នាក់ ស្រី ១៨,៨២ ភាគរយ ស្តីពីបញ្ញត្តិនៃការធានាគុណភាពអប់រំ ២ម៉ូឌុល ដើម្បីជួយខេត្តដែលខ្វះអធិការ
- បំប៉នសមត្ថភាពក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ ស្តីពីរបៀបផ្តល់ដំបូន្មានដើម្បីអនុវត្តសាកល្បងដល់នាយកសាលា និងគ្រូបង្រៀន ២៨១ នាក់ ស្រី ១៦,៣៧ ភាគរយ។

*ប្រការនេះ បានជួយពង្រឹងសមត្ថភាពស្វ័យសិក្សារបស់សិស្ស និងគ្រូ និងបណ្តុះទម្លាប់ការសិក្សាពេញមួយជីវិត។*

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

### *ការវិភាគវឌ្ឍនភាពសូចនាករ*

| | ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ជាក់ស្តែង ២០១៥-១៦ | ចំណុចដៅ ២០១៦-១៧ | ជាក់ស្តែង ២០១៦-១៧ | ស្ថានភាព |
|---|---|---|---|---|---|
| **គោលនយោបាយទី ១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសពេញមួយជីវិតសម្រាប់ទាំងអស់គ្នា** | | | | | |
| ១ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ៥៣,៨%* | ៥៤,២% | ៥៧,៦%* | ↑ |
| | *អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ស្រី)* | ៥៦,៧%* | ៥៧,១% | ៦១,៥%* | ↑ |
| ២ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | ២៤,៣%* | ២៥,៨% | ២៦,៥%* | ↑ |
| | *អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ (ស្រី)* | ២៥,២%* | ២៥,៨% | ២៨,១%* | ↑ |
| ៣ | អត្រាឆ្លងភូមិសិក្សាពីម.បឋមភូមិទៅម.ទុតិយភូមិ | ៧១,១% | ៧៣,១៩% | ៧៤,៥% | ↑ |
| | *អត្រាឆ្លងភូមិសិក្សាពីម.បឋមភូមិទៅម.ទុតិយភូមិ (ស្រី)* | ៧២,៩% | ៧៣,១៩% | ៧៧,៦% | ↑ |
| ៤ | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ៣៩,២% | ៤២% | ៤២,៦% | ↑ |
| | *អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ស្រី)* | ៤១,២% | ៤២% | ៤៦,០% | ↑ |
| ៥ | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ១៩,២%** | ១៧,៥៤% | ១៧,០%*** | ↑ |
| | *អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ស្រី)* | ១៨,២%** | ១៦,៦៦% | ១៥,៥%*** | ↑ |
| ៦ | ចំនួនសិស្សមធ្យមសិក្សាបឋមភូមិទទួលអាហារូបករណ៍ | | ៦០ ០០០ | ៦៩ ៥១៤*** | ↑ |
| ៧ | ភាគរយគ្រឹះស្ថានមធ្យមសិក្សាអនុវត្តកម្មវិធីសាលាកុមារមេត្រី | ២២,៨៦% | ២៦,៧% | ២៣,៣៨% | → |
| ៨ | ភាគរយសាលាមធ្យមសិក្សាមានបង្គន់អនាម័យ | | | | |
| | *មធ្យមសិក្សាបឋមភូមិ* | ៦៥,៥% | ៦៧,៨% | ៨៣,៤% | ↑ |
| | *មធ្យមសិក្សាទុតិយភូមិ* | ៩៨,៥% | ១០០% | ៩១,២% | ↓ |
| ៩ | ភាគរយសាលាមធ្យមសិក្សាមានទឹកស្អាត | | | | |
| | *មធ្យមសិក្សាបឋមភូមិ* | ៣៣,៩% | ៣៦,៥% | ៤៣,៩% | ↑ |
| | *មធ្យមសិក្សាទុតិយភូមិ* | ៥៧,២% | ៦៦,៧% | ៥៣,៩% | ↓ |
| ១០ | ចំនួនវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស | ៤ | ៦ | ៧ | ↑ |
| ១១ | ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស | ១ ០៦៦ | ១ ២៣៨ | ១ ១៤៨ | → |
| | *ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស (ស្រី)* | | ៥១៥ | ៤៦៤ | ↑ |
| ១២ | ចំនួនគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិទទួលការបណ្តុះបណ្តាល រូបមន្ត ១២+៤ | N/A | N/A | អនុវត្តនៅឆ្នាំ២០១៨ | |
| ១៣ | ភាគរយគ្រូបង្រៀនមធ្យមសិក្សាយ៉ាងហោចណាស់មានបរិញ្ញាបត្រ ក្នុងឆ្នាំនីមួយៗ | ៣៤,៥% | ៣៥% | ៣៥,១៨% | ↑ |
| ១៤ | ចំនួនគ្រូបង្រៀនមធ្យមសិក្សាបានទទួលការអភិវឌ្ឍជំនាញវិជ្ជាជីវៈបន្ត ក្នុងឆ្នាំនីមួយៗ | N/A | ៥០០ | ៦៩៨ | ↑ |
| **គោលនយោបាយទី ២ ៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់** | | | | | |
| | N/A | | | | |

__សម្គាល់__: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓សម្រេចមិនបានតាមចំណុចដៅ

* រួមបញ្ចូលទាំងសាលាឯកជន ** ឆ្នាំសិក្សា២០១៤-២០១៥ *** ឆ្នាំសិក្សា២០១៥-២០១៦

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- សមត្ថភាពជំនាញវិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀននៅមធ្យមសិក្សាមិនទាន់ឆ្លើយតបទៅនឹងបរិបទថ្មី
- គណៈគ្រប់គ្រងសាលារៀនមួយចំនួនមិនទាន់មានសមត្ថភាពពេញលេញលើការដឹកនាំគ្រប់គ្រង ផ្អែកលើលទ្ធផល
- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្ភារៈបង្រៀននិងរៀន គ្រូឯកទេសតាមមុខវិជ្ជាមួយចំនួន ជាពិសេសមុខវិជ្ជាវិទ្យាសាស្ត្រ និងគ្រូបង្រៀនបច្ចេកទេសនៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស មិនទាន់ឆ្លើយតបតាមតម្រូវការ
- កម្មវិធីតម្រង់ទិសវិជ្ជាជីវៈ និងប្រឹក្សាអាជីពពុំទាន់បានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា
- សាលារៀនភាគច្រើនពុំទាន់មានលទ្ធភាពរៀបចំបន្ទប់ប្រឹក្សាអាជីព
- ការងារអធិការកិច្ចនៅមធ្យមសិក្សាមិនទាន់បានអនុវត្តទូលំទូលាយ។

## ២.២.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា

### ក. លទ្ធផលសម្រេចបាន

### ក.១ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

គ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមាន ១២១ កើន ៣ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ៤៨ និងឯកជន ៧៣ ដែលមានទីតាំងនៅតាមបណ្តារាជធានី ខេត្ត ២០។ គ្រឹះស្ថានឧត្តមសិក្សាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន ១៦។ គ្រឹះស្ថានឧត្តមសិក្សាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡាមាន ៧៣ រដ្ឋ ១៣ និងឯកជន ៦០។ គ្រឹះស្ថានឧត្តមសិក្សា ៣៨ បណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ។

**តារាងទី១១ ៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ**

| ល.រ | ឈ្មោះក្រសួង ស្ថាប័ន | រដ្ឋ | ឯកជន | សរុប |
|---|---|---|---|---|
| ១ | ក្រសួងអប់រំ យុវជន និងកីឡា | ១៣ | ៦០ | ៧៣ |
| ២ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១២ | ១៣ | ២៥ |
| ៣ | ក្រសួងការពារជាតិ | ៥ | ០ | ៥ |
| ៤ | ក្រសួងធម្មការ និងសាសនា | ៣ | ០ | ៣ |
| ៥ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៣ | ០ | ៣ |
| ៦ | ក្រសួងសុខាភិបាល | ២ | ០ | ២ |
| ៧ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១ | ០ | ១ |
| ៨ | ក្រសួងមហាផ្ទៃ | ១ | ០ | ១ |
| ៩ | ទីស្តីការគណៈរដ្ឋមន្ត្រី | ១ | ០ | ១ |
| ១០ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ១ | ០ | ១ |
| ១១ | ធនាគារជាតិនៃកម្ពុជា | ១ | ០ | ១ |
| ១២ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ | ០ | ១ |
| ១៣ | ក្រសួងរ៉ែ និងថាមពល | ១ | ០ | ១ |
| ១៤ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១ | ០ | ១ |
| ១៥ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ | ០ | ១ |
| ១៦ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | ១ | ០ | ១ |
| | **សរុប** | **៤៨** | **៧៣** | **១២១** |

បុគ្គលិកអប់រំឧត្តមសិក្សាទាំងជនជាតិខ្មែរ និងជនបរទេសមាន ១៣ ៥០២ នាក់ ស្រី ២ ៣១០ នាក់ ស្មើនឹង ១៧,១៦ ភាគរយ ក្នុងនោះគ្រូមានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ៣ ១៦៦ នាក់ ស្មើនឹង ២៣,៥១ ភាគរយ ស្រី ៩៦៧ នាក់ ស្មើនឹង ៣០,៥៤ ភាគរយ កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ៩ ៣២០ នាក់ ស្មើនឹង ៦៩,២៣ ភាគរយ ស្រី ១ ១៦៥ នាក់ ស្មើនឹង ១២,៥០ ភាគរយ និងកម្រិតបណ្ឌិត ១ ០១៦ នាក់ ស្មើនឹង ៧,៥៤ ភាគរយ ស្រី ៩៩ នាក់ ស្មើនឹង ៩,៧៤ ភាគរយ។

### តារាងទី១២ ៖ ការប្រៀបធៀបបុគ្គលិកអប់រំនៅឧត្តមសិក្សា

| គ្រូបង្រៀន | ឆ្នាំសិក្សា២០១៤-២០១៥ | | | | ឆ្នាំសិក្សា២០១៥-២០១៦ | | | |
|---|---|---|---|---|---|---|---|---|
| | បរិញ្ញាបត្រ | បរិ.ជាន់ខ្ពស់ | បណ្ឌិត | សរុប | បរិញ្ញាបត្រ | បរិ.ជាន់ខ្ពស់ | បណ្ឌិត | សរុប |
| ជនជាតិខ្មែរ | ២ ៧៧២ | ៧ ៩៩០ | ៩០៦ | ១១ ៦៦៨ | ២ ៩៩០ | ៨ ៩៨៥ | ៩៤១ | ១២ ៩១៦ |
| ជនបរទេស | ១៩២ | ៣៣១ | ៦៥ | ៥៨៨ | ១៧៦ | ៣៣៥ | ៧៥ | ៥៨៦ |
| **សរុប** | **២ ៩៦៤** | **៨ ៣២១** | **៩៧១** | **១២ ២៥៦** | **៣ ១៦៦** | **៩ ៣២០** | **១ ០១៦** | **១៣ ៥០២** |

### រូបភាពទី២៤ ៖ ការប្រៀបធៀបបុគ្គលិកអប់រំនៅឧត្តមសិក្សាឆ្នាំសិក្សា២០១៤-២០១៥ និង២០១៥-២០១៦




*រូបភាពទី២៤ បញ្ជាក់ថា គុណវុឌ្ឍិរបស់បុគ្គលិកអប់រំបានឆ្លើយតបទៅនឹងកំណែទម្រង់គុណភាពអប់រំនៅឧត្តមសិក្សា។*

និស្សិតកំពុងសិក្សាសរុប ២១៩ ០៦៩ នាក់ ស្រី ៤៣,៦៩ ភាគរយ ក្នុងនោះ៖ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររង ២៣ ៧៤៦ នាក់ ស្រី ៤៧,៩៤ ភាគរយ។ និស្សិតអាហារូបករណ៍មាន ១ ៥៩៩ នាក់ ស្រី ៣៧,៧១ ភាគរយ និងនិស្សិតសិក្សាបង់ថ្លៃ ២២ ១៤៧ នាក់ ស្រី ៤៨,៦៧ ភាគរយ។ ប្រៀបធៀបនឹងឆ្នាំសិក្សាកន្លងមក និស្សិតថ្នាក់បរិញ្ញាបត្ររងថយ ១ ២២៤ នាក់ ស្រីថយ ៧០,៥០ ភាគរយ។

### រូបភាពទី២៥ ៖ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររងពីឆ្នាំសិក្សា២០០៦-០៧ ដល់ឆ្នាំសិក្សា២០១៥-១៦




*រូបភាពទី២៥ បញ្ជាក់ថាចំនួននិស្សិតបរិញ្ញាបត្ររងបានឆ្លើយតបទៅនឹងកំណែទម្រង់វិស័យអប់រំ។*

និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រមាន ១៧៤ ១៤២ នាក់ ស្រី ៤៦,០៥ ភាគរយ បើធៀបនឹងឆ្នាំសិក្សាកន្លងមក និស្សិតថ្នាក់បរិញ្ញាបត្រថយ ៨ ៨៤៥ នាក់ ស្រីថយ ៤៨,៧៩ ភាគរយ។ និស្សិតអាហារូបករណ៍មាន ២៦ ១៧៧ នាក់ ស្រី ៤៥,៩៤ ភាគរយ បើធៀបនឹងឆ្នាំសិក្សាកន្លងមក និស្សិតអាហារូបករណ៍កើន ២ ១៨៥ នាក់ ស្រីកើន ៣០,៩៣ ភាគរយ។ និស្សិតកំពុងសិក្សាឆ្នាំទី១ នៃថ្នាក់បរិញ្ញាបត្រ ៤៤ ៦៥៩ នាក់ ស្រី ៤៦,៨៨ ភាគរយ បើធៀបនឹងឆ្នាំសិក្សាកន្លងមក និស្សិតឆ្នាំទី១ កើន ៣ ៣០៧ នាក់ ស្រីកើន ៤៥,២៣ ភាគរយ។

**រូបភាពទី២៦ ៖ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ពីឆ្នាំសិក្សា ២០០៦-០៧ ដល់ឆ្នាំសិក្សា២០១៥-១៦**




*រូបភាពទី២៦ ឆ្លុះបញ្ចាំងឱ្យឃើញថា និស្សិតស្រីកាន់តែមានកាលានុវត្តភាពបន្តការសិក្សានៅឧត្តមសិក្សា។*

និស្សិតកំពុងសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រមាន ១៩ ៩៥២ នាក់ កើន ២,៧០ ភាគរយ ស្រី ២០,៧៥ ភាគរយ កើន ៣,១១ ភាគរយ ក្នុងនោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ១៨ ៧២៣ នាក់ កើន ២,៥៧ ភាគរយ ស្រី ២១,៧៨ ភាគរយ កើន ៣,១១ ភាគរយ និងថ្នាក់បណ្ឌិត ១ ២២៩ នាក់ កើន ៤,៦០ ភាគរយ ស្រី ៥,១៣ ភាគរយ កើន ៣,២៨ ភាគរយ។ និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រចូលសិក្សាឆ្នាំដំបូងមាន ៤ ២៦៥ នាក់ កើន ៣១,៣៩ ភាគរយ ស្រី ២៥,៨៤ ភាគរយ កើន ២៨,៥៩ ភាគរយ ក្នុងនោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ៤ ១៩៤ នាក់ កើន ២៩,៤០ ភាគរយ ស្រី ២៦,១៨ ភាគរយ កើន ២៨,២៧ ភាគរយ និងថ្នាក់បណ្ឌិត ៧១ នាក់ កើន ១ ៣២០ ភាគរយ ស្រី ៥,៦៣ ភាគរយ កើន ៣០០ ភាគរយ។

**រូបភាពទី២៧ ៖ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីឆ្នាំសិក្សា ២០០៦-០៧ ដល់ឆ្នាំសិក្សា ២០១៥-១៦**



**រូបភាពទី២៨ ៖ និស្សិតកំពុងសិក្សាថ្នាក់បណ្ឌិត ពីឆ្នាំសិក្សា ២០០៦-០៧ ដល់ឆ្នាំសិក្សា២០១៥-១៦**




*រូបភាពទី២៧ និង២៨ បង្ហាញថានិស្សិតរៀនថ្នាក់ក្រោយបរិញ្ញាបត្របានឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច- សង្គម។*

និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររងមាន ១០ ៦៦៥ នាក់ ស្រី ៤៧,៤២ ភាគរយ បើប្រៀបធៀបនឹងឆ្នាំសិក្សាកន្លងមក និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររងកើន ៣ ០០៥ នាក់ ស្រីកើន ៥១,៨៨ ភាគរយ។ និស្សិតអាហារូបករណ៍មាន ៧២៦ នាក់ ស្រី ៣៣,៣៣ ភាគរយ។ បើប្រៀបធៀបនឹងឆ្នាំសិក្សាកន្លងមក និស្សិតអាហារូបករណ៍ថយ ៣៥៧ នាក់ ស្រីថយ ៤៩,៥៧ ភាគរយ។

**រូបភាពទី២៩ ៖ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររង ពីឆ្នាំសិក្សា២០០៦-០៧ ដល់ឆ្នាំសិក្សា២០១៥-១៦**




*រូបភាពទី២៩ បញ្ជាក់ថានិស្សិតស្រីបញ្ចប់ថ្នាក់បរិញ្ញាបត្ររងមានការកើនឡើងគួរឱ្យកត់សម្គាល់។*

និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រមាន ៤៤ ៦០០ នាក់ ស្រី ២០ ៩១៨ នាក់ ស្មើនឹង ៤៦,៩០ ភាគរយ បើប្រៀបធៀបនឹងឆ្នាំសិក្សាកន្លងមក និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រថយ ៤ ៦៥៤ នាក់ ស្រី ១ ៥៦៩ នាក់ ស្មើនឹង ៣៣,៧១ ភាគរយ។ និស្សិតអាហារូបករណ៍មាន ៧ ៨០៤ នាក់ ស្រី ៣ ១៨៧ នាក់ ស្មើនឹង ៤៣,០៤ ភាគរយ។ បើប្រៀបធៀបនឹងឆ្នាំសិក្សាកន្លងមក និស្សិតអាហារូបករណ៍កើន ៥២៤ នាក់ ស្រី ៣៧១ នាក់ ស្មើនឹង ៧០,៨០ ភាគរយ។

### រូបភាពទី៣០ ៖ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រពីឆ្នាំសិក្សា ២០០៦-០៧ ដល់ឆ្នាំសិក្សា២០១៥-១៦




និស្សិតបញ្ចប់ការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រមាន ៣ ៧២៣ នាក់ កើន ២៣,១២ ភាគរយ ស្រី ២៥,៣៦ ភាគរយ ក្នុងនោះបរិញ្ញាបត្រជាន់ខ្ពស់ ៣ ៧០៦ នាក់ កើន ២៣ ភាគរយ ស្រី ២៥,៤២ ភាគរយ កើន ៣៤,៥៧ ភាគរយ (និស្សិតបានសរសេរនិក្ខេបបទបញ្ចប់ការសិក្សា ២៣៨ នាក់ កើន ២១៣,១៦ ភាគរយ ស្រី ១៨,៩១ ភាគរយ កើន ១៣៦,៨៤ ភាគរយ) និងថ្នាក់បណ្ឌិត ១៧ នាក់ កើន ៥៤,៥៥ ភាគរយ។

### រូបភាពទី៣១ ៖ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីឆ្នាំសិក្សា២០០៦-០៧ ដល់ឆ្នាំសិក្សា២០១៥-១៦




### រូបភាពទី៣២ ៖ និស្សិតបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ពីឆ្នាំសិក្សា ២០០៦-០៧ ដល់ឆ្នាំសិក្សា២០១៥-១៦



## រូបភាពទី៣៣ ៖ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់តាមវិស័យ




## រូបភាពទី៣៤ ៖ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់តាមវិស័យ




## រូបភាពទី៣៥ ៖ និស្សិតកំពុងសិក្សាថ្នាក់បណ្ឌិតតាមវិស័យ



## *ការពង្រឹងយន្តការជ្រើសរើសនិស្សិត*

ក្រសួងបាន៖

- បោះពុម្ពសៀវភៅកម្រងព័ត៌មានសម្រាប់ជំនួយស្មារតីដល់បេក្ខជនស្នើសុំអាហារូបករណ៍ចូលរៀនថ្នាក់បរិញ្ញាបត្រ ៧០ ០០០ ក្បាល និងសៀវភៅមគ្គុទ្ទេសក៍សម្រាប់ការជ្រើសរើសគ្រឹះស្ថានឧត្តមសិក្សា និងមុខជំនាញ ៤ ០០០ ក្បាល និងសំណុំពាក្យសុំអាហារូបករណ៍ចំនួន ២៤០ ០០០ ច្បាប់
- បំប៉នមន្ត្រីទទួលបន្ទុកការងារបែងចែកនិងទទួលពាក្យសុំអាហារូបករណ៍ទូទាំងប្រទេស ៥២៩ នាក់ ស្រី ៩,៤៥ ភាគរយ
- ប្រឡង និងជ្រើសរើសនិស្សិតអាហារូបករណ៍ឱ្យចូលរៀនថ្នាក់បរិញ្ញាបត្រ ៤ ៧៨១ នាក់ ស្រី ៥៩,៦១ ភាគរយ ក្នុងនោះនិស្សិតអាទិភាពទូទៅ ៣ ៥២៤ នាក់ ស្រី ៥៤,៨៣ ភាគរយ អាទិភាពនារី ៥៧៧ នាក់ អាទិភាពក្រីក្រ ៤៧០ នាក់ ស្រី ៥៧,៨០ ភាគរយ អាទិភាពតំបន់ជួបការលំបាក ២០២ នាក់ ស្រី ៣៧,៦២ ភាគរយ
- ទទួលនិស្សិតបរទេសមកសិក្សានៅកម្ពុជា ១៨០ នាក់ ស្រី ១៦,៦៦ ភាគរយ មាននិស្សិតអាហារូបករណ៍ ១៦១ នាក់ កើន ៥,៦០ ភាគរយ ស្រី ៣៦ ភាគរយ ក្នុងនោះនិស្សិតវៀតណាម ៩៧ នាក់ ស្រី ២៨,៨៦ ភាគរយ និស្សិតឡាវ ៤៩ នាក់ ស្រី ៣២,៦៥ ភាគរយ និងនិស្សិតសាធារណរដ្ឋប្រជាមានិតចិន ១៥ នាក់ ស្រី ៩៣,៣៤ ភាគរយ។ និស្សិតសិក្សាបង់ថ្លៃសិក្សា ១៩ នាក់ ស្រី ៤២,១០ ភាគរយ ក្នុងនោះនិស្សិតសាធារណរដ្ឋកូរ៉េ ១៣ នាក់ និស្សិតវៀតណាម ៦ នាក់
- បញ្ជូននិស្សិត ៥២៧ នាក់ ស្រី ២៨,៦០ ភាគរយ ទៅសិក្សានៅប្រទេសថៃ សាធារណរដ្ឋប្រជាមានិតចិន វៀតណាម ជប៉ុន ឡាវ សហព័ន្ធរុស្ស៊ី សិង្ហបុរី គូបា និងហ្វីលីពីន
- ទទួលនិស្សិតអាហារូបករណ៍ខ្មែរ និងបរទេសឱ្យស្នាក់នៅមជ្ឈមណ្ឌលអន្តេវាសិកនារី ៨២៦ នាក់ ស្រី ៧២,៤០ ភាគរយ។

*ប្រការនេះបញ្ជាក់ថា ការពង្រឹងយន្តការនៃការផ្លាស់ប្ដូរនិស្សិតក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការកាន់តែមានភាពទូលំទូលាយ។*

## *ការរៀបចំក្របខណ្ឌគោលនយោបាយឧត្តមសិក្សា*

ក្រសួងបាន៖

- ព្រាងគោលនយោបាយស្ដីពីអភិបាលកិច្ច និងហិរញ្ញប្បទាននៅឧត្តមសិក្សា
- ព្រាងគោលនយោបាយស្ដីពី អាហារូបករណ៍ ការឧបត្ថម្ភធន និងឥណទាន សម្រាប់អ្នកសិក្សានៅឧត្តមសិក្សា ដោយបានសិក្សាស្រាវជ្រាវពីប្រទេសក្នុងតំបន់អាស៊ីចំនួន០៥
- ព្រាងផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍវិស័យឧត្តមសិក្សានៅកម្ពុជា២០១៧-២០៣០ តាមរយៈសិក្ខាសាលា ដោយមានអ្នកចូលរួម ១១១ នាក់ ស្រី ២៦,៣១ ភាគរយ។

### *ការទទួលស្គាល់គុណភាពអប់រំនៅឧត្តមសិក្សា*

ក្រសួងបាន៖

- ពិនិត្យតាមដានស្ថានភាពគ្រប់គ្រង និងការបណ្តុះបណ្តាលការជាក់ស្តែងនៅតាមគ្រឹះស្ថានឧត្តមសិក្សា ចំនួន ៦៤
- វាយតម្លៃសាកល្បងគ្រឹះស្ថានឧត្តមសិក្សាបាន ៣៨ ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- ព្រាងគោលការណ៍ណែនាំស្តីពីការធានាគុណភាពអប់រំផ្ទៃក្នុងកម្រិតកម្មវិធីសម្រាប់គ្រឹះស្ថានឧត្តមសិក្សាតាមរយៈសិក្ខាសាលា ដោយមានអ្នកចូលរួម ១៩១ នាក់ ស្រី ១១,៥១ ភាគរយ
- បណ្តុះបណ្តាលនៅតាមគ្រឹះស្ថានឧត្តមសិក្សា ៤៦ អំពីរបៀបសរសេររបាយការណ៍ស្វ័យវាយតម្លៃបែបវិភាគ
- បំពាក់សម្ភារពិសោធន៍ដល់គ្រឹះស្ថានឧត្តមសិក្សា ៣ រួមមានសាកលវិទ្យាល័យបាត់ដំបង សាកលវិទ្យាល័យ **ជា ស៊ីម** កំចាយមារ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- ជួសជុលមន្ទីរពិសោធន៍នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
- បង្កើតសាកលវិទ្យាល័យ **ហេង សំរិន** ត្បូងឃ្មុំ និងជួយគាំទ្រដំណើរការអនុវត្ត
- ទទួលស្គាល់សាកលវិទ្យាល័យវិទ្យាសាស្ត្រ វិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ
- បញ្ឈប់ការទទួលស្គាល់វិទ្យាស្ថានវិទ្យាសាស្ត្រថៃទាំ និងអមរវេជ្ជសាស្ត្រភ្នំពេញ
- អនុញ្ញាតបង្កើតមហាវិទ្យាល័យថ្មី ដេប៉ាតឺម៉ង់ថ្មី និងមុខជំនាញថ្មីរបស់គ្រឹះស្ថានសិក្សាចំនួន៥។

| លរ | សកម្មភាពការងារ | ចំនួនអ្នកចូលរួម | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | បណ្តុះបណ្តាលគ្រឹះស្ថានសិក្សាស្តីពីការអភិវឌ្ឍកម្មវិធីសិក្សាអប់រំផ្តោតលើលទ្ធផលសិក្សារបស់និស្សិតទាំងទ្រឹស្តី និងការរៀបចំកម្មវិធីជាក់ស្តែងចំនួន ១៤គ្រឹះស្ថាន | ៦៦ | ១១ |
| ២ | សិក្ខាសាលាបណ្តុះបណ្តាលគ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈ និងឯកជន ស្តីពីដំណើរការនៃការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា និងរបៀបសរសេររបាយការណ៍បែបវិភាគចំនួន ២លើក | ២៣២ | ៥១ |
| ៣ | សិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីវាយតម្លៃចំនួន ៤លើក | ២៤៧ | ៥០ |
| ៤ | រៀបចំធ្វើម្ចាស់ផ្ទះកិច្ចប្រជុំគុម្ពប្រចាំឆ្នាំ២០១៦ របស់បណ្តាញធានាគុណភាពអាស៊ានដែលមានភ្ញៀវមកពីបណ្តាប្រទេសអាស៊ានរួមមាន៖ ប្រទេសថៃ ម៉ាឡេស៊ី ហ្វីលីពីន វៀតណាម ឡាវ និងទីម័រឡេស | ១៣៥ | ២៨ |
| ៥ | សិក្ខាសាលាការបណ្តុះបណ្តាលពីរលើកដល់មន្ត្រីសម្របសម្រួល និងមន្ត្រីជំនួយការបច្ចេកទេសអំពីរបៀបពិនិត្យរបាយការណ៍វាយតម្លៃវិធីសាស្ត្រសម្របសម្រួលដំណើការវាយតម្លៃ និងការគ្រប់គ្រងព័ត៌មាន និងទិន្នន័យនៃលទ្ធផលវាយតម្លៃគុណភាពអប់រំ | ៧០ | ១៦ |

| | | | |
|---|---|---|---|
| ៦ | សិក្ខាសាលាពិគ្រោះយោបល់លើស្តង់ដាសម្រាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំថ្នាក់បណ្ឌិតចំនួន ២លើក | ១២៤ | ២០ |
| ៧ | បញ្ជូនមន្ត្រីអប់រំចូលរួមវគ្គបណ្តុះបណ្តាលស្តីពីពង្រឹងសមត្ថភាពនូវប្រព័ន្ធធានាគុណភាពសាកលវិទ្យាល័យឆ្ពោះទៅការលើកកម្ពស់គុណភាពនៅប្រទេសអនុតំបន់ទន្លេមេគង្គ | ៩៥ | ១ |

*ប្រការនេះបញ្ជាក់ថា ប្រព័ន្ធធានាគុណភាពអប់រំនៅឧត្តមសិក្សាត្រូវបានរៀបចំ និងកែលម្អជាបណ្តើរៗឆ្ពោះទៅរកវឌ្ឍនភាព។*

### *ការលើកកម្ពស់សកម្មភាពស្រាវជ្រាវ*

ក្រសួងបាន៖

- បង្កើតមូលនិធិស្រាវជ្រាវក្នុងបណ្តាញស្រាវជ្រាវអាស៊ីអាគ្នេយ៍ និងអឺរ៉ុប
- ជំរុញ និងពិនិត្យតាមដានការអនុវត្តគម្រោងស្រាវជ្រាវនានាក្នុងក្របខណ្ឌ Erasmus+
- ជំរុញ និងលើកកម្ពស់ការសិក្សាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យានៅតាមរាជធានីខេត្តចំនួន ៦៦ វិទ្យាល័យ។

| **លរ** | **សកម្មភាពការងារ** | **ចំនួនអ្នកចូលរួម** | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | សិក្ខាសាលាស្តីពីវេទិកាកម្ពុជាសម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍបណ្តាញស្រាវជ្រាវ និងការកសាងសមត្ថភាព | ៧៨ | ១៣ |
| ២ | សិក្ខាសាលាស្តីពីការចែករំលែកចំណេះដឹង និងលទ្ធផលស្រាវជ្រាវ | ១១៨ | ២៥ |
| ៣ | សិក្ខាសាលាស្តីពី"ការណែនាំ ASEAN Citation Index" | ៦៥ | ១០ |
| ៤ | សហការរៀបចំសន្និសិទវិទ្យាសាស្ត្រថ្នាក់ជាតិលើកទី៣ ស្តីពី "ការអភិវឌ្ឍកសិកម្ម និងជនបទ" នៅសាកលវិទ្យាល័យស្វាយរៀង | ៧០ | ២៥ |
| ៥ | បញ្ជូនមន្ត្រីអប់រំចូលរួមសន្និបាតឆ្នាំ២០១៦ ស្តីពីបណ្តាញអន្តរជាតិនៃសង្គមការគ្រប់គ្រងការស្រាវជ្រាវ នៅប្រទេសអូស្ត្រាលី | ៣ | 0 |
| ៦ | បញ្ជូនមន្ត្រីអប់រំទៅចូលរួមការប្រជុំប្រចាំឆ្នាំនៃគណៈកម្មការអចិន្ត្រៃយ៍ ASEAN Citation Index នៅប្រទេសថៃ | ៥ | 0 |
| ៧ | បញ្ជូនមន្ត្រីអប់រំចូលរួមសន្និសិទអន្តរជាតិលើកទី៩ ស្តីពីការអប់រំវិទ្យាសាស្ត្រ និងគណិតវិទ្យានៅក្នុងប្រទេសអភិវឌ្ឍ នៅប្រទេសមីយ៉ាន់ម៉ា | ៥ | 0 |

## ក.២ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

### *ការលើកកម្ពស់អភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា*

ក្រសួងបាន៖

- អភិវឌ្ឍប្រព័ន្ធទិន្នន័យអាហារូបករណ៍កម្មវិធីបញ្ចូលទិន្នន័យសម្រាប់វិទ្យាល័យ
- កសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យាឧត្តមសិក្សានិងភ្ជាប់ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់គ្រឹះស្ថានឧត្តមសិក្សា

- ចេញសេចក្តីណែនាំស្តីពី៖ ១. ការបង្កើតគោលការណ៍វាយតម្លៃថ្នាក់រៀន ២.ការអភិវឌ្ឍកម្មវិធីចុះកម្មសិក្សារបស់និស្សិត ៣. ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ៤. ការរៀបចំរចនាសម្ព័ន្ធ និងយន្តការអនុវត្តគោលនយោបាយស្តីពីការស្រាវជ្រាវ និងអភិវឌ្ឍន៍របស់គ្រឹះស្ថានឧត្តមសិក្សា
- រៀបចំលក្ខណៈវិនិច្ឆ័យសម្រាប់ការងារធានាគុណភាពអប់រំផ្ទៃក្នុង ដើម្បីជួយដល់គ្រឹះស្ថានឧត្តមសិក្សា
- ព្រាងសៀវភៅណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុនៅឧត្តមសិក្សា និងសៀវភៅណែនាំស្តីពីការគ្រប់គ្រងធនធានមនុស្សនៅឧត្តមសិក្សាសម្រាប់គាំទ្រដល់កំណែទម្រង់អភិបាលកិច្ចនិងស្វ័យភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ
- ពិនិត្យតាមដានការផ្សព្វផ្សាយពាណិជ្ជកម្មសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា
- ចេញទិដ្ឋាការផ្សព្វផ្សាយពាណិជ្ជកម្មសិក្សាដល់គ្រឹះស្ថានឧត្តមសិក្សា ១៤។

| ល.រ | សកម្មភាពការងារ | ចំនួនអ្នកចូលរួម | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំសៀវភៅណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងសៀវភៅណែនាំការគ្រប់គ្រងធនធានមនុស្សសម្រាប់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ | ៣៨ | ៧ |
| ២ | សិក្ខាសាលាស្តីពីលទ្ធផលប៉ះពាល់នៃក្របខណ្ឌគុណវុឌ្ឍិនិងលទ្ធផលសិក្សាលើឧត្តមសិក្សានៅអាស៊ាន | ៧៥ | ១៥ |
| ៣ | រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ស៊ីមេអូ រ៉ាយហេដ លើកទី២៤ និងសិក្ខាសាលាថ្នាក់តំបន់ស្តីពីការផ្សារភ្ជាប់ និងចលភាពផ្នែកសិក្សាធិការ៖ ការអនុវត្តថ្នាក់ជាតិលើការផ្លាស់ប្តូរនិស្សិត និងការផ្ទេរក្រេឌីត | ៩៥ | ១៦ |

## *ការអភិវឌ្ឍសមត្ថភាពមន្ត្រីឧត្តមសិក្សា*

ក្រសួងបានបញ្ជូនបុគ្គលិកអប់រំនាយកដ្ឋានឧត្តមសិក្សា នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ គណៈកម្មការទទួលស្គាល់គុណភាពអប់រំនៅកម្ពុជា និងគ្រឹះស្ថានឧត្តមសិក្សាទៅសិក្សាថ្នាក់បណ្ឌិត និងបរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសអូស្ត្រាលី ៦៤ នាក់ ស្រី ២១,៨៧ ភាគរយ ក្នុងនោះនិស្សិត ៥៨ នាក់ បានបញ្ចប់ការសិក្សាជាស្ថាពរ និង ៦ នាក់ កំពុងសិក្សា និងកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅម៉ាឡេស៊ី ១៦ នាក់ ស្រី ៣១,២៥ ភាគរយ។

| ល.រ | សកម្មភាពការងារ | ចំនួនអ្នកចូលរួម | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | វគ្គបណ្តុះបណ្តាលដល់មន្ត្រីនាយកដ្ឋានឧត្តមសិក្សាស្តីពីរបៀបបញ្ចូលទិន្នន័យនិងការវិភាគរបាយការណ៍សម្រាប់គម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា | ៣៥ | ១០ |
| ២ | វគ្គបណ្តុះបណ្តាលស្តីពីការធ្វើចំណាត់ថ្នាក់មុខជំនាញតាមវិស័យ និងការនាំទិន្នន័យនាំចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាឧត្តមសិក្សា | ២៤ | ៣ |
| ៣ | វគ្គបណ្តុះបណ្តាលមន្ត្រីនាយកដ្ឋានឧត្តមសិក្សាស្តីពីការបញ្ចូលទិន្នន័យនៅក្នុងទម្រង់រួម | ៥០ | ៩ |

| | | | |
|---|---|---|---|
| | របស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាឧត្តមសិក្សា និងទាញ ឬបញ្ចូលទិន្នន័យនៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាឧត្តមសិក្សា | | |
| ៤ | វគ្គបណ្តុះបណ្តាលស្តីពីការដំឡើងនិងការប្រើប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាឧត្តមសិក្សា | ២២៨ | ២០ |
| ៥ | សិក្ខាសាលាស្តីពីការស្ថាបនាមូលដ្ឋានគ្រឹះ និងបរិស្ថានគាំទ្រដល់ការឆ្លងភូមិសិក្សារបស់សិស្សពីថ្នាក់ចំណេះទូទៅ នៅឧត្តមសិក្សាលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា | ៧៧ | ២១ |
| ៦ | សិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ផែនការគោល និងគោលនយោបាយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់គ្រឹះស្ថានឧត្តមសិក្សា | ៧៧ | ៧ |
| ៧ | សិក្ខាសាលាស្តីពីឧត្តមភាពក្នុងភាពជាអ្នកដឹកនាំ | ៥៤ | ១១ |
| ៨ | សិក្ខាសាលាស្តីពី "ការពិនិត្យតាមដានការងាររបស់និស្សិត ដែលបានបញ្ចប់ការសិក្សាពីកម្មវិធីអាហារូបករណ៍នៃគម្រោងលើកកម្ពស់គុណភាពនិងសមត្ថភាពឧត្តមសិក្សា" | ៧៧ | ១៥ |
| ៩ | សិក្ខាសាលាបណ្តុះបណ្តាលស្តីពី "ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ" | ២៥ | ៧ |
| ១០ | សិក្ខាសាលាស្តីពី ការកៀរគរមូលនិធិ និងការលើកកម្ពស់កិត្តិសព្ទរបស់សាកលវិទ្យាល័យ | ៦១ | ២ |
| ១១ | សិក្ខាសាលាស្តីពី "ប្រព័ន្ធព័ត៌មានគ្រប់គ្រងនៅក្នុងសាកលវិទ្យាល័យ" | ៣៤ | ៧ |
| ១២ | សហការរៀបចំសន្និសិទអន្តរជាតិអង្គរលើកទី១ស្តីពីគណិតវិទ្យាអនុវត្ត និងស្ថិតិ | ១០៦ | ៦ |
| ១៣ | បញ្ជូនបុគ្គលិកអប់រំទៅសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើវិស័យវិទ្យាសាស្ត្រនៅប្រទេសម៉ាឡេស៊ី | ១៥ | ៦ |
| ១៤ | បញ្ជូនមន្ត្រីអប់រំចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអប់រំនៅឧត្តមសិក្សាសម្រាប់ពេលអនាគតនៅទីក្រុងហុងកុង | ៤ | ១ |
| ១៥ | បញ្ជូនមន្ត្រីអប់រំចូលរួមសន្និសីទសកលស្តីពី វិស្វកម្ម និងបច្ចេកវិទ្យា ២០១៦ នៅប្រទេសម៉ាឡេស៊ី | ៥ | ០ |
| ១៦ | បញ្ជូនមន្ត្រីអប់រំចូលរួមសន្និសិទអន្តរជាតិស្តីពី "ឆ្ពោះទៅរកឧត្តមភាពនៃការដឹកនាំ និងគ្រប់គ្រងឧត្តមសិក្សា" នៅប្រទេសវៀតណាម | ១៣ | ៣ |
| ១៧ | បញ្ជូនមន្ត្រីអប់រំចូលរួមប្រជុំថ្នាក់តំបន់អាស៊ីលើកទី៨ ស្តីពី ការអប់រំនៅឧត្តមសិក្សា នៅប្រទេសសិង្ហបុរី | ៥ | ០ |
| ១៨ | បញ្ជូនមន្ត្រីអប់រំចូលរួមសន្និសីទអន្តរជាតិស្តីពី វិទ្យាសាស្ត្រជីវិត និងវិស្វកម្មជីវៈសាស្ត្រ នៅប្រទេសម៉ាឡេស៊ី | ៤ | ២ |
| ១៩ | បញ្ជូនមន្ត្រីអប់រំចូលរួមសិក្ខាសាលាអន្តរជាតិស្តីពី ការគ្រប់គ្រង និងគោលនយោបាយវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅសាធារណរដ្ឋប្រជាមានិតចិន | ៤ | ០ |
| ២០ | បញ្ជូនមន្ត្រីអប់រំចូលរួមសិក្ខាសាលាអន្តរជាតិស្តីពីការពង្រឹងសមត្ថភាពក្នុងការវាយតម្លៃ និងពិនិត្យតាមដានផ្នែកវិទ្យាសាស្ត្រ នៅសាធារណរដ្ឋប្រជាមានិតចិន | ២ | ០ |
| ២១ | បញ្ជូនមន្ត្រីអប់រំចូលរួមសន្និសិទអន្តរជាតិ២០១៦ស្តីពីគណិតវិទ្យា និងការអនុវត្ត នៅប្រទេសថៃ | ៥ | ១ |

*ប្រការនេះ បានជួយលើកកម្ពស់សមត្ថភាពមន្ត្រីគ្រប់គ្រង និងសាស្ត្រាចារ្យលើផ្នែកនវានុវត្តន៍ និងឧត្តមានុវត្តន៍។*

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

*ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| | ឧត្តមសិក្សា | ជាក់ស្តែង ២០១៥-១៦ | ចំណុចដៅ ២០១៦-១៧ | ជាក់ស្តែង ២០១៦-១៧ | ស្ថានភាព |
|---|---|---|---|---|---|
| គោលនយោបាយទី១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | |
| ១ | ភាគរយនិស្សិតអាហារូបករណ៍រដ្ឋចូលរៀនឆ្នាំទី១ | ១១% | ១២% | ១០%* | → |
| ២ | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២ ឆ្នាំ) | ១៤% | ១៥% | ១០,៨៦%* | ↓ |
| ៣ | សាស្ត្រាចារ្យដែលមានគុណវុឌ្ឍិ | | | | |
| | *បរិញ្ញាបត្រជាន់ខ្ពស់ក្នុងស្រុក* | ៨ ២៤៧ | ៨ ៤៣២ | ៨ ៩៨៥ | ↑ |
| | *បណ្ឌិតក្នុងស្រុក* | ៩៤១ | ៩៦៨ | ៩៣៩ | → |
| | *បរិញ្ញាបត្រជាន់ខ្ពស់នៅបរទេស* | ៤៩ | ៧១ | ៣៣៥ | ↑ |
| | *បណ្ឌិតនៅបរទេស* | ៨០ | ៩៨ | ៧៥ | ↓ |
| ៤ | ភាគរយនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើ | ៨៩,៦%** | ៧៧% | មិនបានអនុវត្ត | |
| គោលនយោបាយទី ២ ៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | |
| ៥ | ភាគរយនៃគ្រឹះស្ថានឧត្តមសិក្សាសម្រេចបានតាមស្តង់ដាធានាគុណភាពផ្ទៃក្នុង | ២៩% | ៣៣,៣% | ៤០% | ↑ |
| ៦ | ភាគរយនៃគ្រឹះស្ថានឧត្តមសិក្សារៀបចំផែនការថវិកាប្រចាំឆ្នាំ | ៣៣% | ៣៤% | ៤០% | ↑ |
| ៨ | ភាគរយថវិកាសម្រាប់អនុវិស័យឧត្តមសិក្សា | ៩% | ១២% | ១២,៦% | ↑ |

<u>សម្គាល់</u>: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

* ស្ថិតិឆ្នាំសិក្សា២០១៥-២០១៦ ** អនុវត្តក្នុងឆ្នាំសិក្សា២០១៤-២០១៥

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- ការជ្រើសរើសនិស្សិតអាហារូបករណ៍ឱ្យចូលរៀននៅឧត្តមសិក្សាមិនទាន់បានគ្រប់ចំនួនតាមចំណុចដៅ
- កង្វះធនធានមនុស្ស សម្ភារៈ និងថវិកាសម្រាប់ដំណើរការបណ្តុះបណ្តាលជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា
- កង្វះមូលនិធិសម្រាប់ការស្រាវជ្រាវ នៅឧត្តមសិក្សា
- សមត្ថភាពស្រូបនិស្សិតរបស់គ្រឹះស្ថានឧត្តមសិក្សានៅតាមខេត្តនៅមានកម្រិត
- កង្វះលិខិតបទដ្ឋានគតិយុត្តស្តីពីស្វ័យភាព និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា។

## ២.២. ៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ

### ក. លទ្ធផលសម្រេចបាន

### ក.១ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

រាជធានី ខេត្តដែលបានអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈមាន ២៥ កម្មវិធីបង្កើនប្រាក់ចំណូលនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍មាន ២៣ កម្មវិធីក្រោយអក្ខរកម្មមាន ២៣ កម្មវិធីចូលរៀនឡើងវិញមាន ២២ បំពេញវិជ្ជាមាន ២១ កម្មវិធីសមមូលបឋមសិក្សាមាន ២០ និងសមមូលមធ្យមសិក្សាបឋមភូមិមាន ២។

**រូបភាពទី៣៦ ៖ ការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធរបស់រាជធានី ខេត្ត**




បើធៀបនឹងឆ្នាំសិក្សា២០១៤-២០១៥ កម្មវិធីក្រោយអក្ខរកម្មថយ ២ កម្មវិធីចូលរៀនឡើងវិញកើន ១ កម្មវិធីបង្កើនប្រាក់ចំណូលថយ ២ កម្មវិធីសមមូលបឋមសិក្សាកើន ៤ សមមូលមធ្យមសិក្សាបឋមភូមិកើន ២ និងបំពេញវិជ្ជាកើន ២ ។

*កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ*

តាមការអង្កេតស្ថានភាពសង្គម-សេដ្ឋកិច្ចនៅកម្ពុជាឆ្នាំ២០១៥ របស់ក្រសួងផែនការបង្ហាញថា អត្រាអក្ខរកម្មជនពេញវ័យអាយុ ១៥ឆ្នាំឡើង បានថយពី ៨០,៧០ ភាគរយ នៅឆ្នាំ២០១៣ មកនៅត្រឹម ៧៨,១០ ភាគរយ នៅឆ្នាំ២០១៤។ ក្រសួងបានប្រារព្ធទិវាអក្ខរកម្មជាតិអន្តរជាតិ ៨កញ្ញា នៅខេត្តពោធិ៍សាត់ ក្រោមប្រធានបទ «អក្ខរកម្មជួយបង្កើនជីវភាពគ្រួសារ» មានអ្នកចូលរួម ១ ៦០០ នាក់ ស្រី ៣៤ ភាគរយ។

**រូបភាពទី៣៧ ៖ អត្រាអក្ខរជនអាយុ១៥ឆ្នាំឡើងពីឆ្នាំ ២០១០ ដល់ ២០១៤**




*ប្រភព៖ របាយការណ៍អង្កេតស្ថានភាពសង្គម-សេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៥ (តុលា ២០១៥)*

ថ្នាក់អក្ខរកម្មវិជ្ជាជីវៈមាន ១ ១០៨ ថ្នាក់ ថយ ២ ៤០១ ថ្នាក់ ស្មើនឹង ៦៨,៤២ ភាគរយ។ ថ្នាក់អក្ខរកម្មវិជ្ជាជីវៈ គ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡាមាន ៩៨៧ ថ្នាក់ ថយ ២ ៤២៨ ថ្នាក់ និងគាំទ្រដោយដៃគូអភិវឌ្ឍ១០ មាន ១២១ ថ្នាក់ កើន ២៧ ថ្នាក់។

ថ្នាក់អក្ខរកម្មនេះ បានអនុវត្តនៅតាមភូមិ ៩៦៣ ឃុំ សង្កាត់ ៦៣៣ ក្រុង ស្រុក ខណ្ឌ ១៨១ ក្នុងរាជធានី ខេត្តទាំង២៥។

គ្រូអក្ខរកម្មវិជ្ជាជីវៈមាន ១ ១២៥ នាក់ ស្រី ៣៧,៧៧ ភាគរយ ថយ ២ ៤០៩ នាក់ ស្រី ៦៥,៣១ ភាគរយ។ គ្រូអក្ខរកម្មវិជ្ជាជីវៈ គ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡា ៩៨៧នាក់ ស្រី ៣៦,០៦ ភាគរយ ថយ ២ ៤២៨ នាក់ ស្រីថយ ៦៩,៦២ ភាគរយ និងគាំទ្រដោយដៃគូអភិវឌ្ឍ ១៣៨ នាក់ ស្រី ៥០ ភាគរយ កើន ១៩ នាក់ ស្រី ៣០,១៩ ភាគរយ។

អ្នកសិក្សាអក្ខរកម្មវិជ្ជាជីវៈមាន ២២ ៦៥២ នាក់ ស្រី ៦៩,៣៨ ភាគរយ ថយ ៥២ ២៤៧ នាក់ ស្រីថយ ៧០,២០ ភាគរយ។ អ្នកសិក្សាគ្រប់គ្រងដោយក្រសួង ២០ ០៨០ នាក់ ស្រី ៦៩,៦៤ ភាគរយ ថយ ៥២ ៧៥២ នាក់ ស្រី ៧២,៨៤ ភាគរយ និងគាំទ្រដោយដៃគូអភិវឌ្ឍមាន ២ ៥៧២ នាក់ ស្រី ៦៧,៣៤ ភាគរយ កើន ៥០៥ នាក់ ស្រី ៣៨,២៣ ភាគរយ។

**តារាងទី១៣ ៖ ចំនួនគ្រូ ថ្នាក់ អ្នកសិក្សាកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ**

| បរិយាយ | | ២០១៤-២០១៥ | | | ២០១៥-២០១៦ | | | កើន/ថយ (+/-) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | សរុប | ស្រី | ចំនួន | សរុប | ស្រី | ចំនួន | សរុប | ស្រី |
| ថ្នាក់ អក្ខរកម្ម | អ.យ.ក | ៣ ៤១៥ | | | ៩៨៧ | | | -២ ៤២៨ | | |
| | ដៃគូ | ៩៤ | | | ១២១ | | | ២៧ | | |
| គ្រូ អក្ខរកម្ម | អ.យ.ក | | ៣ ៤១៥ | ១ ១៧២ | | ៩៨៧ | ៣៥៦ | | -២ ៤២៨ | -៨១៦ |
| | ដៃគូ | | ១១៩ | ៥៣ | | ១៣៨ | ៦៩ | | +១៩ | +១៦ |
| អ្នក សិក្សា | អ.យ.ក | | ៧២ ៨៣២ | ៥១ ៤៨៨ | | ២០ ០៨០ | ១៣ ៩៨៥ | | -៥២ ៧៥២ | -៣៧ ៥០៣ |
| | ដៃគូ | | ២ ០៦៧ | ១ ២៥៣ | | ២ ៥៧២ | ១ ៧៣២ | | +៥០៥ | +៤៧៩ |
| ថ្នាក់សរុប | | ៣ ៥០៩ | | | ១ ១០៨ | | | -២ ៤០១ | | |
| គ្រូសរុប | | | ៣ ៥៣៤ | ១ ២២៥ | | ១ ១២៥ | ៤២៥ | | -២ ៤០៩ | -៨០០ |
| អ្នកសិក្សាសរុប | | | ៧៤ ៨៩៩ | ៥២ ៧៤១ | | ២២ ៦៥២ | ១៥ ៧១៧ | | -៥២ ២៤៧ | -៣៧ ២០៤ |

*តារាងទី១២ បានបង្ហាញថាចំនួនអនក្ខរជនពេញវ័យអាយុ ១៥ ឆ្នាំឡើងដែលបានចូលរៀនកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ។*

## *កម្មវិធីក្រោយអក្ខរកម្ម*

នៅទូទាំងប្រទេសមានបណ្ណាល័យ ៣៧ ថយ ១ ក្នុងនោះបណ្ណាល័យគាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡាមាន ២៨ ថយ ២ និងបណ្ណាល័យគាំទ្រដោយដៃគូអភិវឌ្ឍមាន ៩ កើន ១ និងមណ្ឌលអាន ១៩៧ ថយ ៥៥ មណ្ឌលអានគាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា ១២៥ ថយ ៥៥។

## តារាងទី១៤ ៖ ស្ថិតិបណ្ណាល័យ មណ្ឌលអាន និងអ្នកចូលអាន

| បរិយាយ | | ២០១៤-២០១៥ | | ២០១៥-២០១៦ | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| បណ្ណាល័យ | អយក | ៣០ | | ២៨ | | -២ | |
| | ដៃគូ | ៨ | | ៩ | | ១ | |
| | សរុប | ៣៨ | | ៣៧ | | -១ | |
| មណ្ឌលអាន | អយក | ១៨០ | | ១១៥ | | -៦៥ | |
| | ដៃគូ | ២២ | | ២២ | | ០ | |
| | **សរុប** | **២០២** | | **១៣៧** | | **-៦៥** | |
| ចំនួនអ្នកអាន (បណ្ណាល័យ) | អយក | ១៤ ៩៦៧ | ៧ ០៥៣ | ២៦ ៣៤០ | ១៦ ១៨៣ | ១១ ៣៧៣ | ៩ ១៣០ |
| | ដៃគូ | ១២៤ | ១០៤ | ៧ ២៤៤ | ៣ ៦០២ | ៧ ១២០ | ៣ ៤៩៨ |
| | **សរុប** | **១៥ ០៩១** | **៧ ១៥៧** | **៣៣ ៥៨៤** | **១៩ ៧៨៥** | **១៨ ៤៩៣** | **១២ ៦២៨** |
| ចំនួនអ្នកអាន (មណ្ឌលអាន) | អយក | ៣៧ ៥៩៨ | ២០ ១៦៤ | ៤៨ ៤៩៥ | ២៥ ៧៦៤ | ១៦ ៨០៧ | ៨ ៨៨៨ |
| | ដៃគូ | ១ ៤៣២ | ៦៤៤ | ១៦ ៣៤១ | ៨ ៩៤០ | ១៤ ៩០៩ | ៨ ២៩៦ |
| | **សរុប** | **៣៩ ០៣០** | **២០ ៨០៨** | **៦៤ ៨៣៦** | **៣៤ ៧០៤** | **៣១ ៧១៦** | **១៧ ១៨៤** |
| **អ្នកចូលអានសរុប** | | **៥៤ ១២១** | **២៧ ៩៦៥** | **៩៨ ៤៨៩** | **៥៤ ២៩៩** | **៥០ ២០៩** | **២៩ ៨១២** |

អ្នកចូលអានមាន ៩៨ ៤៨៩ នាក់ ស្រី ៥៥,៣៦ ភាគរយ កើន ៤៤ ២៩៩ នាក់ ស្រីកើន ៩៤,៨៥ ភាគរយ។ អ្នកចូលអាននៅបណ្ណាល័យ និងមណ្ឌលអានគាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា ៧៤ ៨៣៥ នាក់ ស្រី ៥៦,០៥ ភាគរយ កើន ២២ ២៧០ នាក់ ស្រី ៥៤,១២ ភាគរយ និងអ្នកចូលអាននៅបណ្ណាល័យ និងមណ្ឌលអានគាំទ្រដោយដៃគូអភិវឌ្ឍ ២៣ ៥៨៥ នាក់ ស្រី ៥៣,១៧ ភាគរយ កើន ២២ ០២៩ នាក់ ស្រី ១១ ៧៩៨ នាក់។ ក្នុងបណ្ណាល័យ និងមណ្ឌលអានមានសៀវភៅសាសនា ទស្សនាវដ្ដី សៀវភៅរឿង សៀវភៅប្រលោមលោក សៀវភៅសិស្ស គ្រូ និងឯកសារផ្សេងទៀត។

*កម្មវិធីនេះ បានជួយបង្កើនចំណេះដឹង និងទប់ស្កាត់គ្រោះភ្លេចអក្សរដល់អក្ខរជនថ្មី។*

### *កម្មវិធីចូលរៀនឡើងវិញ*

សិស្សបោះបង់ការសិក្សានៅកម្រិតបឋមសិក្សាមាន ៩២ ៤៩០ នាក់ ស្រី ៣៩,៩ ភាគរយ ដែលទាមទារឱ្យពង្រីកការអនុវត្តកម្មវិធីចូលរៀនឡើងវិញ។

## តារាងទី១៥ ៖ ស្ថិតិថ្នាក់ គ្រូ និងសិស្សកម្មវិធីចូលរៀនឡើងវិញ

| បរិយាយ | | ២០១៤-២០១៥ | | ២០១៥-២០១៦ | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ថ្នាក់ | អយក | ៧៧០ | | ៦៨២ | | -៨៨ | |
| | ដៃគូ | ៤៧ | | ៩៤ | | ៤៧ | |
| | **សរុប** | **៨១៧** | | **៧៧៦** | | **-៤១** | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ្រូថ្នាក់ចូលរៀនឡើងវិញ | អយក | ៧៧០ | ២១៥ | ៦៨២ | ១៨៥ | -៨៨ | -៣០ |
| | ដៃគូ | ៤៧ | ១៤ | ៩៤ | ៤៧ | ៤៧ | ៣៣ |
| | **សរុប** | **៨១៧** | **២២៩** | **៧៧៦** | **២៣២** | **-៤១** | **៣** |
| សិស្ស | អយក | ១៣ ៥៨៦ | ៦ ១៥២ | ១២ ១៧១ | ៥ ៥៤៣ | -១ ៨១៥ | -៦០៩ |
| | ដៃគូ | ២៣៤ | ១០៤ | ៨១១ | ២១៤ | ១៧៧ | ១១០ |
| | **សរុប** | **១៣ ៨២០** | **៦ ២៥៧** | **១២ ៥៨២** | **៥ ៧៥៧** | **-១ ២៣៨** | **-៤៩៩** |

ថ្នាក់កម្មវិធីចូលរៀនឡើងវិញមាន ៧៧៦ ថយ ៤១ ថ្នាក់ ក្នុងនោះថ្នាក់គាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា ៦៨២ ថយ ៨៨ និងដៃគូអភិវឌ្ឍមាន ៩៤ ថ្នាក់ កើន ៤៧។

គ្រូកម្មវិធីចូលរៀនឡើងវិញមាន ៧៧៦ នាក់ ស្រី ២៩,៨៩ ភាគរយ ថយ ៤១ នាក់ ស្រីកើន ៥,៩៣ ភាគរយ ក្នុងនោះគ្រូគាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា ៦៨២ នាក់ ថយ ៨៨ នាក់ ស្រី ៩,៧៦ ភាគរយ និងគាំទ្រដោយដៃគូអភិវឌ្ឍ ១ មាន ៩៤ នាក់ កើន ៤៧ នាក់។

សិស្សចូលរៀនឡើងវិញមាន ១២ ៥៨២ នាក់ ស្រី ៥៥,៥៤ ភាគរយ ថយ ១ ២៣៨ នាក់ ស្រីថយ ៧,៩៨ ភាគរយ ក្នុងនោះគាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា ១២ ១៧១នាក់ ស្រី ៥៥,៥៦ ភាគរយ ថយ ១ ៨១៥ នាក់ និងគាំទ្រដោយដៃគូអភិវឌ្ឍ ៨១១ នាក់ កើន ១៧៧ នាក់។

*ការអនុវត្តកម្មវិធីចូលរៀនឡើងវិញបានរួមចំណែកបង្កឱកាសឱ្យសិស្សបោះបង់អាចបន្តការសិក្សាតាមសាលារៀននៅក្នុងប្រព័ន្ធឡើងវិញ។*

### *កម្មវិធីបង្កើនប្រាក់ចំណូលតាមរយៈមជ្ឈមណ្ឌលសិក្សាសហគមន៍*

មជ្ឈមណ្ឌលសិក្សាសហគមន៍គ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡាបានដំណើរការថ្នាក់ជំនាញ ៥១០ ថ្នាក់ លើជំនាញ ៣១ ក្នុងនោះ ថ្នាក់ជំនាញកាត់ដេរមាន ២០៧ ថ្នាក់ សិស្សចូលរៀន ៣ ៨៨៣ នាក់ ស្មើនឹង ៣៩,៧៦ ភាគរយ ស្រី ៩៤,៦៥ ភាគរយ។

*ការគ្រប់គ្រង និងដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍មានប្រសិទ្ធភាព និងធានានិរន្តរភាពដោយមានការឧបត្ថម្ភពេញលេញពីរាជរដ្ឋាភិបាល។*

### តារាងទី១៦ ៖ ស្ថិតិថ្នាក់ គ្រូជំនាញ អ្នករៀនជំនាញមុខរបរ និងមជ្ឈមណ្ឌលសិក្សាសហគមន៍

| បរិយាយ | | ២០១៤-២០១៥ | | ២០១៥-២០១៦ | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ម.ស.ស | អ.យ.ក | ៣២៤ | | ៣២៧ | | ៣ | |
| | ដៃគូ | ១៨ | | ២៦ | | ៨ | |
| | **សរុប** | **៣៤២** | | **៣៥៣** | | **១១** | |
| ថ្នាក់ជំនាញមុខរបរ | អ.យ.ក | ៤៩៩ | | ៥១០ | | ២ | |
| | ដៃគូ | ៤៥ | | ៣៩ | | -៦ | |
| | **សរុប** | **៥៤៤** | | **៥៤០** | | **-៤** | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ្រូជំនាញមុខរបរ | អ.យ.ក | ៥០៥ | ២៦២ | ៥០៣ | ២៧៧ | -២ | ១៥ |
| | ដៃគូ | ៦៣ | ២០ | ៤២ | ២៥ | -២១ | ៥ |
| | **សរុប** | **៥៦៨** | **២៨២** | **៥៤៥** | **៣០២** | **-២៣** | **២០** |
| អ្នករៀនជំនាញ | អ.យ.ក | ៧ ០៦៦ | ៤ ៥៥២ | ៨ ១៩៧ | ៥ ៣៩០ | ១ ១៣១ | ៨៣៨ |
| | ដៃគូ | ១ ០២៤ | ៥៦០ | ១ ៧៥២ | ១ ០៤៧ | ៧២៨ | ៤៨៧ |
| | **សរុប** | **៨ ០៩០** | **៥ ១១២** | **៩ ៩៤៩** | **៦ ៤៣៧** | **១ ៨៥៩** | **១ ៣២៥** |

មជ្ឈមណ្ឌលសិក្សាសហគមន៍សរុប ៣៥៣ កើន ១១ ក្នុងនោះគ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡា ៣២៧ កើន ៣ បានដំណើរការ ៣០៥ និងមជ្ឈមណ្ឌលសិក្សាសហគមន៍គ្រប់គ្រងដោយដៃគូអភិវឌ្ឍ ២៦ កើន ៨ បានដំណើរការ ២៦ ។ ថ្នាក់ជំនាញសរុប ៥៤០ នាក់ ថយ ៤ ក្នុងនោះគ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡា ៥០១ កើន ២ ដៃគូអភិវឌ្ឍ ៣៩ ថយ ៦។ គ្រូជំនាញ ៥៤៥ នាក់ ស្រី ៥៥,៤១ ភាគរយ ថយ ២៣ ប៉ុន្តែស្រីកើន ៧,០៩ ភាគរយ។ គ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡា ៥០៣ នាក់ ស្រី ៥៥,០៦ ភាគរយ ថយ ២ នាក់ ប៉ុន្តែស្រីកើន ៥,៧៣ ភាគរយ និងដៃគូ ៤២ នាក់ ស្រី ៥៩,៥២ ភាគរយ ថយ ២១ នាក់ ស្រីថយ ២៥ ភាគរយ ។ អ្នកចូលរៀនមាន ៩ ៩៤៩ នាក់ ស្រី ៦៤,៦៩ ភាគរយ កើន ១ ៨៥៩ នាក់ ស្រីកើន ២៥,៩២ ភាគរយ។ គ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡា ៨ ១៩៧ នាក់ ស្រី ៦៥,៧៥ ភាគរយ កើន ១ ១៣១ នាក់ ស្រីកើន ១៨,៤១ ភាគរយ និងដៃគូ ១ ៧៥២ នាក់ ស្រី ៥៩,៧៦ ភាគរយ កើន ៧២៨ នាក់ ស្រីកើន ៨៦,៩៦ ភាគរយ ។

### *កម្មវិធីសមមូល-បំពេញវិជ្ជា*

### *កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ*

ថ្នាក់កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធមាន ២៥៧ ថ្នាក់ គ្រូបង្រៀន ២៥៧ នាក់ ស្រី ២៩,១៨ ភាគរយ កើន ៥០ ស្រីកើន ៥០ ភាគរយ។ ក្នុងនោះថ្នាក់គាំទ្រដោយក្រសួង ២៤៥ ថ្នាក់ កើន ៦៧ គ្រូបង្រៀន ២៤៥ នាក់ ស្រី ២៧,៣៤ ភាគរយ កើន ៦៧ នាក់។ ថ្នាក់គាំទ្រដោយដៃគូអភិវឌ្ឍមាន ១២ ថ្នាក់ ថយ ១៧ គ្រូបង្រៀន ១២ នាក់ ស្រី ៦៦,៦៦ ភាគរយ ថយ ១៧នាក់ ។

អ្នកសិក្សាកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធមាន ៥ ១៦៤ នាក់ ស្រី ៥០,៩៦ ភាគរយ កើន ៩៣៦ នាក់ ស្រីកើន ២១,៩៦ ភាគរយ។ អ្នកសិក្សាដែលគ្រប់គ្រងដោយក្រសួងមាន ៤ ៤៦២ នាក់ ស្រី ៥១,៩៧ ភាគរយ កើន ១ ២១៥ នាក់ ស្រីកើន ៤២,៦២ ភាគរយ ។ អ្នកសិក្សាគ្រប់គ្រងដោយដៃគូអភិវឌ្ឍ ៧០២ នាក់ ស្រី ៤៤,៥៨ ភាគរយ ថយ ២៧៩ នាក់ ស្រី ៤១,១៧ ភាគរយ ។

### តារាងទី១៧ ៖ ស្ថិតិថ្នាក់ គ្រូ និងសិស្ស/អ្នករៀនកម្មវិធីសមមូលបឋមសិក្សា

| បរិយាយ | | ២០១៤-២០១៥ | | ២០១៥-២០១៦ | | កើន/ថយ(+/-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ថ្នាក់ | អ.យ.ក | ១៧៨ | | ២៤៥ | | ៦៧ | |
| | ដៃគូ | ២៩ | | ១២ | | -១៧ | |
| | សរុប | ២០៧ | | ២៥៧ | | ៥០ | |
| គ្រូ | អ.យ.ក | ១៧៨ | ៣៣ | ២៤៥ | ៦៧ | ៦៧ | ៣៤ |
| | ដៃគូ | ២៩ | ១២ | ១២ | ៨ | -១៧ | -៤ |
| | សរុប | ២០៧ | ៤៥ | ២៥៧ | ៧៥ | ៥០ | ៣០ |
| សិស្ស | អយក | ៣ ២៤៧ | ១ ៦២៦ | ៤ ៤៦២ | ២ ៣១៩ | ១ ២១៥ | ៦៩៣ |
| | ដៃគូ | ៩៨១ | ៥៣២ | ៧០២ | ៣១៣ | -២៧៩ | -២១៩ |
| | សរុប | ៤ ២២៨ | ២ ១៥៨ | ៥ ១៦៤ | ២ ៦៣២ | ៩៦៣ | ៤៧៤ |

*កម្មវិធីនេះបានជួយដល់ក្រុមមុខសញ្ញាដែលគ្មានឱកាសចូលរៀនតាមសាលារៀនអប់រំក្នុងប្រព័ន្ធ បានរៀនបញ្ចប់កម្រិតបឋមសិក្សា។*

### *កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ*

កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធបានបើកដំណើរការថ្នាក់នៅខេត្តរតនគិរី និងរាជធានីភ្នំពេញ ៤ ថ្នាក់ គ្រូបង្រៀន ១៧ នាក់ ស្រី ២៣,៥២ ភាគរយ សិស្សចូលរៀន ៧៤ នាក់ ស្រី ៥០ ភាគរយ ។

### *មធ្យមសិក្សាបឋមភូមិបំពេញវិជ្ជា*

មធ្យមសិក្សាបឋមភូមិបំពេញវិជ្ជាមានសិស្សចូលរៀន ៨១១ នាក់ ស្រី ២១,៨២ ភាគរយ កើន ២៨៧ នាក់ ស្រីកើន ១៣,៤៦ ភាគរយ។

### *មធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជា*

មធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជាមានសិស្សចូលរៀន ៤ ៨៤១ នាក់ ស្រី ៣៩,៦៤ ភាគរយ កើន ១ ៧៥២ នាក់ ស្រីកើន ៦២,៧៦ ភាគរយ។

### តារាងទី១៨ ៖ ស្ថិតិថ្នាក់ គ្រូ និងសិស្សមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិបំពេញវិជ្ជា

| បរិយាយ | មធ្យមសិក្សាបឋមភូមិបំពេញវិជ្ជា | | | | | | មធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជា | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៤-១៥ | | ២០១៥-១៦ | | កើន ឬ ថយ | | ២០១៤-១៥ | | ២០១៥-១៦ | | កើន/ថយ(+/-) | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| គ្រូ | ប្រើប្រាស់គ្រូអប់រំក្នុងប្រព័ន្ធ | | | | | | | | | | | |
| សិស្ស | ៥២៤ | ១៥៦ | ៨១១ | ១៧៧ | ២៨៧ | ២១ | ៣ ០៨៩ | ១ ១៧៩ | ៤ ៨៤១ | ១ ៩១៩ | ១ ៧៥២ | ៧៤០ |

*កម្មវិធីនេះផ្តល់ការអប់រំនៅកម្រិតមធ្យមសិក្សាដល់អ្នកសិក្សាដែលពុំមានឱកាសគ្រប់គ្រាន់ ដើម្បីឱ្យពួកគេបានរៀន និងប្រឡងបញ្ចប់កម្រិតសិក្សានីមួយៗ ហើយទទួលបានវិញ្ញាបនបត្រ សញ្ញាបត្រដែលមានតម្លៃស្មើកម្រិតមធ្យមសិក្សាចំណេះទូទៅ។*

## *កម្មវិធីកែលម្អគុណភាពនៃជីវិតតាមរយៈសាលារៀនចល័ត*

**តារាងទី១៩ ៖ ស្ថិតិចុះបង្រៀន និងអ្នកចូលរួមកម្មវិធីកែលម្អគុណភាពនៃជីវិត**

| បរិយាយ | ២០១៤-២០១៥ | | | ២០១៥-២០១៦ | | | កើន ( + ) ថយ ( - ) | | | កើន/ថយ(+/-)ជា % | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | សរុប | ស្រី | ចំនួន | សរុប | ស្រី | ចំនួន | សរុប | ស្រី | ចំនួន | សរុប | ស្រី |
| ចុះបង្រៀន | ៥ | | | ៤ | | | -១ | | | -២០ | | |
| អ្នកចូលរួម | | ៥០៨ | ៣៦៤ | | ៣៦៦ | ២១០ | | -១៤២ | -១៥៤ | | -២៧,៩៥ | -៤២,៣១ |

កម្មវិធីកែលម្អគុណភាពនៃជីវិតតាមរយៈរថយន្តចល័តអនុវត្តបាន ៤លើក ថយ ១ លើក មានអ្នកចូលរួម ៣៣៦ នាក់ ស្រី ៦២,៥០ ភាគរយ ថយ ១៤២ នាក់ ស្រីថយ ៤២,៣១ ភាគរយ។

*កម្មវិធីនេះ ផ្តល់ដល់ពលរដ្ឋគ្រប់រូបនូវចំណេះដឹង ឥរិយាបថ តម្លៃ និងបំណិនជីវិតសំខាន់ៗ ដើម្បីជួយពួកគេឱ្យកែលម្អគុណភាពនៃការរស់នៅ។*

## *កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ*

អ្នកសិក្សាបានបញ្ចប់កម្មវិធីអក្ខរកម្មវិជ្ជាជីវៈមាន ១៧ ២៨០ នាក់ ស្រី ៧០,៨០ ភាគរយ ថយ ៣៦ ៧១៦ នាក់ ស្រីថយ ៦៨,៥៣ ភាគរយ។

**រូបភាពទី៣៨ ៖ លទ្ធផលរំដោះគ្រោះមិនចេះអក្សររយៈពេល ៦ ឆ្នាំ**




អ្នកសិក្សាកម្មវិធីអក្ខរកម្មវិជ្ជាជីវៈបានធ្វើបុរេតេស្ត ១៧ ៩៩១ នាក់ ស្រី ៨៦,១៨ ភាគរយ បានធ្វើតេស្តបញ្ចប់ ១៦ ៩៧៩ នាក់ ស្រី ៦០,៦៦ ភាគរយ ធៀបនឹងអ្នកសិក្សាដែលបានចូលរៀន។ អ្នកសិក្សាកម្មវិធីអក្ខរកម្មវិជ្ជាជីវៈបានធ្វើតេស្តជាប់ ១៤ ៧៩៧ នាក់ ស្រី ៨៥,៧៤ ភាគរយ ធៀបនឹងអ្នកសិក្សាដែលបានធ្វើតេស្តបញ្ចប់ ក្នុងនោះអ្នកសិក្សាបានទទួលបណ្ណអក្ខរកម្ម ១០ ៨៣៩ នាក់ ស្រី ៧៨,៨៦ ភាគរយ នៃអ្នកសិក្សាបានធ្វើតេស្តជាប់។

## រូបភាពទី៣៩ ៖ លទ្ធផលកម្មវិធីអក្ខរកម្មឆ្នាំ២០១៦




## *កម្មវិធីក្រោយអក្ខរកម្ម*

## រូបភាពទី៤០ ៖ ការប្រើប្រាស់បណ្ណាល័យ មណ្ឌលអានក្នុងកម្មវិធីក្រោយអក្ខរកម្ម




បណ្ណាល័យមាន ៣៧ កន្លែង ដំណើរការ ៣៣ និងមណ្ឌលអានមាន ១៤៧ ដំណើរការ ១១៩ ។

## *កម្មវិធីចូលរៀនឡើងវិញ*

សិស្សបានបញ្ជូនមាន ១០ ៩១០ នាក់ ស្រី ៤៦,០៤ ភាគរយ ថយ ១ ១៨៦ នាក់ ស្រីថយ ១០,៣០ ភាគរយ។

## រូបភាពទី៤១ ៖ លទ្ធផលកម្មវិធីចូលរៀនឡើងវិញ



### *កម្មវិធីបង្កើនប្រាក់ចំណូល*

សិស្សរៀនជំនាញបានបញ្ចប់ ៨ ២២០ នាក់ ស្រី ៦៧,៩១ ភាគរយ កើន ៦៥៧ នាក់ ស្រីកើន ១៧,៦៩ ភាគរយ។ គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ទាំង ២៥ រាជធានី ខេត្តមាន ១ ៥០៤ នាក់ ស្រី ១៧,៦១ ភាគរយ។

**រូបភាពទី៤២ ៖ លទ្ធផលកម្មវិធីបង្កើនប្រាក់ចំណូល និងមជ្ឈមណ្ឌលសិក្សាសហគមន៍**




### *កម្មវិធីសមមូល-បំពេញវិជ្ជា*

### *កម្មវិធីសមមូលបឋមសិក្សា*

កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ តម្រូវឱ្យអ្នករៀនសិក្សារយៈពេល ២ឆ្នាំ ទើបចប់កម្មវិធី។

ឆ្នាំ២០១៦ សិស្សបានបញ្ចប់កម្មវិធីសមមូលបឋមសិក្សាមាន ៤ ៦២៩ នាក់ ស្រី ៥១,១៥ ភាគរយ កើន ៣ ០០៤ នាក់ ស្រីកើន ២៦៤,៨៦ ភាគរយ។

**រូបភាពទី៤៣ ៖ លទ្ធផលបញ្ចប់កម្មវិធីសមមូលបឋមសិក្សា**




### *កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ*

សិស្សបានបញ្ចប់កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិ ៦៦ នាក់ ស្រី ៥៤,៥៤ ភាគរយ។

*មធ្យមសិក្សាបឋមភូមិបំពេញវិជ្ជា*

បេក្ខជនមធ្យមសិក្សាបឋមភូមិបំពេញវិជ្ជា និងស្វៃរិនមកប្រឡង ៣៦៤ នាក់ ស្រី ៣០,៧៦ ភាគរយ កើន ៥៩នាក់ ស្រីថយ ១៦,៥១ ភាគរយ ហើយក្នុងនោះប្រឡងជាប់ ២៦០ នាក់ ស្រី ៣៤,២៣ ភាគរយ កើន ២០ នាក់ ស្រីកើន ៨,២៤ ភាគរយ។

*មធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជា*

បេក្ខជនមធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជា និងស្វៃរិនបំពេញវិជ្ជាមកប្រឡង ៦ ៥៩៣ នាក់ ស្រី ៣៩,១៦ ភាគរយ ក្នុងនោះប្រឡងជាប់ ៤ ១២៧ នាក់ ស្រី ៥៥,១៩ ភាគរយ កើន ១ ៦១៩ នាក់ ស្រីកើន ៦៧,៧១ ភាគរយ។

## ក.២ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំការគ្រប់គ្រង និងការចាត់ចែងសេវាបង្រៀនគ្រប់កម្មវិធីអប់រំក្រៅប្រព័ន្ធ ដោយអនុលោមតាមអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការគ្រប់គ្រងនិងចាត់ចែងសេវាបង្រៀនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធរបស់រាជរដ្ឋាភិបាល។

ក្រសួងបានៈ

- បំប៉នមន្ត្រីទទួលបន្ទុកការងារអប់រំក្រៅប្រព័ន្ធថ្នាក់ខេត្ត ៨៩ នាក់ ស្រី ១៩,១០ ភាគរយ ស្តីពីការគ្រប់គ្រង និងអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ
- អនុវត្តសាកល្បងកម្មវិធីសិក្សាសម្រាប់កម្មករ កម្មការិនីនៅតាមរោងចក្រ ១៧ ថ្នាក់
- បំប៉នគ្រូអក្ខរកម្មសម្រាប់កម្មករ កម្មការីនីតាមរោងចក្រ
- បំប៉នគ្រូកម្មវិធីសមមូលបឋមសិក្សាថ្នាក់ជាតិ ២៤៦ នាក់ ស្រី ២៨,០៤ ភាគរយ
- អភិវឌ្ឍសមត្ថភាពគ្រប់គ្រងកម្មវិធីចូលរៀនឡើងវិញ ២៤៩ នាក់ ស្រី ១៧,២៦ ភាគរយ
- បំប៉នសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធស្តីពីការរៀបចំផែនការអប់រំក្រៅប្រព័ន្ធ ១១៩ នាក់ ស្រី ១៥,៩៦ ភាគរយ
- អភិវឌ្ឍសមត្ថភាពអ្នកគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដើម្បីផ្ទេរមុខងារជូនថ្នាក់ក្រោមជាតិ ៨៨ នាក់ ស្រី ១៥,៩០ ភាគរយ
- ណែនាំបច្ចេកទេសអំពីការពិនិត្យតាមដាន និងវាយតម្លៃសម្រាប់អនុវិស័យអប់រំក្រៅប្រព័ន្ធ ៣៥៣ នាក់ ស្រី ១០,៤៨ភាគរយ
- បង្កើនសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់ ១២៥នាក់ ស្រី ២០ ភាគរយ។

## ខ.វឌ្ឍនភាពនៃសូចនាករផលសម្រេច

សូចនាករផលសម្រេចរបស់អនុវិស័យអប់រំក្រៅប្រព័ន្ធ ធៀបនឹងផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៦ សម្រេចបាន ៦៦,៦៧ ភាគរយ ជិតសម្រេចបាន ៣៣,៣៤ ភាគរយ ។

## ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច

| ល.រ | ការអប់រំក្រៅប្រព័ន្ធ | ជាក់ស្តែង ២០១៥ | ចំណុចដៅ ២០១៦ | ជាក់ស្តែង ២០១៦ | ស្ថានភាព |
|---|---|---|---|---|---|
| គោលនយោបាយទី១៖ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | |
| ១ | ចំនួនប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | ៥៣ ៩៩៦ | ១៨ ៦០០ | ១៧ ២៨០ | → |
| ២ | ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូល | ១ ៦២៥ | ៤ ២២៨ | ៥ ១៦៤ | ↑ |
| ៣ | ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍ | ៣៤៧ | ៣៤២ | ៣៥៣ | ↑ |
| ៤ | ចំនួនកុមារដែលបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញ និងបានបញ្ជូនទៅក្នុងប្រព័ន្ធ | ១២ ០៩៦ | ១១ ៧០០ | ១០ ៩១០ | → |
| ៥ | ចំនួនអ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ | ៧ ២៧២ | ៧ ៣៧០ | ៨ ២២០ | ↑ |
| គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | |
| ៦ | រាជធានីខេត្តរៀបចំបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ | ២៥ | ២៥ | ២៥ | ↑ |

សម្គាល់: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។បញ្ហាប្រឈមទាំងនោះមានដូចជា៖

- សម្ភារៈសម្រាប់ទ្រទ្រង់ថ្នាក់អក្ខរកម្មវិជ្ជាជីវៈពុំទាន់សមស្រប
- ការវិភាជន៍ថវិកាគាំទ្រការបើកប្រាក់ឧបត្ថម្ភជូនគ្រូជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធនៅមានភាពយឺតយ៉ាវ
- ការផ្សព្វផ្សាយពីកម្មវិធីសមមូលនៅពុំទាន់បានទូលំទូលាយនៅឡើយ
- មជ្ឈមណ្ឌលសិក្សាសហគមន៍មួយចំនួនមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាជនមូលដ្ឋាន
- ការផ្តល់ទិន្នន័យព័ត៌មានអប់រំក្រៅប្រព័ន្ធរបស់រាជធានី ខេត្ត និងដៃគូអភិវឌ្ឍមួយចំនួនមិនទាន់ពេលវេលា
- ខេត្តមួយចំនួនរៀបចំផែនការប្រតិបត្តិ និងបែងចែកថវិកាពុំទាន់ឆ្លើយតបទៅនឹងចំណុចដៅ
- កិច្ចសហការក្នុងការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធរបស់អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធមួយចំនួនមិនទាន់បានទូលំទូលាយ
- ខេត្តមួយចំនួនតូចមិនបានផ្តល់ថវិកាសម្រាប់ដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍និងប្រាក់ឧបត្ថម្ភដល់គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍។

## ២.២.៦ អនុវិស័យ ការអភិវឌ្ឍយុវជន

### ក. លទ្ធផលសម្រេចបាន

*ការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា*

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនបាន៖

- បណ្តុះបណ្តាលថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកការងារអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ស្តីពីការកសាងផែនការ និងឧបករណ៍សម្រាប់ពិនិត្យតាមដាន មានអ្នកចូលរួម ៥៥ នាក់ ស្រី ៤៩,១ ភាគរយ
- អនុម័តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ២០១៦-២០១៨
- បើកកិច្ចប្រជុំលើកទី១ មានអ្នកចូលរួម ៦០ នាក់ ស្រី ១១,៧ ភាគរយ
- ចេញសេចក្តីសម្រេចលេខ ៩៥ សសរ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការកំណត់និមិត្តសញ្ញានិងត្រារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- បោះពុម្ពសៀវភៅគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ៧ ០០០ ក្បាល
- ចេញសេចក្តីសម្រេចលេខ ០២ កជយ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជំនាញចំណុះក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- ចេញសេចក្តីសម្រេចលេខ ០៣ កជយ. ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន
- ចេញសេចក្តីសម្រេចស្តីពីការបង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត លេខ ០៤ កជយ. ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦
- ចេញសេចក្តីសម្រេចស្តីពី បំណែងចែកភារកិច្ចថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍយុវជន លេខ ០១ អគ.កជយ. ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧
- ចេញបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន លេខ ០១ កជយ. ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦
- ចេញបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍយុវជន លេខ ០២ អគ.កជយ. ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧។

#### កម្មវិធីកូនល្អ សិស្សល្អ មិត្តល្អ

*ការងារក្រុមប្រឹក្សាកុមារ*

**តារាងទី២០៖ តារាងប្រៀបធៀបចំនួនក្រុមប្រឹក្សាកុមារឆ្នាំសិក្សា២០១៤-១៥ និង ២០១៥-១៦**

| បរិយាយ | ២០១៤-២០១៥ | ២០១៥-២០១៦ | កើន/ថយ % (+/-) |
|---|---|---|---|
| ចំនួនក្រុមប្រឹក្សាកុមារ | ៧ ៦០១ | ៧ ៩៣១ | ៤,៣៤% |
| ចំនួនសាខា | ៣៨ ២៣៧ | ៣៩ ៥៧៨ | ៣,៥១% |

| | | | |
|---|---|---|---|
| ចំនួនអនុសាខា | ២២៤ ៩៥៧ | ២៣១ ៩០៨ | ៣,៣២ % |
| ចំនួនសមាជិក | ១ ៩៦១ ០២៧ | ១ ៩៧១ ៥៩២ | ០,៧២ % |

តារាងខាងលើបានបង្ហាញថា ក្រុមប្រឹក្សាកុមារ សាខា អនុសាខា និងសមាជិកកើនឡើង ដោយសារការបង្កើតសាលារៀនថ្មី។

*ប្រការនេះបញ្ជាក់ថា រាជធានី ខេត្តបានយកចិត្តទុកដាក់លើការងារក្រុមប្រឹក្សាកុមារ។*

ក្រសួងបានបោះពុម្ពសៀវភៅ កម្មវិធីសាលាកុមារមេត្រីសមាសភាគទី៥ "ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍" ៣ ៥០០ ក្បាល សម្រាប់ចែកជូនក្រុមប្រឹក្សាកុមារតាមរាជធានី ខេត្ត។

### *ការងារក្រុមប្រឹក្សាយុវជន*

**តារាងទី២១ ៖ តារាងប្រៀបធៀបចំនួនក្រុមប្រឹក្សាយុវជនឆ្នាំសិក្សា២០១៤-១៥ និង ២០១៥-១៦**

| បរិយាយ | ២០១៤-២០១៥ | ២០១៥-២០១៦ | កើន/ថយ %(+/-) |
|---|---|---|---|
| ចំនួនក្រុមប្រឹក្សាយុវជន | ៩៩៩ | ៩៥១ | ១,៥៧% |
| ចំនួនសាខា | ៦ ០៣១ | ៦ ០៨២ | ០,៨៩% |
| ចំនួនអនុសាខា | ៣៦ ១៨៦ | ៣៦ ៥៦៩ | ១,០៥% |
| ចំនួនសមាជិក | ២៦៦ ២៩៣ | ២៩៦ ៣៦២ | ១១,២៩% |

*ចំនួនក្រុមប្រឹក្សា សាខា អនុសាខា និងសមាជិកយុវជន មានការកើនឡើងដោយសារកំណើន សាលាមធ្យមសិក្សាថ្មី។ ប្រការនេះបញ្ជាក់ឱ្យឃើញថារាជធានី ខេត្ត យកចិត្តទុកដាក់ចំពោះការងារយុវជន។*

ក្រសួងបាន៖

- ពិនិត្យតាមដានការងារក្រុមប្រឹក្សាកុមារ និងយុវជនបាន ២១២ នៅតាមរាជធានី ខេត្ត
- ប្រជុំបូកសរុបចលនាប្រឡងប្រណាំង ៣ល្អនៅថ្នាក់ជាតិ មានអ្នកចូលរួម ៣៩៨ នាក់ ស្រី ៩១,៩៦ ភាគរយ។ ដោយឡែក រាជធានីភ្នំពេញ ខេត្តកណ្ដាល ព្រៃវែង និងកំពង់ចាម បានប្រជុំបូកសរុប ការងារចលនាប្រឡងប្រណាំង ៣ល្អ។ ខេត្តតាកែវបានរៀបចំនៅថ្នាក់ស្រុក និងសាលាមួយចំនួន។
- លើកទឹកចិត្តកុមារ និងយុវជនដែលជាសមាជិកក្រុមប្រឹក្សាកុមារ និងយុវជន មានស្នាដៃល្អតាមរយៈ កិច្ចសម្ភាស ផ្សព្វផ្សាយតាមវិទ្យុជាតិកម្ពុជាក្នុងនាទីអប់រំការពារសិទ្ធិកុមារ និងយុវជន
- ផ្ដល់រង្វាន់លើកទឹកចិត្តដល់កុមារ និងយុវជន ៩៥០ នាក់ ស្រី ៩០ ភាគរយ មានសៀវភៅ ៩ ១០០ ក្បាល ប៊ិច ៨៩ ប្រអប់ និងសំពៀត ៩៥០
- ផ្ដល់ឱកាសដល់កុមារ និងយុវជនឱ្យចូលរួមក្នុងកម្មវិធីទស្សនកិច្ចសិក្សា និងបោះជំរំ។

### *កម្មវិធីផ្សព្វផ្សាយសកម្មភាពការងារយុវជន*

ក្រសួងបាន៖

- សហការជាមួយក្រសួងព័ត៌មានបង្កើតនាទីអប់រំយុវជននិងកុមារ ដើម្បីផ្សព្វផ្សាយតាមវិទ្យុជាតិកម្ពុជា ដោយមានកម្មវិធីសំណួរ ចម្លើយជូនរង្វាន់ដល់សិស្ស
- សហការជាមួយក្រុមហ៊ុនគុយប៊ូតាកម្ពុជា ផ្តល់កាបូប ៥ ០០០ ដល់សមាជិកក្រុមប្រឹក្សាយុវជននៅវិទ្យាល័យមួយចំនួនក្នុងខេត្តកណ្តាល និងស្វាយរៀង។

### *កម្មវិធីវេទិកាការសិក្សានិងការងារ*

ក្រសួងបាន៖

- រៀបចំវេទិកាការសិក្សា និងការងារនៅខេត្តព្រៃវែង តាកែវ កំពង់ធំ ត្បូងឃ្មុំ បន្ទាយមានជ័យ កំពតនិងកែប មានយុវជនចូលរួម ៦ ៨៦១ នាក់ ស្រី ៣២,២២ ភាគរយ
- ផ្សព្វផ្សាយប្រព័ន្ធអប់រំជំនាញដែលជាតម្រូវការទីផ្សារការងារ
- បណ្តុះបណ្តាលយុវជនពីរបៀបធ្វើផែនការសិក្សាឆ្ពោះទៅរកការចាប់ជំនាញដែលជាឧបនិស្ស័យរបស់ខ្លួន មានអ្នកចូលរួម ៤ ៥៥០ នាក់ ស្រី ២៥,៦៥ ភាគរយ។

### *កម្មវិធីបណ្តុះបណ្តាលជំនាញយុវជនផ្សារភ្ជាប់នឹងសង្គម*

ក្រសួងបាន៖

- បណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាកុមារ និងយុវជន ស្តីពីការចូលរួមការងារសង្គមតាមរយៈ"ចលនា ពលរដ្ឋល្អ បរិស្ថានល្អ និងបេតិកភណ្ឌជាតិ" មានអ្នកចូលរួម ២៤៧ នាក់ ស្រី ៤៥,៧៤ ភាគរយ
- បណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាយុវជនកម្ពុជា ស្តីពីភាពជាអ្នកដឹកនាំ និងបរិស្ថាន មានអ្នកចូលរួម ២៥០ នាក់ ស្រី ៤៦ ភាគរយ
- បណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាយុវជនកម្ពុជាស្តីពីជំនាញបោះជំរំក្រោមប្រធានបទ "យុវជននិងការអភិវឌ្ឍជាតិ" មានអ្នកចូលរួម ៤០០ នាក់ ស្រី ៣៩,២៥ ភាគរយ។

ដោយឡែករាជធានីភ្នំពេញ ខេត្តកំពង់ធំ ត្បូងឃ្មុំ និងឧត្តរមានជ័យ បានរៀបចំកម្មវិធីបោះជំរំ និងទស្សនកិច្ចសិក្សា។

### កម្មវិធីអប់រំអាកប្បកិរិយា

### *ការងារកាយរឹទ្ធិកម្ម*

ក្រសួងបាន៖

- រៀបចំសមាជិកកាយរឹទ្ធិទូទាំងរាជធានី ខេត្តមាន ១៣០ ៩៨៨ នាក់ ស្រី ៤៣,៧២ ភាគរយ
- បំពាក់កន្សែងជូនដល់កាយរឹទ្ធិ ៣ ៨៧៦ នាក់ ស្រី ១៣,៦១ ភាគរយ
- រៀបចំកម្មវិធីបោះជំរំកាយរឹទ្ធិ រាជធានីភ្នំពេញ ខេត្តកណ្តាល និងកំពង់ចាម

- បំប៉នសមត្ថភាពសមាជិកកាយរឹទ្ធិអំពីការតម្រង់ទិសកាយរឹទ្ធិ និងសង្គ្រោះបឋម
- ផ្សព្វផ្សាយផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន ចរាចរណ៍ផ្លូវគោក សុខភាពបន្តពូជ ផ្លូវភេទ សុខភាពគ្រួសារ និងអនាម័យ
- ផ្តល់អាហារូបករណ៍ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដល់សមាជិកកាយរឹទ្ធិ ទៅបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា
- បំផុសសមាជិកកាយរឹទ្ធិឱ្យចូលរួមធ្វើសកម្មភាពសង្គមដូចជាអនាម័យ សម្អាតបរិស្ថាន ទិវាពិភពលោកប្រយុទ្ធប្រឆាំងជំងឺអេដស៍...។

### *ការពង្រឹងសកម្មភាពសមាគមនិស្សិត*

ក្រសួងបាន៖

- រៀបចំសមាគមនិស្សិត ៥៣ នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ
- តម្រង់ទិស និងបណ្តុះបណ្តាលបច្ចេកទេសស្តីពីការរៀបចំសមាគមនៅសាកលវិទ្យាល័យមានជ័យ និងសាកលវិទ្យាល័យ ជាស៊ីម កំចាយមារ។

### *កម្មវិធីផ្លាស់ប្តូរទំនាក់ទំនងយុវជនអន្តរជាតិ*

ក្រសួងបាន៖

- បញ្ជូនយុវជន ២៨ នាក់ ស្រី ៥០ ភាគរយ និងអ្នកដឹកនាំ ១ នាក់ ទៅចូលរួមកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍ និងជប៉ុនលើកទី៤៣ នៅតាមបណ្តាប្រទេសអាស៊ាន និងជប៉ុន
- បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រី ២រូប ទៅចូលរួមការប្រជុំក្រុមការងារអភិវឌ្ឍយុវជនអាស៊ានស្តីពីសន្ទស្សន៍ការអភិវឌ្ឍយុវជនអាស៊ាន នៅលេខាធិការដ្ឋានអាស៊ាន ប្រទេសឥណ្ឌូនេស៊ី
- បញ្ជូនថ្នាក់ដឹកនាំ ១ នាក់ ទៅធ្វើទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន
- បញ្ជូនថ្នាក់ដឹកនាំ ១ នាក់ និងប្រធានប្រតិភូយុវជននាវាអាស៊ីអាគ្នេយ៍ និងជប៉ុនលើកទី៤៣ ចំនួន ១ នាក់ ទៅចូលរួមកិច្ចប្រជុំលើកទី១ នៃគណៈកម្មការគ្រប់គ្រងលើនាវាយុវជនអាស៊ីអាគ្នេយ៍ និងជប៉ុន នៅប្រទេសជប៉ុន
- បញ្ជូនមន្ត្រីដឹកនាំប្រតិភូ ១ នាក់ និងកុមារ ៦ នាក់ ស្រី ៥០ ភាគរយ ទៅចូលរួមសន្និសីទកុមារ នៅប្រទេសជប៉ុន
- បញ្ជូនថ្នាក់ដឹកនាំយុវជន ១ នាក់ ទៅចូលរួមប្រជុំវាយតម្លៃការងារនាវាយុវជនអាស៊ីអាគ្នេយ៍លើកទី៤៣ និងលើកទិសដៅការងារនាវាយុវជនអាស៊ីអាគ្នេយ៍លើកទី៤៤ នៅប្រទេសជប៉ុន
- បញ្ជូនកុមារ និងយុវជនចូលរួមបោះជំរំ ប្រជុំ សិក្ខាសាលា សន្ទនាយុវជនអាស៊ីប៉ាស៊ីហ្វិក វេទិកាយុវជនគំរូ វេទិកាសហគ្រិនវ័យក្មេង ការបណ្តុះបណ្តាលអ្នកដឹកនាំយុវជនអាស៊ានវ័យក្មេង ព្រឹត្តិការណ៍អេកូទេសចរណ៍យុវជនអាស៊ាន ការផ្លាស់ប្តូរបទពិសោធ នៅក្រៅប្រទេសរួមមានប្រទេសសិង្ហបុរី ២៧ នាក់ ស្រី ៤៤,៤៤ ភាគរយ និងមន្ត្រីដឹកនាំ ៣ នាក់ ស្រី ១ នាក់ សាធារណរដ្ឋប្រជាមានិតចិន ១២ នាក់

ស្រី ៥៨,៣៣ ភាគរយ ថៃ ៦ នាក់ ស្រី ៣៣,៣៣ ភាគរយ ជប៉ុន ៧៨ នាក់ ស្រី ៣៥,៨៩ ភាគរយ មន្ត្រីដឹកនាំ ២ នាក់ ស្រី ១ នាក់ ឡាវ ៣ នាក់ ស្រី ៦៦,៦៦ ភាគរយ ឥណ្ឌា ២៤ នាក់ ស្រី ៥០ ភាគរយ មន្ត្រីដឹកនាំ ១ នាក់ និងសាធារណរដ្ឋកូរ៉េ ២០ នាក់ ស្រី ៥០ ភាគរយ

- ដឹកនាំកិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីទទួលបន្ទុកការងារយុវជនលើកទី៨ កិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីទទួលបន្ទុកការងារយុវជនលើកទី៧ កិច្ចប្រជុំយុវជនអាស៊ានលើកទី២១ និងកម្មវិធីប្រគល់រង្វាន់ដល់អង្គការយុវជនអាស៊ានដែលមានស្នាដៃ មានអ្នកចូលរួម ១០០ នាក់ ស្រី ៣៥ ភាគរយ
- ប្រារព្ធខួបលើកទី១៧ ទិវាអន្តរជាតិសម្រាប់យុវជន ១២សីហា ក្រោមប្រធានបទ "អាជីព និងការងារសមរម្យសម្រាប់យុវជនឆ្ពោះទៅរកការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព" មានយុវជនចូលរួម ១ ៧៥០ នាក់ ស្រី ៤២,១៧ ភាគរយ
- ប្រារព្ធខួបលើកទី៦៧ ទិវាកុមារអន្តរជាតិ ១មិថុនា មានអ្នកចូលរួម ១ ៥០០ នាក់ ស្រី ៤៥,៣៣ ភាគរយ ដោយសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- រៀបចំមហាសន្និបាតកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍ មានអ្នកចូលរួម ៣១០ នាក់ ស្រី ៣៧,១០ ភាគរយ នៅខេត្តសៀមរាប
- រៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ដោយសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា
- រៀបចំសិក្ខាសាលាថ្នាក់ឧត្តមមន្ត្រីទទួលបន្ទុកការងារយុវជនអាស៊ានស្តីពី "ការបញ្ចប់ផែនការការងារយុវជនអាស៊ាន និងសំណើសន្ទស្សន៍ការអភិវឌ្ឍយុវជន" មានអ្នកចូលរួម ៦០ នាក់ ស្រី ២៥ ភាគរយ
- ទទួលប្រតិភូកុមារ និងយុវជនជប៉ុន ៦១ នាក់ ស្រី ៦០,៦៥ ភាគរយ។

## *មជ្ឈមណ្ឌលយុវជននិងកម្មវិធីជំនាញវិជ្ជាជីវៈ*

ក្រសួងបាន៖

- បូកសរុបការងារគ្រប់គ្រងមជ្ឈមណ្ឌល និងយុវជន មានថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកការងារមជ្ឈមណ្ឌល ៨៣ នាក់ ស្រី ១៨,០៧ ភាគរយ
- ផ្តល់កុំព្យូទ័រលើតុ ៣០គ្រឿង និងម៉ាស៊ីនព្រីនធ័រ ១គ្រឿង ដល់មជ្ឈមណ្ឌលជាតិយុវជនកម្ពុជា
- ជួសជុលអគារមជ្ឈមណ្ឌលជាតិយុវជននៅខេត្តសៀមរាប ដោយសហការជាមួយអង្គការមូលនិធិក្តីសង្ឃឹមអាស៊ី-អាហ្វ្រិក នៃសាធារណរដ្ឋកូរ៉េ
- ពង្រឹង និងរៀបចំដំណើរការអភិវឌ្ឍមជ្ឈមណ្ឌលយុវជន ២៤ រាជធានី ខេត្ត
- ផ្តល់សេវាបណ្ណាល័យដល់កុមារ និងយុវជន ៥៣២ នាក់ ស្រី ៣៨,៩០ ភាគរយ នៅមជ្ឈមណ្ឌលជាតិយុវជន
- កំណត់ទីតាំងសម្រាប់សង់មជ្ឈមណ្ឌលយុវជនក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ ដោយសហការជាមួយរមណីយដ្ឋានបឹងសំរិទ្ធ។

## *ការបណ្តុះបណ្តាលជំនាញខ្លី*

ក្រសួងបានបណ្តុះបណ្តាលជំនាញខ្លីដល់យុវជន ១ ៣៨៩ នាក់ ស្រី ៥៧,៣១ ភាគរយ លើមុខវិជ្ជាកាត់ដេរ អក្សរភ្លេង កុំព្យូទ័រ ចម្លាក់ស្បែក ចម្លាក់ថ្មកែវ សម្អាងកាយ និងភ្លេងសម័យ។

## *កម្មវិធីយុវជនស្ម័គ្រចិត្ត*

ក្រសួងបាន៖

- បណ្តុះបណ្តាលការងារយុវជនស្ម័គ្រចិត្តថ្នាក់ក្រុង ស្រុក ខណ្ឌ ១៥ នៅតាមរាជធានី ខេត្ត ៨
- បង្កើតក្រុមយុវជនស្ម័គ្រចិត្តថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានសមាជិក ៨០០ នាក់ ស្រី ៣៣,២៥ ភាគរយ
- រៀបចំវេទិកាជាតិស្តីពីការស្ម័គ្រចិត្តនៅកម្ពុជា និងប្រារព្ធទិវាអន្តរជាតិអ្នកស្ម័គ្រចិត្ត ៥ធ្នូ មានអ្នកចូលរួមចំនួន ១ ៧៥០ នាក់ ស្រី ៥១,៨២ ភាគរយ
- លាបថ្នាំការពារជ្រាបទឹកដំបូលអាគារមជ្ឈមណ្ឌលជាតិយុវជនកម្ពុជា ធ្វើធ្នើរដាក់សៀវភៅបន្ថែម ផ្តល់សៀវភៅរឿងព្រេងសម្រាប់កុមារ និងសៀវភៅផ្សេងៗ ២៨០ ក្បាល និងផ្តល់សៀវភៅដល់បណ្ណាល័យ ១៤ តាមស្រុក ដោយសហការជាមួយអង្គការមូលនិធិនៃក្តីសង្ឃឹមអាស៊ី-អាហ្វ្រិក
- ផ្តល់គ្រូឧទ្ទេស និងអ្នកសម្របសម្រួលកម្មវិធីបណ្តុះបណ្តាលយុវជននៅតាមសហគមន៍ដោយសហ-ការជាមួយអង្គការកម្ពុជាដើម្បីស្រាវជ្រាវ អភិវឌ្ឍ និងអប់រំ នៅខេត្តបាត់ដំបង
- បញ្ជូនមន្ត្រីអប់រំបុរស ១ នាក់ ទៅចូលរួមសន្និសីទស្តីពីការងារស្ម័គ្រចិត្ត នៅប្រទេសអាល្លឺម៉ង់
- បញ្ជូនមន្ត្រីអប់រំបុរស ១ នាក់ ទៅចូលរួមពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ស្តីពីកម្មវិធីអ្នកស្ម័គ្រចិត្តអន្តរជាតិម៉ាយខបស៍ក្នុងព្រះរាជាណាចក្រកម្ពុជា នៅប្រទេសម៉ាឡេស៊ី។

## *កម្មវិធីផ្តល់ព័ត៌មានទីផ្សារការងារ និងបាត់ការនៅតាមសហគ្រាសរដ្ឋនិងឯកជន*

ក្រសួងបានដាក់ឱ្យដំណើរការមជ្ឈមណ្ឌលផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ មានអ្នកចូលរួម ៣៥០ នាក់ ស្រី ៤៣,៨៩ ភាគរយ ដោយបានរៀបចំបណ្ណាល័យ បំពាក់សម្ភារៈការិយាល័យ កុំព្យូទ័រ និងម៉ាស៊ីនត្រជាក់ នៅមជ្ឈមណ្ឌលយុវជនខេត្តកំពង់ធំ។

## *កម្មវិធីសហគ្រិនភាព និងភាពជាអ្នកដឹកនាំ*

ក្រសួងបានរៀបចំវេទិកា៖

- យុវជន-សហគ្រិន មានយុវជនចូលរួម ១ ៩៥០ នាក់ ស្រី ៤៣,៥៨ ភាគរយ
- យុវជនស្តីពីភាពជាអ្នកដឹកនាំ និងយុវជន មានយុវជនចូលរួម ២៥០ នាក់ ស្រី ៤០,៨ ភាគរយ។

### *កម្មវិធីទស្សនកិច្ចសិក្សា និងបោះជំរំ*

ក្រសួងបាន៖

- ដឹកនាំប្រតិភូយុវជនស្ម័គ្រចិត្ត ៣០០ នាក់ ស្រី ៤០,៦៦ ភាគរយ ទៅទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធលើការងារស្ម័គ្រចិត្ត ការងារសហគមន៍ និងការស្វែងយល់មរតកវប្បធម៌ខ្មែរ
- បោះជំរំក្រោមប្រធានបទ "យុវជន និងវិទ្យាសាស្ត្រ" ដោយសហការជាមួយអង្គការមូលនិធិក្តីសង្ឃឹមអាស៊ី-អាហ្វ្រិក មានយុវជនចូលរួម ១៣១ នាក់ ស្រី ៣៩,៧ ភាគរយ
- បោះជំរំអន្តរជាតិដោយសហការជាមួយអង្គការសម្ព័ន្ធយុវជនអន្តរជាតិ មានសិស្ស និស្សិតចូលរួម ១ ៨០០ នាក់ ស្រី ៥៥,៥៥ ភាគរយ។

### *ការអភិវឌ្ឍសមត្ថភាព*

ក្រសួងបានបញ្ជូនមន្ត្រីអប់រំ៖

- ២ នាក់ ស្រី ៥០ ភាគរយ ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការវាស់វែង និងវាយតម្លៃលទ្ធផលកម្មវិធីការងារយុវជន" នៅប្រទេសអ៊ីតាលី
- ២ នាក់ ស្រី ៥០ ភាគរយ ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអភិវឌ្ឍកម្មវិធី និងការលើកកម្ពស់ប្រតិបត្តិការសម្រាប់គោលនយោបាយនិងសកម្មភាពយុវវ័យ នៅសាធារណរដ្ឋកូរ៉េ។

## ខ. ការសម្រេចបានសូចនាករផលសម្រេច

### *ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| | ការអភិវឌ្ឍយុវជន | ជាក់ស្តែង ២០១៥-១៦ | ចំណុចដៅ ២០១៦-១៧ | ជាក់ស្តែង ២០១៦-១៧ | ស្ថានភាព |
|---|---|---|---|---|---|
| គោលនយោបាយទី ១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា | | | | | |
| ១ | ចំនួនយុវជនដែលទទួលបានការបណ្តុះបណ្តាលជំនាញខ្លីៗ | ១ ០៥៥ | ៣ ១០០ | ១ ៣៨៩ | ↓ |
| ២ | ចំនួនយុវជនដែលទទួលការបណ្តុះបណ្តាលនិងការបញ្ជ្រាបការងារស្ម័គ្រចិត្ត | ១ ៥០០ | ២ ០០០ | ៣ ១០០ | ↑ |
| ៣ | ចំនួនមជ្ឈមណ្ឌលយុវជន | ១៦ | ១៧ | ២២ | ↑ |
| ៤ | ចំនួនយុវជនដែលបានបង្កើតការងារដោយខ្លួនឯងក្នុងមួយមជ្ឈមណ្ឌលក្នុងមួយឆ្នាំ | ៧ | ១០ | ៧ | ↓ |
| ៥ | ភាគរយសិស្សថ្នាក់ទី៤-៩ចូលរួមក្នុងក្រុមប្រឹក្សាកុមារ | ៩៩% | ១០០% | ៩៩% | → |
| ៦ | ភាគរយសិស្សថ្នាក់ទី១០-១២ចូលរួមក្នុងក្រុមប្រឹក្សាយុវជន | ៨៩% | ៩៨% | ៨៩% | → |
| ៧ | ចំនួនយុវជនដែលបានទទួលការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងសហគ្រិនភាព | ៣៧៥ | ៣០០ | ២៥០ | ↓ |
| គោលនយោបាយទី ២ ៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | |
| | N/A | | | | |

<u>សម្គាល់៖</u> ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- កង្វះមធ្យោបាយ និងសម្ភារបរិក្ខារសម្រាប់ដំណើរការការងារប្រចាំថ្ងៃនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- កង្វះមន្ត្រីមានសមត្ថភាព និងជំនាញផ្នែកយុវជន
- ទីតាំងមជ្ឈមណ្ឌលយុវជនរាជធានី ខេត្តមួយចំនួនធំមិនទាន់មានអគារ និងរបងសម្រាប់ដំណើរការ
- កង្វះការគាំទ្រពីសំណាក់អ្នកពាក់ព័ន្ធ។

គ. បញ្ហាប្រឈម

## ២.២.៧ អនុវិស័យការអប់រំកាយ និងកីឡា

### ក. លទ្ធផលសម្រេចបាន

*ការប្រកួតកីឡាសិស្ស-និស្សិត*

ក្រសួងបាន៖

- ផ្សព្វផ្សាយសេចក្តីណែនាំស្តីពីកម្មវិធីប្រកួតកីឡាជ្រើសរើសជើងឯកទូទាំងប្រទេស រាជធានី ខេត្ត និងគ្រឹះស្ថានសិក្សាទាំងបីកម្រិត
- ប្រកួតកីឡាសិស្សមធ្យមសិក្សាជ្រើសរើសជើងឯកទូទាំងប្រទេសនៅទីរួមខេត្តកំពតមាន ២៥រាជធានីខេត្តចូលរួម ប្រតិភូកីឡា ២ ៨៨០ នាក់ ស្រី ១១២១ នាក់
- ប្រកួតកីឡានិស្សិតឧត្តមសិក្សា និងមធ្យមសិក្សាបច្ចេកទេសនៅរាជធានីភ្នំពេញមាន ២៨គ្រឹះស្ថានសិក្សាចូលរួមប្រតិភូកីឡា ៩៨៧ នាក់ ស្រី ១៩៥ នាក់។

*ការប្រកួតកីឡាជើងឯកតាមសហព័ន្ធ*

ក្រសួងបានរៀបចំការប្រកួត៖

- កីឡាសូហ្វតិន្នីសជ្រើសរើសជើងឯកជាតិនៅរាជធានីភ្នំពេញ មានក្លឹបកីឡា ៨ចូលរួម ប្រតិភូកីឡា ៩២ នាក់ ស្រី ៣១ នាក់
- កីឡាវូស៊ូជ្រើសរើសជើងឯកជាតិនៅរាជធានីភ្នំពេញ មានក្លឹបកីឡា ៩ចូលរួម ប្រតិភូកីឡា ៣០៥ នាក់ ស្រី ១៥៥ នាក់
- កីឡាយូដូជ្រើសរើសជើងឯកនៅរាជធានីភ្នំពេញ មានក្លឹបកីឡា ៥ចូលរួម ប្រតិភូកីឡា ៨៣ នាក់ ស្រី ២១ នាក់
- កីឡាសីប៉ាក់តាក្រជ្រើសរើសជើងឯកជាតិនៅរាជធានីភ្នំពេញមានក្លឹបកីឡា ១៥ចូលរួម ប្រតិភូ ៤០២ នាក់ ស្រី ១៣៣ នាក់
- កីឡាគុងហ្វីលម៉ូដូជ្រើសរើសជើងឯកជាតិនៅរាជធានីភ្នំពេញមានក្លឹបកីឡា ១០ចូលរួម ប្រតិភូកីឡា ១៥០ នាក់ ស្រី ២៦ នាក់
- កីឡាការ៉ាតេដូជ្រើសរើសជើងឯកជាតិនៅរាជធានីភ្នំពេញមានក្លឹបកីឡា ១៧ចូលរួម ប្រតិភូកីឡា ១៨៧នាក់ ស្រី ៦០នាក់
- កីឡាតេក្វាន់ដូអាយធីអេហ្វជ្រើសរើសជើងឯកជាតិនៅរាជធានីភ្នំពេញមានក្លឹបកីឡា ១៤ចូលរួម ប្រតិភូកីឡា ៣៣១ នាក់ ស្រី ៧៦ នាក់
- កីឡាវ៉ូវីណាមជ្រើសរើសជើងឯកជាតិនៅរាជធានីភ្នំពេញមានក្លឹបកីឡា ៧ចូលរួម ប្រតិភូកីឡា ១២៣ នាក់ ស្រី ២៦ នាក់
- កីឡាទូកប្រពៃណីខ្នាតអន្តរជាតិ និងទូកកានូ កាយ៉ាក់ជ្រើសរើសជើងឯកជាតិនៅរាជធានីភ្នំពេញមានក្លឹបកីឡា ៨ចូលរួម ប្រតិភូកីឡា ៤៦២ នាក់ ស្រី ១០៤ នាក់

- កីឡាជិះកង់ដើម្បីទាំងអស់គ្នានៅរាជធានីភ្នំពេញ មានក្លឹបកីឡា ២០ចូលរួម ប្រតិភូកីឡា ២៩៥ នាក់ ស្រី ២៦ នាក់
- កីឡាជាតិលើកទី១ នៅរាជធានីភ្នំពេញ និងខេត្តកំពង់ចាម មាន ១៥ប្រភេទកីឡា៖ កីឡាបាល់ទាត់ បាល់ទះ បាល់បោះ អត្តពលកម្ម ចំបាប់ ប្រដាល់ តេក្វាន់ដូ ដាប៊ីលយូធីអេហ្វ ប៉េតង់ វាយកូនបាល់ វាយកូនឃ្លីលើតុ វាយសី ល្បុក្កតោ កាយសម្ព័ន្ធ ហែលទឹក និងស្វរិនហ្សិកាំប៉ូ ស្មើនឹង ១៨៩ វិញ្ញាសា មានការចូលរួមគ្រប់រាជធានី ខេត្ត ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ប្រតិភូកីឡា ២៧០០ នាក់ ស្រី ៦០៩ នាក់។

*សមិទ្ធផលខាងលើ បានឆ្លុះបញ្ចាំងយ៉ាងប្រត្យក្សអំពីប្រសិទ្ធភាពនិងប្រសិទ្ធផលនៃកំណែទម្រង់វិស័យអប់រំកាយ និងកីឡា។*

**តារាងទី២១ ៖ លទ្ធផលនៃការប្រកួតកីឡាជាលក្ខណៈអន្តរជាតិ**

| ប្រភេទកីឡា | ចំនួនកីឡាករ | ទីកន្លែង | ឈ្មោះការប្រកួត | មេដាយ | | | |
|---|---|---|---|---|---|---|---|
| | | | | មាស | ប្រាក់ | សំរឹទ្ធិ | សរុប |
| បាល់ទាត់ អត្តពលកម្ម វាយកូនឃ្លីលើតុ និងគុនដាវ | ៥៩ | សិង្ហបុរី | សាកលវិទ្យាល័យអាស៊ីអាគ្នេយ៍លើកទី១៨ | ០៤ | ០១ | ០២ | ០៧ |
| សិស្សមធ្យមសិក្សា | ៣៧ | ថៃ | សិស្សមធ្យមសិក្សាអាស៊ីអាគ្នេយ៍លើកទី៨ | ០ | ០ | ០១ | ០១ |
| ចំបាប់ | ៨៧ | កម្ពុជា | ជើងឯកអាស៊ីអាគ្នេយ៍ | ០៣ | ១០ | ១៧ | ៣០ |
| តេក្វាន់ដូ | ៩១ | កម្ពុជា | ជើងឯកអាស៊ីអាគ្នេយ៍លើកទី១ | ៣១ | ១០ | ១១ | ៥២ |
| តេក្វាន់ដូ WTF | ៣ | ហ្វីលីពីន | ប្រកួតជម្រុះកីឡាអូឡាំពិក | ០១ | ០ | ០ | ០១ |
| តេក្វាន់ដូ WTF | ៣ | ហ្វីលីពីន | ជើងឯកអាស៊ីតេក្វាន់ដូលើកទី២២ | ០ | ០១ | ០១ | ០២ |
| ប៉េតង់ បាល់ទាត់ វាយសី វាយកូនឃ្លីលើតុ សីប៉ាក់តាក្រ Folk Sport | ៨១ | ថៃ | កីឡាសុឆន្ទៈអនុតំបន់ទន្លេមេគង្គលើកទី២១ | ១៣ | ០៧ | ០៤ | ២៤ |
| ការ៉ាតេដូ | ១៣ | ម៉ាឡេស៊ី | ជើងឯកអាស៊ីអាគ្នេយ៍លើកទី៥ | ០០ | ០១ | ០០ | ០១ |
| ប៉េតង់ | ២១ | ឡាវ | ជើងឯកអាស៊ីអាគ្នេយ៍លើកទី៣ | ០៥ | ០៥ | ០៦ | ១៦ |
| ប៉េតង់ | ៩ | វៀតណាម | ជើងឯកបើកទូលាយលើកទី២៥ | ០១ | 0 | 0 | ០១ |
| បាល់ទះឆ្នេរខ្សាច់ ប៉េតង់ វ៉ូវីណាម ចំបាប់ MAtial Art | ៦២ | វៀតណាម | កីឡាឆ្នេរខ្សាច់ អាស៊ីលើកទី៥ | ០៦ | ០៦ | ០៩ | ២១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សូហ្វតេនីស | ១២ | ថៃ | ប្រកួតជើងឯកសូហ្វតេនីស ពិភពលោកជុំ លើកទី២ | ០១ | ០២ | ០១ | ០៤ |
| សូហ្វតេនីស | ១០ | សាធារណៈរដ្ឋកូរ៉េ | ប្រកួតកីឡាពានរង្វាន់សូហ្វតេនីសកូរ៉េ | ០០ | ០០ | ០១ | ០១ |
| សូហ្វតេនីស | ១១ | ម៉ាឡេស៊ី | ប្រកួតជើងឯកសូហ្វតេនីសអាស៊ីអាគ្នេយ៍ | ០០ | ០១ | ០០ | ០១ |
| តេក្វាន់ដូ WTF | ៤ | រុស្ស៊ី | ប្រកួតកីឡាអន្តរជាតិកុមារអាស៊ី លើកទី៦ | ០០ | ០០ | ០១ | ០១ |
| ល្បុក្កតោ | ៩ | វៀតណាម | ប្រកួតកីឡាជើងឯកពិភពលោក យុទ្ធគុនវៀតណាម វ៉ូវីណាម ទ្រីយិន លើកទី១ | ០០ | ០០ | ០២ | ០២ |
| ឈិនឡូន | ១៩ | មីយ៉ាន់ម៉ា | ជើងឯកអាស៊ីលើកទី២ | ០១ | ០០ | ០២ | ០៣ |
| កាយវប្បកម្ម | ៦ | ថៃ | ជើងឯកអាស៊ីអាគ្នេយ៍ | ០១ | ០០ | ០១ | ០២ |
| កាយវប្បកម្ម | ៨ | ថៃ | ជើងឯកពិភពលោក | ០០ | ០០ | ០១ | ០១ |
| សីប៉ាក់តាក្រ | ២១ | ថៃ | ពានរង្វាន់ស្តេចថៃ | ០០ | ០២ | ០២ | ០៤ |
| គុងហ្វីលម៉ូដូ | ៥ | កូរ៉េ | ប្រកួតកីឡាយុទ្ធគុនពិភពលោក | ០០ | ០០ | ០២ | ០២ |
| វូស៊ូ | ១៧ | ចិន | សម្តែងក្បាច់គុនតៃជីសុខភាពពិភពលោក លើកទី៦ | ០០ | ០៧ | ១៤ | ២១ |
| សូហ្វតេនីស | ១៧ | ជប៉ុន | ប្រកួតកីឡាសូហ្វតេនីសជើងឯកអាស៊ី | ០០ | ០១ | ០០ | ០១ |
| **សរុបមេដាយ** | | | | **៦៧** | **៥៤** | **៧៨** | **១៩៩** |

*លទ្ធផលនៃការប្រកួតកីឡាជាលក្ខណៈអន្តរជាតិខាងលើ បង្ហាញថា វិស័យកីឡាមានវឌ្ឍនភាពគួរជាទីមោទនៈ។ ប្រការដែលគួរឱ្យកត់សម្គាល់គឺការកើនប្រភេទកីឡា គុណផលកីឡាល្អប្រសើរ ជាពិសេសចំនួនមេដាយមានការកើនឡើង។*

## *ការពង្រឹងសកម្មភាពអប់រំកាយក្នុងម៉ោងសិក្សា និងសកម្មភាពកីឡាក្រៅម៉ោងសិក្សា*

ក្រសួងបាន៖

- អនុវត្តកម្មវិធីប្រកួតកីឡាសិស្សបឋមសិក្សា មធ្យមសិក្សា និងនិស្សិតឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេស ប្រចាំឆ្នាំសិក្សា២០១៥-២០១៦
- ផ្អាកការប្រកួតកីឡាសិស្សបឋមសិក្សាជ្រើសរើសជើងឯកទូទាំងប្រទេសប្រចាំឆ្នាំសិក្សា២០១៥-១៦

- អនុវត្តម៉ោងមុខវិជ្ជាអប់រំកាយក្នុងម៉ោងនិងកីឡាក្រៅម៉ោងសិក្សានៅគ្រឹះស្ថានបឋមសិក្សានិងមធ្យមសិក្សា
- ណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ឱ្យរៀបចំការប្រកួតកីឡាសិស្ស នៅគ្រឹះស្ថានបឋមសិក្សា មធ្យមសិក្សា និងនិស្សិតឧត្តមសិក្សា-មធ្យមសិក្សាបច្ចេកទេស
- រៀបចំទិវាអប់រំកាយ នៅសាលាបឋមសិក្សាគោលដៅ៥ នៅខេត្តបាត់ដំបង មានសិស្សានុសិស្សចូលរួម ៨ ១៣០ នាក់ ស្រី ៥៧,៣៦ ភាគរយ
- បោះពុម្ពសៀវភៅសិក្សាគោលអប់រំកាយសម្រាប់គ្រូ នៅគ្រឹះស្ថានបឋមសិក្សា ៥១ ០០០ ក្បាល និងបែងចែកជូនមន្ទីរអប់រំ យុវជន និងកីឡាទាំង ២៥ រាជធានី ខេត្ត
- អនុម័តកម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំកាយ សម្រាប់គ្រូនៅគ្រឹះស្ថានមធ្យមសិក្សាបឋមភូមិ
- អភិវឌ្ឍសៀវភៅមុខវិជ្ជាអប់រំកាយ សម្រាប់គ្រូនៅសាលាគរុកោសល្យ និងវិក្រឹតការ រាជធានី ខេត្ត
- បញ្ជូនមន្ត្រីជំនាញអប់រំកាយ និងកីឡា ១០ នាក់ ស្រី ២០ ភាគរយ ទៅទស្សនកិច្ចសិក្សាលើការបង្រៀនមុខវិជ្ជាអប់រំកាយ នៅតាមគ្រឹះស្ថានសិក្សាប្រទេសជប៉ុន
- ពិនិត្យតាមដាន និងវាយតម្លៃការហាត់និងការបង្ហាត់មុខវិជ្ជាអប់រំកាយ នៅតាមគ្រឹះស្ថានសិក្សាទាំងបីកម្រិត
- ពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពកីឡាក្រៅម៉ោងសិក្សាតាមសាលារៀន ដោយសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តទាំង២៥
- ពិនិត្យតាមដាន និងវាយតម្លៃ ដោយសហការជាមួយសហព័ន្ធកីឡាបាល់ទាត់ ដើម្បីជ្រើសរើសសាលាមធ្យមសិក្សាដែលមានទីលានកីឡាគ្រប់គ្រាន់ សម្រាប់អនុវត្តកម្មវិធីកីឡាថ្នាលក្រៅម៉ោងសិក្សាមួយសាលា មួយរាជធានីខេត្ត ។

### *ការកសាងលិខិតបទដ្ឋានស្តីពីការអប់រំកាយ និងកីឡា*

ក្រសួងបាន ៖

- បកប្រែនិងចងក្រងឯកសារមេរៀនអប់រំកាយនិងកីឡាសម្រាប់គរុសិស្សមាន ឯកសារកាយសរីរសាស្ត្របទបញ្ញាកីឡាបាល់ទាត់ បាល់ទះ ហែលទឹក និងវិធីសាស្ត្របង្ហាត់កីឡាបាល់ទាត់ កីឡាកាយសម្ព័ន្ធ
- បោះពុម្ពផ្សាយសៀវភៅកម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ ទី៨ និងទី៩
- ប្រកាសទទួលស្គាល់និងផ្តល់ប្រាក់រង្វាន់ ៤៣២ ០០០ ០០០ រៀល ដល់គ្រូបង្វឹក គ្រូជំនួយ និងកីឡាករ ៣៦ នាក់ នៃការប្រកួតកីឡាបាល់ទាត់មិត្តភាពអន្តរជាតិកម្ពុជា ថៃអលស្តារ នៅរាជធានីភ្នំពេញ
- ប្រកាសទទួលស្គាល់និងផ្តល់ប្រាក់រង្វាន់ ១៦០ ០០០ ០០០៛ ដល់គ្រូបង្វឹក កីឡាការ ២ នាក់ ស្រី ១ នាក់ នៃការប្រកួតជម្រុះកីឡាតេក្វាន់ដូ ដើម្បីដណ្តើមសិទ្ធិចូលរួមកីឡាអូឡាំពិក ប្រទេសហ្វីលីពីន

- ប្រកាសទទួលស្គាល់និងផ្តល់ប្រាក់រង្វាន់ ៣៧ ០០០ ០០០ រៀល ដល់គ្រូបង្វឹក កីឡាករ កីឡាការិនី ៣ នាក់ ស្រី ២ នាក់ នៃការប្រកួតជើងឯកអាស៊ីតេក្វាន់ដូលើកទី២២ ប្រទេសហ្វីលីពីន
- ប្រកាសទទួលស្គាល់និងផ្តល់ប្រាក់រង្វាន់ ២៣៣ ៩០០ ០០០ រៀល ដល់គ្រូបង្វឹក កីឡាករ កីឡាការិនី ៨៦ នាក់ ស្រី ២១ នាក់ នៃការប្រកួតកីឡាសុធន្ទ:អនុតំបន់ទន្លេមេគង្គលើកទី២១
- ប្រកាសទទួលស្គាល់និងផ្តល់ប្រាក់រង្វាន់ ២៣១ ០០០ ០០០ រៀល ដល់គ្រូបង្វឹក គ្រូជំនួយ និងកីឡាករ ៣៣ នាក់ នៃការប្រកួតកីឡាបាល់ទាត់ជម្រុះពានរង្វាន់ទ្វីបអាស៊ីយូអេអុី រវាងកម្ពុជានិងឆាយនីស តៃប៉ិ នៅរាជធានីភ្នំពេញ
- ប្រកាសទទួលស្គាល់និងផ្តល់ប្រាក់រង្វាន់ ២១ ៦០០ ០០០ រៀល ដល់គ្រូបង្វឹក កីឡាករ ៣ នាក់ នៃការប្រកួតកីឡា ការ៉ាតេដូ ជ្រើសរើសជើងឯកអាស៊ីអាគ្នេយ៍លើកទី៥ ប្រទេសម៉ាឡេស៊ី
- ប្រកាសទទួលស្គាល់ និងផ្តល់ប្រាក់រង្វាន់ ២៣១ ០០០ ០០០ រៀល ដល់គ្រូបង្វឹក គ្រូជំនួយ និងកីឡាករ ៣៣ នាក់ នៃការប្រកួតកីឡាមិត្តភាពរវាងក្រុមកីឡាបាល់ទាត់ជម្រើសជាតិកម្ពុជា និងក្រុមជម្រើសជាតិសិង្ហបុរី
- ប្រកាសទទួលស្គាល់ និងផ្តល់ប្រាក់រង្វាន់ ២២ ០០០ ០០០ រៀល ដល់គ្រូបង្វឹក ២ នាក់ ស្រី ១ នាក់ នៃការប្រកួតកីឡាអន្តរជាតិកុមារអាស៊ីលើកទី៦ ប្រទេសរុស្ស៊ី
- ប្រកាសទទួលស្គាល់ និងផ្តល់ប្រាក់រង្វាន់ ១ ៣៧២ ០០០ ០០០ រៀល ដល់គ្រូបង្វឹក គ្រូជំនួយ និងកីឡាករ ៣៨ នាក់ ស្រី ១៦ នាក់ នៃការប្រកួតកីឡាអាស៊ីឆ្នេរខ្សាច់លើកទី៥ ប្រទេសវៀតណាម
- ប្រកាសទទួលស្គាល់ និងផ្តល់ប្រាក់រង្វាន់ ៣៥ ០០០ ០០០ រៀល ដល់គ្រូបង្វឹក គ្រូជំនួយ និងកីឡាករ ៥ នាក់ នៃការប្រកួតកីឡាសិស្សអាស៊ានលើកទី៨ ប្រទេសថៃ
- ប្រកាសទទួលស្គាល់ និងផ្តល់ប្រាក់រង្វាន់ ២៤០ ០០០ ០០០ រៀល ដល់គ្រូបង្វឹក និងកីឡាករ ២ នាក់ នៃការប្រកួតកីឡាប៉េតង់ជើងឯកពិភពលោកលើកទី៤៧ ប្រទេសម៉ាដាហ្គាស្កា
- ប្រកាសទទួលស្គាល់មជ្ឈមណ្ឌលកីឡាប្រយុទ្ធកម្ពុជា-ជប៉ុន
- ប្រកាសទទួលស្គាល់ និងផ្តល់ប្រាក់រង្វាន់ ៣៣១ ០០០ ០០០ រៀល ដល់គ្រូបង្វឹក គ្រូជំនួយ និងកីឡាករ នៃការប្រកួតកីឡាឈិនឡូនជ្រើសរើសជើងឯកអាស៊ីលើកទី២ នៅប្រទេសមីយ៉ាន់ម៉ា
- ប្រកាសទទួលស្គាល់ និងផ្តល់ប្រាក់រង្វាន់ ៦១ ៦០០ ០០០ រៀល ដល់គ្រូបង្វឹក គ្រូជំនួយ និងកីឡាករ នៃការប្រកួតកីឡាស្វហ្វតិន្ទីសជ្រើសរើសជើងឯកអាស៊ីអាគ្នេយ៍ នៅប្រទេសម៉ាឡេស៊ី
- ប្រកាសទទួលស្គាល់និងផ្តល់ប្រាក់រង្វាន់ ២៥,០០០,០០០ រៀល ដល់គ្រូបង្វឹក គ្រូជំនួយ និងកីឡាករ នៃការប្រកួតកីឡាកាយវប្បកម្មជ្រើសរើសជើងឯកអាស៊ីអាគ្នេយ៍លើកទី១៣ នៅប្រទេសថៃ
- កិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសជាមិត្ត ទទួលយកគ្រូបរទេសលើប្រភេទកីឡាចំបាប់ វាយសីស្វូវិនហ្សិកាំប៉ូ តេក្វាន់ដូ អាយធីអេហ្វ តេក្វាន់ដូ ដាប់បីលយូធីអេហ្វ និងប្រភេទកីឡារាំ
- ចុះអនុស្សរណ:យោគយល់គ្នាសម្រាប់អភិវឌ្ឍវិស័យកីឡាជាមួយប្រទេសវៀតណាម

- អនុញ្ញាតដល់គណៈកម្មាធិការប្រតិបត្តិអាណត្តិថ្មីសហព័ន្ធកីឡាជាតិ ១០ ធ្វើសកម្មភាពអភិវឌ្ឍប្រភេទកីឡារបស់ខ្លួន៖
    - សហព័ន្ធកីឡាបេស្បលខ្មែរ អាណត្តិទី៤ ឆ្នាំ២០១៥-២០១៩
    - សហព័ន្ធកីឡាទាញព្រ័ត្រកម្ពុជា អាណត្តិទី៣ ឆ្នាំ២០១៦-២០២០
    - ខេមរសហព័ន្ធកីឡាកាយវប្បកម្ម អាណត្តិទី២ ឆ្នាំ២០១៦-២០២០
    - ខេមរសហព័ន្ធកីឡាតេក្វាន់ដូដាប់ប៊ែលយូធីអេហ្វ អាណត្តិទី៥ ឆ្នាំ២០១៦-២០២០
    - សហព័ន្ធកីឡាតេក្វាន់ដូអាយធីអេហ្វ អាណត្តិទី៥ ឆ្នាំ២០១៦-២០២០
    - សហព័ន្ធកីឡាឡើងភ្នំកម្ពុជា អាណត្តិទី២ ឆ្នាំ២០១៦-២០២០
    - សហព័ន្ធកីឡាវាយសីកម្ពុជា អាណត្តិទី៦ ឆ្នាំ២០១៦-២០២០
    - សហព័ន្ធកីឡាទូកក្ដោងកម្ពុជា អាណត្តិទី១ ឆ្នាំ២០១៥-២០១៩
    - សហព័ន្ធកីឡាយានយន្តកម្ពុជា អាណត្តិទី២ ឆ្នាំ២០១៦-២០២០
    - សហព័ន្ធកម្ពុជាបង្ហាត់ជិះសេះ អាណត្តិទី២ ឆ្នាំ២០១៦-២០២០
- ផលិតទស្សនាវដ្ដីចំនួន ០៦ លេខ (០៨៧-០៩២) ចំនួន ១២ ០០០ក្បាល
- ផលិតសៀវភៅក្រាំងមាសប្រវត្តិសង្ខេបជ័យលាភីស៊ីហ្គេម ពីឆ្នាំ១៩៩៥ ដល់ ឆ្នាំ២០១៥។

## *ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តកីឡា*

ក្រសួងបានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡា ៖

- ពហុកីឡដ្ឋានជាតិ មានទីលានបាល់បោះ ៣ ទីលានបាល់ទះ ២ និងទីលានវាយកូនបាល់ ២
- វិទ្យាស្ថានជាតិអប់រំកាយ និងកីឡាមាន៖ សាលហ្វឹកហាត់តេក្វាន់ដូ១ បន្តសាងសង់សាលពហុកីឡាដំបូលទូក១
- សាលាថ្នាលនិស្ស័យកីឡានៅវាលស្បូវ រាជធានីភ្នំពេញ
- អគារមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា នៅពហុកីឡដ្ឋានជាតិ រាជធានីភ្នំពេញ
- ទីលានបាល់បោះ ៣ ទីលានបាល់ទះ ២ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ។

## *ការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំកាយ និងកីឡា*

ក្រសួងបាន៖

- បំប៉នសមត្ថភាពមុខវិជ្ជាអប់រំកាយ និងកីឡាដល់គ្រូបឋមសិក្សា មានអ្នកចូលរួម ៣៨៧ នាក់ ស្រី ១០៧ នាក់
- បំប៉នសមត្ថភាពគ្រូបង្គោលស្តីពីការចងក្រងទិន្នន័យតេស្តកាយសម្បទាកុមារ អាយុ៦ ទៅ ១២ ឆ្នាំ មានអ្នកចូលរួម ១៦៥ នាក់ ស្រី ៦៣ នាក់

- បញ្ជូនមន្ត្រីអាជ្ញាកណ្ដាលកីឡាបាល់ទាត់ ១ រូប ទៅចូលរួមវគ្គសុក្រិត្យការអាជ្ញាកណ្ដាលបាល់ទាត់អន្តរជាតិ ប្រទេសឡាវ
- បញ្ជូនគ្រូឧទ្ទេសទៅបណ្ដុះបណ្ដាលអាជ្ញាកណ្ដាលកីឡាបាល់ទាត់ និងបាល់ទះ ដល់មន្ត្រីកីឡាក្រោមឱវាទមន្ទីរអប់រំ យុវជន និង កីឡា នៅខេត្តកំពង់ស្ពឺ
- បណ្ដុះបណ្ដាលអាជ្ញាកណ្ដាល ថៅក្រម កីឡាបាល់ទះ វាយសី ប្រដាល់ កាយសម្ព័ន្ធ អត្តពលកម្ម បាល់បោះ និងសីប៉ាក់តាក្រ ២១០ នាក់ ស្រី ៣៦ នាក់
- ផ្សព្វផ្សាយច្បាប់ បទបញ្ជាប្រកួតលើប្រភេទកីឡាបាល់បោះ ហែលទឹក ការ៉ាតេដូ តេក្វាន់ដូ វ៉ូវីណាម ល្បុក្កតោ និងវាយសី ២២៦ នាក់ ស្រី ៣០ នាក់
- ផ្សព្វផ្សាយពីការរៀបចំការប្រកួត និងបញ្ញត្តិរួម ស្ដីពីការប្រកួតកីឡាជាតិ ៦លើក មានអ្នកចូលរួម ៦០០ នាក់ ស្រី ១២០ នាក់
- បំប៉នសមត្ថភាពស្ដីពីការប្រឆាំងការប្រើប្រាស់សារធាតុដូប៉ានៅក្នុងវិស័យកីឡាដល់មន្ត្រីអប់រំយុវជន និងកីឡា ៥ខេត្តមាន ខេត្តបាត់ដំបង ស្វាយរៀង កំពង់ឆ្នាំង ពោធិសាត់ និងកំពង់ធំ មានអ្នកចូលរួម ៣៦០ នាក់ ស្រី ២៩ នាក់
- បំប៉នសមត្ថភាពការរៀបចំផែនការ និងទ្រឹស្ដីហាត់ហ្វឹកហ្វឺនដល់គ្រូបង្វឹក និងអនុរក្ស ១១៣ នាក់ ស្រី ១៩ នាក់
- បំប៉នសមត្ថភាពគ្រូអប់រំកាយនិងកីឡា មានអ្នកចូលរួម ១៨០ នាក់ ស្រី ២១នាក់
- បំប៉នគ្រូឧទ្ទេសថ្នាក់ស្រុក ក្រុង មុខវិជ្ជាអប់រំកា និងកីឡា មានអ្នកចូលរួម ៣៨៧ នាក់ ស្រី១០៧នាក់
- បំពេញទស្សនកិច្ចសិក្សា ស្ដីពីអប់រំកាយ និងកីឡាប្រទេសថៃ
- សហការជាមួយអង្គការបេះដូងមាស រៀបចំសិក្ខាសាលាស្ដីពីការប្រើប្រាស់សៀវភៅព្រាងមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាបឋមភូមិ នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។

### *ការលើកកម្ពស់សមត្ថភាពកីឡាករ*

ក្រសួងបាន៖

- សហការរៀបចំពិធីសំណេះសំណាលជាមួយមហាគ្រូសារកីឡា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** នៅមជ្ឈមណ្ឌលពិរពណ៌ និងសន្និបាតកោះពេជ្រ
- សហការរៀបចំពិធីសំណេះសំណាលជាមួយកីឡាករ កីឡាការិនីជម្រើសជាតិ ដែលបានទទួលជ័យលាភី នៅវិមានសន្តិភាពក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

- សំណេះសំណាលជាមួយគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករ កីឡាការិនីជម្រើសជាតិក្នុងថ្ងៃយុទ្ធនាការដំបូងនៃការហាត់ហ្វឹកហ្វឺន ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅវិទ្យាស្ថានជាតិអប់រំ
- ប្រគល់ប្រាក់រង្វាន់លើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ជូនដល់ជ័យលាភីនៃការប្រកួតកីឡាជាលក្ខណៈអន្តរជាតិនានា (ការប្រកួតប៉េតង់ជើងឯកអាស៊ីលើកទី១៩ កាយសម្ព័ន្ធជើងឯកអាស៊ីលើកទី៥ ជម្រុះអូឡាំពិករដូវក្តៅនៅទីក្រុងរីយ៉ូ តេក្វាន់ដូជើងឯកអាស៊ីលើកទី១៨ ឈិនឡូនជើងឯកអាស៊ីលើកទី២ កីឡាសុធន្ធៈអនុតំបន់ទន្លេមេគង្គ បំពាក់មេដាយក្រុមប្រឹក្សាកីឡាអាស៊ីអាគ្នេយ៍ដល់វីរកីឡាការិនី ស៊ន សៀវម៉ី ដែលជាប់ជាកីឡាការិនីពេញសិទ្ធចូលរួមប្រកួតកីឡាអូឡាំពិករដូវក្តៅនៅទីក្នុងរីយ៉ូ កីឡាអាស៊ីឆ្នេរខ្សាច់លើកទី៥) នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡាក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- ទទួលយកគ្រូបង្វឹក អនុរក្ស និងកីឡាករ កីឡាការិនីជម្រើសជាតិថ្នាល ១៧២ នាក់ ស្រី ៣០ នាក់ ពីសហព័ន្ធកីឡាជាតិ ៩ មកហាត់ហ្វឹកហ្វឺនរយៈពេល១២ខែ ក្នុងនោះកីឡាបាល់ទាត់U១៤ និងU១៦ ចំនួន ៥៤ នាក់ ឱ្យធ្វើការហ្វឹកហាត់ ស្នាក់នៅ រៀនសូត្រ នៅមជ្ឈមណ្ឌលសាលាកីឡាបាល់ទាត់បាទី សម្រាប់ត្រៀមធ្វើម្ចាស់ផ្ទះការប្រកួតកីឡាស៊ីហ្គេមឆ្នាំ ២០២៣
- ទទួលយកគ្រូបង្វឹក អនុរក្ស និងកីឡាករ កីឡាការិនីជម្រើសជាតិ ៤១៧ នាក់ ស្រី ៨៨ នាក់ ពីសហព័ន្ធកីឡាជាតិ ២៦។

ក្រសួងបានបញ្ជូនៈ

- កីឡាករ កីឡាការិនីហែលទឹក ២ នាក់ ស្រី ១ នាក់ ទៅហាត់ហ្វឹកហ្វឺននៅប្រទេសថៃ
- កីឡាករ កីឡាការិនី ចំបាប់ ៣នាក់ ស្រី២នាក់ ទៅហាត់ហ្វឹកហ្វឺននៅសាធារណរដ្ឋ កូរ៉េ
- កីឡាករ កីឡាការិនី តេក្វាន់ដូ ដាប៊ីលយូធីអេហ្វ ៣ នាក់ ស្រី ២ នាក់ ទៅហាត់ហ្វឹកហ្វឺននៅសាធារណរដ្ឋកូរ៉េ
- កីឡាករ កីឡាការិនី តេក្វាន់ដូ ដាប៊ីលយូធីអេហ្វ ៣ នាក់ ស្រី ២ នាក់ ទៅហាត់ហ្វឹកហ្វឺននៅសាធារណរដ្ឋកូរ៉េ
- កីឡាការិនី អត្តពលកម្ម ១ នាក់ ទៅហាត់ហ្វឹកហ្វឺននៅប្រទេស កេនយ៉ា
- កីឡាករ វាយកូនឃ្លីលើតុ ១ នាក់ ទៅហាត់ហ្វឹកហ្វឺននៅប្រទេសវៀតណាម
- កីឡាករ កីឡាការិនី បាល់ទះឆ្នេរខ្សាច់ អត្តពលកម្ម វ៉ូវីណាម ប្រណាំងទោចក្រយាន ២០ នាក់ ស្រី ៤ នាក់ ទៅហាត់ហ្វឹកហ្វឺននៅប្រទេសវៀតណាម
- កីឡាករ ស្ទូហ្សតិន្ទីស ៥ នាក់ ទៅហាត់ហ្វឹកហ្វឺននៅសាធារណរដ្ឋកូរ៉េ
- កីឡាករ កីឡាការិនី វូស៊ូ វាយកូនឃ្លីលើតុ ហែលទឹក ១៥ នាក់ ស្រី ២ នាក់ ទៅហាត់ហ្វឹកហ្វឺននៅសាធារណរដ្ឋប្រជាមានិតចិន។

*ការងារបណ្តុះបណ្តាលគ្រូអប់រំកាយ និងមន្ត្រីជំនាញ*

ក្រសួងបាន៖

- បញ្ចប់ការបណ្តុះបណ្តាលគរុសិស្សជំនាន់ទី២៤ ចំនួន ១៤៩ នាក់ ស្រី ៣២ នាក់
- ជ្រើសរើសសិស្សឱ្យចូលរៀន ជំនាន់ទី២៦ ចំនួន ១០០ នាក់ ស្រី ២០ នាក់
- បន្តបណ្តុះបណ្តាលគរុសិស្សជំនាន់ទី២៥ ចំនួន ១០០ នាក់ ស្រី ២២ នាក់ និងគរុសិស្សជំនាន់ទី២៦ ចំនួន ១០០ នាក់ ស្រី ២០ នាក់
- កែលម្អកម្មវិធីសិក្សាអប់រំកាយ និងកីឡា សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ឯកទេសអប់រំកាយ និងកីឡា
- បញ្ជូនមន្ត្រី ៥ នាក់ ស្រី ១ នាក់ ទៅបន្តការសិក្សាថ្នាក់ឧត្តម នៅប្រទេសវៀតណាម។

*ការលើកកម្ពស់ភាពជាអ្នកដឹកនាំ*

ក្រសួងបាន៖

- កែលម្អការបង្ហាត់បង្រៀនរបស់គ្រូអប់រំកាយ និងកីឡា តាមរយៈការពិនិត្យតាមដានចំណុចខ្វះខាត នៅលើទីលានបាន២៤ខេត្ត
- វាយតម្លៃការងារកម្មសិក្សារបស់គរុសិស្សអប់រំកាយ និងកីឡា។

## ខ. ការសម្រេចបានសូចនាករផលសម្រេច

*ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| | ការអប់រំកាយនិងកីឡា | ជាក់ស្តែង ២០១៥-១៦ | ចំណុចដៅ ២០១៦-១៧ | ជាក់ស្តែង ២០១៦-១៧ | ស្ថានភាព |
|---|---|---|---|---|---|
| គោលនយោបាយទី ១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | |
| ១ | ចំនួនគ្រូអប់រំកាយនិងកីឡាបណ្តុះបណ្តាលក្នុងមួយឆ្នាំ | ១៥០ | ១០០ | ១០០ | ↑ |
| ២ | ទីលានកីឡាចំនួន៤ ត្រូវបានកែលម្អ៖ | | | | |
| | - ពហុកីឡដ្ឋានជាតិ | | ១០០% | ១០០% | ↑ |
| | - សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | | ១០០% | ១០០% | ↑ |
| | - វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា | | ចាប់ផ្តើម | ៥០% | → |
| | - កីឡដ្ឋានខេត្តសៀមរាប | | | ចាប់ផ្តើម | ↓ |
| ៣ | គ្រឹះស្ថានមធ្យមសិក្សាមាន៖ | | | | |
| | - ទីលានបាល់ទាត់ ១០ | ២ | ២ | ០ | ↓ |
| | - ទីលានបាល់បោះ ១៥ | ៣ | ៣ | ៣ | ↑ |
| | - ទីលានបាល់ទះ ២០ | ៤ | ៤ | ៣ | → |
| គោលនយោបាយទី ២ ៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | |
| | N/A | | | | |

<u>សម្គាល់</u>: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓សម្រេចមិនបានតាមចំណុចដៅ

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា៖

- ការអនុវត្តសកម្មភាពនិងការប្រើប្រាស់ម៉ោងអប់រំកាយនៅតាមសាលារៀនពុំទាន់អនុវត្តពេញលេញ
- សាលារៀនមួយចំនួនពុំមានទីលានសមស្រប សម្រាប់អនុវត្តសកម្មភាពអប់រំកាយ និងកីឡា
- កីឡដ្ឋាននៅខេត្តព្រះសីហនុ កំពត សៀមរាប កោះកុង តាកែវ បាត់ដំបង កំពង់ឆ្នាំង ពោធិ៍សាត់ មណ្ឌលគីរី ក្រចេះ ត្បូងឃ្មុំ ព្រៃវែង និងកណ្ដាល ពុំទាន់មានលទ្ធភាពជួសជុល កែលម្អ
- កីឡដ្ឋាននៅខេត្តកំពង់ធំ និងរតនគិរី ពុំទាន់បានទទួលជាផ្លូវការពីក្រុមហ៊ុនឯកជន
- កង្វះធនធានមនុស្សផ្នែកគ្រូបង្វឹក អាជ្ញាកណ្ដាល ថៅក្រម កីឡាករ និងមន្ត្រីរៀបចំការប្រកួត
- ថវិកាសម្រាប់ធ្វើសកម្មភាពអប់រំកាយ និងកីឡានៅតាមរាជធានី ខេត្ត នៅមានកម្រិតទាប
- ថវិកាក្នុងការបណ្ដុះបណ្ដាលធនធានមនុស្ស និងជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធកីឡាឆ្ពោះទៅកាន់ឆ្នាំ២០២៣ នៅមានកម្រិតទាប
- ការសាងសង់មជ្ឈមណ្ឌលថ្នាលនិស្សិតកីឡានៅវាលស្បូវមានការយឺតយ៉ាវ
- អគារសិក្សា និងអន្តេវាសិកដ្ឋាននៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាមិនទាន់គ្រប់គ្រាន់
- លទ្ធផលនៃការប្រកួតជ្រើសរើសជើងឯកថ្នាក់ជាតិមានគុណផលទាបនៅឡើយ បើធៀបទៅនឹងគុណផលនៃការប្រកួតកីឡាស៊ីហ្គេម
- កង្វះការគាំទ្រពីដៃគូអភិវឌ្ឍលើវិស័យកីឡា។

## ៣. ទិសដៅឆ្នាំសិក្សា ២០១៦-២០១៧

ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ទាំងបញ្ហាប្រឈមតាមអនុវិស័យ និងបញ្ហាប្រឈមជាលក្ខណៈអន្តរអនុវិស័យ និងផ្អែកលើបទពិសោធកន្លងមក ក្រសួងអប់រំ យុវជន និងកីឡា នឹងជំរុញល្បឿនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន តាមទិសដៅដូចខាងក្រោម ៖

### ៣.១ ទិសដៅតាមអនុវិស័យ

#### *៣.១.១ អនុវិស័យ ការអប់រំកុមារតូច*

- បង្កើនអត្រាចូលរៀនរបស់កុមារអាយុ ៣ ឆ្នាំ ៤ ឆ្នាំ និង ៥ ឆ្នាំ ឱ្យឆ្លើយតបនឹងចំណុចដៅ
- ពង្រីកនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធសេវាអប់រំកុមារតូច ផ្តោតលើការកសាង ជួសជុលអគារសិក្សា និងកែលម្អបរិស្ថានសិក្សាឱ្យមានលក្ខណៈស្តង់ដា និងស្របតាមនិយាមគរុកោសល្យ
- ពង្រឹងការអនុវត្តយន្តការគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច
- ពង្រីកកម្មវិធីអប់រំមាតាបិតាដោយផ្តោតលើសេវាអាហារូបត្ថម្ភ ការលើកម្ពស់សុខភាព អនាម័យ ការថែទាំ និងការប្រើប្រាស់សេវាសុខាភិបាល
- បន្តកម្មវិធីផ្តល់ថ្នាំទម្លាក់ព្រូន ពិនិត្យសុខភាព និងកាយសម្បទាបុគ្គលិកអប់រំ និងអ្នកសិក្សា ដោយសហការជាមួយក្រសួងសុខាភិបាល ផ្តល់ការអប់រំសុខភាព អនាម័យ សុខភាពមាត់-ធ្មេញ អាហារូប-ត្ថម្ភ និងសេវាសុខាភិបាលដទៃទៀត
- បន្តចាក់ផ្សាយកម្មវិធី "ស្រឡាញ់កូន" តាមទូរទស្សន៍ជាតិកម្ពុជា
- អភិវឌ្ឍកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ
- ពង្រឹងសមត្ថភាពគ្រប់គ្រងនាយក នាយិកាសាលាមត្តេយ្យសិក្សា
- ពង្រឹងការអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ការសិក្សាស្រាវជ្រាវ និងវិភាគសម្រាប់អនុវិស័យអប់រំកុមារតូច
- រៀបចំលិខិតបទដ្ឋានគតិយុត្តដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធានានិរន្តរភាពមត្តេយ្យសិក្សាសហគមន៍។

#### *៣.១.២ អនុវិស័យ ការអប់រំបឋមសិក្សា*

- កែលម្អនីតិវិធីនៃការពង្រាយគ្រូ
- ពង្រឹងប្រសិទ្ធភាព និងសក្តិសិទ្ធិភាពនៃការប្រើប្រាស់ថវិកាសាលារៀន
- កែលម្អលក្ខខណ្ឌផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងសិស្សរៀនពូកែ
- ពង្រឹងកម្មវិធីអំណានថ្នាក់ទី១ ទី២ និងទី៣
- ទស្សនកិច្ចសិក្សាស្តីពីវិធីសាស្ត្របង្រៀននៅតាមសាលារៀន
- ពិនិត្យឡើងវិញអំពីវិធីសាស្ត្របង្រៀននៅតាមសាលាគរុកោសល្យ

- បន្តអនុវត្តស្តង់ដាអំណានភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ទី១ ទី២ និងទី៣
- រៀបចំផែនការតម្រូវការ និងការផ្គត់ផ្គង់សៀវភៅសិក្សាគោលតាមសាលារៀនឱ្យមានលក្ខណៈប្រាកដប្រជា
- បណ្តុះបណ្តាលគ្រូចេញថ្មី និងវិក្រឹតការគ្រូបង្រៀន១២+២ ទៅជា ១២+៤ ដោយផ្តោតលើគ្រូបង្រៀនកម្រិតមូលដ្ឋាន
- បំប៉នសមត្ថភាពគ្រូបង្រៀនបឋមសិក្សា ស្តីពីវិធីសាស្ត្របង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ និងទី៥
- កែលម្អកម្មវិធីសិក្សាលម្អិត សម្រាប់បឋមសិក្សាគ្រប់កម្រិតថ្នាក់
- អភិវឌ្ឍប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបឋមសិក្សា
- រៀបចំសាលាកុមារមេត្រីកម្រិតអភិវឌ្ឍជាបណ្តើរៗឱ្យទៅជាសាលាបឋមសិក្សាជំនាន់ថ្មី
- លើកទឹកចិត្តគ្រូបង្រៀននៅអនុវិទ្យាល័យឱ្យទៅជួយបង្រៀននៅបឋមសិក្សាផ្នែកបំណិនជីវិត
- បំផុសយុទ្ធនាការប្រមូលកុមារចូលរៀនថ្នាក់ទី១ ដល់អាយុសិក្សាឱ្យចូលរៀនត្រូវតាមអាយុពីគ្រប់ភាគីពាក់ព័ន្ធ
- បង្កើនគណនេយ្យភាពសង្គម
- ពង្រឹងភាពជាអ្នកដឹកនាំនិងគ្រប់គ្រងនៅកម្រិតសាលារៀន
- ជំរុញការបង្កើត និងការអនុវត្តយន្តការគណៈកម្មការទ្រទ្រង់សាលានៅតាមសាលារៀនឱ្យមានប្រសិទ្ធភាព
- ពង្រឹងការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្ស
- ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីធានាគុណភាពអប់រំ
- ផ្សព្វផ្សាយ និងអនុវត្តសាកល្បងស្តង់ដាសាលាបឋមសិក្សា។

### *៣.១.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស*

- ពង្រីកសាលារៀនជំនាន់ថ្មីឱ្យបាន ៣ បន្ថែមទៀត
- បន្តទប់ស្កាត់ការបោះបង់ការសិក្សារបស់សិស្ស
- ជំរុញដំណើរការក្លឹបសិក្សាមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ ប្រវត្តិវិទ្យា និងអក្សរសាស្ត្រខ្មែរ
- បន្តអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រប្រកបដោយសមធម៌ និងបរិយាបន្ន
- ពង្រីកសាលាកុមារមេត្រីនៅសាលាមធ្យមសិក្សាបឋមភូមិ
- ពង្រឹងការអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន នៅតាមគ្រឹះស្ថានសិក្សា
- ពង្រឹងប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ដើម្បីធានាគុណភាពអប់រំ
- ធ្វើតេស្តវាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ

- បន្តបំប៉នគ្រូមត្តេយ្យសិក្សា និងគ្រូបឋមសិក្សា ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ៣ ០០០ នាក់
- ពង្រឹងតួនាទីនិងការទទួលខុសត្រូវរបស់គណៈកម្មការទ្រទ្រង់សាលា
- អនុវត្តសាកល្បងកម្រងសាលាមធ្យមសិក្សានៅតាមខេត្តគោលដៅ
- បន្តការផ្តល់សេវាសុខភាពចាំបាច់ដល់បុគ្គលិកអប់រំ និងអ្នកសិក្សា ដូចជា ការពិនិត្យសុខភាព ការផ្តល់ថ្នាំទម្លាក់ព្រូន ថ្នាំបង្ការ ការផ្តល់ប្រអប់សង្គ្រោះបឋម និងវិធីសាស្ត្រសង្គ្រោះបឋម
- អភិវឌ្ឍកម្មវិធីទូរសព្ទដៃសម្រាប់លើកកម្ពស់ការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- កសាងស្តង់ដាសាលាមធ្យមសិក្សា។

### ៣.១.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា

- អនុម័តគោលនយោបាយជាតិស្តីពីអាហារូបករណ៍ ការឧបត្ថម្ភធន និងឥណទានសម្រាប់អ្នកសិក្សានៅឧត្តមសិក្សា
- បង្កើនចំនួននិស្សិតផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម សិល្បៈច្នៃប្រឌិត និង គណិតសាស្ត្រ
- ពង្រីកសេវាកម្ម និងធនធានរបស់គ្រឹះស្ថានឧត្តមសិក្សាតាមតំបន់
- អភិវឌ្ឍផែនការសកម្មភាពដើម្បីកាត់បន្ថយគម្លាតរវាងនិស្សិតដែលបានបញ្ចប់ការសិក្សា និងតម្រូវការទីផ្សារការងារ
- អនុម័តសៀវភៅណែនាំប្រតិបត្តិស្តីពីគម្រោងស្រាវជ្រាវ
- កសាងគោលនយោបាយអភិវឌ្ឍធនធានមនុស្សសម្រាប់ឧត្តមសិក្សា
- អភិវឌ្ឍលក្ខណវិនិច្ឆ័យនិងគោលការណ៍ណែនាំអំពីការធានាគុណភាពផ្ទៃក្នុង
- អនុម័តលិខិតបទដ្ឋានស្តីពីស្វ័យភាពរបស់គ្រឹះស្ថានឧត្តមសិក្សា
- រៀបចំយន្តការអនុវត្តព្រះរាជក្រឹត្យស្តីពីឋានៈសាស្ត្រាចារ្យ
- អនុម័តប្រកាសអន្តរក្រសួងស្តីពីគោលការណ៍របបប្រាក់ឧបត្ថម្ភសេវាវាយតម្លៃគុណភាពឧត្តមសិក្សា។

### ៣.១.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ

- បង្កើនសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់
- ពង្រឹងការអនុវត្តអក្ខរកម្មវិជ្ជាជីវៈ និងបំណិនជីវិត
- បង្កើនចំនួនអក្ខរជនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធសម្រាប់កុមារ យុវជនក្រៅសាលា
- ប្រមូលកុមារបោះបង់ការសិក្សាឱ្យចូលរៀនក្នុងកម្មវិធីចូលរៀនឡើងវិញឱ្យបានច្រើន និងធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធ
- បង្កើនចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូល

- បំប៉នគ្រូឧទ្ទេសថ្នាក់ខេត្តសម្រាប់កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ
- បំប៉នការធ្វើផែនការអប់រំក្រៅប្រព័ន្ធ
- ពង្រឹងសមត្ថភាពគ្រូឧទ្ទេសកម្មវិធីចូលរៀនឡើងវិញ
- រៀបចំទិវាអក្ខរកម្មជាតិ-អន្តរជាតិ ៨កញ្ញា
- បំប៉នកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិ
- ពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ ដោយផ្សារភ្ជាប់ជាមួយប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ
- រៀបចំប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល
- រៀបចំកម្មវិធីសិក្សាគោលនៃជំនាញមុខរបរសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍។

### ៣.១.៦ អនុវិស័យ ការអភិវឌ្ឍយុវជន

- រៀបចំបង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង-ស្ថាប័ន រាជធានី-ខេត្ត ឃុំ-ស្រុក
- រៀបចំសន្ទស្សន៍ការអភិវឌ្ឍយុវជនកម្ពុជា
- រៀបចំកម្មវិធីសិក្សាសមមូលតាមប្រព័ន្ធអ៊ិនធឺណែត
- បន្តផ្សព្វផ្សាយខ្លឹមសារស្តីពីកម្មវិធីអប់រំបំណិនជីវិតដូចជា ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង អំពើហិង្សា និងមេរោគអេដស៍ ជំងឺអេដស៍ នៅតាមអនុ-វិទ្យាល័យនិងវិទ្យាល័យ
- បន្តពង្រឹងក្រុមប្រឹក្សាកុមារនិងយុវជនតាមគ្រឹះស្ថានសិក្សា
- បង្កើតនិងជំរុញការងារក្លឹបសិក្សា
- បន្តការងារប្រឹក្សាអាជីពតាមរយៈវេទិកាការសិក្សានិងការងារ
- ពង្រីកមជ្ឈមណ្ឌលផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ
- បញ្ចូលកម្មវិធីអប់រំសហគ្រិនភាពទៅក្នុងកម្មវិធីសិក្សាបំណិនជីវិត
- បង្កើនសកម្មភាពការងារយុវជនស្ម័គ្រចិត្ត
- អនុវត្តសាកល្បងគម្រោងបណ្តុះបណ្តាលជំនាញការងាររបស់យុវជន តាមរយៈការងារស្ម័គ្រចិត្តដោយសហការជាមួយភ្នាក់ងារអង្គការសហប្រជាជាតិខាងការងារស្ម័គ្រចិត្ត។

### ៣.១.៧ អនុវិស័យការអប់រំកាយ និងកីឡា

- បន្តផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា
- កែសម្រួលប្រកាសអន្តរក្រសួងលេខ១៣២ ស្តីពីគោលការណ៍ចំណាយថវិកាប្រកួតកីឡាថ្នាក់រាជធានីខេត្ត និងថ្នាក់ជាតិ
- ប្រតិភូកម្មមុខងារនិងការគាំទ្រថវិកាទៅសហព័ន្ធកីឡាជាតិ ដើម្បីពន្លឿនការអភិវឌ្ឍឆ្ពោះទៅឆ្នាំ ២០២៣

- ពង្រឹងយុត្តិធម៌ក្នុងការប្រកួតកីឡាដោយប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- សម្រិតសម្រាំងកីឡាករឆ្នើមតាមរយៈការប្រកួតកីឡាសិស្ស និងមហាជន និងប្រកួតជើងឯកជាតិតាមសហព័ន្ធ
- ពង្រឹងការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាអប់រំកាយក្នុងម៉ោងសិក្សា នៅគ្រឹះស្ថានសិក្សា
- ពង្រឹងសមាគមកីឡា ក្លឹបកីឡា នៅតាមគ្រឹះស្ថានសិក្សា និងក្របខណ្ឌមហាជន
- អភិវឌ្ឍកម្មវិធីសិក្សាសម្រាប់គ្រូអប់រំកាយ និងកីឡា ១២+៤
- អភិវឌ្ឍធនធានមនុស្សផ្នែកអប់រំកាយ និងកីឡា ត្រៀមលក្ខណៈឆ្ពោះទៅឆ្នាំ២០២៣
- លើកកម្ពស់គុណផលកីឡាតាមរយៈការប្រមូលផ្ដុំក្រុមកីឡាជម្រើសជាតិ និងក្រុមជម្រើសជាតិថ្នាលមកហាត់ហ្វឹកហ្វឺន ដើម្បីត្រៀមលក្ខណៈធ្វើម្ចាស់ផ្ទះការប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣
- លើកកម្ពស់គុណភាពបណ្ដុះបណ្ដាលគរុសិស្សអប់រំកាយ និងកីឡា
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តអប់រំកាយ និងកីឡា
- ស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយឯកសារកីឡាប្រពៃណី
- ផ្សព្វផ្សាយសមិទ្ធផល និងផ្តល់ចំណេះដឹង ជំនាញអប់រំកាយ និងកីឡា តាមរយៈទស្សនាវដ្ដីកីឡា។

## ៣.២ បញ្ហាប្រឈម និងទិសដៅកំណែទម្រង់ឆ្លងអនុវិស័យ

### *៣.២.១ ការពង្រឹងការងារគោលនយោបាយនិងផែនការ*

*បញ្ហាប្រឈម*

- កង្វះភាពសម្បូរបែបទិន្នន័យគុណភាពអប់រំ
- ផែនការប្រតិបត្តិប្រចាំឆ្នាំ មិនទាន់គ្រប់ជ្រុងជ្រោយនិងភាពប្រទាក់ក្រឡាគ្នាពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសសាលារៀន
- ការកសាងផែនការ និងការគ្រប់គ្រងតាមអនុវិស័យមិនទាន់បានពេញលេញ
- កង្វះសុខដុមនីយកម្មរវាងការកសាងផែនការ និងថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- កង្វះសមត្ថភាពមន្ត្រីជំនាញលើផ្នែកផែនការ ស្ថិតិ វិភាគគោលនយោបាយ ការពិនិត្យតាមដាននិងវាយតម្លៃ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**ទិសដៅ**

- ពង្រីកទិន្នន័យផ្នែកគុណភាពអប់រំ
- បង្កើនប្រសិទ្ធភាពនៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសាលារៀន
- ធ្វើសុខដុមនីយកម្មរវាងគោលនយោបាយ ផែនការ និងថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- សម្របសម្រួល និងគាំទ្រក្រុមការងារតាមអនុវិស័យលើការរៀបចំផែនការ គ្រប់គ្រង និងពិនិត្យឡើងវិញ
- ធ្វើបច្ចុប្បន្នភាពគោលនយោបាយអប់រំឱ្យឆ្លើយតបទៅនឹងបរិបទថ្មី
- ពង្រឹងការពិនិត្យតាមដាន និងវាយតម្លៃនៅគ្រប់លំដាប់ថ្នាក់
- អភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញលើផ្នែកផែនការ ស្ថិតិ វិភាគគោលនយោបាយ ការពិនិត្យតាមដាន និងវាយតម្លៃទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### ៣.២.២ ការងារវិមជ្ឈការ និងវិសហមជ្ឈការ

**បញ្ហាប្រឈម**

- លិខិតបទដ្ឋានគាំទ្រការងារផ្ទេរមុខងារវិស័យអប់រំមានភាពយឺតយ៉ាវ
- កង្វះការគាំទ្រនិងជំរុញការវាយតម្លៃផលប៉ះពាល់លើសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត
- កង្វះសមត្ថភាពមន្ត្រីជំនាញលើការងារវិមជ្ឈការ និងវិសហមជ្ឈការ។

**ទិសដៅ**

- ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រវិស័យអប់រំ
- សិក្សាពីផលប៉ះពាល់នៃការផ្ទេរមុខងារវិស័យអប់រំទៅថ្នាក់ក្រោមជាតិ
- លើកកម្ពស់ការផ្ដល់សេវាសាធារណៈវិស័យអប់រំនិងផ្ដល់អាជ្ញាបណ្ណដល់គ្រឹះស្ថានសិក្សាឯកជន
- ពង្រឹងការរៀបចំ និងការអនុវត្តក្របខណ្ឌច្បាប់ និងគោលនយោបាយវិស័យអប់រំ
- ពង្រឹងយន្តការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សក្នុងវិស័យអប់រំ
- ពង្រឹងសមត្ថភាពនិងការអនុវត្តតាមគោលការណ៍អភិបាលកិច្ចល្អក្នុងការគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងសមត្ថភាពគ្រប់គ្រង ដោះស្រាយវិវាទ គាំពារ និងផ្ដល់ប្រឹក្សាច្បាប់ជូនបុគ្គលិកអប់រំ
- ពង្រឹងសមត្ថភាពនិងសិក្សាវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត
- អភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញលើការងារវិមជ្ឈការ និងវិសហមជ្ឈការ។។

### ៣.២.៣ ការងារគ្រប់គ្រងបុគ្គលិក

**បញ្ហាប្រឈម**

- ភាពយឺតយ៉ាវនៃការតាំងស៊ប់ក្នុងក្របខណ្ឌជូនគ្រូបង្រៀនចេញថ្មីគ្រប់កម្រិតដែលបានបញ្ចប់កម្មសិក្សា និងអតីតបុគ្គលិក
- កង្វះវិធានការសមស្រប ដើម្បីដោះស្រាយគ្រូបង្រៀននៅតំបន់ដាច់ស្រយាល ជួបការលំបាក និងលើសគ្រូបង្រៀននៅទីប្រជុំជន។

### ទិសដៅ

- ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានមនុស្សនៅថ្នាក់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សា
- ពង្រឹងការអនុវត្តគោលការណ៍ស្តីពីការផ្លាស់ទីកន្លែងធ្វើការ ការបែងចែកគ្រូចេញថ្មី និងការអនុវត្តវិន័យការងាររបស់បុគ្គលិកអប់រំ
- ផ្សព្វផ្សាយដល់គរុសិស្ស និស្សិត អំពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ច្បាប់ គោលការណ៍ប្រតិបត្តិ និងលាភការដែលត្រូវទទួលបាន
- ពង្រឹងការងារគ្រប់គ្រង និងប្រើប្រាស់មន្ត្រីរាជការ គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរវេន និងគ្រូបង្រៀនថ្នាក់គួប
- អភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់គ្រង និងមន្ត្រីជំនាញលើការគ្រប់គ្រងនិងប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស។

## *៣.២.៤ ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

### *បញ្ហាប្រឈម*

- កង្វះប្រសិទ្ធភាពក្នុងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ តាមអង្គភាពថវិការដ្ឋបាលកណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- កង្វះសមត្ថភាពមន្ត្រីជំនាញផ្នែកហិរញ្ញវត្ថុ
- ការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុនៅក្រសួងអប់រំ យុវជន និងកីឡាមិនទាន់ឆ្លើយតបទាំងស្រុងទៅនឹងផែនការ
- នីតិវិធីទូទាត់មានភាពស្មុគ្រស្មាញ និងតម្រូវឱ្យប្រើប្រាស់ពេលវេលាយូរ។

### ទិសដៅ

- ពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០១៨-២០២០ និងផែនការថវិកាប្រចាំឆ្នាំរបស់ក្រសួង
- រៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងការងារលទ្ធកម្ម
- ពង្រឹងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សា
- អភិវឌ្ឍសមត្ថភាពមន្ត្រីឱ្យឆ្លើយតបទៅនឹងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ
- ពង្រឹងការប្រើប្រាស់ប្រព័ន្ធគណនីធនាគារប្រាក់បៀវត្ស នៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ
- ដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការប្រើប្រាស់មូលនិធិកែលម្អសាលារៀន។

### ៣.២.៥ ការងារបណ្តុះបណ្តាល និងវិក្រឹតការ

**បញ្ហាប្រឈម**

- សមត្ថភាពគ្រូឧទ្ទេសមិនទាន់ឆ្លើយតបទៅនឹងបរិការណ៍បច្ចុប្បន្ន
- កង្វះសម្ភារបរិក្ខារនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។

**ទិសដៅ**

- ប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងបាត់ដំបង ឱ្យទៅជាវិទ្យាស្ថានគរុកោសល្យ អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេស
- ជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់ភូមិសិក្សា ៣ ៥០០ នាក់
- បន្តបណ្តុះបណ្តាលគ្រូមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធពន្លឿនឆ្ពោះទៅបរិញ្ញាបត្រ
- បន្តបំប៉នគ្រូមត្តេយ្យសិក្សា បឋមសិក្សា ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋានជំនាន់ទី១០ វេនទី២ ចំនួន ១ ៥០០ នាក់ និងជំនាន់ទី១១ វេនទី១ ចំនួន ១ ៥០០ នាក់
- បន្តពង្រឹងសមត្ថភាពគ្រប់គ្រងជូននាយក នាយករងសាលាគរុកោសល្យ សាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ។

### ៣.២.៦ ការងារអភិវឌ្ឍកម្មវិធីសិក្សា

**បញ្ហាប្រឈម**

- កង្វះធនធានមនុស្ស និងមន្ត្រីជំនាញឯកទេសគណិតវិទ្យា វិទ្យាសាស្ត្រ និងកម្មវិធីសិក្សា
- យន្តការបែងចែក និងគ្រប់គ្រងសៀវភៅសិក្សាគោលមិនទាន់ឆ្លើយតប
- ការផ្គត់ផ្គង់សៀវភៅសិក្សាគោល កម្មវិធីសិក្សាថ្មី និងផ្តល់សៀវភៅគ្រូដល់គ្រូបង្រៀនតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាកមិនទាន់ធានាបានតាមស្តង់ដាកំណត់
- ការទម្លាក់ថវិកាតាមជុំមិនឆ្លើយតបនឹងតម្រូវការក្នុងការអនុវត្តជាក់ស្តែង។

**ទិសដៅ**

- បញ្ចប់កម្មវិធីសិក្សាលម្អិត និងស្តង់ដា
- អនុម័តគំរូតែងសេចក្តីសម្រាប់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ
- ផ្សព្វផ្សាយឯកសារណែនាំស្តីពីការរៀននិងបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- រៀបចំមហោស្រពនិងពិព័រណ៍ មុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- អនុម័តមេរៀនសង្ខេបមុខវិជ្ជាប្រវត្តិវិទ្យាថ្នាក់ទី១២
- រៀបចំសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជា
- រៀបចំទិវាជាតិអំណាន ១១ មីនា និងរៀបចំព្រឹត្តិការណ៍ជំរុញការអានតាមសាលាបឋមសិក្សា

- ផ្គត់ផ្គង់សៀវភៅសិក្សាគោលតាមផលធៀបសៀវភៅសិក្សា-សិស្សស្មើ ១:១ នៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ
- ផ្គត់ផ្គង់សៀវភៅសិក្សាគោលតាមផលធៀបសៀវភៅសិក្សា-សិស្សស្មើ ២:១ នៅមធ្យមសិក្សាទុតិយភូមិ
- បញ្ចប់ឯកសារស្តីពីការប្រែប្រួលអាកាសធាតុ ថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២។

### *៣.២.៧ ការងាររដ្ឋបាល*

#### បញ្ហាប្រឈម

- ការផ្តល់គ្រឿងឥស្សរិយយសឆ្នាំ២០១៣ ឆ្នាំ២០១៤ ឆ្នាំ២០១៥ និងឆ្នាំ២០១៦
- ពុំទាន់មានប្រព័ន្ធគ្រប់គ្រងទិន្នន័យឯកសារ និងបណ្ណសារដ្ឋាន។

#### ទិសដៅ

- បន្តពង្រឹងការគ្រប់គ្រងលិខិតរដ្ឋបាល ពិសេសចរាចរលិខិត
- ជំរុញការផ្តល់គ្រឿងឥស្សរិយយសការងារជូនបុគ្គលិកអប់រំនៅថ្នាក់ជាតិ និងក្រោមជាតិ
- អភិវឌ្ឍសមត្ថភាពការងារគ្រប់គ្រងរដ្ឋបាលអប់រំ បណ្ណសារ និងពិធីការ
- បន្តរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យឯកសារ និងបណ្ណសារដ្ឋានក្រសួងអប់រំ យុវជន និងកីឡា។

### *៣.២.៨ ការងារព័ត៌មាន និងកិច្ចការអាស៊ាន*

#### បញ្ហាប្រឈម

- ការប្រមូលព័ត៌មាន ការផលិតឯកសារ និងការផ្សព្វផ្សាយព័ត៌មានវិស័យអប់រំ យុវជន និងកីឡាមិនទាន់ទទួលបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់
- ការផ្តល់ព័ត៌មាន និងទំនាក់ទំនងសាធារណៈវិស័យអប់រំ យុវជន និងកីឡារបស់បុគ្គលិកអប់រំមិនទាន់បានល្អប្រសើរ និងចំគោលដៅ
- ការផ្សព្វផ្សាយការយល់ដឹងពីអាស៊ាន-ស៊ីមេអូ និងលទ្ធផលនៃកិច្ចប្រជុំអាស៊ាន-ស៊ីមេអូដល់បុគ្គលិកអប់រំ សិស្ស និស្សិត និងយុវជន មិនទាន់បានទូលំទូលាយ
- ការយល់ដឹងពីការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិកាមិនទាន់ច្បាស់លាស់
- នីតិវិធីហិរញ្ញវត្ថុមានភាពស្មុគស្មាញមិនទាន់រៀបចំបានល្អប្រសើរធ្វើឱ្យដំណើរការទូទាត់ និងការដកសាច់ប្រាក់មិនបានទាន់ពេលវេលាសម្រាប់អនុវត្ត។

#### ទិសដៅ

- អនុម័តគោលនយោបាយសិក្សាពីចម្ងាយ
- បញ្ចប់ការធ្វើបច្ចុប្បន្នភាពគោលនយោបាយបច្ចេកវិទ្យាសារគមនាគមន៍ និងព័ត៌មានក្នុងវិស័យអប់រំ
- ប្រមូលព័ត៌មាន ផលិត ឯកសារ និងផ្សព្វផ្សាយព័ត៌មានអប់រំ យុវជន និងកីឡា

- ពង្រឹងកិច្ចសហប្រតិបត្តិការពីអង្គភាព ដៃគូ និងអ្នកពាក់ព័ន្ធក្នុងការផ្តល់ព័ត៌មានពីកម្មវិធី និងសកម្មភាពនានា
- ផ្សព្វផ្សាយចំណេះដឹងអាស៊ាន-ស៊ីមេអូ និងលទ្ធផលកិច្ចប្រជុំអាស៊ាន-ស៊ីមេអូ ដល់បុគ្គលិកអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បំប៉នជំនាញព័ត៌មាន និងទំនាក់ទំនងសាធារណៈដល់បុគ្គលិកអប់រំទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ៣.២.៩ ការងារសំណង់សិក្សា

### បញ្ហាប្រឈម

- ការសាងសង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធអប់រំមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង
- ការគ្រប់គ្រង ថែទាំហេដ្ឋារចនាសម្ព័ន្ធអប់រំ តាមគ្រឹះស្ថានសិក្សា និងតាមអង្គភាពក្រោមឱវាទនៅមានកម្រិត។

### ទិសដៅ

- សាងសង់អគារសិក្សាចំនួន ៩២ ខ្នង និងជួសជុលអាគារសិក្សាចំនួន ៧៥ កន្លែង
- បន្តសាងសង់អគារសិក្សាវិទ្យាសាស្រ្ត បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ១ ខ្នង ៨ ជាន់ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- ពិនិត្យតាមដានការងារសាងសង់អគារសិក្សាថ្មី និងការងារជួសជុល
- ពង្រឹងសមត្ថភាពគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ។

## ៣.២.១០ ការងារបោះពុម្ព និងចែកផ្សាយ

### ទិសដៅ

- អភិវឌ្ឍសៀវភៅសិក្សាគោល ហ្វឹកហាត់ អំណានបន្ថែម និងសម្ភារឧបទេសផ្សេងៗ
- បោះពុម្ពសៀវភៅសិក្សាគោល ហ្វឹកហាត់ និងអំណានបន្ថែម
- ដឹកជញ្ជូនសៀវភៅសិក្សាគោលជូនសាលារៀនទូទាំងប្រទេស
- ពង្រីកការលក់សៀវភៅសិក្សា សម្ភារឧបទេស និងសម្ភារៈការិយាល័យជូនអតិថិជនទូទៅ។

## ៣.២.១១ ការងារអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

### ទិសដៅ

- ធ្វើអធិការកិច្ចការងារគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋនៅអង្គភាពថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈ ៩៣៦ អង្គភាព
- ត្រួតពិនិត្យវឌ្ឍនភាពលើការកែលម្អតាមអនុសាសន៍នៅអង្គភាពថ្នាក់ក្រោមជាតិនិងគ្រឹះស្ថានសិក្សាសាធារណៈ ៩៣ អង្គភាព
- ស្រាវជ្រាវពាក្យបណ្តឹង ឬបាតុភាពមិនប្រក្រតីពាក់ព័ន្ធវិស័យអប់រំ
- បំប៉នមន្ត្រីអធិការកិច្ចស្តីពីកម្មវិធីអធិការកិច្ចផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែង ៦០ នាក់

- ផ្សព្វផ្សាយរបាយការណ៍អធិការកិច្ចរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ២ ដែលមានការចូលរួមពីមន្ត្រីថ្នាក់មន្ទីរ ការិយាល័យ និងគ្រឹះស្ថានសិក្សា សរុប ១១៩ នាក់។

### *៣.២.១២ ការងារសវនកម្មផ្ទៃក្នុង*

**បញ្ហាប្រឈម**

- កង្វះសមត្ថភាពមន្ត្រីជំនាញផ្នែកសវនកម្ម។

**ទិសដៅ**

- ធ្វើសវនកម្មនៅតាមសវនដ្ឋានថ្នាក់កណ្តាល ៦ ថ្នាក់រាជធានី ខេត្ត ១៣ និងថ្នាក់ក្រុង ស្រុក ខណ្ឌ ៧៨ អង្គភាព
- ធ្វើសវនកម្មនៅតាមសវនដ្ឋានថ្នាក់សាលារៀនចំណេះទូទៅ ២១០ សាលាគរុកោសល្យនិងវិក្រឹតការ ខេត្ត ២ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ១ អង្គភាព
- អភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញសវនកម្មផ្ទៃក្នុង។

### *៣.២.១៣ ការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ*

**បញ្ហាប្រឈម**

ការរៀបចំបញ្ជីសារពើភ័ណ្ឌនៅតាមរាជធានី ខេត្តមួយចំនួន ពុំទាន់ឆ្លើយតបបានទាំងស្រុងទៅតាមសារាចរលេខ ០៧ របស់រាជរដ្ឋាភិបាល។

**ទិសដៅ**

- បន្តបំប៉នមន្ត្រីជំនាញ លើការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ
- ពង្រឹងការអនុវត្តប្រកាស និងសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាលើការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ
- ពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធបង់ចូលថវិការដ្ឋដែលបានមកពីចលនទ្រព្យ និងអចលនទ្រព្យ
- ធ្វើបច្ចុប្បន្នភាពអចលនទ្រព្យ និងរថយន្ត និងគ្រឿងចក្រ
- ផ្គត់ផ្គង់ និងពិនិត្យតាមដានការប្រើប្រាស់សម្ភារបរិក្ខារអប្បបរមាសម្រាប់ការងាររដ្ឋបាលសាលារៀននៅតាមវិទ្យាល័យ។

## ៤. សេចក្តីសន្និដ្ឋាន

ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងស្ថិតក្នុងដំណាក់កាលកែទម្រង់ស៊ីជម្រៅដោយផ្តោតលើការអនុវត្តសសរស្តម្ភកំណែទម្រង់ធំៗប្រាំ។ ប្រការនេះទាមទារឱ្យមានការគិតគូរអំពីអភិក្រមទូទាំងវិស័យ

ពាក់ព័ន្ធនឹងការពង្រីកកាលានុវត្តភាព លើគ្រប់ការដ្ឋានអនុវិស័យទាំងប្រាំពីរប្រកបដោយសមត្ថភាព និងប្រសិទ្ធភាព។

សមិទ្ធផលដែលសម្រេចបានខាងលើ ពិតជាបានបង្ហាញយ៉ាងប្រត្យក្ស ពីការខិតខំប្រឹងប្រែងរបស់យើងទាំងអស់គ្នា ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់តាមតួនាទីនិងភារកិច្ច សំដៅធ្វើឱ្យការអភិវឌ្ឍវិស័យអប់រំមានការរីកចម្រើន ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨។ ការចូលរួមពីសំណាក់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងប្រាកដនិយមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់ក្តីសង្ឃឹម និងភាពជឿជាក់ខ្ពស់ចំពោះជោគវាសនាអនាគតរបស់ប្រជាជនម្នាក់ៗ របស់គ្រួសារនីមួយៗ និងប្រទេសជាតិទាំងមូល។

# ផ្នែកទី ២

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១ ៖ ចំនួនសកម្មភាពនៃផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៦

| ល.រ | អង្គភាព | សកម្មភាព សរុប | បាន បញ្ចប់ | កំពុង អនុវត្ត | មិនទាន់ អនុវត្ត |
|---|---|---|---|---|---|
| ១ | នាយកដ្ឋានអប់រំកុមារតូច | ៣២ | ៣២ | ០ | ០ |
| ២ | នាយកដ្ឋានបឋមសិក្សា | ៤១ | ៣៣ | ៣ | ៥ |
| ៣ | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | ៣៤ | ២៣ | ៦ | ៥ |
| ៤ | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ១៥ | ១៤ | ១ | ០ |
| ៥ | នាយកដ្ឋានសុខភាពសិក្សា | ២៨ | ២៤ | ៣ | ១ |
| ៦ | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | ៣៣ | ២៩ | ១ | ៣ |
| ៧ | នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ | ២៤ | ២៤ | ០ | ០ |
| ៨ | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | ១៨ | ១៣ | ២ | ៣ |
| ៩ | នាយកដ្ឋានឧត្តមសិក្សា | ៤៨ | ៣៥ | ៩ | ៤ |
| ១០ | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | ១៥ | ៦ | ៥ | ៤ |
| ១១ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ៣៧ | ២៦ | ០ | ១១ |
| ១២ | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | ៦ | ៦ | ០ | ០ |
| ១៣ | សាកលវិទ្យាល័យស្វាយរៀង | ២៨ | ២៥ | ២ | ១ |
| ១៤ | សាកលវិទ្យាល័យមានជ័យ | ១៥ | ១៤ | ១ | ០ |
| ១៥ | សាកលវិទ្យាល័យបាត់ដំបង | ១៦ | ១៦ | ០ | ០ |
| ១៦ | សាលកវិទ្យាល័យ ជា ស៊ីម កំចាយមារ | ២៥ | ១៨ | ៧ | ០ |
| ១៧ | គណៈកម្មាការទទួលស្គាល់គុណភាពអប់រំ | ១៦ | ១១ | ៤ | ១ |
| ១៨ | វិទ្យាស្ថានបច្ចេកទេសកម្ពុជា | ៤៥ | ៤៤ | ១ | ០ |
| ១៩ | វិទ្យាស្ថានជាតិអប់រំ | ២១ | ១៩ | ១ | ១ |
| ២០ | វិទ្យាស្ថានកំពង់ឈើទាល | ១៧ | ១១ | ២ | ៤ |
| ២១ | នាយកដ្ឋានអប់រំកាយ និងកីឡា | ៦ | ៥ | ១ | ០ |
| ២២ | នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត | ១៧ | ១៣ | ២ | ២ |
| ២៣ | វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា | ៩ | ៤ | ៥ | ០ |
| ២៤ | មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | ២២ | ២០ | ២ | ០ |
| ២៥ | នាយកដ្ឋានយុវជន | ១៨ | ១៧ | ១ | ០ |
| ២៦ | នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌលយុវជន | ២៣ | ២០ | ០ | ៣ |
| ២៧ | នាយកដ្ឋានផែនការ | ២៤ | ២៤ | ០ | ០ |
| ២៨ | នាយកដ្ឋានបុគ្គលិក | ៣៥ | ២៩ | ៥ | ១ |
| ២៩ | នាយកដ្ឋានហិរញ្ញវត្ថុ | ១២ | ១២ | ០ | ០ |
| ៣០ | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | ៧ | ៤ | ០ | ៣ |
| ៣១ | នាយកដ្ឋានធានាគុណភាពអប់រំ | ១៨ | ១៥ | ១ | ២ |
| ៣២ | អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | ៧ | ៧ | ០ | ០ |
| ៣៣ | នាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន | ២៣ | ១៩ | ៤ | ០ |
| ៣៤ | នាយកដ្ឋាននីតិកម្ម | ៤១ | ២៧ | ៩ | ៥ |
| ៣៥ | នាយកដ្ឋានសំណង់ | ២៩ | ២៦ | ០ | ៣ |
| ៣៦ | នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | ១០ | ១០ | ០ | ០ |
| ៣៧ | នាយកដ្ឋានរដ្ឋបាល | ១៥ | ១៥ | ០ | ០ |
| ៣៨ | នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ | ២៦ | ២២ | ៣ | ១ |

| | | | | | |
|---|---|---|---|---|---|
| ៣៩ | នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | ១៨ | ១៨ | ០ | ០ |
| ៤០ | នាយកដ្ឋានគោលនយោបាយ | ៨ | ៦ | ១ | ១ |
| ៤១ | នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ | ៩ | ៧ | ២ | ០ |
| ៤២ | កម្មវិធីទី៦៖ កម្មវិធីផ្សេងៗ | ២៥ | ២៤ | ១ | ០ |
| **សរុប** | | **៩១៦** | **៧៦៧** | **៨៥** | **៦៤** |

## ឧបសម្ព័ន្ធទី២ ៖ ចំនួនសកម្មភាពនៃទិសដៅសន្និបាតអប់រំឆ្នាំសិក្សា ២០១៥-២០១៦

| ល.រ | ផ្នែកសំខាន់ៗ | សកម្មភាពសរុប | បានបញ្ចប់ | កំពុងអនុវត្ត | មិនបានអនុវត្ត |
|---|---|---|---|---|---|
| **ក. ទិសដៅកំណែទម្រង់សំខាន់ៗ** | | | | | |
| ១ | ការពង្រឹងប្រព័ន្ធផែនការ | ១៣ | ៨ | ៥ | ០ |
| ២ | ការងារវិមជ្ឈការ និងវិសហមជ្ឈការ | ៦ | ៤ | ២ | ០ |
| ៣ | ការគ្រប់គ្រងបុគ្គលិក | ៦ | ៦ | ០ | ០ |
| ៤ | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ៧ | ៤ | ៣ | ០ |
| **សរុប** | | **៣២** | **២២** | **១០** | **០** |
| **ខ. ទិសដៅតាមអនុវិស័យ** | | | | | |
| ១ | អនុវិស័យ ការអប់រំកុមារតូច | ១៦ | ១១ | ៤ | ១ |
| ២ | អនុវិស័យ ការអប់រំបឋមសិក្សា | ២៤ | ១១ | ១៣ | ០ |
| ៣ | អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ២៦ | ១២ | ១៤ | ០ |
| ៤ | អនុវិស័យ ការអប់រំឧត្តមសិក្សា | ១៨ | ១១ | ៦ | ១ |
| ៥ | អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ | ៩ | ៨ | ១ | ០ |
| ៦ | អនុវិស័យ ការអភិវឌ្ឍយុវជន | ១៤ | ៩ | ១ | ៤ |
| ៧ | អនុវិស័យ ការអប់រំកាយ និងកីឡា | ២២ | ១២ | ៨ | ២ |
| **សរុប** | | **១២៩** | **៧៤** | **៤៧** | **៨** |
| **គ. ទិសដៅឆ្លងអនុវិស័យ** | | | | | |
| ១ | ការងារអភិវឌ្ឍកម្មវិធីសិក្សា | ៥ | ២ | ៣ | ០ |
| ២ | ការងាររដ្ឋបាល | ៤ | ៣ | ១ | ០ |
| ៣ | ការងារទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ | ៣ | ០ | ៣ | ០ |
| ៤ | ការងារព័ត៌មាន និងកិច្ចការអាស៊ាន | ៦ | ៤ | ២ | ០ |
| ៥ | ការងារសំណង់សិក្សា | ៣ | ២ | ១ | ០ |
| ៦ | ការងារបោះពុម្ព និងចែកផ្សាយ | ៤ | ៤ | ០ | ០ |
| ៧ | ការងារធានាគុណភាពអប់រំ | ៦ | ៥ | ១ | ០ |
| **សរុប** | | **៣១** | **២០** | **១១** | **០** |
| **សរុបរួម** | | **១៩២** | **១១៦** | **៦៨** | **៨** |

## ឧបសម្ព័ន្ធទី៣ ៖ វឌ្ឍនភាពការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា ២០១៥-២០១៦
## កំណែទម្រង់សំខាន់ៗ

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| **១. ការពង្រឹងប្រព័ន្ធផែនការ** | | |
| - សម្របសម្រួលការធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍដោយចីរភាពទី៤ ស្តីពីការអប់រំ | ១ | - បានរៀបចំសេចក្តីព្រាងសូចនាករ និយមន័យ ទិន្នន័យឆ្នាំគោល |
| - បន្សុំអាទិភាពកំណែទម្រង់ ១៥ ចំណុចទៅក្នុងផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពប្រចាំឆ្នាំ ព្រមទាំងពិនិត្យតាមដានវឌ្ឍនភាពតាមដំណាក់កាល | ១ | - បានបន្សុំអាទិភាពកំណែទម្រង់ ១៥ ចំណុច ទៅក្នុងរបាយការណ៍ពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨ |
| - ជំរុញការរៀបចំ ការអនុវត្ត និងការពិនិត្យតាមដានវឌ្ឍនភាពសកម្មភាពគោលនយោបាយរបស់អនុវិស័យ និងកម្មវិធីកំណែទម្រង់ | ២ | ផ្សារភ្ជាប់សរសរស្តម្ភទាំង៥ និងកំណែទម្រង់ទាំង ១៥ ចំណុច បានសិក្សាស្រាវជ្រាវលើ៖<br>- និយាមនៃការប្រើប្រាស់បុគ្គលិក<br>- ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ |
| - ដាក់ឱ្យអនុវត្តការប្រមូលស្ថិតិតាមប្រព័ន្ធOnline នៅគ្រប់រាជធានី ខេត្ត | ២ | - សមត្ថភាពមន្ត្រីទទួលបន្ទុកការងារមិនទាន់ឆ្លើយតបទៅនឹងការគ្រប់គ្រង និងប្រើប្រាស់ប្រព័ន្ធនៅឡើយ<br>- កុំព្យូទ័រ ម៉ាស៊ីនមេ(Server) ឧបករណ៍ប្រើប្រាស់ផ្សេងៗពុំឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ជាក់ស្តែង |
| - បង្កើនប្រសិទ្ធភាពនិងគុណភាពនៃការប្រមូលស្ថិតិពីស្ថាប័នពាក់ព័ន្ធនិងផ្នែកឯកជន | ២ | - មានយន្តការច្បាស់លាស់លើការប្រមូលស្ថិតិអប់រំសាធារណៈ ឯកជន និងក្រសួងពាក់ព័ន្ធមានរចនាសម្ព័ន្ធគ្រប់គ្រង និងទទួលខុសត្រូវលើការប្រមូលស្ថិតិច្បាស់លាស់<br>- មានកិច្ចសហការណ៍ល្អជាមួយដៃគូ និងក្រសួងពាក់ព័ន្ធ មានប្រព័ន្ធប្រមូល បញ្ចូល និងផលិតទិន្នន័យច្បាស់លាស់ |
| - សិក្សាផលប៉ះពាល់នៃការអនុវត្តគោលនយោបាយរបស់ក្រសួង | ២ | សិក្សាលើ ២ ចំណុច ៖<br>- គោលនយោបាយនៃការផ្តល់អាហារូបករណ៍<br>- គោលនយោបាយនិយាមនៃការប្រើប្រាស់ បុគ្គលិក |
| - សិក្សាស្រាវជ្រាវពីការបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ១ | - បានអនុវត្តចប់រួចរាល់ ហើយរបាយការណ៍ស្រាវជ្រាវបានដាក់ជូនដល់ថ្នាក់ដឹកនាំដើម្បីធ្វើការសម្រេចចិត្ត |
| - បង្កើនគុណភាពនៃការរៀបចំប្រតិបត្តិប្រចាំឆ្នាំនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | ១ | - បានដាក់ពិន្ទុផែនការប្រតិបត្តិប្រចាំឆ្នាំថ្នាក់ រាជធានី ខេត្ត និងផ្តល់យោបល់ត្រឡប់ដល់រាជធានី ខេត្ត |
| - សហការរៀបចំចវិកាកាន់តែឆ្លើយតបនឹងអាទិភាពគោលនយោបាយ និងមានការសម្របសម្រួលគ្នាល្អ រវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ១ | - បានសហការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធី ដោយផ្អែកលើអាទិភាពគោលនយោបាយកំណែទម្រង់វិស័យអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| - សម្របសម្រួលនិងគាំទ្រដំណើរការរបស់ក្រុមការងារតាមអនុវិស័យ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | ១ | - បានសម្របសម្រួលជាមួយក្រុមការងារតាមអនុវិស័យលើការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ និងដំណើរការក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| - ដាក់ឱ្យដំណើរការប្រព័ន្ធព័ត៌មានគ្រប់គ្រងជំនួយនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ | ១ | - បានដំណើរការប្រព័ន្ធព័ត៌មានគ្រប់គ្រងជំនួយនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត |
| - រៀបចំក្របខណ្ឌពិនិត្យតាមដាននិងវាយតម្លៃ | ២ | - សេចក្តីព្រាងទី១ |
| - ជំរុញការរៀបចំរបាយការណ៍សមិទ្ធកម្មនៅតាមអង្គភាពអនុវត្តថវិកាកម្មវិធី | ១ | - បានផ្សព្វផ្សាយ |
| **២. ការងារវិមជ្ឈការ និងវិសហមជ្ឈការ** | | |
| - ផ្ទេរមុខងារការអប់រំមត្តេយ្យសិក្សា ការអប់រំបឋមសិក្សា និងមុខងារការអប់រំក្រៅប្រព័ន្ធជូនរដ្ឋបាលថ្នាក់ក្រោមជាតិ នៅខេត្តបាត់ដំបង | ១ | - អនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ |
| - រៀបចំលិខិតបទដ្ឋានគតិយុត្តគាំទ្រតាមអនុវិស័យ និងការធ្វើកំណែទម្រង់វិស័យអប់រំ | ២ | - រៀបចំកិច្ចពិគ្រោះយោបល់លើលិខិតបទដ្ឋាន ៦ អ្នកចូលរួម ១២៥នាក់ ស្រី១៨នាក់ ពីការគាំទ្រការផ្ទេរមុខងារវិស័យអប់រំឱ្យទៅដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ |
| - ពង្រឹងការអនុវត្តច្បាប់ស្តីពីការអប់រំ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអប់រំ | ២ | - កសាងលិខិតបទដ្ឋានចំនួន ២២<br>- វាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានចំនួន ៤<br>- កសាងសមត្ថភាពចំនួន ៧៦១ នាក់ |
| - ពង្រឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងវិស័យអប់រំ | ១ | - កសាងផែនការសកម្មភាព<br>- ពង្រឹងសមត្ថភាពចំនួន ២១៣ នាក់ |
| - ពង្រឹងការអនុវត្តការងារវិមជ្ឈការ វិសហមជ្ឈការវិស័យអប់រំ | ១ | - កសាងសមត្ថភាពមន្ត្រីរដ្ឋបាលក្រុង ស្រុក១៥៧ នាក់<br>- ផ្សព្វផ្សាយគោលនយោបាយ និងក្របខណ្ឌច្បាប់ ១១២ នាក់ |
| - ពង្រឹងយន្តការគតិយុត្តគ្រប់គ្រង និងដោះស្រាយវិវាទបុគ្គលិកអប់រំ | ១ | - កសាងសមត្ថភាព ២០៧ នាក់<br>- វិវាទ ១៣ ករណី |
| **៣. ការគ្រប់គ្រងបុគ្គលិក** | | |
| - ពិនិត្យតាមដាននិងពង្រឹងការងារគ្រប់គ្រង និងប្រើប្រាស់មន្ត្រីរាជការ គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរវេន និងបង្រៀនថ្នាក់គួប | ១ | - ចុះត្រួតពិនិត្យ ២៥ រាជធានី ខេត្ត ៤០ ក្រុង ស្រុក ខណ្ឌ និង ១១០ សាលា<br>- ការគ្រប់គ្រងមន្ត្រីរាជការភាគច្រើនប្រតិបត្តិបានតាមគោលការណ៍ណែនាំ<br>- ការប្រើប្រាស់គ្រូជាប់កិច្ចសន្យា ពីរវេន និងថ្នាក់គួបបានល្អប្រសើរ (គ្មានការបន្លំដើម្បីយកថវិការដ្ឋ) |
| - សហការជាមួយអង្គភាពពាក់ព័ន្ធ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីត្រួតពិនិត្យការផ្លាស់ទីកន្លែងធ្វើការ ការបែងចែកគ្រូចេញថ្មី និងការអនុវត្តវិន័យការងាររបស់បុគ្គលិកអប់រំ | ១ | - អនុវត្តបាន១០០%(ផែនការ១៨រាជធានី ខេត្ត)<br>- បានចុះសហការជាមួយមន្ទីរអេយក រាជធានី ខេត្ត ១៥ ដើម្បីពិនិត្យនិងសម្រេចអនុញ្ញាតឱ្យបុគ្គលិកអប់រំបានផ្លាស់ប្តូរទីកន្លែងធ្វើការក្នុងរាជធានី ខេត្ត<br>- ការផ្លាស់ប្តូរបុគ្គលិកអប់រំ បានអនុវត្តគោលការណ៍ផ្លាស់ប្តូរ ដោយបានទប់ស្កាត់ការផ្លាស់ចូលអង្គភាពដែលលើសតម្រូវការ |
| - រៀបចំវគ្គតម្រង់ទិសគរុសិស្ស និស្សិត អំពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ច្បាប់ និងគោលការណ៍ | ១ | - អនុវត្តបាន ១៦ រាជធានី ខេត្ត មានគរុសិស្ស និស្សិតចូលរួម ៣ ៦៩៥ នាក់ ស្រី ១ ៨៩៣ នាក់ |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| នានាដែលមន្ត្រីរាជការត្រូវប្រតិបត្តិ និងលាភការដែលត្រូវទទួលបាន | | |
| - ជំរុញការអនុវត្តគោលការណ៍វាយតម្លៃលទ្ធផលបំពេញការងាររបស់មន្ត្រីរាជការ | ១ | - ផ្សព្វផ្សាយប្រព័ន្ធវាយតម្លៃគុណផលការងារមានអ្នកចូលរួម ៥៤ នាក់ ស្រី១៦ នាក់<br>- សិក្ខាពិនិត្យឡើងវិញនិងពង្រឹងការអនុវត្តប្រព័ន្ធវាយតម្លៃគុណផលការងារ និងបណ្តុះបណ្តាលមន្ត្រីបង្គោលបាន ៣ លើក មានអ្នកចូលរួម ១៣៤ នាក់ ស្រី ៦៧ នាក់ |
| - អនុវត្តផែនការសកម្មភាពសម្រាប់ការអនុវត្តគោលនយោបាយ ស្តីពីធនធានមនុស្សក្នុងវិស័យ អប់រំ | ១ | - សិក្ខាសាលាផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្តផែនការសកម្មភាពគោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ ១លើក មានអ្នកចូលរួម ៥២នាក់ ស្រី ១២នាក់ |
| - ពង្រឹងសមត្ថភាពមន្ត្រីជំនាញ និងមន្ត្រីគ្រប់គ្រងទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាលើការងារប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ការងារគ្រប់គ្រងបុគ្គលិក និងភាសាបរទេស | ១ | - បណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកប្រើប្រាស់ប្រព័ន្ធ មានអ្នកចូលរួម ៣៣ នាក់ ស្រី ៥ នាក់<br>- បំប៉នមន្ត្រីជំនាញពីរបៀបទាញ ទិន្នន័យចេញពីប្រព័ន្ធដើម្បីប្រើប្រាស់ ៤ វគ្គ មានអ្នកចូលរួម ១១៣ នាក់ ស្រី ១៥ នាក់<br>- បណ្តុះបណ្តាលពីរបៀបប្រមូលទិន្នន័យនិងការបំពេញកម្រងសំណួរមានអ្នកចូលរួម ៣២៧នាក់ ស្រី ៣៩នាក់ |
| **៤. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** | | |
| - រៀបចំផែនការចំណាយរយៈពេលមធ្យមឆ្នាំ២០១៧-២០១៩ និងគម្រោងថវិកាប្រចាំឆ្នាំ២០១៧ | ១ | - បានរៀបចំផែនការចំណាយរយៈពេលមធ្យមឆ្នាំ២០១៧-២០១៩ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦-២០១៨ និងគម្រោងថវិកាប្រចាំឆ្នាំ២០១៧ |
| - បន្តកែសម្រួលអនុក្រឹត្យនិងប្រកាសអន្តរក្រសួងដែលពាក់ព័ន្ធដល់ការអនុវត្តថវិកា | ២ | - បន្តរៀបចំប្រកាសអន្តរក្រសួងថ្មី ស្តីពីនីតិវិធីអនុវត្តថវិកានៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាគរុកោសល្យ និងវិក្រឹតការ និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម<br>- បន្តកែសម្រួលប្រកាសអន្តរក្រសួងលេខ ៥០៥ សហវ ស្តីពីគោលការណ៍សម្រាប់ការប្រឡងមធ្យមសិក្សាចំណេះទូទៅប្រឡងឧត្តមសិក្សាមធ្យមសិក្សាបច្ចេកទេសនិងវិជ្ជាជីវៈប្រឡងគ្រូ បង្រៀន និងប្រឡងអាហារូបករណ៍ |
| - បន្តអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ១ | - បានរៀបចំសៀវភៅផែនការសកម្មភាពកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣របស់ក្រសួង |
| - បន្តរៀបចំការគ្រប់គ្រងហិរញ្ញវត្ថុ តាមប្រព័ន្ធព័ត៌មានវិទ្យា | ១ | - បានរៀបចំបណ្តាញ និងបណ្តុះបណ្តាល ដល់គ្រប់អង្គភាពថវិកា |
| - ពង្រឹងសមត្ថភាពអង្គភាពថវិកាក្នុងការអនុវត្តថវិកាកម្មវិធី | ១ | - បំប៉នស្តីពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ<br>- វគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តថវិកាកម្មវិធី<br>- បំប៉នស្តីពីការអនុវត្តថវិកាជំនួយកែលម្អសាលារៀន<br>- ពិនិត្យឡើងវិញលើការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៦ |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| | | - ពិគ្រោះយោបល់រៀបចំសៀវភៅណែនាំស្ដីពីការអនុវត្តថវិកាមូលនិធិកម្មវិធីជំនួយកែលម្អសាលារៀន ( SIF ) |
| - បន្តសិក្សាស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងផ្ទៃក្នុង និងប្រតិបត្តិការហិរញ្ញវត្ថុសម្រាប់រៀបចំជាមូលដ្ឋានធ្វើសវនកម្មផ្ទៃក្នុង | ២ | - បន្តសិក្សាស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តថ្មីៗពាក់ព័ន្ធនឹងការគ្រប់គ្រងផ្ទៃក្នុង និងប្រតិបត្តិការហិរញ្ញវត្ថុសម្រាប់រៀបចំជាមូលដ្ឋានធ្វើសវនកម្មផ្ទៃក្នុងដែលចាំបាច់ត្រូវសិក្សាឈ្វេងយល់ និងអនុវត្ត |
| - បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពង្រឹងសមត្ថភាពបុគ្គលិកនាយកដ្ឋានសវនកម្មផ្ទៃក្នុង អំពីការអនុវត្តស្តង់ដារបាយការណ៍សវនកម្មផ្ទៃក្នុងក្រសួងអប់រំ យុវជន និងកីឡា និងចុះកម្មសិក្សាការងារសវនកម្មផ្ទៃក្នុងនៅតាមសវនដ្ឋាន | ២ | - ដើម្បីពង្រឹងសមត្ថភាពមន្ត្រីនាយកដ្ឋានសវនកម្មផ្ទៃក្នុងលើការសរសេរបាយការណ៍ស្តង់ដាសវនកម្មផ្ទៃក្នុង<br>- បានសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល្បងធ្វើសវនកម្មផ្ទៃក្នុងលើសមិទ្ធកម្មនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត និងសាលារៀន១ |

**បញ្ជាក់៖** **១- អនុវត្តរួចរាល់** **២- កំពុងអនុវត្ត** **៣- មិនទាន់បានចាប់ផ្តើមអនុវត្ត**

## ឧបសម្ព័ន្ធទី៤ ៖ វឌ្ឍនភាពការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា ២០១៥-២០១៦ អនុវិស័យ

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| **១. អនុវិស័យ ការអប់រំកុមារតូច** | | |
| - បង្កើនអត្រាចូលរៀនរបស់កុមារអាយុ ៣ ឆ្នាំ ៤ ឆ្នាំ និង ៥ ឆ្នាំ ឱ្យឆ្លើយតបនឹងចំណុចដៅ | ១ | - កុមារអាយុ ៥ឆ្នាំបានចូលរៀន ៦៦,៣១ ភាគរយ<br>- កុមារអាយុ ៤ឆ្នាំបានចូលរៀន ៣៧,៣០ ភាគរយ<br>- កុមារអាយុ ៣ឆ្នាំបានចូលរៀន ២០,២០ ភាគរយ |
| - ពង្រីកនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធសេវាអប់រំកុមារតូច ផ្តោតលើការកសាង ជួសជុលអគារសិក្សា និងកែលម្អបរិស្ថានសិក្សាឱ្យមានលក្ខណៈស្តង់ដា និងស្របតាមនិយាមគរុកោសល្យ | ២ | - ស្តង់ដាសេវា មិនបានអនុវត្តពេញលេញ |
| - រៀបចំនិងអនុវត្តស្តង់ដា សេវាសាលាមត្តេយ្យសិក្សា | ២ | - នាយក នាយិកា គ្រូមត្តេយ្យសិក្សារដ្ឋ សហគមន៍ និងមាតាបិតាបង្គោលទទួលការបំប៉នសមត្ថភាពស្តីពីការអនុវត្តសេវាតាមស្តង់ដា<br>- រៀបចំសេចក្តីព្រាងសេចក្តីណែនាំអនុវត្តស្តង់ដាសេវាអប់រំកុមារតូច |
| - អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំកុមារតូចថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ១ | - មន្ត្រីថ្នាក់ជាតិ ៣២ នាក់ ស្រី ២៤ នាក់ ទទួលការបំប៉នស្តីពីការអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យអប់រំកុមារតូច ព្រមទាំងការរៀបចំរបាយការណ៍ការវិភាគទិន្នន័យ លើការវាយតម្លៃផ្អែកបរិស្ថានសេវាអប់រំកុមារតូច<br>- មន្ត្រីថ្នាក់ក្រោមជាតិ ៤២៤ នាក់ ស្រី ២៨៣ នាក់ ទទួលការបំប៉នស្តីពីដំណើរការអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃសម្រាប់អនុវិស័យអប់រំកុមារតូច |
| - គាំទ្រប្រព័ន្ធអប់រំកុមារតូចថ្នាក់ក្រោមជាតិក្នុងការផ្ទេរមុខងារ | ១ | - គណៈអភិបាលខេត្ត ក្រុង ស្រុក ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ៧៦នាក់ ទទួលបានចំណេះដឹងស្តីពីការគ្រប់គ្រងមុខងារអប់រំកុមារតូចនៅថ្នាក់ក្រោមជាតិ |
| - ពង្រឹងការអនុវត្តយន្តការគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច | ១ | - បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធតាមរយៈការប្រជុំគណៈកម្មាធិការជាតិ និងមន្ត្រីជំនាញ |
| - ពង្រីកកម្មវិធីអប់រំមាតាបិតាដោយផ្តោតលើសេវាអាហារូបត្ថម្ភ ការលើកកម្ពស់សុខភាព អនាម័យ ការថែទាំ និងការប្រើប្រាស់សេវាសុខាភិបាល | ១ | - កម្មវិធីអប់រំមាតាបិតាបានពង្រីកតាមផែនការ |
| - បន្តកម្មវិធីផ្តល់ថ្នាំទម្លាក់ព្រូន ពិនិត្យសុខភាព និងកាយសម្បទាបុគ្គលិកអប់រំ និងអ្នកសិក្សា ដោយសហការជាមួយក្រសួងសុខាភិបាល ផ្តល់ការអប់រំសុខភាព អនាម័យ សុខភាពមាត់-ធ្មេញអាហារូបត្ថម្ភ និងសេវាសុខាភិបាលដទៃទៀត | ២ | - បានអនុវត្តការទម្លាក់ថ្នាំព្រូននៅគ្រប់ថ្នាក់មត្តេយ្យសិក្សានៃសាលាបឋមសិក្សា |
| - ផលិត និងផ្សព្វផ្សាយវីដេអូសម្រាប់កម្មវិធីអប់រំមាតាបិតា | ១ | - បានសម្ពោធកម្មវិធី "ស្រលាញ់កូន" ចាក់ផ្សាយលើកញ្ចក់ទូរទស្សន៍ជាតិកម្ពុជា រៀងរាល់ថ្ងៃច័ន្ទ និងថ្ងៃសុក្រ វេលាម៉ោង ៥ល្ងាច |
| - ពង្រឹងយន្តការអនុវត្តកម្មវិធីអប់រំបរិយាប័ន្ន និងការអប់រំពហុភាសាផ្អែកមត្តេយ្យសិក្សា | ១ | - បានអនុវត្តកម្មវិធីតាមផែនការ |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| - អភិវឌ្ឍកម្មវិធីសិក្សាលម្អិតនិងស្តង់ដាសមត្ថភាព | ១ | - បានរៀបចំក្របខណ្ឌកម្មវិធីសិក្សាថ្មីចំណេះទូទៅ (ចាប់ពីមត្តេយ្យសិក្សាឡើងទៅ) |
| - ពង្រឹងសមត្ថភាពគ្រប់គ្រងដល់នាយក នាយិកា សាលាមត្តេយ្យសិក្សា | ១ | - នាយក នាយិកា នៃសាលាមត្តេយ្យសិក្សា និងសាលាបឋមសិក្សាដែលមានថ្នាក់មត្តេយ្យសិក្សាទទួលការបំប៉នស្តីពីការគ្រប់គ្រងថ្នាក់មត្តេយ្យសិក្សាតាមស្តង់ដាគុណភាព |
| - ពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាព ការងារបណ្តុះបណ្តាលគ្រូបង្រៀន និងផ្សព្វផ្សាយកម្រងព្រឹត្តិបត្រវាយតម្លៃការងារបណ្តុះបណ្តាលគ្រូបង្រៀន | ៣ | មិនទាន់បានអនុវត្ត |
| - បន្តបំប៉នគ្រូបង្រៀនមត្តេយ្យសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន | ១ | គ្រូមត្តេយ្យ បានបំប៉នទៅជាគ្រូកម្រិតមូលដ្ឋាន |
| - ពង្រឹងការអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ការសិក្សាស្រាវជ្រាវ និងវិភាគសម្រាប់អនុវិស័យអប់រំកុមារតូច | ១ | - បានបើកវគ្គបំប៉នសមត្ថភាពស្តីពីការរៀបចំរបាយការណ៍ការវិភាគទិន្នន័យ លើការវាយតម្លៃផ្នែកបរិស្ថានសេវាអប់រំកុមារតូច |
| - ធានានិរន្តរភាពមត្តេយ្យសិក្សាសហគមន៍ | ២ | - បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ និងត្រៀមឆ្លងអន្តរក្រសួង |
| **២. អនុវិស័យ ការអប់រំបឋមសិក្សា** | | |
| - កែលម្អគោលនយោបាយពង្រាយគ្រូ | ២ | - កំពុងពង្រាងលិខិតបទដ្ឋាន |
| - លើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាសាលារៀន | ១ | - ផ្តល់ថវិកាគ្រប់សាលារៀនតាមរយៈប្រព័ន្ធធានាគារ |
| - ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីធានាគុណភាពអប់រំ | ២ | - បន្តបណ្តុះបណ្តុះមន្ត្រីថ្នាក់ក្រោមជាតិ ស្តីពីការវាយតម្លៃនៅ ១២ ខេត្ត |
| - ផ្សព្វផ្សាយលទ្ធផលតេស្តវាយតម្លៃថ្នាក់ជាតិ ថ្នាក់ទី ៣ | ១ | - ផ្សព្វផ្សាយទូទាំងប្រទេសពីលទ្ធផលតេស្តថ្នាក់ទី៣ |
| - បន្តធ្វើតេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី ៦ | ២ | - រៀបចំផ្សព្វផ្សាយ |
| - ពង្រឹងហេដ្ឋារចនាសម្ព័ន្ធអប់រំ | ២ | - បំប៉នគណៈគ្រប់គ្រងសាលារៀន |
| - កែលម្អលក្ខខណ្ឌផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងសិស្សរៀនពូកែ | ១ | - អនុវត្តរៀងរាល់ឆ្នាំ ប៉ុន្តែមិនបានផ្តល់ដល់សិស្សរៀនពូកែ |
| - ពង្រឹងសមត្ថភាពអាននៅថ្នាក់ទី១ ទី២ និងទី៣ | ២ | - បំប៉នគ្រូថ្នាក់ទី១ ទី២ និងទី៣ ៣៥៨ សាលា ១៩ ក្រុងស្រុក និង ៧ខេត្ត |
| - បញ្ចូលវិធីសាស្ត្របង្រៀនថ្មី ទៅក្នុងស្ថាប័នបណ្តុះបណ្តាលគ្រូបង្រៀន | ១ | - អនុវត្តការបញ្ចូលវិធីសាស្ត្របង្រៀនថ្មី |
| - ប្រើប្រាស់គ្រូភាសាអង់គ្លេស ពីមធ្យមសិក្សាឱ្យជួយបង្រៀននៅបឋមសិក្សា | ២ | - កំពុងបំប៉នការប្រើប្រាស់សៀវភៅភាសាអង់គ្លេសថ្នាក់ទី៤ ដល់ថ្នាក់ទី៦ នៅខេត្តស្វាយរៀង ២៩១ នាក់ |
| - ផ្គត់ផ្គង់សៀវភៅសិក្សាគោលឱ្យឆ្លើយតបនឹងតម្រូវការរបស់សិស្ស | ២ | - ផ្គត់ផ្គង់សៀវភៅសិក្សាគោល ៥ ២៦៨ ០០០ ច្បាប់ |
| - ជ្រើសរើស និងបណ្តុះបណ្តាលគ្រូបឋមសិក្សា | ១ | - អនុវត្តរៀងរាល់ឆ្នាំ |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| - បន្តបំប៉នគ្រូបង្រៀនបឋមសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន | ១ | - បំប៉នគ្រូបង្រៀនបឋមសិក្សា ២ ៩៩២ នាក់ ស្រី ១ ៥១២ នាក់ ឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន |
| - បំប៉នសមត្ថភាពគ្រូបង្រៀនបឋមសិក្សា ស្តីពីវិធីសាស្ត្របង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ និងទី៥ | ២ | - បំប៉នការប្រើប្រាស់សៀវភៅដល់គ្រូ ១ ២៧៩ នាក់ ស្រី ៥៨៣ នាក់ |
| - អភិវឌ្ឍកម្មវិធីសិក្សាលម្អិតនិងស្តង់ដាសមត្ថភាពគ្រប់មុខវិជ្ជា | ២ | - អនុវត្តក្របខណ្ឌកម្មវិធីគ្រប់មុខវិជ្ជាពីថ្នាក់ទី១ ដល់ទី៦ |
| - អភិវឌ្ឍសាលាកុមារមេត្រីកម្រិតខ្ពស់ឱ្យទៅជាសាលាបឋមសិក្សាជំនាន់ថ្មី | ២ | - សាលាបឋមសិក្សាទួលគោក នៅរាជធានីភ្នំពេញ<br>- សាលាបឋមសិក្សារាជអគ្គមហេសី ស្រុកឧត្តុង ខេត្តកំពង់ស្ពឺ |
| - បន្តបំប៉នសមត្ថភាពនាយក នាយិកាសាលាបឋមសិក្សា | ១ | - បំប៉ននាយក នាយិកា ៦១៨ នាក់ ស្រី ១១០ នាក់ ស្តីពីបំណិនវិជ្ជាជីវៈ |
| - ពង្រឹងតួនាទីនិងការទទួលខុសត្រូវរបស់គណៈកម្មការទ្រទ្រង់សាលា | ២ | - បន្តពង្រឹងតួនាទីភារកិច្ចឱ្យគ្រប់រាជធានី ខេត្ត |
| - បំប៉នគ្រូបង្រៀនស្តីពីជំនាញបង្រៀនកុមារដែលមានតម្រូវការពិសេស | ២ | - បណ្តុះបណ្តាលគ្រូដើម្បីជួយដល់កុមារពិការ ១ ៩៩៩ នាក់ ស្រី ៧៩៦ នាក់ |
| - បន្តកម្មវិធីផ្តល់ថ្នាំទម្លាក់ព្រូន ពិនិត្យសុខភាព និងកាយសម្បទាបុគ្គលិកអប់រំ និងអ្នកសិក្សា ដោយសហការជាមួយក្រសួងសុខាភិបាល ផ្តល់ការអប់រំសុខភាព អនាម័យ សុខភាពមាត់-ធ្មេញអាហារូបត្ថម្ភ និងសេវាសុខាភិបាលដទៃទៀត | ១ | - សិស្សថ្នាក់ទី១ ៩៨ ភាគរយ ក្នុងខេត្តកំពង់ឆ្នាំង តាកែវ កែប ប៉ៃលិន និង កំពត បានពិនិត្យកាយសម្បទា<br>- សិស្សបឋមសិក្សាទូទាំងប្រទេស ៩៥ ភាគរយ បានទទួលថ្នាំទំលាក់ព្រូន ២ ដង ក្នុងមួយឆ្នាំ |
| - បន្តការផ្តល់សម្ភារបរិក្ខារអនាម័យ ដូចជាកន្លែងលាងដៃ បង្គន់អនាម័យ និងទឹកស្អាត | ១ | - កន្លែងលាងសម្អាតដៃ ៦០ ភាគរយ<br>- ផ្គត់ផ្គង់ទឹកស្អាត ៥៩ ភាគរយ<br>- ប្រើប្រាស់បង្គន់អនាម័យ ៧០ ភាគរយ |
| - អភិវឌ្ឍខ្លឹមសារកម្មវិធីសិក្សាលម្អិតស្តីពីការអប់រំសុខភាពចាប់ពីថ្នាក់ទី១ ដល់ទី៦ ដើម្បីបញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ ២០១៦-២០២៥ | ២ | - កំពុងអនុវត្តបាន ៦០ ភាគរយ |
| - បន្តការផ្តល់សេវាសុខភាពចាំបាច់ និងកម្មវិធីអប់រំសុខភាព បង្ការជំងឺឆ្លង ជំងឺមិនឆ្លង សុវត្ថិភាពចរាចរផ្លូវគោក និងសុវត្ថិភាពចរាចរផ្លូវគោកដល់ដល់បុគ្គលិកអប់រំ និងអ្នកសិក្សា | ១ | - អនុវត្តរៀងរាល់ឆ្នាំ |
| - រៀបចំលិខិតបទដ្ឋានគតិយុត្តិដើម្បីផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិ | ១ | - អនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ |
| **៣. អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស** | | |
| - បង្កើតឱកាសទី២ សម្រាប់ការទទួលបានការបញ្ចប់ថ្នាក់មធ្យមសិក្សាតាមរយៈការបង្កើតប្រព័ន្ធសមមូលសញ្ញាបត្រ | ១ | - បញ្ចប់តាមគោលដៅគ្រោងទុក |
| - កែលម្អគោលនយោបាយពង្រាយគ្រូ | ១ | - បញ្ចប់តាមគោលដៅគ្រោងទុក |
| - បន្តទប់ស្កាត់ការបោះបង់ការសិក្សារបស់សិស្ស | ២ | - បន្តអនុវត្តពេញលេញ ៥ ខេត្តគោលដៅ |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| - បង្កើតក្លឹបសិក្សាដើម្បីជំរុញស្វ័យសិក្សារបស់សិស្សលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ | ២ | - កំពុងអនុវត្តសេចក្តីណែនាំលេខ ១៣ អយក.សណន ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ |
| - បន្តអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ | ១ | - បន្តអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ ដោយពង្រីកវិសាលភាពដល់សិស្សជនជាតិដើមភាគតិច |
| - ពង្រីកការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅសាលាមធ្យមសិក្សាបឋមភូមិ | ២ | - បន្តអនុវត្ត និងពង្រីកបន្ថែម ៥ ខេត្តគោលដៅ |
| - ជំរុញនិងពង្រឹងការអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន នៅតាមគ្រឹះស្ថានសិក្សា | ២ | - បន្តពិនិត្យតាមដានលើការអនុវត្ត |
| - អនុវត្តសាកល្បងកម្មវិធីវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) | ២ | - បន្ត និងពង្រីកការអនុវត្តកម្មវិធី STEM ផ្អែកលើគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា |
| - ផលិត និងផ្សព្វផ្សាយវីដេអូស្តីពីការបង្រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រ | ១ | - ផ្សព្វផ្សាយឯកសារណែនាំពីរបៀបប្រើប្រាស់ឌីវីឌី វីដេអូស្តីពីការបង្រៀន គណិតវិទ្យា និងវិទ្យាសាស្ត្រ ថ្នាក់ទី៩ និងទី១២ |
| - ពង្រឹងការអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មី និងជំរុញកម្មវិធីសាលារៀនជំនាន់ថ្មីនៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ | ១ | - ពិធីសម្ពោធដាក់ឱ្យដំណើរការសាលារៀនជំនាន់ថ្មី |
